# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# របបគតិយុត្តនៃការរៀបចំ និង គ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **ក.ជុំ លីអេង**

**ស្រេង សិរីវុឌ្ឍ**

សាស្ត្រាចារ្យណែនាំ

លោកស្រី៖ **ម៉ូលី បញ្ញា**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de droit et des Sciences Economiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# របបគតិយុត្តនៃការរៀបចំ និង គ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **ក.ជុំ លីអេង**

**ស្រេង សិរីវុឌ្ឍ**

សាស្ត្រាចារ្យណែនាំ

លោកស្រី៖ **ម៉ូលី បញ្ញា**


ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្ដីថ្លែងអំណរគុណ

នាងខ្ញុំ **ជុំ លីអេង** និងខ្ញុំបាទ **ស្រេង សិរីវុឌ្ឍ** ដែលជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី ២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាល័យសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៧-២០២១។

ជាបឋមយើងខ្ញុំសូមធ្វើការសម្ដែងនូវមនោសញ្ចេតនាប្រកបកតញ្ញូតាធម៌ និងគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

| | | | |
|---|---|---|---|
| លោកឪពុក | **ជុំ សំអុល** | លោកឪពុក | **ម៉ឺន ពៅ** |
| អ្នកម្ដាយ | **វ៉ាន់ ស៊ីណា** | អ្នកម្ដាយ | **លឹម ច័ន្ទរដ្ឋា** |

ដែលជាអ្នកមានគុណ ជាអ្នកដែលកូនចៅគ្រប់រូបជំពាក់គ្រប់បែបយ៉ាង លោកទាំងបួន ជាអ្នកផ្ដល់នូវកំណើត ផ្ដល់នូវអ្វីគ្រប់យ៉ាង ផ្ដល់ទាំងថវិកាក្នុងការសិក្សារៀនសូត្រ ផ្ដល់នូវទីជម្រកដែលពោរពេញទៅដោយសុភមង្គល ផ្ដល់នូវការអប់រំទូន្មាន ផ្ដល់នូវកម្លាំងចិត្តសព្វបែបយ៉ាង។ គុណូបការៈរបស់លោកទាំងបួនរូបពិតជាធំធេងណាស់ ដោយលោកខិតខំប្រឹងប្រែងទាំងកម្លាំងកាយ និងចិត្ត ពលីគ្រប់បែបយ៉ាងក្នុងការថៃទាំ ចិញ្ចឹមមបីបាច់ថែរក្សាកូនគ្រប់រូប ផ្ដល់នូវសេចក្ដីអាណិតស្រឡាញ់ ក្ដីមេត្តាករុណា ប្រកបដោយគុណវិហារធម៌ទាំងបួន ដែលបានជម្រុញ លើកទឹកចិត្ត និងទំនុកបម្រុងគ្រប់បែបយ៉ាង ដើម្បីឲ្យកូនខិតខំសិក្សារៀនសូត្ររហូតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រមួយនេះ។

ចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោក-លោកស្រីទាំងអស់** ដែលជាសាស្ត្រាចារ្យដែលបានបម្រើការងារនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ពួកគាត់ប្រៀបបីដូចជាសសរគ្រឹះនៃចំណេះដឹង ដែលលោកទាំងអស់បានខិតខំបណ្ដុះបណ្ដាល និងផ្ដល់ចំណេះដឹងដល់ពួកយើងខ្ញុំ ព្រមទាំងបង្ហាត់បង្រៀន អប់រំ ទូន្មាន លះបង់ពេលវេលាដ៏មានតម្លៃ ព្រមទាំងកម្លាំងកាយ និងកម្លាំងចិត្ត ក្នុងការណែនាំ និងពិគ្រោះពិភាក្សាផ្នែកច្បាប់នានាដល់យើងខ្ញុំទាំងពីរនាក់ដើម្បីឲ្យយើងខ្ញុំទាំងពីរ ទទួលបាននូវសមត្ថភាពយល់ដឹងផ្នែកនីតិសាស្ត្រលើបញ្ហាដែលពាក់ព័ន្ធនឹងវិស័យច្បាប់នានានៅក្នុងប្រទេស ព្រមទាំងច្បាប់អន្តរជាតិផងដែរ។

ចំពោះលោកស្រីសាស្ត្រាចារ្យ **ម៉ូលី បញ្ញា** ដែលលោកស្រីជាសាស្ត្រចារ្យប្រកបដោយគតិបណ្ឌិត និងចំណេះដឹងជ្រៅជ្រះ ដែលបានផ្ដល់ការយកចិត្តទុកដាក់ធ្វើការណែនាំសារណាបញ្ចប់ការសិក្សារបស់ក្រុមយើងខ្ញុំ និងបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការណែនាំផ្ដល់យោបល់ និងកែតម្រូវនូវរាល់កំហុសនានាដែលបានកើតមានឡើង ក្នុងគោលបំណងជួយឲ្យសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំសម្រេចបានជារូបរាង និងទទួលបានជោគជ័យ។

យើងខ្ញុំទាំងពីរនាក់សូមបួងសួងដល់រាល់វត្ថុសក្ដិសិទ្ធិទាំងអស់ សូមជួយថែរក្សា និងប្រសិទ្ធិពរជ័យ ដល់រូបលោកអ្នកមានគុណទាំងអស់ឲ្យជួបប្រទះតែពុទ្ធពរ ទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

យើងខ្ញុំទាំងពីរនាក់ក្នុងនាមជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានសិក្សាអស់រយៈពេល៤ឆ្នាំដ៏មានតម្លៃកន្លងមកនេះ យើងខ្ញុំទាំងពីរនាក់ដែលបានទទួលនូវចំណេះដឹងយ៉ាងច្រើន ក្រោមការខិតខំបង្ហាត់បង្រៀនពីសំណាក់លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ។ ទន្ទឹមនឹងនេះនៅក្នុងចំណោមមុខវិជ្ជាជាច្រើន ដែលយើងខ្ញុំទាំងពីរនាក់បានសិក្សាកន្លងមក យើងខ្ញុំទាំងពីរនាក់មានចំណាប់អារម្មណ៍យ៉ាងខ្លាំងទៅលើមុខវិជ្ជា **នីតិនគរូបនីយកម្ម និងសំណង់** ដែលទាក់ទងទៅនឹងការអភិវឌ្ឍទៅលើវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលបានជម្រុញឲ្យយើងខ្ញុំទាំងពីរនាក់បានសម្រេចចិត្តស្វះស្វែងធ្វើការស្រាវជ្រាវក្នុងគោលបំណងសរសេរសារណាបញ្ចប់ការសិក្សានេះ ដោយផ្ដោតសំខាន់ទៅលើប្រធានបទមួយស្ដីអំពី **របបគតិយុត្តនៃការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជា** ។

មូលហេតុចម្បង ដែលបណ្ដាលឲ្យយើងខ្ញុំទាំងពីរនាក់មូលមតិសម្រេចចិត្តជ្រើសរើសយកប្រធានបទនេះ គឺដោយសារយើងខ្ញុំមានការយល់ឃើញថា ប្រទេសកម្ពុជា គឺជាប្រទេសដែលកំពុងអភិវឌ្ឍន៍ ដែលហេតុនេះវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គឺជាវិស័យដែលកំពុងមានភាពរីកចម្រើនយ៉ាងខ្លាំងក្លា និងមានសន្ទុះក្នុងការអភិវឌ្ឍនៅក្នុងប្រទេសស្ទើតែគ្រប់ខេត្តក្រុង ដោយគេចាត់សម្គាល់យ៉ាងខ្លាំងគឺ ខេត្តព្រះសីហនុ ដែលនៅក្នុងចន្លោះពេល៥ឆ្នាំចុងក្រោយនេះ គឺត្រូវបានអភិវឌ្ឍខ្លាំងជាងគេនៅក្នុងប្រទេសកម្ពុជា។ ជាពិសេសរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ទាក់ទងនឹងតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជាហាក់មានសន្ទុះយ៉ាងខ្លាំងទាក់ទងនឹងការអភិវឌ្ឍ និងការវិនិយោគនៅតំបន់ឆ្នេរ ដោយឃើញមានការទាក់ទាញវិនិយោគិន និងភ្ញៀវទេសចរជាតិ និងអន្តរជាតិយ៉ាងច្រើនកុះករ មកវិនិយោគ និងមកលេងកម្សាន្តនៅតំបន់ឆ្នេរ។ ហេតុនេះហើយទើបធ្វើឲ្យយើងខ្ញុំទាំងពីរនាក់មានការចាប់អារម្មណ៍ និងចង់យល់ដឹងទាក់ទងនឹងការរៀបចំ គ្រប់គ្រង និងទិដ្ឋភាពច្បាប់ដែលអនុវត្តលើវិស័យនេះ។

យើងខ្ញុំទាំងពីរនាក់សង្ឃឹមថា ឯកសារសារណាដែលក្រុមយើងខ្ញុំបានចងក្រងឡើងនេះ អាចជួយរួមចំណែកក្នុងការសិក្សាស្រាវជ្រាវសម្រាប់ផ្ដល់ជាជំនួយដល់និស្សិតជំនាន់ក្រោយ និងអាចជាអត្ថប្រយោជន៍ដល់អ្នកសិក្សាស្រាវជ្រាវ បងប្អូន មិត្តនិស្សិតឲ្យបានសិក្សាស្វែងយល់កាន់តែច្បាស់ទាក់ទងនឹងការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជានេះ។ ទោះបីជាក្រុមយើងខ្ញុំខិតខំស្វះស្វែងអស់ពីសមត្ថភាពក្ដី យ៉ាងណាក៏កម្រងឯកសារសារណានេះប្រាកដជាមានកំហុសខុសឆ្គងខ្លះៗ ដែលអាចកើតមានជាយថាហេតុ ហេតុដូចនេះហើយយើងខ្ញុំទាំងពីរនាក់ទទួលស្វាគមន៍នូវរាល់មតិរិះគន់ ការណែនាំ ការកែតម្រូវ ពីសំណាក់លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ រៀមច្បង មិត្តនិស្សិត អ្នកសិក្សាស្រាវជ្រាវគ្រប់ជំនាន់ និងពីគ្រប់មជ្ឈដ្ឋានទាំងអស់ដោយក្ដីរីករាយ និងក្ដីគោរពជានិច្ច ក្នុងគោលបំណងឲ្យស្នាដៃរបស់យើងខ្ញុំនេះ កាន់តែមានភាពត្រឹមត្រូវ និងទទួលបាននូវការជឿទុកចិត្តពីសំណាក់មិត្តអ្នកអានទាំងឡាយ។ យើងខ្ញុំទាំងពីរនាក់សុំអនុញ្ញាតធ្វើការសូមអភ័យទោសទុកជាមុននូវរាល់កំហុសខុសឆ្គង ដែលកើតមានឡើងជាយថាហេតុ និងសូមអរគុណ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

ក. លំនាំបញ្ហាស្រាវជ្រាវ ........ ១

ខ. ចំណោទបញ្ហានៃការដោះស្រាយ ........ ២

គ. គោលបំណងនៃការស្រាវជ្រាវ ........ ៣

ឃ. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ៣

ង. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ........ ៣

ច. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ ........ ៤

ឆ. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៦

**ជំពូកទី១**

**សញ្ញាណគតិយុត្តនៃការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជា**

**ផ្នែកទី១៖ សញ្ញាណទូទៅនៃការកំណត់តំបន់ឆ្នេរ** ........ ៧

**កថាខណ្ឌទី១ ការកំណត់លក្ខណៈនៃតំបន់ឆ្នេរ** ........ ៧

វាក្យខណ្ឌទី១៖ ខ្លឹមសារ និងអត្ថន័យនៃតំបន់ឆ្នេរ ........ ៧

វាក្យខណ្ឌទី២៖ ទីតាំងភូមិសាស្ត្រនៃតំបន់ឆ្នេរ ........ ៧

**កថាខណ្ឌទី២៖ សញ្ញាណទូទៅនៃការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរ** ........ ៩

វាក្យខណ្ឌទី១៖ ការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរ ........ ៩

វាក្យខណ្ឌទី២៖ ការកំណត់ការប្រើប្រាស់តំបន់ឆ្នេរ ........ ៩

វាក្យខណ្ឌទី៣៖ តួនាទី និងភារកិច្ចរបស់អាជ្ញាធររៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរ ........ ១១

**ផ្នែកទី២៖ សញ្ញាណទូទៅនៃការអភិវឌ្ឍ និងគ្រប់គ្រងតំបន់ឆ្នេរ** ........ ១២

**កថាខណ្ឌទី១៖ ផែនការ និងគោលនយោបាយអភិវឌ្ឍតំបន់ឆ្នេរ** ........ ១២

វាក្យខណ្ឌទី១៖ ផែនការគោលនៃការអភិវឌ្ឍតំបន់ឆ្នេរ ........ ១២

វាក្យខណ្ឌទី២៖ គោលនយោបាយសេដ្ឋកិច្ច និងការអភិវឌ្ឍតំបន់ឆ្នេរ ........ ១៤

ក. កិច្ចសហប្រតិបត្តិការវិនិយោគរវាងកម្ពុជា-ចិន ........ ១៤

ខ. កិច្ចសហប្រតិបត្តិការវិនិយោគរវាង កម្ពុជា-ថៃ និងវៀតណាម ........ ១៥

**កថាខណ្ឌទី២៖ ក្របខណ្ឌគតិយុត្តិនៃការវិនិយោគ និងធ្វើអាជីវកម្មនៅតំបន់ឆ្នេរ** ........ ១៦

វាក្យខណ្ឌទី១៖ អាជ្ញាបណ្ណវិនិយោគ និងអាជីវកម្ម ........ ១៦

វាក្យខណ្ឌទី២៖ តួនាទី និងភារកិច្ចរបស់អាជ្ញាធរគ្រប់គ្រងវិនិយោគ និងអាជីវកម្មតំបន់ឆ្នេរ ........ ១៧

**កថាខណ្ឌទី៣៖ ទស្សនវិស័យរបស់កម្ពុជាចំពោះការអភិវឌ្ឍតំបន់ឆ្នេរ** ........................ ២០

វាក្យខណ្ឌទី១៖ ផែនការគ្រប់គ្រង និងវិនិយោគតំបន់ឆ្នេរ ........................................... ២០

វាក្យខណ្ឌទី២៖ ការគ្រប់គ្រងអាជ្ញាបណ្ណសាងសង់ និងអាជីវកម្មតំបន់ឆ្នេរ............................ ២១

# ជំពូកទី២

# វិធាន លិខិតបទដ្ឋានគតិយុត្ត និងស្ថាប័នដែលមានសមត្ថកិច្ចរៀបចំ និងគ្រប់គ្រង តំបន់ឆ្នេរនៅកម្ពុជា

**ផ្នែកទី១៖ វិធាន និងលិខិតបទដ្ឋានគតិយុត្តដែលគ្រប់គ្រងតំបន់ឆ្នេរ**............................២៣

**កថាខណ្ឌទី១៖ ខ្លឹមសារនៃលិខិតបទដ្ឋានគ្រប់គ្រងតំបន់ឆ្នេរ** ......................................២៣

វាក្យខណ្ឌទី១៖ គោលការណ៍រដ្ឋធម្មនុញ្ញ......................................................................២៣

វាក្យខណ្ឌទី២៖ គោលការណ៍ទូទៅនៃនីតិនគរូបនីយកម្ម និងសំណង់ .................................. ២៤

វាក្យខណ្ឌទី៣៖ សារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ............២៥

**កថាខណ្ឌទី២៖ ការវិវត្តនៃលិខិតបទដ្ឋានគតិយុត្តដែលគ្រប់គ្រងតំបន់ឆ្នេរ**............... ២៦

**ផ្នែកទី២៖ ស្ថាប័នមានសមត្ថកិច្ចរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរ**....................................៣០

**កថាខណ្ឌទី១៖ ស្ថាប័នជំនាញ**................................................................................៣០

វាក្រខណ្ឌទី១៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ..........................................៣០

ក. នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការវិនិយោគ និងទំនាក់ទំនងអន្តរជាតិ ...................៣២

ខ. នាយកដ្ឋានរៀបចំដែនដី ............................................................................៣២

គ. នាយកដ្ឋាននគរូបនីយកម្ម ..........................................................................៣៣

វាក្យខណ្ឌទី២៖ គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ................... ៣៤

ក. រចនាសម្ព័ន្ធរបស់គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា......... ៣៤

ខ. តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា .. ៣៥

វាក្យខណ្ឌទី៣៖ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ កម្ពុជា ....................................................................................................... ៣៦

ក. រចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរ សមុទ្រកម្ពុជា ............................................................................................ ៣៦

ខ. តួនាទី និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍ តំបន់ឆ្នេរសមុទ្រកម្ពុជា .................................................................................. ៣៧

គ. តួនាទី និងភារកិច្ចរបស់ផ្នែកនីមួយៗ.......................................................................៣៨
**កថាខណ្ឌទី២៖ ស្ថាប័នពាក់ព័ន្ធផ្សេងទៀត**...........................................................................៤២
វាក្យខណ្ឌទី១៖ នាយកដ្ឋានអភិរក្សសមុទ្រនិងតំបន់ឆ្នេរ នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន .......................................................................៤២
ក. រចនាសម្ព័ន្ធរបស់នាយកដ្ឋានអភិរក្សសមុទ្រនិងតំបន់ឆ្នេរ .................................. ៤២
ខ. តួនាទី និងភារកិច្ចរបស់ការិយាល័យនីមួយៗ ............................................. ៤៣
វាក្យខណ្ឌទី២៖ មន្ទីរទេសចរណ៍នៃខេត្តតំបន់ឆ្នេរសមុទ្រទាំង០៤..................................៤៨
ក. រចនាសម្ព័ន្ធរបស់មន្ទីរទេសចរណ៍នៃខេត្តតំបន់ឆ្នេរសមុទ្រទាំង០៤.......................៤៨
ខ. តួនាទី និងភារកិច្ចរបស់ការិយាល័យគ្រប់គ្រងឆ្នេរ ........................................៤៨
គ. តួនាទី និងភារកិច្ចរបស់ការិយាល័យទេសចរណ៍កោះរ៉ុង..................................៤៩

## ជំពូកទី៣
## បញ្ហាប្រឈម និងដំណោះស្រាយចំពោះការរំលោភបំពានតំបន់ឆ្នេរនៅកម្ពុជា

**ផ្នែកទី១៖ បញ្ហាប្រឈមនៃការអភិវឌ្ឍតំបន់ឆ្នេរ**........................................................... ៥១
**កថាខណ្ឌទី១៖ ផលប៉ះពាល់ដែលអាចកើតមាន** .......................................................... ៥១
វាក្យខណ្ឌទី១៖ ការសិក្សាពីបរិស្ថានជុំវិញ.................................................................... ៥១
វាក្យខណ្ឌទី២៖ ការសិក្សាពីផលប្រយោជន៍ប្រជាជន ........................................................ ៥២
**កថាខណ្ឌទី២៖ ប្រភេទផ្សេងៗនៃវិវាទ**................................................................... ៥២
វាក្យខណ្ឌទី១៖ វិវាទរវាងរដ្ឋ និងវិស័យឯកជន ............................................................. ៥២
វាក្យខណ្ឌទី២៖ វិវាទរវាងរដ្ឋ និងប្រជាជន.....................................................................៥៣
វាក្យខណ្ឌទី៣៖ វិវាទរវាងវិស័យឯកជន និងប្រជាជន ........................................................ ៥៤
**ផ្នែកទី២៖ យន្តការនៃការដោះស្រាយវិវាទ** ........................................................................ ៥៤
**កថាខណ្ឌទី១៖ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ**............................................. ៥៥
វាក្យខណ្ឌទី១៖ ការចរចា ........................................................................................ ៥៥
វាក្យខណ្ឌទី២៖ សន្ទានកម្ម....................................................................................... ៥៦
វាក្យខណ្ឌទី៣៖ សមត្ថកិច្ចរបស់អាជ្ញាធរពាក់ព័ន្ធ ........................................................ ៥៨
**កថាខណ្ឌទី២៖ ដំណោះស្រាយវិវាទតាមប្រព័ន្ធតុលាការ**.............................................. ៥៩
វាក្យខណ្ឌទី១៖ បណ្ដឹងរដ្ឋប្បវេណី ............................................................................ ៦០
វាក្យខណ្ឌទី២៖ បណ្ដឹងព្រហ្មទណ្ឌ ............................................................................ ៦១

**សេចក្ដីសន្និដ្ឋាន**........................................................................................................................ ៦៣
**អនុសាសន៍**.................................................................................................................................. ៦៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្ដីផ្ដើម

## ក. លំនាំបញ្ហានៃការស្រាវជ្រាវ

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយដែលសម្បូរទៅដោយធនធានធម្មជាតិ បរិស្ថានធម្មជាតិ រមណីយដ្ឋាននានា និងតំបន់ទាក់ទាញជាច្រើន ដែលជាសម្បត្តិដ៏មានតម្លៃរបស់ប្រទេសជាតិ។ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយ និងចិត្ត ដើម្បីរៀបចំ គ្រប់គ្រង និងអភិវឌ្ឍនូវតំបន់ទាំងនេះ ដើម្បីថែរក្សា ការពារ និងធ្វើឲ្យមានការរីកចម្រើននៃវិស័យសេដ្ឋកិច្ច ទេសចរណ៍ និងកំណើនប្រជាជននៅក្នុងតំបន់ទាំងនេះ ក៏ដូចជាព្រះរាជាណាចក្រកម្ពុជាទាំងមូលដែលទាមទារឲ្យមានការអភិវឌ្ឍផ្នែករូបវន្តសមស្រប និងកាត់បន្ថយភាពក្រីក្រ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។ ជាពិសេសចំពោះតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានបញ្ចូលជាសមាជិកក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១១ នៅទីក្រុងទូបាគូតា ប្រទេសសេណេហ្គាល់ ដោយក្លឹបឆ្នេរស្អាតបំផុតលើពិភពលោក ដោយសារភាពសម្បូរបែបនៃជីវៈចម្រុះ ភាពប្រណីតនៃបរិស្ថានធម្មជាតិ តម្លៃអេកូឡូស៊ី សេដ្ឋកិច្ច សង្គម វប្បធម៌ និងប្រពៃណីក្នុងតំបន់ ព្រមទាំងភាពទាក់ទាញផ្នែកទេសចរណ៍ផងដែរ។ នៅព្រះរាជាណាចក្រកម្ពុជា មានខេត្តចំនួន០៤ ដែលជាខេត្តតំបន់ឆ្នេរសមុទ្ររួមមាន ខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តកំពត និងខេត្តកែប ដែលខេត្តទាំងនេះសម្បូរទៅដោយឆ្នេរសមុទ្រស្រស់ស្អាត និងតំបន់កោះជាច្រើន។ ចំពោះសន្ទុះនៃការអភិវឌ្ឍនៅតំបន់ឆ្នេរហាក់មានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារតែតំបន់ឆ្នេរជាគោលដៅមួយដែលមានសារៈសំខាន់នាំមកនូវការរីកចម្រើន ពោលគឺ វិស័យទេសចរណ៍ និងវិស័យសេដ្ឋកិច្ច ភាគច្រើនយើងអាចមើលឃើញពីសន្ទុះនៃការអភិវឌ្ឍ និងការវិនិយោគតំបន់ឆ្នេរនៃខេត្តទាំង០៤ តែម្តង។ ជាក់ស្តែងយើងអាចមើឃើញពីរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំប្រចាំខែកុម្ភៈ ឆ្នាំ២០២១ និងលើកទិសដៅការងារបន្តរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងនោះទាក់ទងនឹងការងារគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ក្រសួងបាននឹងកំពុងចុះប្រមូលទិន្នន័យ ផ្ទៀងផ្ទាត់ទិន្នន័យ និងធ្វើអត្តសញ្ញាណកម្មប្រភេទឆ្នេរសមុទ្រនៅខេត្តព្រះសីហនុ និងខេត្តកំពត សម្រាប់ការងារកសាងផែនទីដីចំណីឆ្នេរសមុទ្រកម្ពុជា បានធ្វើការចុះពិនិត្យតាមដានជាប្រចាំការអនុវត្តគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវក្រុងក្នុងខេត្តព្រះសីហនុ ហើយគិតមកដល់ខែកុម្ភៈ ឆ្នាំ២០២១ ការអនុវត្តគម្រោងសម្រេចបាន១០០%។ បានចុះពិនិត្យតាមដានជាប្រចាំការអនុវត្តគម្រោងសាងសង់ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ចំនួន២កន្លែង (ស្ថានីយទី១ មានសមត្ថភាពប្រព្រឹត្តកម្ម៥ ២០០ម$^{៣}$/ថ្ងៃ និងស្ថានីយទី២ មានសមត្ថភាពប្រព្រឹត្តកម្ម៧ ២០០ម$^{៣}$/ថ្ងៃ ក្នុងខេត្តព្រះសីហនុ ដើម្បីបញ្ចៀសទឹកកខ្វក់កុំឲ្យហូរចូលសមុទ្រ ហើយគិតមកដល់ខែកុម្ភៈ ឆ្នាំ២០២១ ស្ថានីយទី១ សម្រេចបាន៦៣% និងស្ថានីយទី២ សម្រេចបាន ៧៤% បានចុះពិនិត្យតាមដានជាប្រចាំការអនុវត្តគម្រោងសាងសង់បង្គន់អនាម័យសាធារណៈនៅតាមបណ្តោយឆ្នេរសមុទ្រខេត្តព្រះសីហនុ សម្រាប់សាធារណជន និងអ្នកទេសចរ ស្របតាមគោលការណ៍ឯកភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** រួមទាំងការងារជាច្រើនផ្សេងទៀតសម្រាប់ការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរសមុទ្រ

នៃព្រះរាជាណាចក្រកម្ពុជា។

ស្របពេលជាមួយសន្ទុះនៃការអភិវឌ្ឍ និងការវិនិយោគ ព្រមទាំងវិស័យទេសចរណ៍នៅតំបន់ឆ្នេរនេះ បណ្តាលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរត្រូវបានបង្កើតឡើង ហើយក៏មានការវិវត្តរួមទាំងតាក់តែងបន្ថែមផងដែរ ដើម្បីបំពេញតម្រូវការនៃការអភិវឌ្ឍវិស័យតំបន់ឆ្នេរនៅកម្ពុជា។ របបគតិយុត្ត គឺជាវិធានដែលបានបង្កើតឡើងក្នុងគោលបំណងគ្រប់គ្រង សម្របសម្រួល កំណត់លក្ខខណ្ឌចាំបាច់ និងធានានូវភាពត្រឹមត្រូវស្របតាមច្បាប់ ព្រមជាមួយនឹងសិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់រូបវន្តបុគ្គល និងនីតិបុគ្គលដែលពាក់ព័ន្ធក្នុងវិស័យតំបន់ឆ្នេរនេះ។ ទន្ទឹមនឹងនេះតម្រូវការនៃវិធានច្បាប់ អ្នកជំនាញ និងអ្នកយល់ដឹងពីវិស័យនេះក៏នៅតែមានតម្រូវការផងដែរ ប៉ុន្តែចំពោះអត្រានៃបុគ្គលដែលយល់ដឹងអំពីវិធាន និងលិខិតបទដ្ឋានគតិយុត្តរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅមានកម្រិត រីឯចំពោះសាធារណជនទូទៅក៏នៅមានចំនួនតិចដែលបានយល់ដឹងច្បាស់អំពីច្បាប់ វិធាន និងលិខិតបទដ្ឋានគតិយុត្ត រួមទាំងសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន ដែលត្រូវមាន និងត្រូវចូលរួមដើម្បីធានានូវភាពស្របច្បាប់ ប្រសិទ្ធភាព និងចីរភាព ហើយចំពោះបុគ្គលដែលប្រព្រឹត្តសកម្មភាពផ្ទុយនឹងការគ្រប់គ្រង និងភាពស្របច្បាប់ក៏នៅតែបន្តមាន ដែលទាមទារឲ្យមានចំណាត់ការដោះស្រាយពីក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។

កត្តាទាំងអស់នេះជាហេតុនាំឲ្យយើងខ្ញុំទាំងពីរនាក់ ដែលក្នុងនាមជានិស្សិតផ្នែកនីតិសាស្ត្រ ត្រៀមខ្លួននឹងបញ្ចប់ការសិក្សានាពេលខាងមុខនេះ ដោយបានទទួលនូវការអប់រំ ការណែនាំ បណ្តុះបណ្តាល ជ្រោមជ្រែង និងការចង្អុលបង្ហាញពីសំណាក់សាស្ត្រាចារ្យណែនាំរបស់យើងខ្ញុំ យើងខ្ញុំបានសិក្សាស្រាវជ្រាវនូវប្រធានបទ "**របបគតិយុត្តនៃការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជា**" នេះដើម្បីទទួលបានចំណេះដឹងបន្ថែមទាក់ទងទៅនឹងការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរ ដំណើរការនៃគម្រោងអភិវឌ្ឍន៍ និងការវិនិយោគនានានៅតំបន់ឆ្នេរ ការដោះស្រាយបញ្ហាប្រឈមទាំងឡាយដែលកើតមានឡើងនៅតំបន់ឆ្នេរ និងដើម្បីជាអត្ថប្រយោជន៍ជូនដល់បុគ្គលដែលមានបំណងស្វែងយល់អំពីរបបគតិយុត្តសម្រាប់វិស័យនេះ បានទទួលដឹង និងបានសិក្សាស្វែងយល់ផងដែរ។

### ខ. ចំណោទបញ្ហានៃការដោះស្រាយ

យើងបានដឹងហើយការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជា ត្រូវបានអនុលោមទៅតាមបទប្បញ្ញត្តិច្បាប់នានា និងផែនការសម្រាប់រៀបចំ គ្រប់គ្រង និងការអភិវឌ្ឍ រួមទាំងក្របខណ្ឌគតិយុត្តនៃការវិនិយោគនៅតំបន់ឆ្នេរ និងយន្តការដោះស្រាយសម្រាប់បញ្ហាប្រឈមដែលកើតមានឡើងនៅតំបន់ឆ្នេរ ដែលបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការថែរក្សា និងការពារតំបន់ឆ្នេរនៅកម្ពុជាយើង។ បើយើងនិយាយអំពីសមត្ថកិច្ចចំពោះការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរវិញ យើងឃើញថាមានស្ថាប័នជាច្រើនដែលមានសមត្ថកិច្ច និងពាក់ព័ន្ធចំពោះសកម្មភាពនានានៅតំបន់ឆ្នេរនេះ។

ដូច្នេះ យើងគួរស្វែងយល់ថា៖

- តើសញ្ញាណគតិយុត្តនៃការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជាមានខ្លឹមសារយ៉ាងដូចម្តេចខ្លះ?

- តើមានវិធាន និងលិខិតបទដ្ឋានគតិយុត្តអ្វីខ្លះដែលមានអានុភាពលើការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជា ហើយតើលិខិតបទដ្ឋានទាំងនោះមានការវិវត្តយ៉ាងដូចម្តេច?
- តើមានស្ថាប័នណាខ្លះដែលមានសមត្ថកិច្ចចំពោះការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជា ហើយស្ថាប័នទាំងនេះមានរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចអ្វីខ្លះចំពោះកិច្ចការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជា?
- នៅពេលដែលមានផលប៉ះពាល់ បញ្ហាវិវាទ និងការរំលោភបំពាននៅតំបន់ឆ្នេរកើតមានឡើង តើមានយន្តការដោះស្រាយបែបណាខ្លះសម្រាប់ទប់ស្កាត់បញ្ហាទាំងអស់នេះ?

## គ. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ គឺដើម្បីបង្ហាញអំពីខ្លឹមសារលម្អិតនៃវិធាន និងលិខិតបទដ្ឋានគតិយុត្តដែលជាគោល និងជាមូលដ្ឋានក្នុងការបម្រើឲ្យការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជា ដែលអ្នកសិក្សាស្រាវជ្រាវ សាធារណជន ជាពិសេសវិនិយោគិនដែលមានបំណងចង់ធ្វើការវិនិយោគក្នុងគោលដៅអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនានា និងជម្រុញវិស័យសេដ្ឋកិច្ចនៅតំបន់ឆ្នេរនេះ ឲ្យទទួលបានការយល់ដឹងបន្ថែមឲ្យបានកាន់តែច្បាស់លាស់អំពីលក្ខខណ្ឌដែលបានកំណត់ រួមទាំងសិទ្ធិ និងកាតព្វកិច្ចដ៏ចាំបាច់។ ម្យ៉ាងវិញទៀតការស្រាវជ្រាវមួយនេះក៏មានគោលបំណងក្នុងការបំភ្លឺ និងចង្អុលបង្ហាញដល់បងប្អូន មិត្តនិស្សិត និងអ្នកសិក្សាជំនាន់ក្រោយៗបានស្វែងយល់ និងទទួលបាននូវចំណេះដឹងបន្ថែមទៀតអំពីការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជានេះផងដែរ ព្រមទាំងបំផុសនូវស្មារតីក្នុងការស្រាវជ្រាវ និងការចងក្រងនូវស្នាដៃថ្មីៗសម្រាប់ទុកជាទុនដល់អ្នកសិក្សាគ្រប់ៗរូប។

## ឃ. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទស្តីពី **"របបគតិយុត្តនៃការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជា"** នេះគឺផ្តោតសំខាន់លើការធ្វើការសិក្សាចំពោះតែសញ្ញាណគតិយុត្តនៃការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរ វិធាន និងលិខិតបទដ្ឋានគតិយុត្តនៃការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរ ការវិវត្តនៃលិខិតបទដ្ឋានដែលរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរ ស្ថាប័នដែលមានសមត្ថកិច្ចរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរ និងបញ្ហាប្រឈម រួមទាំងដំណោះស្រាយចំពោះការរំលោភបំពាននៅតំបន់ឆ្នេរដែលសិក្សាពីឆ្នាំ១៩៩៣ រហូតដល់ត្រឹមខែមីនា ឆ្នាំ២០២១។

## ង. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ចំពោះសារៈសំខាន់នៃការសិក្សាស្រាវជ្រាវនេះ យើងខ្ញុំនឹងផ្តោតសំខាន់ទៅលើអត្ថប្រយោជន៍ដែលនឹងទទួលបានជា៣ (បី) ផ្នែកសំខាន់ៗដូចជា៖

- **ចំពោះអ្នកវិនិយោគិន**
  - ដើម្បីឲ្យរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងធ្វើការវិនិយោគ និងអភិវឌ្ឍនៅតំបន់ឆ្នេរ បានយល់ដឹងពីលក្ខខណ្ឌគតិយុត្តនៃការវិនិយោគ

- ដើម្បីឲ្យបានយល់ដឹងកាន់តែច្បាស់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនចំពោះកិច្ចការវិនិយោគនៅតំបន់ឆ្នេរ
- យល់ដឹងពីការហាមឃាត់មិនឲ្យអនុវត្តចំពោះសកម្មភាពណាខ្លះនៅតំបន់ឆ្នេរ និងសកម្មភាពដែលត្រូវបានអនុញ្ញាតឲ្យអនុវត្តនៅតំបន់ឆ្នេរ
- យល់ដឹងពីគោលការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានកំណត់ចំពោះកិច្ចការវិនិយោគ និងអភិវឌ្ឍនៅតំបន់ឆ្នេរ។

➢ **ចំពោះអ្នកសិក្សាស្រាវជ្រាវ**

- ជាប្រភពឯកសារសម្រាប់សិស្សនិស្សិត ដែលមានបំណងចង់យល់ដឹងឲ្យបានកាន់តែច្បាស់ចំពោះការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរ ពោលគឺ អាចយកមកធ្វើជាមូលដ្ឋានក្នុងការស្រាវជ្រាវបន្ថែម
- ដើម្បីបង្កើតនូវចំណេះដឹង និងជំនាញថ្មីៗដែលខ្លួនមិនធ្លាប់បានដឹងពីមុនមក និងអាចយកមកសិក្សាស្វែងយល់ក្នុងស្ថានភាពជាក់ស្តែងបាន
- ទទួលបានចំណេះដឹងកាន់តែជ្រាលជ្រៅទាក់ទងនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យល់ដឹងអំពីទិដ្ឋភាពនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដែលមានអានុភាពលើការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរ ជាមួយនឹងទិដ្ឋភាពជាក់ស្តែងដែលកើតមានឡើងនាពេលបច្ចុប្បន្ន។

➢ **ចំពោះយើងខ្ញុំទាំងពីរនាក់**

- តាមរយៈការសិក្សាស្រាវជ្រាវប្រធានបទនេះ គឺដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- ដើម្បីពង្រឹងនូវចំណេះដឹងរបស់យើងខ្ញុំទាំងពីរនាក់ឲ្យកាន់តែមានភាពល្អប្រសើរជាងមុន
- បានសិក្សាឈ្វេងយល់កាន់តែជ្រាលជ្រៅទាក់ទិននឹងនីតិនគរូបនីយកម្ម និងសំណង់ បន្ថែមមួយកម្រិតទៀត ដែលអាចផ្តល់នូវភាពងាយស្រួលពេលដែលយើងខ្ញុំជួបនូវទិដ្ឋភាពជាក់ស្តែង
- ជាពិសេសបានយល់ច្បាស់ពីនីតិវិធីក្នុងការដំណើរការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជា
- បានទទួលការយល់ដឹងបន្ថែមអំពីតួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័ន និងអាជ្ញាធរ ដែលមានសមត្ថកិច្ចចំពោះការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរ
- និងបានជ្រាបច្បាស់ពីនីតិវិធីនៃការដោះស្រាយចំពោះករណីវិវាទដែលកើតមានឡើងនៅតំបន់ឆ្នេរ។

## ច. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ទាក់ទិននឹងតម្រូវការព័ត៌មាន ដើម្បីឲ្យដំណើរការនៃការសិក្សាស្រាវជ្រាវប្រកបដោយភាពជោគជ័យ ពោលគឺត្រូវកំណត់ទិន្នន័យចំនួន២ (ពីរ) សំខាន់ៗដែលរួមមាន ទិន្នន័យចម្បង និងទិន្នន័យបន្ទាប់បន្សំ។

➢ **ទិន្នន័យចម្បង** រាល់ឯកសារទាំងឡាយណាដែលជាបទដ្ឋានគតិយុត្ត ហើយដែលត្រូវបានប្រកាសចូល

ជាធរមានឲ្យអនុវត្ត ពោលគឺៈ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា,០៤ សីហា ១៩៩៤
- ច្បាប់ភូមិបាលនៃព្រះរាជាណាចក្រកម្ពុជា, ៣០ សីហា ២០០១
- ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣
- ព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៧៩ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៅកម្ពុជា, ១៦ កុម្ភៈ ២០១២
- អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់,លេខ៨៦អនក្រ/បក, ១៩ ធ្នូ ១៩៩៧
- អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ៦២អនក្រ/បក, ២០ កក្កដា ១៩៩៩
- សារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា, លេខ០១/សរណន, ០៣ កុម្ភៈ ២០១២
- និងឯកសារចម្បងសំខាន់ៗជាច្រើនទៀត។

➢ **ទិន្នន័យបន្ទាប់បន្សំ** គឺជាទិន្នន័យដែលបានមកពីៈ

- សៀវភៅ និងអត្ថបទមេរៀនដែលបានរៀបរៀងឡើងដោយលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- សៀវភៅដែលបានរៀបរៀងឡើងដោយក្រសួង ស្ថាប័ន នៃព្រះរាជាណាចក្រកម្ពុជា
- សារណាបញ្ចប់ការសិក្សារបស់និស្សិតគ្រប់ជំនាន់
- ប្រភពឯកសារដែលអាចរកបានតាមរយៈប្រព័ន្ធអ៊ីនធើណេត (Internet)
- កម្មវិធីដែលសិក្សាពីវិស័យច្បាប់ និងព័ត៌មានដែលមាននៅលើបណ្តាញសង្គមនានា។

វិធីសាស្ត្រវិភាគទិន្នន័យ ចំពោះវិធីសាស្ត្រនៃការវិភាគត្រូវបានបែងចែកជាពីរផ្នែកគឺៈ

➢ **ការវិភាគទិន្នន័យតាមបែបបរិមាណ** សំដៅដល់ការវិភាគទិន្នន័យមួយប្រភេទ ដែលមានប្រើទិន្នន័យជាតួរលេខច្បាស់លាស់

➢ **ការវិភាគទិន្នន័យតាមបែបគុណភាព** សំដៅដល់ការវិភាគទិន្នន័យដែលមាន ឬទិន្នន័យដែលទទួលបានពីការចុះកម្មសិក្សា ឬបានមកពីការសាកសួរដោយប្រើកម្រងសំណួរដើម្បីចេញជាលទ្ធផល។

ដោយឡែកសម្រាប់ការវិភាគទិន្នន័យរបស់ក្រុមយើងខ្ញុំ គឺយើងខ្ញុំបានធ្វើការវិភាគដោយប្រមូលទិន្នន័យតាមរយៈការស្នើសុំផ្តល់នូវការប្រឹក្សាពីសំណាក់លោកស្រីសាស្ត្រាចារ្យណែនាំ សិស្សច្បងរួមសាលា និងមិត្តនិស្សិត

រួមជំនាន់ រួចធ្វើការវិភាគចេញជាលទ្ធផលមួយដ៏ល្អប្រសើរ។

ជាដំបូងត្រូវធ្វើការប្រមូលទិន្នន័យឲ្យបានច្បាស់លាស់ និងគ្រប់គ្រាន់។ បន្ទាប់ពីទទួលបានគ្រប់គ្រាន់អស់ហើយ យើងខ្ញុំនឹងធ្វើការវិភាគដោយធ្វើការប្រៀបធៀបជាមួយនឹង៖

- អត្ថបទច្បាប់ដែលមានជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា (រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា សារាចរណែនាំលេខ០១/សរណន ស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធ)
- ទ្រឹស្តីដែលបានសិក្សាកន្លងមកជាមួយលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ ដែលពោរពេញទៅដោយសមត្ថភាព និងបទពិសោធន៍ជាច្រើនឆ្នាំក្នុងការបណ្តុះបណ្តាលចំណេះដឹងដល់សិស្សនិស្សិតផ្នែកនីតិសាស្ត្រ និងការអនុវត្តជាក់ស្តែង ជាពិសេសទាក់ទងនឹងផ្នែកនីតិនគរូបនីយកម្ម និងសំណង់នេះ
- រួមទាំងឯកសារពាក់ព័ន្ធជាច្រើនផ្សេងទៀត។

## ឆ. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ គឺផ្តោតសំខាន់ទៅលើរបបគតិយុត្តនៃការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជា ដែលផ្តោតជាពិសេសទៅលើការរៀបចំសោភណភាព និងបរិស្ថាននៅតំបន់ឆ្នេរ ការគ្រប់គ្រងទៅលើសកម្មភាពនានានៅតំបន់ឆ្នេរ ការអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធនានានៅតំបន់ឆ្នេរ និងការវិនិយោគនៅតំបន់ឆ្នេរ ក្នុងគោលដៅជម្រុញឲ្យមានការរីកចម្រើននៃវិស័យសេដ្ឋកិច្ច និងវិស័យទេសចរណ៍ រួមទាំងការដោះស្រាយចំពោះបញ្ហាដែលកើតមានឡើងនៅតំបន់ឆ្នេរ ដើម្បីចូលរួមថែរក្សា និងការពារតំបន់ឆ្នេរផងដែរ។ សារណានេះ យើងខ្ញុំបានបែងចែករចនាសម្ព័ន្ធនៃការស្រាវជ្រាវជា៣ជំពូកផ្សេងគ្នាគឺ៖

- **ជំពូកទី១៖ សញ្ញាណគតិយុត្តនៃការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជា**
- **ជំពូកទី២៖ វិធាន លិខិតបទដ្ឋានគតិយុត្ត និងស្ថាប័នដែលមានសមត្ថកិច្ចរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជា**
- **ជំពូកទី៣៖ បញ្ហាប្រឈម និងដំណោះស្រាយចំពោះការរំលោភបំពានតំបន់ឆ្នេរនៅកម្ពុជា**

# ជំពូកទី១
# សញ្ញាណគតិយុត្តនៃការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជា

# ជំពូកទី១
# សញ្ញាណគតិយុត្តនៃការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជា

## ផ្នែកទី១៖ សញ្ញាណទូទៅនៃការកំណត់តំបន់ឆ្នេរ

### កថាខណ្ឌទី១៖ ការកំណត់លក្ខណៈនៃតំបន់ឆ្នេរ

#### វាក្យខណ្ឌទី១៖ ខ្លឹមសារ និងអត្ថន័យនៃតំបន់ឆ្នេរ

យោងទៅតាមការបកស្រាយភូមិសាស្ត្រវិទ្យា តំបន់ឆ្នេរសមុទ្រ គឺជាតំបន់មួយដែលភ្ជាប់គ្នារវាងទឹកសមុទ្រជាមួយនិងស្ថានដី ដែលការភ្ជាប់គ្នានេះបានបង្កើតឲ្យមានជាតំបន់មួយដែលសម្បូរទៅដោយរលកបោកបក់នៃសមុទ្រជាមួយនិងដីខ្សាច់ជាច្រើនបូករួមជាមួយនិងថ្មតូចៗជាច្រើនប្រភេទលាយគ្នា បានបង្កើតទៅជាឆ្នេរសមុទ្រមួយ។ ដោយដីខ្សាច់ និងថ្មតូចៗនេះ បានបង្កឡើងដោយសារតែរលកបោកបក់របស់ទឹកសមុទ្រទង្គិចជាមួយនឹងថ្មអស់រយៈពេលជាយូរឆ្នាំបានបង្កឡើងនូវស្រទាប់ខ្សាច់ និងថ្មនេះឡើងរហូតដល់សព្វថ្ងៃនេះ។[1]

ដោយឡែកយោងតាមវាក្យសព្ទនៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិវិញ អត្ថន័យនៃតំបន់ឆ្នេរសមុទ្រ សំដៅដល់តំបន់ដីគោកដែលស្ថិតនៅជាប់សមុទ្រ និងទទួលរងឥទ្ធិពលនៃសមុទ្រមាននៅខេត្តកំពត កោះកុង ក្រុងព្រះសីហនុ និងក្រុងកែប ដោយរួមបញ្ចូលទាំងបូរណភាពដែនសមុទ្រ ដែលលាតសន្ធឹងដល់ព្រំប្រទល់តំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ព្រះរាជាណាចក្រកម្ពុជា។

#### វាក្យខណ្ឌទី២ ទីតាំងភូមិសាស្ត្រនៃតំបន់ឆ្នេរ

តំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានកំណត់លក្ខណៈជា ដែនគោក កោះ និងដែនទឹក ដែលយើងអាចកំណត់សម្គាល់ទីតាំងភូមិសាស្ត្របានថា៖

ចំពោះឆ្នេរសមុទ្រ ត្រូវកំណត់ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតនៃទឹកសមុទ្រឡើងមកលើ រហូតដល់ខ្សែបន្ទាត់ហាមឃាត់ការកាន់កាប់ឬសាងសង់នានា ជាថ្ម ដីឬខ្សាច់ ដែលបានកំណត់ទុកជាតំបន់សម្រាប់ប្រើប្រាស់ជាសាធារណៈ និងត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ។ ទំហំឆ្នេរសមុទ្រត្រូវកំណត់ដូចខាងក្រោម៖

- ឆ្នេរជម្រាលត្រូវកំណត់យ៉ាងតិច៣០ម៉ែត្រ ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតទៅខាងដីគោក។
- ឆ្នេរចោតត្រូវកំណត់យ៉ាងតិច២០ម៉ែត្រ ចាប់ពីចំណុចកំពូលនៃផ្ទៃចោតមកខាងដីគោក។

ក្នុងករណីដែលស្ថានភាពទីតាំងជាក់ស្តែងនៃឆ្នេរជម្រាល មិនអាចកំណត់តាមទំហំខាងលើបាន ទំហំឆ្នេរសមុទ្រត្រូវកែឆ្នៃឬពង្រីកបន្ថែម ដើម្បីបង្កើតជាឆ្នេរសម្រាប់ដើរលេងកម្សាន្តប្រសិនបើអាចធ្វើទៅបាន។

ដីចំណីឆ្នេរសមុទ្រ គឺជាផ្ទៃដីចាប់រាប់ពីខ្សែបន្ទាត់ឆ្នេរខាងលើមកទិសខាងដីគោក។ ដីចំណីឆ្នេរសមុទ្រជាដី

---

[1] www.nationalgeographic.org/encyclopedia/beach, (ចូលទស្សនាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង ១៣:៣៥នាទីរសៀល)

សាធារណៈរបស់រដ្ឋ លើកលែងតែមានការកាន់កាប់ស្របច្បាប់។ ប្រវែងឬទំហំដីចំណីឆ្នេរសមុទ្រ ត្រូវកំណត់ដូចខាងក្រោម៖

- ប្រវែងទទឹងដីចំណីឆ្នេរសមុទ្រ ត្រូវកំណត់យ៉ាងតិច៥០ម៉ែត្រគិតពីខ្សែបន្ទាត់ឆ្នេរខាងលើទៅខាងដីគោក
- ក្នុងករណីដែលតាមបណ្តោយឆ្នេរសមុទ្រមានផ្លូវសាធារណៈរួចហើយ ដីចំណីឆ្នេរសមុទ្រអាចកំណត់មកទល់នឹងផ្លូវសាធារណៈនេះ។

ផ្លូវសាធារណៈតាមបណ្តោយដីចំណីឆ្នេរសមុទ្រ គឺជាផ្លូវដែលសាងសង់ឡើងនៅជាប់ខ្សែបន្ទាត់ខាងក្រៅនៃដីចំណីឆ្នេរសមុទ្រ ដែលខណ្ឌចែកដីចំណីឆ្នេរសមុទ្រជាមួយតំបន់រណប។ ផ្លូវនេះជារបាំងទប់ស្កាត់ការរំលោភបំពានកាន់កាប់ដីចំណីឆ្នេរសមុទ្រ។

តំបន់រណប គឺជាតំបន់មួយប្លុកស្ថិតនៅចន្លោះផ្លូវសាធារណៈតាមបណ្តោយឆ្នេរសមុទ្រ និងផ្លូវស្របបន្ទាប់មួយទៀត ដែលស្ថិតក្នុងទិសខាងដីគោក។

ដៃសមុទ្រ គឺជាផ្ទៃទឹកដែលត្រូវតែភ្ជាប់ទៅនឹងផ្ទៃទឹកសមុទ្រ។ ទំហំផ្ទៃទឹកសមុទ្រ ត្រូវកំណត់យកត្រឹមខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុត។

ស្ទឹង ព្រែក ផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន គឺជាផ្ទៃទឹកសាបដែលតភ្ជាប់ទៅនឹងផ្ទៃទឹកសមុទ្រ។ ទំហំទទឹងស្ទឹង ព្រែក ផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន ត្រូវកំណត់ត្រឹមខ្សែបន្ទាត់កម្រិតទឹកខ្ពស់បំផុតទាំងសងខាងនៅរដូវវស្សា លើកលែងតែមានទឹកជំនន់ខុសធម្មតា។ ទំហំដីចំណីស្ទឹង ព្រែក ផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន ត្រូវកំណត់ចម្ងាយ២០ (ម្ភៃ) ម៉ែត្រយ៉ាងតិចពីខ្សែបន្ទាត់ទឹកខ្ពស់បំផុតនៅរដូវវស្សា។

កោះ គឺជាផ្ទៃដីដែលហ៊ុមព័ទ្ធដោយទឹកសមុទ្រ។ ព្រំប្រទល់ដីកោះក្នុងសមុទ្រ ត្រូវកំណត់ត្រឹមខ្សែទឹកជោរអតិបរមាឡើងលើ។ កោះអាចមានទំហំតូច ឬធំខុសៗគ្នា ដែលអាចប្រើប្រាស់ក្នុងគោលដៅផ្សេងៗ លើកលែងតែមានការកំណត់ដោយឡែក។ កោះអាចជាកម្មវត្ថុសម្រាប់ការរស់នៅ និងការអភិវឌ្ឍ ស្របតាមគោលដៅនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ការពារជាតិ និងទេសចរណ៍។

ដូចនេះចំពោះការកំណត់លក្ខណៈនៃតំបន់ឆ្នេរ គឺយើងអាចឃើញពីការកំណត់ទីតាំងភូមិសាស្ត្រនៅតំបន់ឆ្នេរ ដែលត្រូវបានកំណត់អំពីព្រំប្រទល់ ទំហំ និងប្រវែងចម្ងាយផ្សេងៗពីគ្នាទៅតាមទីតាំងនីមួយៗ ដោយក្នុងនោះបង្ហាញពីការកំណត់នូវព្រំប្រទល់ ទំហំ និងប្រវែងចម្ងាយនៃឆ្នេរសមុទ្រ ដីចំណីឆ្នេរសមុទ្រ ផ្លូវសាធារណៈតាមបណ្តោយដីចំណីឆ្នេរសមុទ្រ តំបន់រណប ដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលនាវា ឬក្បូនអាចចេញចូលបាន បណ្តែតបាន និងកោះ។

## កថាខណ្ឌទី២៖ សញ្ញាណទូទៅនៃការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរ

### វាក្យខណ្ឌទី១៖ ការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរ

ការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរ សំដៅដល់ការរៀបចំនូវសោភណភាពនៅតំបន់ឆ្នេរ ដោយមានការពិនិត្យទៅលើអនាម័យ និងបរិស្ថាននៅតំបន់ឆ្នេរ រួមទាំងការរៀបចំនូវសណ្តាប់ធ្នាប់ដោយមិនឲ្យមានការធ្វើអាជីវកម្មខ្នាតតូច ខ្នាតធំ ដែលមិនមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចបានឡើយ ជាពិសេសគឺ ការធ្វើការសាងសង់នូវប្រភេទសំណង់រឹងមាំនៅលើតំបន់ឆ្នេរដែលច្បាប់បានហាមឃាត់។ ម្យ៉ាងវិញទៀត ដើម្បីឲ្យការគ្រប់គ្រងតំបន់ឆ្នេរប្រកបទៅដោយប្រសិទ្ធភាព និងក្នុងគោលបំណងនៃការអភិវឌ្ឍបៃតងផងដែរនោះត្រូវមានយុទ្ធសាស្ត្រដូចខាងក្រោម៖

- ការគ្រប់គ្រងសំណល់រឹង និងសំណល់រាវ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងប្រជាជនដែលរស់នៅក្បែរតំបន់ឆ្នេរ
- ការកំណត់តំបន់ឆ្នេរសមុទ្រសម្រាប់គោលដៅអភិវឌ្ឍ និងការអភិរក្ស
- រៀបចំការប្រើប្រាស់ដីចំណីឆ្នេរសមុទ្រ ក្នុងគោលដៅសាងសង់ហេដ្ឋារចនាសម្ព័ន្ធ លំនៅឋាន សំណង់សាធារណៈ និងឯកជនសម្រាប់បម្រើវិស័យទេសចរណ៍ជាដើម
- ធ្វើការសិក្សា វាយតម្លៃ និងវិភាគឲ្យបានលម្អិតពីសកម្មភាពទាំងឡាយនៅតាមឆ្នេរសមុទ្រ បណ្តោយឆ្នេរសមុទ្រ ដៃសមុទ្រ ស្ទឹង ព្រែក (ដែលតភ្ជាប់នឹងសមុទ្រ) និងកោះ
- ការគ្រប់គ្រងធនធានទឹកសមុទ្រ និងធនធានដែលពាក់ព័ន្ធនឹងទឹកសមុទ្រ
- ធ្វើការផ្សព្វផ្សាយ និងអប់រំពីការអភិវឌ្ឍក្នុងគោលដៅអភិវឌ្ឍបៃតងនៅតំបន់ឆ្នេរដល់សាធារណជនទូទៅ។[2]

### វាក្យខណ្ឌទី២៖ ការកំណត់ការប្រើប្រាស់តំបន់ឆ្នេរ

ការកំណត់ការប្រើប្រាស់តំបន់ឆ្នេរត្រូវបានបែងចែកដាច់ដោយឡែកពីគ្នា ដែលយើងអាចមើលឃើញពីការបែងចែកដូចខាងក្រោម៖

នៅលើឆ្នេរសមុទ្រ អាចអនុញ្ញាតឲ្យដាក់ឆត្រ កៅអី និងតុតូចៗតាមចំនួនសមស្រប ដែលអាចផ្លាស់ប្តូរទីតាំងបាន សម្រាប់គោលដៅសម្រាកលំហែកាយ និងត្រូវរៀបចំដាក់តូបឆ្មាំឆ្នេរសមុទ្រ ដោយបំពាក់សម្ភារ និងឧបករណ៍ចាំបាច់តាមតម្រូវការ ដើម្បីឃ្លាំមើល រួមទាំងការពារសុវត្ថិភាពជូនសាធារណជន និងអ្នកទេសចរ។

ដីចំណីឆ្នេរសមុទ្រ ជាទូទៅប្រើប្រាស់សម្រាប់ជាសួនបៃតង និងបណ្តាញទេសភាព ឬសម្រាប់ដាំដើមឈើសម្គាល់ព្រំឆ្នេរ និងចំណីឆ្នេរ ដោយបន្តទៅជាប់នឹងផ្លូវសាធារណៈដែលស្ថិតក្នុងទិសខាងដីគោក។

---

[2] ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង, ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍន៍បៃតងឆ្នាំ២០១៣-២០៣០, ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង, ទំព័រ១៤ និង១៥

ចំពោះដីចំណីឆ្នេរសមុទ្រដែលមានមនុស្សរស់នៅច្រើន និងមានលក្ខណៈជាទីប្រជុំជន ឬមានសកម្មភាពទេសចរណ៍ ការប្រើប្រាស់ត្រូវបានកំណត់ខាងក្រោម៖

- អាចអនុញ្ញាតឲ្យសាងសង់ជាសំណង់តូបតូចៗ សម្រាប់ការបម្រើដល់សេវាកម្មទេសចរណ៍នៅចន្លោះដើមឈើដែលមានចម្ងាយពីតូបមួយទៅតូបមួយទៀតយ៉ាងតិច១៥ម៉ែត្រ ដើម្បីសម្រួលដល់ការឆ្លងកាត់របស់សាធារណជន និងអ្នកទេសចរ និងរក្សាគំហើញទៅលំហសមុទ្រ។ សំណង់តូបតូចៗនេះត្រូវរៀបចំឲ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស និងមានច្រកដើរចេញចូលច្បាស់លាស់ដើម្បីចៀសវាងផលប៉ះពាល់ដល់សួនច្បារ និងទេសភាពបៃតង
- អាចអនុញ្ញាតឲ្យមានសំណង់ជានិមិត្តរូបផ្សេងៗ ជាលក្ខណៈរូបចម្លាក់ស្តូប ឬសិល្បៈសាធារណៈ
- អាចអនុញ្ញាតឲ្យមាននូវចំណតយានយន្តទេសចរណ៍គ្រប់ប្រភេទ ធ្វើការចូលចតនៅក្នុងបរិវេណដីចំណីឆ្នេរសមុទ្រ ដែលមិនប៉ះពាល់ដល់សួនច្បារ និងទេសភាពបៃតង
- អាចអនុញ្ញាតឲ្យសាងសង់ជាបង្គន់អនាម័យសាធារណៈដែលមានលក្ខណៈសោភណភាព និងចំនួនសមស្រប សម្រាប់បម្រើដល់សាធារណជន និងអ្នកទេសចរ ដោយស្ថិតនៅតាមទីតាំងសមស្រប និងមិនប៉ះពាល់ដល់ទស្សនីយភាពតំបន់
- មិនអាចអនុញ្ញាតឲ្យសាងសង់កំពង់ផែពាណិជ្ជកម្ម លើកលែងតែកំពង់ផែដែលមានស្រាប់ និងទីតាំងដែលមានសក្តានុពលខ្លាំង និងចាំបាច់សម្រាប់សាងសង់កំពង់ផែ
- មិនអាចអនុញ្ញាតឲ្យមានសំណង់រឹងមាំនៅលើដីចំណីឆ្នេរសមុទ្រ លើកលែងតែសំណង់នោះត្រូវសាងសង់ឡើងក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈ និងទេសចរណ៍ដូចជា៖
    - ច្រកចូលឬស្ពានសម្រាប់តភ្ជាប់ទៅរកកំពង់ផែ ដែលមានទូកទេសចរណ៍ឬទូកម៉ាស៊ីនតូចៗសម្រាប់ភ្ញៀវទេសចរឬសាធារណជនប្រើប្រាស់។ កំពង់ផែទាំងនេះត្រូវមានទីតាំងសមស្រប និងមិនមានការរំខានដល់សកម្មភាពឆ្លងកាត់ឆ្នេរសមុទ្រ
    - សារមន្ទីរជីវៈចម្រុះ រុក្ខជាតិសមុទ្រ ត្រីសមុទ្រ (Aquariusm) ដែលនៅផ្នែកខាងមុខសំណង់ស្ថាបត្យកម្មនេះអាចឲ្យភ្ញៀវទេសចរឬសាធារណជនអាចឆ្លងកាត់បាន
    - ទីតាំងផ្សេងទៀតដែលរាជរដ្ឋាភិបាលអនុញ្ញាត។

រីឯដីចំណីឆ្នេរស្ថិតក្នុងតំបន់ដែលមិនមានមនុស្សរស់នៅច្រើន និងមិនមែនជាទីប្រជុំជន ការប្រើប្រាស់ត្រូវបានកំណត់ដូចខាងក្រោម៖

- អាចអនុញ្ញាតឲ្យមានសំណង់កំពង់ផែពាណិជ្ជកម្ម ឬកំពង់ផែនេសាទ។ ចំពោះកំពង់ផែដែលមានស្រាប់ត្រូវរៀបចំឲ្យមានការគ្រប់គ្រងអនាម័យនិងបរិស្ថាន ជាពិសេស កាកសំណល់រាវ និងកាកសំណល់រឹង។ ក្នុងករណីចាំបាច់ គឺត្រូវធ្វើការសិក្សាពីផលប៉ះពាល់បរិស្ថាននិងភាពសមស្របនៃទីតាំង ដើម្បីធានាសុវត្ថិភាព

សុខុមាលភាព និងការកាត់បន្ថយហានិភ័យផ្សេងៗ

- អាចអនុញ្ញាតឲ្យមានការរៀបចំជាតំបន់ទេសចរណ៍លើទឹក កំពង់ផែទេសចរណ៍ ឬតំបន់កម្សាន្តថ្មីដោយមានការគ្រប់គ្រងអនាម័យ បរិស្ថាន ជាពិសេសកាកសំណល់រាវ និងកាកសំណល់រឹងស្របតាមបទដ្ឋានបច្ចេកទេស ដើម្បីការពារធនធានទឹក ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះ
- អាចអនុញ្ញាតឲ្យមានការរៀបចំជាភូមិទេសចរណ៍នៅក្នុងទីតាំងភូមិឋានថ្មី ឬដែលមានស្រាប់ទៅតាមស្ថានភាព និងសក្តានុពលជាក់ស្តែងនៃទីតាំងនីមួយៗ
- ត្រូវធ្វើការសិក្សាទីតាំង និងវាយតម្លៃហេតុប៉ះពាល់បរិស្ថានឲ្យបានត្រឹមត្រូវ ស្របតាមបទដ្ឋានបច្ចេកទេសនូវរាល់សំណើសុំធ្វើការអភិវឌ្ឍសាងសង់នានាដូចជា សំណង់រោងចក្រ ឧស្សាហកម្ម រោងជាង និងស្ថានីយផ្សេងៗជាដើម ដែលអាចមានកម្រិតបញ្ចេញផ្សែងពុលខ្ពស់ទៅក្នុងបរិយាកាស និងបញ្ចេញសំឡេងរំខានខ្លាំងដល់តំបន់ជិតខាង
- អាចអនុញ្ញាតឲ្យមានការអភិវឌ្ឍ ឬឲ្យមានសំណង់ផ្សេងៗទៀតស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល។

**វាក្យខណ្ឌទី៣៖ តួនាទី និងភារកិច្ចរបស់អាជ្ញាធររៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរ**

អាជ្ញាធររៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរ មានតួនាទី និងភារកិច្ចក្នុងការត្រួតពិនិត្យតាមដានលើសកម្មភាពនានានៅតំបន់ឆ្នេរ រក្សាសណ្តាប់ធ្នាប់ បរិស្ថាន សោភណភាពតំបន់ឆ្នេរ និងធានាសុវត្ថិភាពដល់អ្នកទេសចរ និងសាធារណជន ព្រមទាំងការពារមិនឲ្យមានសកម្មភាពខុសច្បាប់ និងមានការរំលោភបំពាននៅតំបន់ឆ្នេរ។ លើសពីនេះទៅទៀត អាជ្ញាធររៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរក៏មានតួនាទី និងភារកិច្ចក្នុងការទទួលខុសត្រូវលើការគ្រប់គ្រង និងអភិរក្សតំបន់ឆ្នេរឲ្យមានចីរភាព និងសមធម៌ និងចាត់នូវវិធានការចាំបាច់ដើម្បីទប់ស្កាត់សកម្មភាពអសកម្មទាំងឡាយដែលអាចប៉ះពាល់ដល់បរិស្ថាន និងធនធានធម្មជាតិនៅតំបន់ឆ្នេរ។ ម្យ៉ាងវិញទៀតចំពោះអាជ្ញាធរដែលមានសមត្ថកិច្ចពាក់ព័ន្ធនឹងតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជាវិញ មានតួនាទី និងភារកិច្ចក្នុងការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី ព្រមទាំងផែនការគ្រប់គ្រងការអភិវឌ្ឍក្នុងតំបន់ឆ្នេរសមុទ្រជាបន្ទាន់នូវរាល់ទីតាំងទាំងឡាយណាដែលពុំទាន់មាននូវប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី ដើម្បីសុំការសម្រេចពីស្ថាប័នមានសមត្ថកិច្ច និងដាក់ឲ្យប្រើប្រាស់ជាផ្លូវការ។

ជាពិសេស គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា មានតួនាទី និងការទទួលខុសត្រូវដូចខាងក្រោម៖

- ការដាក់បញ្ចូលគោលបំណងអភិរក្សបរិស្ថាន និងការអភិវឌ្ឍប្រកបដោយនិរន្តរភាពចូលទៅក្នុងការគ្រប់គ្រងតំបន់ឆ្នេរ
- ការចូលរួមជាសាធារណៈ និងការទទួលបានព័ត៌មានបរិស្ថានពាក់ព័ន្ធទៅនឹងការសម្រេចចិត្តទាំងអស់អំពីការគ្រប់គ្រងតំបន់ឆ្នេរ ស្របតាមបទប្បញ្ញត្តិជាធរមាន

- ការដាក់បញ្ចូលវិធីសាស្ត្រនៃការបង្កឲ្យមានភាពធន់ស៊ាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ចូលទៅក្នុងគម្រោង និងសកម្មភាពនានានៅក្នុងក្នុងតំបន់ឆ្នេរ
- ការចាត់វិធានការ និងកាត់បន្ថយផលប៉ះពាល់ដែលអាចកើតមានឡើងទៅលើទឹកនៃតំបន់ឆ្នេរ ដោយគ្រប់គ្រងធនធានធម្មជាតិ និងសកម្មភាពរបស់មនុស្សទាំងឡាយនៅតាមទីជម្រាលទឹកនៃតំបន់ឆ្នេរ
- ការគ្រប់គ្រងធនធានធម្មជាតិ និងសកម្មភាពរបស់មនុស្សនៅក្នុងតំបន់ឆ្នេរ ទៅតាមវិធីសាស្ត្រដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីជៀសវាង និងកាត់បន្ថយផលប៉ះពាល់ដែលមិនអាចព្យាករណ៍បានពាក់ព័ន្ធទៅនឹងទឹកនៃតំបន់ឆ្នេរ
- ការគ្រប់គ្រងប្រកបដោយភាពសកម្ម និងទូលំទូលាយ លើប្រភពសារជាតិបំពុលបរិស្ថាន និងសារធាតុបំពុលខ្យល់ រឹង រាវទាំងឡាយ នៅតាមច្រាំងសមុទ្រ និងប្រភពសារជាតិពុលដែលកើតពីដី
- ការគ្រប់គ្រង ក្តាប់ស្ថានភាព និងការពារសន្តិសុខតាមតំបន់ឆ្នេរក្នុងករណីបាក់ស្រុត ការបោកបក់នៃព្យុះ និងផលប៉ះពាល់ដែលពាក់ព័ន្ធផ្សេងទៀត។[3]

ការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរ បានបង្ហាញការកំណត់នូវការប្រើប្រាស់តំបន់ឆ្នេរ និងសមត្ថកិច្ចរបស់អាជ្ញាធររៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរ ដែលក្នុងគោលដៅរៀបចំ និងគ្រប់គ្រងសណ្តាប់ធ្នាប់ រក្សាសោភណភាព ការពារបរិស្ថាន និងធនធានតំបន់ឆ្នេរ ធ្វើការគ្រប់គ្រងសកម្មភាពទាំងឡាយរបស់មនុស្សនៅតំបន់ឆ្នេរ ការពារសន្តិសុខ និងសុខសុវត្ថិភាពរបស់សាធារណជន ក៏ដូចជាអ្នកទេសចរ រួមទាំងទប់ស្កាត់រាល់សកម្មភាពទាំងឡាយដែលធ្វើឲ្យប៉ះពាល់ដល់បរិស្ថាន និងធនធានតំបន់ឆ្នេរ។ ហើយចំពោះអាជ្ញាធរដែលមានសមត្ថកិច្ចត្រូវប្រកាន់ខ្ជាប់ និងទទួលខុសត្រូវចំពោះតួនាទី និងភារកិច្ចរបស់ខ្លួន ដើម្បីឲ្យការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរប្រកបទៅដោយប្រសិទ្ធភាព និងចីរភាព។

## ផ្នែកទី២៖ សញ្ញាណទូទៅនៃការអភិវឌ្ឍ និងគ្រប់គ្រងតំបន់ឆ្នេរ

### កថាខណ្ឌទី១៖ ផែនការ និងគោលនយោបាយអភិវឌ្ឍតំបន់ឆ្នេរ

#### វាក្យខណ្ឌទី១៖ ផែនការគោលនៃការអភិវឌ្ឍតំបន់ឆ្នេរ

ការអភិវឌ្ឍតំបន់ឆ្នេរ ត្រូវមាននូវការផ្តួចផ្តើមគម្រោងរៀបចំកសាងសំណង់ផ្សេងៗនៅតំបន់ឆ្នេរ ដែលត្រូវដាក់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យភាពសមស្របតាមគោលនយោបាយ និងបទដ្ឋានបច្ចេកទេសរៀបចំដែនដី និងនគរូបនីយកម្មក្នុងគោលដៅថែរក្សា ការពារ និងលើកកម្ពស់សោភណភាពបរិស្ថានក្នុងតំបន់ឆ្នេរសមុទ្រ។ ការអភិវឌ្ឍ និងការសាងសង់សំណង់នានានៅក្នុងតំបន់ឆ្នេរ ត្រូវគោរពតាមប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី និងបទប្បញ្ញត្តិជាធរមាន។ ចំពោះទីតាំងដែលពុំទាន់មានប្លង់គោលប្រើប្រាស់ដី

[3] សេចក្តីព្រាងក្រមបរិស្ថាននិងធនធានធម្មជាតិ កំណែ៩.១, ២៥ កក្កដា ២០១៧, មាត្រា៥១៥

និងផែនការប្រើប្រាស់ដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់សេចក្តីណែនាំលម្អិតសម្រាប់អនុវត្ត។

ដើម្បីលើកកម្ពស់សោភណភាពបរិស្ថានធម្មជាតិ និងសំណង់ ការអភិវឌ្ឍសំណង់អគារក្នុងតំបន់រណបនៃតំបន់ឆ្នេរត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ត្រូវមានសន្ទស្សន៍ទាប សម្រាប់គ្រប់ប្រភេទសំណង់អគារ ដូចមានចែងក្នុងបទដ្ឋាននគរូបនីយកម្ម
- ត្រូវរៀបចំឲ្យមានសួនច្បារ ដាំស្មៅ ដាំដើមឈើ និងមានផ្លូវថ្មើរជើងនៅលើចិញ្ចើមផ្លូវ ស្របតាមបទដ្ឋានបច្ចេកទេស
- ត្រូវរៀបចំជាលំហសាធារណៈ សួនច្បារ សួនកម្សាន្ត ឬឧទ្យានសាធារណៈជាដើម ដើម្បីលើកកម្ពស់សោភណភាពតំបន់ឆ្នេរសមុទ្រ
- ត្រូវមានលិខិតអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចជាមុនសម្រាប់រាល់ការដាក់តាំងស្លាកពាណិជ្ជកម្ម។

ការអភិវឌ្ឍកោះក្នុងកម្មវត្ថុសម្រាប់ការរស់នៅ ត្រូវគោរពតាមប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី និងបទប្បញ្ញត្តិជាធរមាន ឬតាមផែនការអភិវឌ្ឍន៍ដែលរាជរដ្ឋាភិបាល ឬក្រសួងស្ថាប័នមានសមត្ថកិច្ចបានអនុញ្ញាត។

ចំពោះការអភិវឌ្ឍ និងការសាងសង់នៅលើកោះក្នុងកម្មវត្ថុផ្សេងក្រៅពីការរស់នៅ គឺរាជរដ្ឋាភិបាលកម្ពុជាអាចធ្វើការអភិវឌ្ឍកោះដោយផ្ទាល់ ឬសហការជាមួយវិស័យឯកជន ឬផ្តល់សិទ្ធឲ្យឯកជនធ្វើការអភិវឌ្ឍ ស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល។ បន្ទាប់ពីមានការសម្រេចពីរាជរដ្ឋាភិបាល បុគ្គលដែលទទួលបានសិទ្ធិត្រូវរៀបចំផែនការអភិវឌ្ឍន៍កោះជាលក្ខណៈរូបវន្តឲ្យបានសមស្រប និងដាក់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ពិនិត្យភាពស្របតាមគោលនយោបាយ និងបច្ចេកទេសរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ការអភិវឌ្ឍនេះត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ត្រូវមានសន្ទស្សន៍ទាប ឬមធ្យម
- ត្រូវការពារធនធានធម្មជាតិ និងរក្សាព្រៃឈើដែលមានស្រាប់ឲ្យបានយ៉ាងតិច៦០% (ហុកសិប) ភាគរយ
- ត្រូវសាងសង់សំណង់ដែលមានលក្ខណៈជាខ្មែរ
- ត្រូវរៀបចំប្លង់អភិវឌ្ឍន៍រូបវន្ត ដែលបង្ហាញពីការប្រើប្រាស់ដីតំបន់សាធារណៈ សួនច្បារ សួនឧទ្យាន និងបណ្តាញបៃតង រួមទាំងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធដូចជាផ្លូវសាធារណៈ ផ្លូវថ្មើរជើង ប្រព័ន្ធចម្រុះទឹកកខ្វក់ជាដើម ឲ្យបានត្រឹមត្រូវស្របតាមបទដ្ឋានបច្ចេកទេស និងស្ថានភាពភូមិសាស្ត្រ
- ត្រូវរៀបចំឲ្យមានកំពង់ផែនាវាចម្លងខ្នាតតូច ឬកំពង់ផែទេសចរណ៍ ដែលអាចឲ្យអ្នកទេសចរ និងសាធារណជនទូទៅអាចចេញចូលបាន តាមស្ថានភាពជាក់ស្តែង និងមានទីតាំងសមស្រប
- ត្រូវរៀបចំឲ្យមានការគ្រប់គ្រងកាកសំណល់រឹង និងរាវ តាមបទដ្ឋានបច្ចេកទេស ដើម្បីជៀសវាងការបោះចោលសំរាម និងការបង្ហូរទឹកកខ្វក់ចូលក្នុងសមុទ្រ មុនពេលធ្វើប្រព្រឹត្តកម្ម

- ត្រូវធ្វើការថែរក្សា ការពារ កែច្នៃ និងប្រើប្រាស់ធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះគ្រប់ប្រភេទ ដូចជា ផ្កាថ្ម ត្រី និងរុក្ខជាតិសមុទ្រ ដែលមាននៅជុំវិញកោះ ដើម្បីគោលដៅទេសចរណ៍។

រីឯចំពោះកោះដែលមិនមានអំណោយផលដល់ការប្រើប្រាស់ និងមិនអាចធ្វើការអភិវឌ្ឍផ្សេងៗបាន ត្រូវរក្សាទុកសភាពដើមសម្រាប់ជាប្រយោជន៍ដល់ការលើកកម្ពស់ទេសភាពសមុទ្រ។

នៅលើដែនទឹកសមុទ្រ គឺមាននូវការអភិវឌ្ឍកំពង់ផែទេសចរណ៍ ឬទីតាំងកម្សាន្តបណ្តែតទឹក និងក្នុងទឹកនានា ដែលត្រូវស្នើសុំការអនុញ្ញាតពីគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍឆ្នេរសមុទ្រកម្ពុជា **(គ.អ.ឆ.ក)** ដើម្បីពិនិត្យភាពសមស្របនៃទីតាំង ស្របតាមគោលនយោបាយ និងបទដ្ឋានបច្ចេកទេសរៀបចំដែនដី និងនគរូបនីយកម្ម។

ដូចនេះចំពោះរាល់ការអភិវឌ្ឍក្នុងតំបន់ឆ្នេរសមុទ្រ និងកោះ និងការធ្វើសកម្មភាពសេដ្ឋកិច្ច និងទេសចរណ៍ ត្រូវធានាដល់សុវត្ថិភាពសាធារណៈ សង្គម និងបរិស្ថាន ដោយត្រូវគោរពតាមច្បាប់ បទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេសនានានៃព្រះរាជាណាចក្រកម្ពុជា។

## វាក្យខណ្ឌទី២៖ គោលនយោបាយសេដ្ឋកិច្ច និងការអភិវឌ្ឍតំបន់ឆ្នេរ

តំបន់ឆ្នេរនៅកម្ពុជា គឺជាប៉ូលនៃការអភិវឌ្ឍ និងសេដ្ឋកិច្ចដ៏សំខាន់មួយរបស់កម្ពុជា ដែលចាំបាច់ត្រូវតែមានការអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធនានា និងកិច្ចសហប្រតិបត្តិការវិនិយោគអន្តរជាតិ ដើម្បីធ្វើការឆ្លើយតបទៅនឹងនិន្នាការកើនឡើងនៃវិស័យសេដ្ឋកិច្ច និងទេសចរណ៍របស់ប្រទេស។ ជាពិសេសគឺ ការរួមចំណែកដល់ការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន និងការកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើនប្រាក់ចំណូលរួមជាមួយនឹងការទាក់ទាញភ្ញៀវទេសចរ និងការទាក់ទាញនូវវិនិយោគពីបរទេសបន្ថែមទៀត។ ម្យ៉ាងវិញទៀត តំបន់ឆ្នេរក៏ជាច្រកសេដ្ឋកិច្ចមួយដែលផ្តោតសំខាន់ទៅលើការធ្វើពាណិជ្ជកម្ម ការវិនិយោគនូវវិស័យនៃការដឹកជញ្ជូនទំនិញ និងភ្ញៀវទេសចរផងដែរ ដែលជាការផ្សារភ្ជាប់នូវទំនាក់ទំនងអន្តរជាតិក្នុងការជម្រុញកិច្ចសហប្រតិបត្តិការ និងកំណើនសេដ្ឋកិច្ចជាតិ។

### ក. កិច្ចសហប្រតិបត្តិការវិនិយោគតំបន់ឆ្នេររវាងកម្ពុជា-ចិន

យើងអាចមើលឃើញពីការវិនិយោគរបស់ក្រុមហ៊ុន Z.Q បានធ្វើការប្រកាសវិនិយោគតំបន់ឆ្នេរដែលស្ថិតនៅក្នុងព្រះសីហនុ គឺរមណីយដ្ឋាន និងមជ្ឈមណ្ឌលពាណិជ្ជកម្មឆ្នេរមាស ឆ្នេរប្រាក់ នៅតំបន់រាម ស្ថិតនៅផ្ទៃដីជាង ៦២ហិកតា។ រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់សិទ្ធិទៅឲ្យក្រុមហ៊ុន Z.Q អន្តរជាតិនូវផ្ទៃដីទំហំ ៦២,៨៥ ហិកតា ស្ថិតក្នុងភូមិស្មាច់ដែង ឃុំរាម ខេត្តព្រះសីហនុ ដើម្បីធ្វើការអភិវឌ្ឍប្រែក្លាយទៅជាទីក្រុងរណបដ៏ស្រស់បំព្រងរបស់ខេត្តព្រះសីហនុជាមាត់សមុទ្រមួយនេះនៅថ្ងៃអនាគត ដែលមានឈ្មោះថា តំបន់អភិវឌ្ឍន៍ឆ្នេរមាស ឆ្នេរប្រាក់ ហើយការប្រារព្ធពិធីបញ្ចុះបឋមសិលាបើកការដ្ឋានជាផ្លូវការ ដើម្បីដំណើរការសាងសង់គម្រោងមួយនេះ ដែលបានធ្វើឡើងកាលពីរសៀលថ្ងៃទី១៣ ខែមករាឆ្នាំ២០១៩ កន្លងទៅនេះ។[4]

[4] https://www.tnaot.com/km/m/detail/article/994242, (ចូលទស្សនាថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង ២០:៤៣នាទីយប់)

## ខ. កិច្ចសហប្រតិបត្តិការវិនិយោគតំបន់ឆ្នេររវាងកម្ពុជា-ថៃ និងវៀតណាម

ជាក់ស្តែងនៅក្នុងកិច្ចប្រជុំត្រីភាគីលើកទី៣ (កម្ពុជា-វៀតណាម-ថៃ) តាមរយៈ Video Conference ស្តីពីកិច្ចសហប្រតិបត្តិការច្រកសេដ្ឋកិច្ច (កម្ពុជា-វៀតណាម-ថៃ) ផ្តោតសំខាន់ទៅលើការធ្វើពាណិជ្ជកម្ម វិនិយោគ នូវវិស័យនៃការដឹកជញ្ជូនទំនិញ ភ្ញៀវទេសចរណ៍តាមផ្លូវទឹក គោក អាកាស រវាងប្រទេសទាំងបី។ ដែលកិច្ចប្រជុំពិភាក្សានេះផ្តោតលើរបៀបវារៈ៖[5]

- របាយការណ៍របស់អគ្គនាយក
- បញ្ហាដែលត្រូវបានទទួលស្គាល់តួនាទីរបស់ CVTEC ក្នុងការលើកស្ទួយច្រករបៀងសេដ្ឋកិច្ចតំបន់ឆ្នេរភាគខាងត្បូងដោយនិយម វ៉ាត់ផានិត ប្រធានគណៈកម្មាធិការកិច្ចតំបន់ឆ្នេរកម្ពុជា វៀតណាម និងថៃ (CVTEC) ភាគីថៃ និងការធ្វើបច្ចុប្បន្នភាពទៅលើវឌ្ឍនភាពនៃសន្និសីទកិច្ចសហប្រតិបត្តិការច្រករបៀងសេដ្ឋកិច្ចកម្ពុជា វៀតណាម និងថៃ (CVTEC) បន្ទាប់ពីចុះហត្ថលេខាលើការលើកស្ទួយ និងជម្រុញកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម ការវិនិយោគ ការដឹកជញ្ជូន ទេសចរណ៍ និង MICE តាមរយៈច្រករបៀងសេដ្ឋកិច្ចតំបន់ឆ្នេរក្នុងចំណោមប្រទេសទាំងបី។
- បញ្ហាដែលត្រូវពិចារណា (ព្រាង) ផែនការយុទ្ធសាស្ត្រ (CVTEC) ក្នុងការលើកស្ទួយច្រករបៀងសេដ្ឋកិច្ចតំបន់ឆ្នេរភាគខាងត្បូងដោយ (ក្រុមអ្នកស្រាវជ្រាវនៃសាកលវិទ្យាល័យសភាពាណិជ្ជកម្មថៃ) ។
- និងបញ្ហាផ្សេងៗទៀត។

ការចូលរួមក្នុងសន្និសីទនេះភាគីកម្ពុជាមានខេត្តទាំងបួននៃតំបន់ឆ្នេរសមុទ្ររួមមាន ខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តកំពត និងខេត្តកែប ភាគីវៀតណាមមានខេត្តកាម៉ៅ និងភាគីថៃមានខេត្តត្រាត បានពិភាក្សាការងារមួយចំនួនទាក់ទងទៅនឹងការអនុវត្តកិច្ចព្រមព្រៀង (MOU) រវាងប្រទេសទាំងបី ការអនុវត្តកិច្ចព្រមព្រៀងកន្លងមកនឹងបន្តអនុវត្តឲ្យមានប្រសិទ្ធភាពក្នុងគោលដៅជម្រុញនូវកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម ការវិនិយោគ ការដឹកជញ្ជូនទេសចរណ៍ និង MICE តាមរយៈច្រករបៀងសេដ្ឋកិច្ចតំបន់ឆ្នេរក្នុងចំណោមប្រទេស កម្ពុជា វៀតណាម និងថៃ។

ដូចនេះកិច្ចសហប្រតិបត្តិការវិនិយោគរវាងកម្ពុជា-ចិន និងកិច្ចសហប្រតិបត្តិការវិនិយោគរវាងកម្ពុជា-ថៃ និងវៀតណាម បានបង្ហាញឲ្យឃើញពីការរីកចម្រើននៃការអភិវឌ្ឍនានា និងការលូតលាស់ផ្នែកសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ជាពិសេសទាក់ទងនឹងការអភិវឌ្ឍតំបន់ឆ្នេរនៅកម្ពុជាឲ្យមានការទាក់ទាញនូវទេសចរណ៍ ការរីកចម្រើននូវវិស័យសំណង់ ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធនានានៅជុំវិញតំបន់ឆ្នេរ ការរីកចម្រើននៃវិស័យពាណិជ្ជកម្ម ការដឹកជញ្ជូនទំនិញ និងភ្ញៀវទេសចរតាមរយៈច្រករបៀងសេដ្ឋកិច្ចតំបន់ឆ្នេរនៃប្រទេសទាំង០៤ ដែលបានផ្តល់នូវ

---

[5] https://www.kohkong.gov.kh/archives/70981, (ចូលទស្សនាថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង ២០:៥៦នាទីយប់)

សារៈប្រយោជន៍យ៉ាងសំខាន់មួយផងដែរសម្រាប់ប្រទេសកម្ពុជា។

**កថាខណ្ឌទី២៖ ក្របខណ្ឌគតិយុត្តិនៃការវិនិយោគ និងធ្វើអាជីវកម្មនៅតំបន់ឆ្នេរ**

**វាក្យខណ្ឌទី១៖ អាជ្ញាបណ្ណវិនិយោគ និងអាជីវកម្ម**

រាល់បុគ្គលដែលមានបំណងបង្កើតគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវដាក់សំណើវិនិយោគនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាតាមទម្រង់ និងតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់នេះ និងអនុក្រឹត្យ។[6]

នៅក្នុងរយៈពេល០៣ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាទទួលបានសំណើវិនិយោគ ក្រុមប្រឹក្សានេះត្រូវចេញវិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌ ឬលិខិតបដិសេធទៅឲ្យអ្នកស្នើសុំ។

ប្រសិនបើសំណើវិនិយោគផ្តល់ជូននូវព័ត៌មានទាំងអស់ដែលតម្រូវដោយអនុក្រឹត្យ និងប្រសិនបើសកម្មភាពដែលស្នើសុំពុំមានបញ្ជាក់នៅក្នុងបញ្ជីគម្រោងហាមឃាត់ដែលមានចែងនៅក្នុងអនុក្រឹត្យទេនោះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញវិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌ។ ផ្ទុយទៅវិញ បើសំណើវិនិយោគនោះពុំឆ្លើយតបតាមលក្ខខណ្ឌខាងលើនោះទេ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញលិខិតបដិសេធជូនទៅអ្នកស្នើសុំ។

វិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់ពីការយល់ព្រម អនុញ្ញាត ការជម្រះបញ្ជី អាជ្ញាបណ្ណ លិខិតអនុញ្ញាតឬបញ្ជិកានានា ដែលត្រូវជាតម្រូវការសម្រាប់ដំណើរការគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ រួមទាំងបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលដែលទទួលបន្ទុកក្នុងការចេញលិខិតយល់ព្រមជម្រះបញ្ជី អាជ្ញាបណ្ណ លិខិតអនុញ្ញាឬបញ្ជិកាទាំងនោះផង។ វិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌត្រូវបញ្ជាក់ផងដែរនូវការលើកទឹកចិត្តនានា ដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានសិទ្ធិទទួល ដូចមានចែងក្នុងមាត្រា ១៤ថ្មី នៃច្បាប់នេះ និងការទទួលស្គាល់លើលក្ខន្តិកៈនៃនីតិបុគ្គលដែលជាអ្នកអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

ប្រសិនបើក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ខកខានពុំបានចេញវិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌត្រូវបានចាត់ទុកថា បានយល់ព្រមដោយស្វ័យប្រវត្តិតាមទម្រង់ដូចមានកំណត់ដោយអនុក្រឹត្យ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវទទួលយកនូវអាជ្ញាបណ្ណទាំងអស់ពីក្រសួងស្ថាប័នពាក់ព័ន្ធ ដូចមានចែងក្នុងវិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌជំនួសមុខឲ្យអ្នកស្នើសុំ។ រាល់ស្ថាប័នមានសមត្ថកិច្ចរបស់រដ្ឋាភិបាលដែលទទួលបន្ទុកចេញលិខិតអនុញ្ញាតការជម្រះបញ្ជី អាជ្ញាបណ្ណ លិខិតយល់ព្រមឬបញ្ជិកាដែលមានរាយបញ្ជាក់នៅក្នុងវិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌត្រូវចេញឯកសារទាំងនេះ យ៉ាងយូរបំផុតឲ្យបានមុន ២៨ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទនៃវិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌ។ មន្ត្រីរាជការណាមួយដែលខកខានពុំបានឆ្លើយតបទៅនឹងពាក្យស្នើសុំដោយគ្មានមូលហេតុត្រឹមត្រូវតាមកាលកំណត់ ត្រូវផ្តន្ទាទោសតាមច្បាប់។

[6] ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩,០៣ កុម្ភៈ ឆ្នាំ២០០៣, មាត្រា៦ថ្មី

ក្នុងរយៈពេល ២៨ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាចេញនូវវិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ។ ការចេញវិញ្ញាបនបត្រចុះបញ្ជីស្ថាពរ មិនមែនជាការលើកលែងឲ្យគម្រោងវិនិយោគមានលក្ខណៈសម្បត្តគ្រប់គ្រាន់រួចផុតពីការទទួលនូវលិខិតអនុញ្ញាតនានាដែលក្រសួងស្ថាប័នមានសមត្ថកិច្ចកំណត់ឡើយ។ ទោះបីផុតរយៈពេល ២៨ថ្ងៃ ដូចមានក្នុងកថាខណ្ឌ ៦ ខាងលើក៏ដោយ រាល់ស្ថាប័នមានសមត្ថកិច្ចត្រូវតែចេញលិខិតអនុញ្ញាតតាមការកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិនានា។ កាលបរិច្ឆេទនៃការចេញជូននូវិញ្ញាបនបត្រចុះបញ្ជីស្ថាពរ គឺជាកាលបរិច្ឆេទនៃការចាប់ផ្ដើមគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

រាល់លិខិតបដិសេធត្រូវមានបញ្ជាក់មូលហេតុច្បាស់លាស់ពីការមិនអាចទទួលសំណើវិនិយោគ រួមទាំងព័ត៌មានបន្ថែម ដើម្បីផ្ដល់លទ្ធភាពឲ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាអាចចេញវិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌ។[7]

ទាក់ទងនឹងគម្រោងវិនិយោគដែលមានទុនវិនិយោគទាបជាង ២.០០០.០០០ (ពីរលាន) ដុល្លាអាមេរិក ត្រូវធ្វើការស្នើសុំចុះបញ្ជីពីអនុគណៈកម្មការវិនិយោគខេត្ត-ក្រុង ដែលសំដៅដល់អនុគណៈកម្មការវិនិយោគខេត្ត-ក្រុង ដែលបានបង្កើតឡើងឡើងដោយអនុក្រឹត្យ ដើម្បីពិនិត្យសម្រេចចុះបញ្ជីវិនិយោគខេត្ត-ក្រុង។[8]

សម្រាប់គម្រោងវិនិយោគដែលមានទុនវិនិយោគចាប់ពី ២.០០០.០០០ (ពីរលាន) ដុល្លាអាមេរិក រហូតដល់ ៥០.០០០.០០០ (ហាសិបលាន) ដុល្លាអាមេរិក ត្រូវធ្វើការស្នើសុំចុះបញ្ជីពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

ចំណែកឯគម្រោងវិនិយោគដែលមានទុនចាប់ពី ៥០.០០០.០០០ (ហាសិបលាន) ដុល្លាអាមេរិក ឡើងទៅ ត្រូវធ្វើការស្នើសុំចុះបញ្ជីពីរាជរដ្ឋាភិបាល។[9]

ដូច្នេះចំពោះវិនិយោគិនដែលមានបំណងធ្វើការវិនិយោគ ក៏ដូចជាបង្កើតអាជីវកម្មនៅតំបន់ឆ្នេរ ត្រូវធ្វើការប្រតិបត្តិ និងគោរពតាមក្របខណ្ឌគតិយុត្តនៃការវិនិយោគ និងអាជីវកម្មនៅតំបន់ឆ្នេរ ដើម្បីទទួលបានអាជ្ញាបណ្ណ និងសិទ្ធិស្របច្បាប់ក្នុងការដំណើរការវិនិយោគ និងការធ្វើអាជីវកម្មរបស់ខ្លួននៅតំបន់ឆ្នេរនៃព្រះរាជាណាចក្រកម្ពុជា។

**វាក្យខណ្ឌទី២៖ តួនាទី និងភារកិច្ចរបស់អាជ្ញាធរគ្រប់គ្រងវិនិយោគ និងអាជីវកម្មតំបន់ឆ្នេរ**

អាជ្ញាធរដែលគ្រប់គ្រងលើការវិនិយោគ និងការធ្វើអាជីវកម្មតំបន់ឆ្នេរ រួមមានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុគណៈកម្មការវិនិយោគនៃខេត្តតំបន់ឆ្នេរសមុទ្រទាំង០៤។ តួនាទី និងភារកិច្ចរបស់អាជ្ញាធរគ្រប់គ្រងវិនិយោគ និងអាជីវកម្មតំបន់ឆ្នេរត្រូវបានកំណត់បែងចែក និងមានខ្លឹមសារដូចខាងក្រោម។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានសមត្ថកិច្ច និងភារកិច្ចដូចតទៅ៖

---

[7] ច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជានាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩,០៣ កុម្ភៈ ឆ្នាំ២០០៣, មាត្រា៧ថ្មី

[8] អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១១១អនក្រ/បក, ២៧ កញ្ញា ២០០៥, មាត្រា៤

[9] អនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, លេខ៤៨៦អនក្រ/បក, ១៤ តុលា ២០១៣, មាត្រា១១

- ជាសេនាធិការ និងជាច្រកចេញ-ចូលតែមួយ របស់រាជរដ្ឋាភិបាល ក្នុងកិច្ចការនីតិសម្បទានិងអភិវឌ្ឍន៍ និងការវិនិយោគសាធារណៈ ការវិនិយោគឯកជន ការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- ទាក់ទងជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ក្នុងគោលបំណងធ្វើឲ្យគេយល់ជ្រួតជ្រាបអំពីយុទ្ធសាស្ត្រ និងបណ្តាអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍ប្រទេស ដើម្បីសម្របសម្រួលការទទួល និងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការឲ្យមានប្រសិទ្ធភាពស្របតាមសេចក្តីត្រូវការ និងអាទិភាពរបស់ប្រទេសជាតិ ដោយប្រកាន់តួនាទីជាម្ចាស់ សម្រាប់សម្រេចលទ្ធផលជូនប្រទេសជាតិ
- សម្របសម្រួលការងាររវាងក្រសួង និងស្ថាប័ននានា ដែលមានការពាក់ព័ន្ធជាមួយនឹងដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងជាមួយអ្នកវិនិយោគ
- តម្រង់ទិសក្នុងការបែងចែក ក្នុងការប្រើប្រាស់ធនធានសាធារណៈ និងធនធានឯកជនក្នុងកិច្ចអភិវឌ្ឍន៍កម្ពុជា
- បង្កលក្ខណៈងាយស្រួល និងសម្រួលកិច្ចការដល់ដៃគូអភិវឌ្ឍន៍ និងដល់អ្នកវិនិយោគ
- ពិនិត្យ និងសម្រេចរាល់កិច្ចការនីតិសម្បទានិងអភិវឌ្ឍន៍ និងគម្រោងវិនិយោគរបស់ដៃគូអភិវឌ្ឍន៍គម្រោងវិនិយោគឯកជន និងការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស។[10]

ចំពោះការគ្រប់គ្រងកិច្ចការវិនិយោគសាធារណៈ ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលមានការពាក់ព័ន្ធទៅនឹងបណ្តាក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាល ត្រូវកំណត់ដូចតទៅ៖[11]

- ជាអ្នកសម្របសម្រួលក្នុងការកំណត់លំដាប់អាទិភាពនៃកម្មវិធី និងគម្រោងវិនិយោគរបស់ដៃគូអភិវឌ្ឍន៍សម្រាប់រយៈពេលមធ្យម និងរយៈពេលមួយឆ្នាំ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាបង្អួចការទូតផ្លូវការ
- ក្រសួងផែនការ សហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ជាអ្នកដឹកនាំក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ៥ឆ្នាំ និងកម្មវិធីវិនិយោគសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអ្នករៀបចំការប៉ាន់ប្រមាណស្ថានភាពម៉ាក្រូសេដ្ឋកិច្ចរយៈពេលមធ្យម ជាអ្នករៀបចំថវិកា សម្រាប់អនុវត្តកម្មវិធីវិនិយោគសាធារណៈប្រចាំឆ្នាំ និងជាអ្នកត្រួតពិនិត្យការប្រើប្រាស់ហិរញ្ញប្បទាន
- ក្រសួងជំនាញ ជាអ្នករៀបចំផែនការអភិវឌ្ឍន៍តាមវិស័យ និងគម្រោងវិនិយោគសាធារណៈ តាមផ្នែកដោយសហការយ៉ាងជិតស្និតជាមួយក្រសួងផែនការ និងជាមួយ "ក.អ.ក" ព្រមទាំងជាមួយអ្នកអនុវត្តកម្មវិធី និង

[10] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, លេខ៤៨៦អនក្រ/បក, ១៤ តុលា ២០១៣, មាត្រា១០

[11] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, លេខ៤៨៦អនក្រ/បក, ១៤ តុលា ២០១៣, មាត្រា១៤

គម្រោងវិនិយោគសាធារណៈតាមផ្នែកដែលមានការពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់ខ្លួន។

ចំពោះក្នុងកិច្ចការវិនិយោគឯកជន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានភារកិច្ចដូចតទៅ៖[12]

- បំពេញតួនាទីជាយន្តការ ច្រកចេញ-ចូលតែមួយ និងជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការពិនិត្យ និងសម្រេចលើការវិនិយោគនានាដូចបានកំណត់នៅក្នុងមាត្រា ៣ នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- ធ្វើការវិនិយោគ ការប្រណាំងប្រជែងដណ្តើមឈ្នះ លើទីផ្សារអន្តរជាតិសម្រាប់ប្រទេសកម្ពុជា លើកឡើងនូវទស្សនៈអនាគតអំពីកិច្ចការវិនិយោគឯកជនសម្រាប់ប្រទេសកម្ពុជា និងសម្រេចឲ្យបាននូវទស្សនៈនេះដោយធ្វើឲ្យប្រទេសកម្ពុជាក្លាយទៅជាសាជីវកម្មកម្ពុជា។ សហការជាមួយក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ដើម្បីរៀបចំយុទ្ធសាស្ត្រនៃការវិនិយោគឯកជន និងដើម្បីលើកគម្រោងនានាសម្រាប់ការវិនិយោគឯកជន
- ផ្សព្វផ្សាយអំពីគម្រោងនានាសម្រាប់ការវិនិយោគឯកជន ដែលរាជរដ្ឋាភិបាលបានលើកឡើង និងផ្តល់គម្រោងទាំងនោះទៅឲ្យអ្នកវិនិយោគ តាមនីតិវិធីដែលមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងនៃ ក.អ.ក
- សម្របសម្រួលការគ្រប់គ្រងគម្រោងសម្បទាននៃវិស័យហេដ្ឋារចនាសម្ព័ន្ធ
- លើកគម្រោង និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលស្តីអំពីការរៀបចំ និងការកែលំអច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានផ្សេងៗ ដែលទាក់ទងនឹងការវិនិយោគឯកជន ក្នុងគោលបំណងបង្កើតលក្ខខណ្ឌដែលអនុគ្រោះ និងដែលលើកទឹកចិត្តដល់អ្នកវិនិយោគ ដើម្បីបង្កើនប្រសិទ្ធភាពការងារក្នុងវិស័យវិនិយោគឯកជន
- រៀបចំចងក្រងឯកសារ និងលិខិតបទដ្ឋាននានា ដែលទាក់ទងទៅនឹងកិច្ចការវិនិយោគឯកជនសម្រាប់ការផ្សព្វផ្សាយនៅក្នុងប្រទេស និងក្រៅប្រទេស
- ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងលើកឡើងនូវវិធានការចាំបាច់សម្រាប់កែលម្អ និងតម្រង់ទិសការងារវិនិយោគឯកជន។

អនុគណៈកម្មការវិនិយោគខេត្តតំបន់ឆ្នេរសមុទ្រទាំង០៤ មានភារកិច្ចដូចតទៅ៖

- ត្រូវដំណើរការការងារតាមនីតិវិធីច្បាប់ និងបទប្បញ្ញត្តិស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការចុះបញ្ជីសំណើវិនិយោគរបស់ក្រុមហ៊ុនថ្មី ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ចំពោះគម្រោងដែលមានទុនវិនិយោគទាបជាង ២.០០០.០០០ (ពីរលាន) ដុល្លាអាមេរិក
- ត្រូវផ្តល់នូវឯកសារពាក់ព័ន្ធនឹងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មការវិនិយោគកម្ពុជា បន្ទាប់ពីបានចុះបញ្ជីវិនិយោគរួចហើយ ដើម្បីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មការវិនិយោគកម្ពុជា មានមូលដ្ឋានក្នុងការត្រួតពិនិត្យ និងផ្តល់នូវការលើកទឹកចិត្តលើ

[12] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, លេខ៩៤៨៦អនក្រ/បក, ១៤ តុលា ២០១៣, មាត្រា១៧

សំណើនាំចូលរបស់អ្នកវិនិយោគ។

ចំពោះអាជ្ញាធរដែលមានសមត្ថកិច្ចគ្រប់គ្រងការវិនិយោគ និងអាជីវកម្មនៅតំបន់ឆ្នេរ ត្រូវបានកំណត់ពីតួនាទី និងភារកិច្ចដាច់ដោយឡែកពីគ្នាទៅតាមគម្រោងវិនិយោគនីមួយៗ រួមមានសមត្ថកិច្ចរបស់អនុគណៈកម្មការវិនិយោគ សមត្ថកិច្ចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ដូច្នេះនៅពេលដែលមានគម្រោងវិនិយោគចូលមកកម្ពុជាអាជ្ញាធរទាំងនេះនឹងបំពេញតួនាទី និងភារកិច្ចទៅតាមសមត្ថកិច្ចរបស់ខ្លួន និងប្រតិបត្តិការតាមនីតិវិធីច្បាប់ រួមទាំងបទប្បញ្ញត្តិស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីសម្របសម្រួលគម្រោងវិនិយោគ និងសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងទៀតចំពោះកិច្ចការនេះ។

## កថាខណ្ឌទី៣៖ ទស្សនវិស័យរបស់កម្ពុជាចំពោះការអភិវឌ្ឍតំបន់ឆ្នេរ

### វាក្យខណ្ឌទី១៖ ផែនការគ្រប់គ្រង និងវិនិយោគតំបន់ឆ្នេរ

ដើម្បីឲ្យតំបន់ឆ្នេរនៅកម្ពុជាទទួលបាននូវភាពទាក់ទាញ និងមានវិនិយោគិនមកវិនិយោគនៅកម្ពុជានោះគឺត្រូវផ្តោតជាសំខាន់ទៅលើការគ្រប់គ្រងមួយដែលប្រកបទៅដោយគុណភាព និងមានសក្តានុពល ពោលគឺត្រូវអនុលោមទៅតាមលិខិតបទដ្ឋានរបស់ជាតិជាកំណត់។ នៅក្នុងផែនការគ្រប់គ្រងតំបន់ឆ្នេរនេះទៀតសោត គឺបានធ្វើការកំណត់នូវគោលការណ៍ក៏ដូចជាលក្ខខណ្ឌមួយចំនួនទៅដល់បុគ្គល ដែលមានបំណងមកធ្វើការវិនិយោគនៅកម្ពុជាដោយស្របតាមបទប្បញ្ញត្តិច្បាប់ និងដើម្បីទទួលបានការគាំពារពីច្បាប់ផងដែរ។

រាល់ការប្រគល់សិទ្ធិឲ្យឯកជនធ្វើការវិនិយោគក្នុងតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា គឺត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- រៀបចំឲ្យមានច្រកចេញចូលនៅតាមបណ្តោយឆ្នេរសមុទ្រ ដើម្បីអាចឲ្យភ្ញៀវទេសចរ និងសាធារណជនចេញចូលដើរលេងកម្សាន្ត និងប្រើប្រាស់បាន
- អនុវត្តតាមប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី និងបទប្បញ្ញត្តិជាធរមាន។ ចំពោះទីតាំងដែលពុំទាន់មានប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវរៀបចំសេចក្តីណែនាំលម្អិតសម្រាប់អនុវត្ត
- ត្រូវរៀបចំឲ្យមានប្រព័ន្ធគ្រប់គ្រងកាកសំណល់រាវ ដោយរៀបចំឲ្យមានអាងចម្រោះ ប្រព័ន្ធលូ និងប្រព័ន្ធគ្រប់គ្រងគុណភាពទឹក និងគ្រប់គ្រងកាកសំណល់រឹង ស្របតាមបទដ្ឋានបច្ចេកទេស ចំពោះរាល់ការអភិវឌ្ឍ
- ត្រូវធ្វើការសិក្សាទីតាំង និងវាយតម្លៃផលប៉ះពាល់បរិស្ថាន ឲ្យបានត្រឹមត្រូវហ្មត់ចត់ស្របតាមបទដ្ឋានបច្ចេកទេស នូវរាល់សំណើសុំធ្វើការអភិវឌ្ឍសំណង់នានា ដូចជាសំណង់រោងចក្រ ឧស្សាហកម្ម រោងជាង និងស្ថានីយផ្សេងៗជាដើម ដែលអាចមានកម្រិតបញ្ចេញផ្សែងបំពុលខ្ពស់ទៅក្នុងបរិយាកាស និងកម្រិតបញ្ចេញសម្លេងរំខានថ្លង់ដល់តំបន់ជិតខាង។

**វាក្យខណ្ឌទី២៖ ការគ្រប់គ្រងអាជ្ញាបណ្ណសាងសង់ និងអាជីវកម្មតំបន់ឆ្នេរ**

លិខិតអនុញ្ញាតសាងសង់ ឬអាជ្ញាបណ្ណសាងសង់កំណត់បានថាជាសេវានគរូបនីយកម្ម និងសំណង់ និងជាបន្ទុករបស់ស្ថាប័នជំនាញ ដែលត្រូវធ្វើការសិក្សាបែងចែកអំពីលក្ខខណ្ឌក្នុងការផ្តល់នូវលិខិតអនុញ្ញាតសាងសង់ ឬអាជ្ញាបណ្ណសាងសង់នេះ។[13]

ដើម្បីទទួលបានលិខិតអនុញ្ញាតសាង ឬអាជ្ញាបណ្ណសាងសង់ ដោយយោងតាមលិខិតបទដ្ឋានដែលពាក់ព័ន្ធទៅនឹងការងារសាងសង់ ស្ថាប័នជំនាញតម្រូវឲ្យបុគ្គលបំពេញនូវលក្ខខណ្ឌមួយចំនួនដោយបែងចែកតាមកម្មវត្ថុនៃពាក្យសុំសាងសង់ និងប្រភេទនៃបុគ្គលដែលជាអ្នកដាក់ពាក្យសុំ។ ទីមួយបើសិនជាក្នុងករណីដែលអ្នកដាក់ពាក្យសុំជារូបវន្តបុគ្គល គឺតម្រូវឲ្យមានពាក្យសុំអាជ្ញាបណ្ណសាងសង់ ផ្តត់ផ្គង់ឯកសារដែលពាក់ព័ន្ធទៅនឹងអត្តសញ្ញាណក្បាលដី រៀបចំប្លង់ស្ថាបត្យកម្ម និងប្លង់បង្គុំសំណង់ លទ្ធផលធ្វើតេស្តពិសោធន៍ដី រូបថតទីតាំងដីមានបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច។ ទីពីរបើសិនជាក្នុងករណីដែលអ្នកដាក់ពាក្យសុំជានីតិបុគ្គលវិញ តម្រូវឲ្យបំពេញនូវលក្ខខណ្ឌមួយចំនួនដូចជា ពាក្យសុំអាជ្ញាបណ្ណសាងសង់ ឯកសារបញ្ជាក់អត្តសញ្ញាណក្បាលដី រូបថតទីតាំងដី វិញ្ញាបនបត្របញ្ជាក់អត្តសញ្ញាណក្រុមហ៊ុន ប៉ាតង់ក្រុមហ៊ុន អាករលើតម្លៃបន្ថែមរបស់ក្រុមហ៊ុន លក្ខន្តិកៈក្រុមហ៊ុន ប្លង់គោលអភិវឌ្ឍដីករណីក្រុមហ៊ុនអភិវឌ្ឍទីក្រុងរណប វិញ្ញាបនបត្រស្តាពដែលចេញដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលហៅកាត់ថា ក.អ.ក លទ្ធផលនៃការធ្វើតេស្តពិសោធន៍ដី និងជាចុងក្រោយនោះគឺ រៀបចំប្លង់បង្គុំសំណង់ និងប្លង់ស្ថាបត្យកម្ម។

ចំពោះការគ្រប់គ្រងទៅលើលិខិតអនុញ្ញាតសាងសង់ ឬអាជ្ញាបណ្ណសាសង់ ត្រូវបានបែងចែកជាសមត្ថកិច្ចរបស់សាលាខេត្ត សាលាក្រុង និងសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ដែលត្រូវបានកំណត់ដូចខាងក្រោម៖

- ខេត្ត-ក្រុង មានសមត្ថកិច្ចក្នុងការចេញលិខិតអនុញ្ញាតសាង់សង់ ក្រោមការទទួលខុសត្រូវរបស់ខ្លួន
- លិខិតអនុញ្ញាតសាងសង់ ត្រូវបានចុះហត្ថលេខាដោយប្រតិភូរាជរដ្ឋាភិបាលប្រចាំទីក្រុង ឬដោយអភិបាលខេត្ត-ក្រុង ឬអភិបាលរងដែលបានទទួលសិទ្ធិប្រទាន។ រាល់ការបដិសេធមិនផ្តល់លិខិតអនុញ្ញាតសាងសង់ ត្រូវមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរនូវមូលហេតុច្បាស់លាស់។[14]

រីឯសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលគឺ មានលិខិតអនុញ្ញាតសាងសង់មួយចំនួន ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ដែលរាជរដ្ឋាភិបាលមានសិទ្ធិសម្រេចផ្តល់លិខិតអនុញ្ញាតសាងសង់ចំពោះប្រភេទសំណង់ដូចតទៅ៖

- បណ្តាអគារដែលមានឧបនិស្ស័យខាងពាណិជ្ជកម្ម និងឧស្សាហកម្ម ដែលមានផ្ទៃក្រឡាកម្រាលលើសពី

[13] ប៉ូលី បញ្ញា, "នីតិនគរូបនីយកម្ម និងសំណង់",(មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ឆ្នាំសិក្សា២០២០-២០២១), លិខិតអនុញ្ញាតសាងសង់ និងលិខិតអនុញ្ញាតរុះរើ

[14] អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់, លេខ៨៦អនក្រ/បក, ១៩ ធ្នូ ១៩៩៧, មាត្រា៤

៣.០០០ ម៉ែត្រទ្វេគុណ

- រាល់សណ្ឋាគារ ត្រូវចាត់ទុកជាអគារមានឧបនិស្ស័យពាណិជ្ជកម្ម
- បណ្តាអគារសម្រាប់ការបង្កបង្កើនផលិតផលកសិកម្ម សម្រាប់ធ្វើអាជីវកម្មពី ៥០០ ហិកតាឡើងទៅ
- បណ្តាអាកាសយានដ្ឋាន កំពង់ផែ ស្ថានីយអយស្ម័យយាន និងស្ថានីយរថយន្ត
- បណ្តាសំណង់សាធារណៈ និងឯកជន ដែលមានផ្ទៃក្រឡាកម្រាលលើសពី ៣.០០០ ម៉ែត្រទ្វេគុណ និងផ្ទៃកពង្រីកបន្ថែមដោយគិតទាំងអគារមានស្រាប់ ដែលលើសពី ៣.០០០ ម៉ែត្រទ្វេគុណ (វប្បធម៌ អប់រំកីឡា រដ្ឋបាល ទេសចរណ៍ សុខាភិបាល ថាមពលទឹក...)
- បណ្តាសំណង់សំខាន់ៗ ក្នុងទីដ្ឋានការពារ និងក្នុងក្របខណ្ឌបរិស្ថាន ទេសភាព បេតិកភណ្ឌ ប្រវត្តិសាស្ត្រ បូរាណវត្ថុ និងវប្បធម៌
- ការកែប្រែបណ្តាអគារ ជាផលប្រយោជន៍បេតិកភណ្ឌដែលបានកំណត់ទុក
- បណ្តាសំណង់លើទីដីក្នុងភាពមើលឃើញទៅវិញទៅមក ជាមួយប្រាង្គប្រាសាទប្រវត្តិសាស្ត្រ
- បណ្តាសំណង់ និងការ្យ សម្រាប់ការពារ និអគារយោធា
- នៅក្នុងករណីនេះលិខិតអនុញ្ញាតសាងសង់ ត្រូវចុះហត្ថលេខាដោយប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ បន្ទាប់ពីទទួលបានយោបល់ឯកភាពពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។[15]

ដូចនេះទស្សនវិស័យរបស់កម្ពុជាចំពោះការអភិវឌ្ឍតំបន់ឆ្នេរ គឺផ្តោតទៅលើផែនការគ្រប់គ្រង និងវិនិយោគតំបន់ឆ្នេរ និងការគ្រប់គ្រងអាជ្ញាបណ្ណសាងសង់ និងអាជីវកម្មតំបន់ឆ្នេរ ដើម្បីឲ្យតំបន់ឆ្នេរទទួលបាននូវការវិនិយោគដ៏ល្អប្រសើរ រួមទាំងការសាងសង់នៅតំបន់ឆ្នេរប្រកបដោយប្រសិទ្ធភាព និងត្រឹមត្រូវតាមបទប្បញ្ញត្តិដែលមានជាធរមាន។ ដូចនេះនៅពេលដែលរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងក្នុងការវិនិយោគ និងសាងសង់សំណង់នានាក្នុងគោលដៅអាជីវកម្ម ឬកម្មវត្ថុផ្សេងទៀត ត្រូវធ្វើការបំពេញទៅតាមគោលការណ៍ និងផែនការរបស់រាជរដ្ឋាភិបាល និងលក្ខខណ្ឌផ្សេងៗ ព្រមទាំងគោរពតាមបទប្បញ្ញត្តិនៃការសាសង់ និងវិនិយោគដែលបានកំណត់ជាធរមាន ដើម្បីទទួលបាននូវសិទ្ធិស្របច្បាប់ក្នុងការធ្វើការដំណើរការវិនិយោគ និងការសាសង់របស់ខ្លួននៅតំបន់ឆ្នេរនៃព្រះរាជាណាចក្រកម្ពុជា។

[15] អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់, លេខ៨៦អនក្រ/បក, ១៩ ធ្នូ ១៩៩៧, មាត្រា៥

# ជំពូកទី២

# វិធាន លិខិតបទដ្ឋានគតិយុត្ត និងស្ថាប័ន ដែលមានសមត្ថកិច្ចរៀបចំ និងគ្រប់គ្រង តំបន់ឆ្នេរនៅកម្ពុជា

# ជំពូកទី២
# វិធាន លិខិតបទដ្ឋានគតិយុត្ត និងស្ថាប័នដែលមានសមត្ថកិច្ចរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជា

## ផ្នែកទី១៖ វិធាន និងលិខិតបទដ្ឋានគតិយុត្តដែលគ្រប់គ្រងតំបន់ឆ្នេរ

ដើម្បីឲ្យការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរប្រកបទៅដោយប្រសិទ្ធភាព និងចីរភាព ត្រូវអនុលោមទៅតាមបទប្បញ្ញត្តិដែលរួមមាន គោលការណ៍រដ្ឋធម្មនុញ្ញ គោលការណ៍ទូទៅនៃនីតិនគរូបនីយកម្ម និងសំណង់ និងសារាចរណែនាំលេខ០១/សរណន ស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា។

### កថាខណ្ឌទី១៖ ខ្លឹមសារនៃលិខិតបទដ្ឋានគ្រប់គ្រងតំបន់ឆ្នេរ

#### វាក្យខណ្ឌទី១៖ គោលការណ៍រដ្ឋធម្មនុញ្ញ

គោលការណ៍រដ្ឋធម្មនុញ្ញ គឺសំដៅទៅលើវិធានដែលមានអត្ថន័យអនុញ្ញាតឲ្យស្ថាប័នជំនាញនៃវិស័យនគរូបនីយកម្ម និងសំណង់ គ្រប់គ្រងអភិវឌ្ឍដី និងផ្តត់ផ្គង់សេវានគរូបនីយកម្ម ដោយឈរលើមូលដ្ឋាននៃការធានាដល់កម្មសិទ្ធឯកជន និងលក្ខខណ្ឌជីវិតរបស់ប្រជាពលរដ្ឋ[16] ដែលមានគោលដៅក្នុងធានានូវផលប្រយោជន៍រួម ទាំងផលប្រយោជន៍ជាតិ និងផលប្រយោជន៍របស់ប្រជាជនផងដែរ។ ដោយអនុលោមតាមមាត្រា ៣៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានចែងថា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ ហើយចំពោះសេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវទទួលបានការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ។ មាត្រា ៣៦ វាក្យខណ្ឌ១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរសមស្របតាមសមត្ថភាពរបស់ខ្លួន និងតាមសេចក្តីត្រូវការរបស់សង្គម។ មាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ គឺមានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរទេទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ហើយកម្មសិទ្ធិឯកជនស្របច្បាប់ ស្ថិតនៅក្រោមការគាំពារនៃច្បាប់ ដែលចំពោះការនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឲ្យធ្វើក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុន ដោយសមរម្យ និងយុត្តិធម៌។ ទាក់ទងនឹងផលប្រយោជន៍របស់ជាតិ ដូចជាការគ្រប់គ្រងនិងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ មាត្រា ៥៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានចែងថាទ្រព្យសម្បត្តិរដ្ឋមានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្រ បាតសមុទ្រ ឆ្នេរសមុទ្រ អាកាស កោះ ទន្លេ ព្រែក ស្ទឹង បឹង ព្រៃឈើ

[16] ប៉ូលី បញ្ញា, "នីតិនគរូបនីយកម្ម និងសំណង់",(មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ឆ្នាំសិក្សា២០២០-២០២១), ០៥

ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ចវប្បធម៌ មូលដ្ឋានការពារប្រទេស សំណង់ផ្សេងៗទៀត ដែលបានកំណត់ថាជារបស់រដ្ឋ ដែលការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋនឹងត្រូវកំណត់ក្នុងច្បាប់។ ចំពោះកាតព្វកិច្ចរបស់រដ្ឋក្នុងការគ្រប់គ្រង មាត្រា ៥៩ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ រដ្ឋត្រូវការពារបរិស្ថាន និងតុល្យភាព នៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឲ្យមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រងមានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្ម និងខ្សាច់ ត្បូង ថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆា ធនធានជលផល។

ដូចនេះចំពោះវិស័យរៀបចំ គ្រប់គ្រង ក៏ដូចជាការអភិវឌ្ឍតំបន់ឆ្នេរនៅកម្ពុជា បានបង្ហាញពីការទទួលបានសិទ្ធិ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋនៅតំបន់ឆ្នេរ ដែលពួកគាត់អាចធ្វើអាជីវកម្មលក់ដូរប្រកបរបរចិញ្ចឹមជីវិត និងមានសិទ្ធិក្នុងការវិនិយោគនៅតំបន់ឆ្នេរដោយអនុលោមតាមបទប្បញ្ញត្តិ និងស្របច្បាប់។ ចំពោះរដ្ឋ គឺត្រូវអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួនចំពោះការរៀបចំ គ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ និងត្រូវមានការធានាដល់កម្មសិទ្ធិ ព្រមទាំងមានការផ្តល់ជាសំណងក្នុងករណីដែលមានការដកហូតកម្មសិទ្ធិរបស់ឯកជន សម្រាប់ការធ្វើការអភិវឌ្ឍ និងដើម្បីប្រយោជន៍សាធារណៈ។

### វាក្យខណ្ឌទី២៖ គោលការណ៍ទូទៅនៃនីតិនគរូបនីយកម្ម និងសំណង់

គោលការណ៍ទូទៅនៃនីតិនគរូបនីយកម្ម និងសំណង់ កំណត់អំពីលទ្ធភាពនៃការអភិវឌ្ឍរួមមានគម្រោងទូទៅ និងគម្រោងពិសេស។ កំណត់អំពីសមភាពចំពោះការអភិវឌ្ឍដី មានអត្ថន័យកំណត់ព្រំដែននៃសិទ្ធិកម្មសិទ្ធិរវាងកម្មសិទ្ធិឯកជន និងកម្មសិទ្ធិសាធារណៈលើដីដែលអភិវឌ្ឍន៍ ក្នុងនោះស្ថាប័នជំនាញត្រូវធ្វើការត្រួតពិនិត្យឲ្យបានច្បាស់លាស់ និងរាល់ការរៀបចំលិខិតបទដ្ឋានទាំងឡាយដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងអភិវឌ្ឍដីយ៉ាងណាកុំឲ្យមានការបំពានទៅលើកម្មសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋ។ កំណត់តុល្យភាពនៃគុណសម្បត្តិ និងគុណវិបត្តិនៃការអភិវឌ្ឍដីនៅក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។[17]

ចំពោះការរៀបចំ គ្រប់គ្រង ក៏ដូចជាការអភិវឌ្ឍតំបន់ឆ្នេរ ក៏ត្រូវគោរពតាមគោលការណ៍នេះផងដែរ ដោយធានាបាននូវកម្មសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋ ហើយស្ថាប័នជំនាញនឹងធ្វើការត្រួតពិនិត្យលើការរៀបចំ គ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ ដែលត្រូវមានលក្ខណៈត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស និងបទដ្ឋានគតិយុត្តដែលមានចែង ព្រមទាំងគិតអំពីផលប្រយោជន៍ដែលទទួលបានពីការអភិវឌ្ឍតំបន់ឆ្នេរ និងចាត់វិធានការចាំបាច់ ដើម្បីធ្វើការទប់ស្កាត់ផលប៉ះពាល់ដែលកើតមានឡើងពីការអភិវឌ្ឍតំបន់ឆ្នេរនៅក្នុងខេត្តតំបន់ឆ្នេរសមុទ្រទាំង០៤ (ខេត្តព្រះសីហនុ ខេត្តកំពត ខេត្តកែប និងខេត្តកោះកុង)។

[17] ប៉ូលី បញ្ញា, "នីតិនគរូបនីយកម្ម និងសំណង់",(មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ឆ្នាំសិក្សា២០២០-២០២១), ០៦

## វាក្យខណ្ឌទី៣៖ សារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា

ដើម្បីជាប្រយោជន៍ដល់សង្គម ការរីកចម្រើននៃវិស័យសេដ្ឋកិច្ច ទេសចរណ៍ បរិស្ថានវប្បធម៌ និងប្រពៃណីក្នុងតំបន់ឆ្នេរ រាជរដ្ឋាភិបាលកម្ពុជា មានផែនការគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរឲ្យបានត្រឹមត្រូវ មានប្រសិទ្ធភាព និងប្រកបដោយចីរភាព ដើម្បីចៀសវាង និងទប់ស្កាត់ផលប៉ះពាល់ដែលកើតមានឡើង។

ការរៀបចំ គ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ ចាំបាច់ត្រូវគោរពតាមបទប្បញ្ញត្តិដែលមានជាធរមាន។ ជាក់ស្តែងនៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញសារាចរណែនាំលេខ០១/សរណន ស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ដែលសារាចរនេះមានវិសាលភាពក្នុងការគ្រប់គ្រង កំណត់ពីកាតព្វកិច្ច និងករណីយកិច្ចដែលត្រូវបំពេញមុនពេលធ្វើការរៀបចំ គ្រប់គ្រង ក៏ដូចជាអភិវឌ្ឍតំបន់ឆ្នេរ ដោយត្រូវធានានូវសុវត្ថិភាពសាធារណៈ សង្គម និងបរិស្ថាន ដើម្បីឲ្យមានភាពត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស និងបទប្បញ្ញត្តិដែលមានជាធរមាន។

សារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០១២ ដែលសារាចរនេះបែងចែកជា១១ចំណុច។ សារាចរនេះចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី ព្រមទាំងកំណត់ពីនីតិវិធី និងដំណើរការនៃការរៀបចំ គ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ។ ជាពិសេសនោះគឺ សារាចរនេះជាមូលដ្ឋាននៃការរៀបចំ គ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងកំណត់ពីសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន អាជ្ញាធរ និងអង្គភាពពាក់ព័ន្ធនៅក្នុងកិច្ចការនេះ។ រហូតមកដល់បច្ចុប្បន្ន សារាចរនេះនៅតែមានសុពលភាព និងនៅតែជាមូលដ្ឋានគោលក្នុងការរៀបចំ គ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរដដែល។

ដើម្បីឲ្យការរៀបចំ គ្រប់គ្រង ក៏ដូចជាការអភិវឌ្ឍតំបន់ឆ្នេរនេះប្រកបដោយប្រសិទ្ធភាព និងចីរភាព សារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានបង្កើតឡើង។ សារាចរនេះត្រូវបានបង្កើតឡើងក្នុងគោលបំណង៖

- ការរីកចម្រើននៃវិស័យសេដ្ឋកិច្ច និងទេសចរណ៍តំបន់ឆ្នេរនៃព្រះរាជាណាចក្រកម្ពុជា
- ចៀសវាង និងទប់ស្កាត់ផលប៉ះពាល់ដល់ការអភិវឌ្ឍទេសចរណ៍ សេដ្ឋកិច្ចសង្គម បរិស្ថានវប្បធម៌ និងប្រពៃណីក្នុងតំបន់ឆ្នេរ
- ធានាដល់ការគ្រប់គ្រង ប្រើប្រាស់ ថែរក្សា ការពារ និងអភិវឌ្ឍតំបន់ឆ្នេរនៃព្រះរាជាណាចក្រកម្ពុជា។

សារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរនៃព្រះរាជាណាចក្រកម្ពុជានេះ ត្រូវបានចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រីនាថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ដែលរួមមានចំនួន១១ចំណុច៖

- ចំណុចទី១ កំណត់ពីខ្លឹមសារ និងការប្រើប្រាស់ឆ្នេរសមុទ្រ
- ចំណុចទី២ កំណត់ពីខ្លឹមសារ និងការប្រើប្រាស់ដីចំណីឆ្នេរសមុទ្រ
- ចំណុចទី៣ កំណត់ពីខ្លឹមសារ និងការរៀបចំលើផ្លូវសាធារណៈតាមបណ្តោយដីចំណីឆ្នេរសមុទ្រ

- ចំណុចទី៤ កំណត់ពីខ្លឹមសារនៃតំបន់រណបតាមបណ្តោយផ្លូវសាធារណៈ និងការអភិវឌ្ឍទាក់ទងនឹងសំណង់អគារនៅក្នុងតំបន់នេះ
- ចំណុចទី៥ កំណត់ពីការរៀបចំផ្លូវសាធារណៈ ផ្លូវថ្មើរជើង និងសួនច្បារ ឬបណ្តាញបៃតងក្នុងទិសឆ្ពោះទៅមាត់សមុទ្រ
- ចំណុចទី៦ កំណត់ពីខ្លឹមសារ និងលក្ខណៈនៃដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលតភ្ជាប់ទៅនឹងមាត់សមុទ្រ
- ចំណុចទី៧ កំណត់ពីខ្លឹមសារនៃកោះ និងកម្មវត្ថុនៃការប្រើប្រាស់ និងអភិវឌ្ឍកោះ
- ចំណុចទី៨ កំណត់ពីខ្លឹមសារ និងគោលការណ៍ទាក់ទងនឹងដែនទឹកសមុទ្រ
- ចំណុចទី៩ កំណត់ពីការអភិវឌ្ឍ និងការសាងសង់ក្នុងតំបន់ឆ្នេរសមុទ្រ
- ចំណុចទី១០ បញ្ជាក់ពីការមិនមានផលប្រតិសកម្មនៃសារាចរនេះ
- ចំណុចទី១១ បញ្ជាក់ពីការមិនពាក់ព័ន្ធទៅនឹងអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីច្បាប់សមុទ្រ ឆ្នាំ១៩៨២ និងកំណត់ពីសមត្ថកិច្ចរបស់អាជ្ញាធរពាក់ព័ន្ធ។

**កថាខណ្ឌទី២៖ ការវិវត្តនៃលិខិតបទដ្ឋានគតិយុត្តដែលគ្រប់គ្រងតំបន់ឆ្នេរ**

តាមរយៈការរៀបចំ គ្រប់គ្រង និងការអភិវឌ្ឍតំបន់ឆ្នេរនៅកម្ពុជាយើង គឺមានការវិវត្តជាច្រើនទៅតាមដំណាក់កាលក៏ដូចជាសម័យកាលនីមួយៗ ដែលមានខ្លឹមសារដូចខាងក្រោម៖

នៅឆ្នាំ១៩៩៣ គឺយើងមាននូវរដ្ឋធម្មនុញ្ញដែលបានបញ្ញត្តិទាក់ទងទៅនឹងសិទ្ធិ ករណីយកិច្ច និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋ រួមទាំងរដ្ឋផងដែរ ដែលទាក់ទងទៅនឹងការប្រកបរបរចិញ្ចឹមជីវិត ការថែរក្សា ការពារទ្រព្យសម្បត្តិរដ្ឋ ក៏ដូចជាការគ្រប់គ្រង ប្រើប្រាស់ និងចាត់ចែងនូវទ្រព្យសម្បត្តិរដ្ឋ និងធនធានធម្មជាតិផ្សេងទៀត។ ជាការពិតណាស់នៅកម្ពុជាយើង ចំពោះការរៀបចំ គ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ នៅមុនពេលដែលមានលិខិតបទដ្ឋានសម្រាប់វិស័យតំបន់ឆ្នេរនេះ គឺរាល់ការអនុវត្តនូវទាំងឡាយសកម្មភាពនៅតំបន់ឆ្នេរត្រូវអនុលោមតាមគោលការណ៍រដ្ឋធម្មនុញ្ញ ដែលគោលការណ៍រដ្ឋធម្មនុញ្ញនេះអនុញ្ញាតឲ្យស្ថាប័នជំនាញនៃវិស័យនគរូបនីយកម្ម និងសំណង់ អាចធ្វើការគ្រប់គ្រងអភិវឌ្ឍ ដោយធានានូវកម្មសិទ្ធិឯកជន ការរស់នៅរបស់ប្រជាពលរដ្ឋ និងផលប្រយោជន៍រួម។ មាត្រា ៣៥ និងមាត្រា ៣៦ វាក្យខណ្ឌ១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានចែងទាក់ទងទៅនឹងសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការចូលរួមក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ ហើយមានសិទ្ធិក្នុងការជ្រើសរើសនូវមុខរបរសមស្របតាមសមត្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម ដែលមានន័យថាចំពោះប្រជាពលរដ្ឋដែលរស់នៅតំបន់ឆ្នេរ អាចធ្វើការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនៅតំបន់ឆ្នេរ ដូចជាការធ្វើការវិនិយោគតំបន់ឆ្នេរ ការសាងសង់សណ្ឋាគារស្របច្បាប់សម្រាប់បម្រើសេវាកម្មស្នាក់នៅរបស់ភ្ញៀវទេសចរ និងការប្រកបនូវអាជីវកម្មដែលមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចសម្រាប់បំពេញជីវភាពរស់នៅ ក៏ដូចជាស្របតាមតម្រូវការរបស់ភ្ញៀវទេសចរផងដែរ។ មាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានចែង

ផងដែរថា ជនណាក៏ដោយ ទោះជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ហើយមានតែរូបវន្តបុគ្គល និងនីតិបុគ្គលដែលមានសញ្ជាតិខ្មែរប៉ុណ្ណោះដែលមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ចំពោះកម្មសិទ្ធិឯកជនស្របច្បាប់ត្រូវស្ថិតនៅក្រោមការគាំពារនៃច្បាប់ និងចំពោះការដកហូតកម្មសិទ្ធិអំពីជនណាមួយ ដើម្បីផលប្រយោជន៍សាធារណៈ គឺត្រូវមានការផ្តល់ជាសំណងដោយសមរម្យ និងយុត្តិធម៌ ដែលមានន័យថា ប្រជាពលរដ្ឋដែលរស់នៅតាមតំបន់ឆ្នេរស្របច្បាប់ ហើយត្រូវបានរដ្ឋធ្វើការដកហូតនូវកម្មសិទ្ធិដើម្បីការអភិវឌ្ឍតំបន់ឆ្នេរនោះនឹងទទួលបាននូវសំណងសមរម្យសម្រាប់ករណីនេះ។ មាត្រា៥៨ និង៥៩ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ក៏បានចែងផងដែរទ្រព្យសម្បត្តិរដ្ឋរួមមានដីធ្លី ក្រោមដី ភ្នំ សមុទ្រ បាតសមុទ្រ ឆ្នេរសមុទ្រជាដើម ហើយចំពោះការគ្រប់គ្រង ប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋនឹងត្រូវកំណត់នៅក្នុងច្បាប់ ហើយចំពោះកាតព្វកិច្ចរបស់រដ្ឋ គឺត្រូវរក្សាការពារបរិស្ថាន និងតុល្យភាពនៃភោគទ្រព្យធម្មជាតិ ដោយត្រូវចាត់ចែងផែនការច្បាស់លាស់សម្រាប់ការគ្រប់គ្រងដែលមានន័យថាចំពោះលក្ខខណ្ឌដែលទាក់ទងនឹងការគ្រប់គ្រង ប្រើប្រាស់ ក៏ដូចជាការចាត់ចែងតំបន់ឆ្នេរនេះ គឺត្រូវគោរពគោលការណ៍នៃមាត្រានេះ និងត្រូវគោរពតាមច្បាប់ដែលបានកំណត់។

ក្រោយមកនៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវសារាចរណែនាំលេខ ០១/សរណន ស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់វិស័យតំបន់ឆ្នេរនេះ។ រាជរដ្ឋាភិបាលកម្ពុជា មានផែនការគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរឲ្យបានត្រឹមត្រូវ មានប្រសិទ្ធភាព និងចីរភាព ដើម្បីចៀសវាង និងទប់ស្កាត់ផលប៉ះពាល់ដល់ការអភិវឌ្ឍទេសចរណ៍ សេដ្ឋកិច្ចសង្គម បរិស្ថានវប្បធម៌ និងប្រពៃណីក្នុងតំបន់ឆ្នេរសមុទ្រ។ ដោយយោងតាមសារាចរណែនាំលេខ០១/សរណន ស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា នៅតំបន់ឆ្នេរអាចអនុញ្ញាតឲ្យមានការដាក់ឆត្រ កៅអី និងតុតូចៗ តាមចំនួនសមស្របដែលអាចផ្លាស់ប្តូរទីតាំងបាន ដែលប្រជាពលរដ្ឋរស់នៅតាមតំបន់ឆ្នេរអាចធ្វើការប្រកបរបរអាជីវកម្មស្របតាមការអនុញ្ញាតរបស់អាជ្ញាធរមានសមត្ថកិច្ច។ មួយវិញទៀតប្រជាពលរដ្ឋដែលរស់នៅតាមតំបន់ឆ្នេរមានកាតព្វកិច្ចក្នុងការចូលរួមជួយថែរក្សា ការពារបរិស្ថាន និងអនាម័យនៅតាមតំបន់ឆ្នេរ និងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការទប់ស្កាត់នូវការរំលោភបំពានតំបន់ឆ្នេរ។ ចំពោះអាជ្ញាធរមានសមត្ថកិច្ចនៅតំបន់ឆ្នេរ មានតួនាទី និងភារកិច្ចក្នុងការតាមដានត្រួតពិនិត្យនូវរាល់សកម្មភាពនៅតំបន់ឆ្នេរដូចជាការសាងសង់សំណង់ផ្សេងៗ និងធ្វើការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងរក្សាសណ្តាប់ធ្នាប់នៅតាមតំបន់ឆ្នេរ ហើយអាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើការពិនិត្យរាល់ការស្នើសុំសាងសង់ ក៏ដូចជាធ្វើការចេញនូវលិខិតអនុញ្ញាតសម្រាប់រាល់ការស្នើសុំតាំងនូវស្លាកសញ្ញាពាណិជ្ជកម្មផងដែរ។ ម្យ៉ាងវិញទៀតភារកិច្ចសំខាន់ គឺអាជ្ញាធរមានសមត្ថកិច្ចត្រូវរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី ព្រមទាំងផែនការគ្រប់គ្រងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រជាបន្ទាន់នូវរាល់ទីតាំងទាំងឡាយណាដែលពុំទាន់មានប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី ដើម្បីសុំការសម្រេចពីស្ថាប័នមានសមត្ថកិច្ច និងដាក់ឲ្យប្រើប្រាស់ជាផ្លូវការ។ ជាពិសេសទាក់ទងនឹងលក្ខខណ្ឌក្នុងការអភិវឌ្ឍ និងអាជីវកម្មនៅតំបន់ឆ្នេរនេះ គឺ

ត្រូវគោរពតាមគោលការណ៍របស់សារាចរណែនាំ ដែលមិនអនុញ្ញាតឲ្យមាននូវសំណង់រឹងមាំនៅលើដីចំណីឆ្នេរសមុទ្រដែលខុសពីលក្ខខណ្ឌបានកំណត់ ហើយរាល់ការអភិវឌ្ឍ និងការសាងសង់នានានៅក្នុងតំបន់រណបតាមបណ្តោយផ្លូវសាធារណៈនៅតំបន់ឆ្នេរ ត្រូវគោរពតាមប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី និងបទប្បញ្ញត្តិជាធរមាន។ ការអភិវឌ្ឍកោះក្នុងកម្មវត្ថុសម្រាប់រស់នៅ ត្រូវគោរពតាមប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី ព្រមទាំងបទប្បញ្ញតិជាធរមាន ឬតាមផែនការអភិវឌ្ឍដែលរាជរដ្ឋាភិបាល ឬក្រសួងស្ថាប័នមានសមត្ថកិច្ចអនុញ្ញាត។ ហើយចំពោះការអភិវឌ្ឍ និងការសាងសង់នៅតំបន់កោះក្នុងកម្មវត្ថុផ្សេងវិញ គឺត្រូវមានការរៀបចំផែនការអភិវឌ្ឍន៍ជាលក្ខណៈរូបន្តឲ្យបានសមស្រប និងដាក់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ពិនិត្យភាពស្របតាមគោលនយោបាយ និងបច្ចេកទេសរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ដូចនេះរាល់ការអភិវឌ្ឍក្នុងតំបន់ឆ្នេរសមុទ្រនិងកោះ និងការធ្វើសកម្មភាពសេដ្ឋកិច្ចនិងទេសចរណ៍ ត្រូវធានាដល់សុវត្ថិភាពសាធារណៈ សង្គម និងបរិស្ថាន ដោយត្រូវគោរពតាមច្បាប់ បទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេសដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវសេចក្តីសម្រេចលេខ១៣១/សសរ ស្តីពីការដាក់ឲ្យអនុវត្តគោលការណ៍ណែនាំអភិវឌ្ឍន៍រមណីយដ្ឋានឆ្នេរសមុទ្រ។ សេចក្តីសម្រេចនេះ មានគោលដៅដាក់ឲ្យអនុវត្ត "គោលការណ៍ណែនាំអភិវឌ្ឍន៍រមណីយដ្ឋានឆ្នេរសមុទ្រ" ប្រកបដោយប្រសិទ្ធភាព សំដៅដល់ការចូលរួមអភិវឌ្ឍរមណីយដ្ឋានឆ្នេរសមុទ្រ ឲ្យក្លាយជាផលិតផលទេសចរណ៍ប្រកដោយគុណភាព សុវត្ថិភាព និងនិរន្តរភាព។ សេចក្តីសម្រេចនេះមានគោលបំណងក្នុងការៈ

- ផ្តល់ដល់អ្នកអភិវឌ្ឍរមណីយដ្ឋានឆ្នេរសមុទ្រនូវឧបករណ៍ឯកសារជំនួយដល់ការរៀបចំនូវផែនការមេអភិវឌ្ឍន៍រមណីយដ្ឋានឆ្នេរសមុទ្ររបស់ខ្លួនប្រកបដោយគុណភាព ការទទួលខុសត្រូវ និងនិរន្តរភាពផ្នែកបរិស្ថាន សេដ្ឋកិច្ច និងសង្គម
- ផ្តល់នូវឯកសារណែនាំដល់ការរៀបចំផែនការគ្រប់គ្រងទេសចរណ៍ឆ្នេរសមុទ្រនីមួយៗ សំដៅធានាបានគុណភាពសេវាកម្ម សុវត្ថិភាពទេសចរណ៍នៅតាមឆ្នេរសមុទ្រ ដោយផ្តោតសំខាន់ទៅលើការអប់រំ ការផ្តល់ព័ត៌មាន និងការគ្រប់គ្រងបរិស្ថាន សុវត្ថិភាព សេវាកម្ម និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធបៃតងប្រកបដោយគុណភាព និងឆ្លើយតបចំពោះគោលការណ៍ទប់ស្កាត់ និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការរៀបចំដែនដី និងនគរូបនីយកម្ម ព្រមទាំងជម្រុញស្មារតីចូលរួមរបស់ប្រតិបត្តិករទេសចរណ៍ក្នុងអភិបាលកិច្ចល្អលើបរិស្ថាន អនាម័យតំបន់ឆ្នេរសមុទ្រកម្ពុជា។

បន្តរហូតមកដល់ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវអនុក្រឹត្យលេខ៨១ អនក្រ/បក ស្តីពីការដាក់ឲ្យប្រើប្រាស់នូវផែនការរៀបចំដែនដីខេត្តព្រះសីហនុ ដែលមានចក្ខុវិស័យដល់ឆ្នាំ២០៣០។ ផែនការរៀបចំដែនដីខេត្តព្រះសីហនុ ត្រូវបានកសាងឡើងដោយផ្អែកលើកត្តាទីតាំងភូមិសាស្ត្រនៃតំបន់ឆ្នេរសមុទ្រ

កម្ពុជា កត្តាធនធានធម្មជាតិ បរិស្ថាន ប្រវត្តិសាស្ត្រ វប្បធម៌ និងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ស្របតាមគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗ ពាក់ព័ន្ធនឹងការរៀបចំដែនដី និងនគរូបនីយកម្មនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ចក្ខុវិស័យដល់ឆ្នាំ២០៣០ នៃផែនការរៀបចំដែនដីខេត្តព្រះសីហនុ គឺរៀបចំ និងអភិវឌ្ឍខេត្តព្រះសីហនុ ជាប៉ូលអភិវឌ្ឍជាតិប្រកបដោយចីរភាពនៅតំបន់ឆ្នេរសមុទ្រកម្ពុជា តាមរយៈការអភិវឌ្ឍទីក្រុងទំនើប រមណីយដ្ឋានឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក តំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ច្រកចេញចូលអន្តរជាតិ មជ្ឈមណ្ឌលកំណើនជាតិ មជ្ឈមណ្ឌលភស្តុភារកម្មជាតិ ដោយមានទំនាក់ទំនងជាមួយទីផ្សារអាស៊ាន និងទីផ្សារសកលលោក ព្រមទាំងមជ្ឈមណ្ឌលឧស្សាហកម្មផលិតកម្មបែបបច្ចេកវិទ្យាទំនើប ដែលមានសុខដុមនីយកម្មជាមួយនឹងបរិស្ថានរស់នៅល្អប្រសើរ ដោយផ្អែកលើសក្តានុពលសេដ្ឋកិច្ច ទីតាំងភូមិសាស្ត្រនៃតំបន់ឆ្នេរសមុទ្រកម្ពុជា និងក្របខណ្ឌជាតិ តំបន់ និងអន្តរជាតិ ព្រមទាំងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា និងគោលនយោបាយតាមវិស័យសំខាន់ៗជាច្រើនទៀតរបស់រាជរដ្ឋាភិបាល។

នៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ មានការអនុម័តនូវប្លង់គោលប្រើប្រាស់ដីក្រុងកែប និងប្លង់គោលប្រើប្រាស់ដីក្រុងកំពត របស់គណៈកម្មាធិការរៀបចំដែនដីនគរូបនីយកម្មថ្នាក់ជាតិ។

ប្លង់គោលប្រើប្រាស់ដីក្រុងកែប ចក្ខុវិស័យឆ្នាំ២០៣០ ត្រូវបានអនុម័ត និងដាក់ឲ្យប្រើប្រាស់ជាផ្លូវការដោយសេចក្តីសម្រេចលេខ០០១/សសរ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ សម្រាប់ការអភិវឌ្ឍទីក្រុងកែបរហូតដល់ឆ្នាំ២០៣០។ ប្លង់គោលប្រើប្រាស់ដីក្រុងកែបមានចក្ខុវិស័យ សំដៅរៀបចំ និងអភិវឌ្ឍក្រុងកែប ជាទីក្រុងទំនើបមានខ្យល់អាកាសធម្មជាតិបរិសុទ្ធ ឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក សម្រាប់ការស្នាក់នៅ ប្រកបការងារ និងទេសចរណ៍ ដែលមានគុណភាពបរិស្ថានរស់នៅល្អ ផាសុខភាព និងសុភមង្គលល្អតាមរយៈការអភិវឌ្ឍជាទីក្រុង៖

- គោលដៅទេសចរណ៍ឆ្នេរសមុទ្រ កោះ និងធម្មជាតិ ដែលស្អាតបំផុតលើសកលលោក
- ទីក្រុងបៃតង បុរីលំនៅឋានស្ងប់ស្ងាត់ មជ្ឈមណ្ឌលការងារ ធុរកិច្ច អប់រំ សិក្សា ស្រាវជ្រាវ ដែលមានហេដ្ឋារចនាសម្ព័ន្ធសេវកម្ម និងគុណភាពបរិស្ថានរស់នៅបៃតងធម្មជាតិល្អប្រណីត ប្រកបដោយសុភមង្គល
- គ្រប់គ្រង និងអភិបាលកិច្ចល្អ
- ចីរភាព តុល្យភាព និងសមាហរណកម្មការអភិវឌ្ឍ ប្រកបដោយទឹកសមុទ្រខៀវស្រងាត់ និងខ្យល់អាកាសល្អបរិសុទ្ធ និង
- ជ័យលាភីទីក្រុងឆ្នេរសមុទ្រ ដែលស្អាតបផុតលើសកលលោក ដែលមានភ្ញៀវទេសចរជាតិ និងអន្តរជាតិមកសម្រាកលម្ហែកម្សាន្តគ្រប់រដូវកាល។

ប្លង់គោលប្រើប្រាស់ដីក្រុងកំពត ចក្ខុវិស័យឆ្នាំ២០៣០ ត្រូវបានអនុម័ត និងដាក់ឲ្យប្រើប្រាស់ជាផ្លូវការដោយសេចក្តីប្រកាសសម្រេចលេខ០០៣/សសរ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ សម្រាប់ការអភិវឌ្ឍក្រុងកំពត

រហូតដល់ឆ្នាំ២០៣០។ ប្លង់គោលប្រើប្រាស់ដីក្រុងកំពតមានចក្ខុវិស័យ គឺសំដៅរៀបចំ និងអភិវឌ្ឍក្រុងកំពត ជាក្រុងគុជបៃតង ឆ្នេរសមុទ្រ ធម្មជាតិ វប្បធម៌ និងពាណិជ្ជកម្ម តាមរយៈការអភិវឌ្ឍជាទីក្រុង៖

- រមណីយដ្ឋានគុជទេសចរណ៍ឆ្នេរសមុទ្រ ធម្មជាតិ និងវប្បធម៌ ដែលស្អាតបំផុតលើសកលលោក
- មជ្ឈមណ្ឌលកែច្នៃផលិតផលកសិកម្ម ឧស្សាហកម្ម
- ទីផ្សារអន្តរជាតិសម្រាប់ផលិតផលកសិកម្ម និងចែកចាយទំនិញ
- ជាទីក្រុងទំនើបដែលមានហេដ្ឋាចនាសម្ព័ន្ធ សេវាកម្មទីក្រុង និងគុណភាពបរិស្ថានរស់នៅល្អប្រសើរ
- គ្រប់គ្រង និងអភិបាលកិច្ចល្អ។

ដូចនេះចំពោះការវិវត្តនៃលិខិតបទដ្ឋានរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនេះ បានប្រព្រឹត្តទៅតាមដំណាក់កាលនីមួយៗដែលរួមមាន គោលការណ៍រដ្ឋធម្មនុញ្ញ សារាចរណែនាំលេខ០១/សរណន ស្តីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចលេខ១៣១/សសរ ស្តីពីការឲ្យអនុវត្តគោលការណ៍ណែនាំអភិវឌ្ឍន៍រមណីយដ្ឋានឆ្នេរសមុទ្រ ផែនការរៀបចំដែនដីខេត្តព្រះសីហនុ ប្លង់គោលប្រើប្រាស់ដីក្រុងកែប និងប្លង់គោលប្រើប្រាស់ដីក្រុងកំពត។ ថ្វីត្បិតតែលិខិតបទដ្ឋានគ្រប់គ្រងតំបន់ឆ្នេរមានការវិវត្តក៏ពិតមែន ប៉ុន្តែលិខិតបទដ្ឋាននេះនៅតែមានអានុភាពអនុវត្តចំពោះកិច្ចការរៀបចំ គ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ ដោយក្នុងគោលដៅ និងគោលបំណងដើម្បីថែរក្សា ការពារបរិស្ថានតំបន់ឆ្នេរ ជម្រុញវិស័យទេចរណ៍ វិស័យសេដ្ឋកិច្ច និងសង្គមនៅតំបន់ឆ្នេរឲ្យមានការរីកចម្រើនលូតលាស់ប្រកបដោយប្រសិទ្ធភាព និងចីរភាព។

## ផ្នែកទី២៖ ស្ថាប័នមានសមត្ថកិច្ចរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរ

### កថាខណ្ឌទី១៖ ស្ថាប័នជំនាញរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរ

#### វាក្យខណ្ឌទី១៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានបង្កើតនៅចុងឆ្នាំ១៩៩៨ តាមព្រះរាជក្រឹត្យលេខ នសរកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ នៅក្នុងនីតិកាលទី២នៃរដ្ឋសភាទើបច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានចូលជាធរមានតាមព្រះរាជក្រមលេខ នសរកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់បេសកកម្មឲ្យដឹកនាំ និងគ្រប់គ្រងការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា លើកលែងតំបន់ណា ឬសមត្ថកិច្ចណា ដែលរដ្ឋាភិបាលប្រគល់សមត្ថកិច្ចឲ្យស្ថាប័នមួយផ្សេងទៀត។[18]

[18] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ៦២អនក្រ/បក, ២០ កក្កដា ១៩៩៩, មាត្រា២

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានរចនាសម្ព័ន្ធដូចតទៅ៖[19]

១-ថ្នាក់កណ្តាល

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អធិការដ្ឋាន
- អគ្គនាយកដ្ឋានរដ្ឋបាល រួមមាន:
  - នាយកដ្ឋានរដ្ឋបាល និង កិច្ចការទូទៅ
  - នាយកដ្ឋានបុគ្គលិក
  - នាយកដ្ឋាន ផែនការ សេដ្ឋកិច្ច និងហិរញ្ញកិច្ច
  - នាយកដ្ឋាននីតិកម្ម
  - នាយកដ្ឋាន អភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការវិនិយោគ និងទំនាក់ទំនងអន្តរជាតិ។
- អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្មរួមមាន:
  - នាយកដ្ឋាន ស្រាវជ្រាវ និងបទប្បញ្ញត្តិ
  - នាយកដ្ឋាន រៀបចំដែនដី
  - នាយកដ្ឋាននគរូបនីយកម្ម។
- អគ្គនាយកដ្ឋានសំណង់រួមមាន:
  - នាយកដ្ឋាន ស្រាវជ្រាវបច្ចេកទេសសំណង់
  - នាយកដ្ឋាន សិក្សាគំរោងប្លង់
  - នាយកដ្ឋាន សំណង់។
- អគ្គនាយកដ្ឋានសុរិយោដីរួមមាន:
  - នាយកដ្ឋាន គ្រប់គ្រងដីធ្លី
  - នាយកដ្ឋាន អធិការកិច្ចភូមិបាល
  - នាយកដ្ឋាន បច្ចេកទេស
  - នាយកដ្ឋាន អភិរក្សសុរិយោដី
  - នាយកដ្ឋាន ភូមិសាស្រ្ត។
- មន្ទីរពិសោធន៍

[19] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ៦២អនក្រ/បក, ២០ កក្កដា ១៩៩៩, មាត្រា៤

- មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ
- គ្រឹះស្ថាន និងសហគ្រាសក្រោមឱវាទ
- អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ។

២-អង្គភាពមូលដ្ឋាន

- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត-ក្រុង
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ខណ្ឌ-ស្រុក។

**ក. នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការវិនិយោគ និងទំនាក់ទំនងអន្តរជាតិ**

នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការវិនិយោគ និងទំនាក់ទំនងអន្តរជាតិនេះមានតួនាទី និងភារកិច្ចៈ[20]

- រៀបចំអភិវឌ្ឍសេដ្ឋកិច្ច និងវិនិយោគ ស្របតាមនយោបាយរៀបចំដែនដី និងនគរូបនីយកម្ម ដោយធ្វើទំនាក់ទំនងជាមួយបណ្តាអ្នកផ្តល់ទុនជាប្រាក់ខ្ចី ឬជាជំនួយអន្តរជាតិ អ្នកវិនិយោគទុន ក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងទីស្តីការគណៈរដ្ឋមន្ត្រី
- វិភាគបណ្តាគម្រោងវិនិយោគទុន អំពីគុណភាព និងចំណុចខ្វះខាត ឬភាពមិនប្រក្រតីរបស់គម្រោងក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខេត្ត-ក្រុង
- តាមដានរាល់ការអនុវត្តគម្រោងដែលបានអនុម័តហើយ
- សម្របសម្រួលជំនួយបរទេស
- ធ្វើផែនការទំនាក់ទំនងបរទេស
- ធ្វើជាសេនាធិការឲ្យក្រសួងក្នុងការធ្វើការទំនាក់ទំនង សហប្រតិបត្តិការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងធ្វើសហប្រតិបត្តិការអន្តរជាតិ។

**ខ. នាយកដ្ឋានរៀបចំដែនដី**

នាយកដ្ឋានរៀបចំដែនដី មានតួនាទី និងភារកិច្ចៈ[21]

- រៀបចំគោលនយោបាយ ផែនការ និងយុទ្ធសាស្ត្ររៀបចំដែនដី ធានាការប្រើប្រាស់ដីធ្លី ធនធានធម្មជាតិឲ្យបានសមស្របប្រកបដោយតុល្យភាព និងចីរភាព
- រៀបចំឯកសារបច្ចេកទេសសម្រាប់ប្រជុំអន្តរក្រសួង
- ធ្វើសេនាធិការជូនក្រសួងក្នុងការកសាងនីតិវិធី សម្រាប់ធ្វើសកម្មភាពថ្នាក់ជាតិ សេវាតាមវិស័យ សេវា

---

[20] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ៦២អនក្រ/បក, ២០ កក្កដា ១៩៩៩, មាត្រា១២

[21] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ៦២អនក្រ/បក, ២០ កក្កដា ១៩៩៩, មាត្រា១៥

ថ្នាក់តំបន់ និងថ្នាក់ខេត្ត-ក្រុង

- ធ្វើវិភាគសម្រាប់អនាគត និងកសាងទម្រង់គម្រោង ផែនការ កម្មវិធី ក្នុងការរៀបចំ កែលម្អ បណ្តាញហេដ្ឋារចនាសម្ព័ន្ធកម្រិតជាតិ ដើម្បីអភិវឌ្ឍដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការកំណត់បណ្តាញគមនាគមន៍ ប្រព័ន្ធធារាសាស្ត្រ អាងទឹក កំពង់ផែ អាកាសយានដ្ឋាន និងកំណត់ការរៀបចំដែនដី ចែកជាតំបន់សំខាន់ៗដូចជា តំបន់ឧស្សាហកម្ម កសិកម្ម ពាណិជ្ជកម្ម លំនៅដ្ឋានទេសចរណ៍ និងតំបន់ធម្មជាតិដូចជា ព្រៃ ភ្នំ បឹង ជ្រោះ ទន្លេ សមុទ្រ ឆ្នេរសមុទ្រ តំបន់រក្សាទុកជាដើម
- តាមដានការអនុវត្តការងាររបស់បណ្តាក្រសួង និងអាជ្ញាធរដែនដីខេត្ត-ក្រុង ទាក់ទងនឹងការរៀបចំដែនដីឲ្យស្របតាមអាទិភាពដែលបានកំណត់ក្នុងក្របខណ្ឌនយោបាយរៀបចំដែនដី
- តាមដានកត់ត្រាជាប្រចាំរាល់ទិន្នន័យសេដ្ឋកិច្ចសង្គមលើគម្រោងផែនទីជាតិ។

### គ. នាយកដ្ឋាននគរូបនីយកម្ម

នាយកដ្ឋាននគរូបនីយកម្ម មានតួនាទី និងភារកិច្ចៈ[22]

- លើកសំណើសេចក្តីព្រាងច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋាន ស្តីពីនគរូបនីយកម្ម
- អនុវត្តនយោបាយនគរូបនីយកម្ម ដើម្បីអភិវឌ្ឍទីក្រុង ទីប្រជុំជន ជនបទ និងតំបន់ផ្សេងៗទៀតដែលជះឥទ្ធិពលលើទីក្រុង ដើម្បីលើកស្ទួយសណ្តាប់ធ្នាប់សង្គម សោភណភាព សុវត្ថិភាព និងសុខុមាលភាព
- សិក្សារៀបចំប្លង់មេ និងប្លង់លម្អិត ដោយបែងចែកទីក្រុង និងតំបន់ជុំវិញទីក្រុង ជាតំបន់សម្រាប់ទីតាំងមជ្ឈមណ្ឌលពាណិជ្ជកម្ម សិប្បកម្ម រដ្ឋបាល ទីតាំងសម្រាប់សកម្មភាពអប់រំ លំនៅដ្ឋាន ដីបម្រុង សាលារៀន ទីលានកីឡា ចំណីសងខាងផ្លូវសាធារណៈ ទីលំហែកាយ មន្ទីរពេទ្យ ទីសក្ការៈបូជា វត្តអារាម សួនច្បារសាធារណៈជាដើម
- សហការជាមួយស្ថាប័នពាក់ព័ន្ធរៀបចំគម្រោងបណ្តាញហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ប្រព័ន្ធធ្វើដំណើរសាធារណៈ បណ្តាញលូទឹកស្អុយ បណ្តាញទឹកស្អាត អគ្គិសនី ទូរគមនាគមន៍ និងបណ្តាញផ្សេងទៀតសម្រាប់តម្រូវការក្នុងក្រុង
- រៀបចំកែលម្អគុណភាពទីក្រុង និងតំបន់ថ្មីក្នុងទីក្រុង
- រៀបចំគម្រោងបង្កើតទីក្រុងថ្មី និងតំបន់អភិវឌ្ឍន៍សហគមន៍ថ្មី
- តាមដានកត់ត្រា វិភាគទិន្នន័យ សេដ្ឋកិច្ច សង្គម សមត្ថភាពផ្គត់ផ្គង់ ដឹកជញ្ជូន ស្ថិតិជំរឿន ដង់ស៊ីតេកំណើនប្រជាជន និងកត្តាផ្សេងទៀត ដែលជះឥទ្ធិពលទៅលើការអភិវឌ្ឍទីក្រុង

[22] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ៦២អនក្រ/បក, ២០ កក្កដា ១៩៩៩, មាត្រា១៦

- ពិនិត្យ និងផ្តល់លិខិតអនុញ្ញាតសាងសង់
- ត្រួតពិនិត្យ និងមានវិធានការសម្រាប់អនុវត្តនយោបាយនគរូបនីយកម្មឲ្យមានប្រសិទ្ធភាព។

ដូចនេះនៅក្នុងវិស័យតំបន់ឆ្នេរ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានសមត្ថកិច្ចក្នុងការចូលរួមរៀបចំការអភិវឌ្ឍសេដ្ឋកិច្ច និងកិច្ចការវិនិយោគនៅតំបន់ឆ្នេរ ក៏ដូចជាទំនាក់ទំនងជាមួយអ្នកវិនិយោគផងដែរ។ម្យ៉ាងវិញទៀតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានសមត្ថកិច្ចក្នុងការពិនិត្យភាពសមស្របតាមគោលនយោបាយ និងបទដ្ឋានបច្ចេកទេសរៀបចំដែនដី និងនគរូបនីយកម្ម ចំពោះកិច្ចការរៀបចំ កសាងហេដ្ឋារចនាសម្ព័ន្ធនៅតំបន់ឆ្នេរ ដែលក្នុងគោលដៅថែរក្សា ការពារ និងលើកកម្ពស់សោភណភាពបរិស្ថានក្នុងតំបន់ឆ្នេរ។ មិនត្រឹមតែប៉ុណ្ណោះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក៏មានសមត្ថកិច្ចក្នុងការកំណត់សេចក្តីណែនាំសម្រាប់អនុវត្តលើការអភិវឌ្ឍ និងការសាងសង់សំណង់នានានៅតំបន់ឆ្នេរផងដែរ។

### វាក្រខណ្ឌទី២៖ គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា

#### ក. រចនាសម្ព័ន្ធរបស់គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា

គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ហៅកាត់ថា គ.អ.ឆ.ក ជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រង និងការអភិវឌ្ឍនៅតាមតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជាប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវ។

គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ៖[23]

| | | |
|---|---|---|
| - នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | | ប្រធានកិត្តិយស |
| - រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | ប្រធាន |
| - រដ្ឋមន្ត្រីក្រសួងបរិស្ថាន | | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | | អនុប្រធានអចិន្ត្រៃយ៍ |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ០១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ០១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការពារជាតិ | ០១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ០១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ០១រូប | សមាជិក |

[23] ព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៧៩ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា, ១៦ កុម្ភៈ ២០១២, មាត្រា២

| | | |
|---|---|---|
| - រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧត្តុនិយម | ០១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | ០១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងផែនការ | ០១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល | ០១រូប | សមាជិក |
| - អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | សមាជិក |
| - អគ្គស្នងការនគរបាលជាតិ | | សមាជិក |
| - មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | | សមាជិក |
| - អភិបាលនៃគណៈអភិបាលខេត្តតំបន់ឆ្នេរសមុទ្រទាំង០៤ | | សមាជិក |
| - តំណាំងគណៈកម្មាធិការជាតិលម្ហសមុទ្រ | ០១រូប | សមាជិក |
| - តំណាំងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | ០១រូប | សមាជិក |
| - តំណាងអគ្គនាយកដ្ឋានបច្ចេកទេសនៃក្រសួងបរិស្ថាន | ០១រូប | សមាជិក |
| - តំណាងអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្មនៃក្រសួង រៀបចំដែនដី នគរូបនីយកម្ម និសំណង់ | ០១រូប | សមាជិក |
| - អគ្គលេខាធិការ គ.អ.ឆ.ក | | សមាជិក។ |

**ខ. តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា**

គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាមានតួនាទី និងភារកិច្ចដូចតទៅៈ

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព កម្មវិធី និងគម្រោងផ្សេងៗ ដែលទាក់ទងនឹងការគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ
- រៀបចំបទដ្ឋានគតិយុត្ត និងគោលការណ៍ចាំបាច់នានា ដើម្បីធានានូវការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍនៅតាមតំបន់ឆ្នេរសមុទ្រ ប្រកបដោយតម្លាភាព សមធម៌ និងនិរន្តរភាពបរិស្ថាន
- ពិនិត្យ បង្ការ និងចាត់វិធានការចាំបាច់ ដើម្បីទប់ស្កាត់រាល់សកម្មភាពអសកម្មទាំងឡាយដែលអាចប៉ះពាល់ដល់បរិស្ថាន និងធនធានធម្មជាតិនៅតាមតំបន់ឆ្នេរសមុទ្រ
- ពិនិត្យ និងវាយតម្លៃរាល់គម្រោងអភិវឌ្ឍ និងការអនុវត្តគម្រោងទាំងនេះនៅតាមតំបន់ឆ្នេរសមុទ្រឲ្យស្របតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល សម្រាប់ការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ
- ចូលរួមពិនិត្យ និងផ្តល់មតិជូនស្ថាប័នមានសមត្ថកិច្ច ចំពោះសំណើសុំវិនិយោគដែលពាក់ព័ន្ធលើឆ្នេរសមុទ្រ ដីចំណីឆ្នេរសមុទ្រ តំបន់រណប កោះ ដែនទឹកសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលតភ្ជាប់ទៅនឹងសមុទ្រ និងផ្ទៃទឹកដែលជាប់នឹងឆ្នេរសមុទ្រ
- ពិនិត្យ តាមដាន និងសម្របសម្រួលរាល់សកម្មភាពដែលកំពុងអនុវត្ត គ្រោងនឹងអនុវត្ត របស់ក្រសួង ស្ថាប័ន

រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការជាតិ និងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិលនានា និងផ្នែកឯកជនដែលមាននៅតាមតំបន់ឆ្នេរសមុទ្រ ដើម្បីឲ្យការងារមានភាពរលូន ប្រកបដោយប្រសិទ្ធភាព និងធានាបាននូវនិរន្តរភាព

- បញ្ជ្រាបការយល់ដឹងដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ផ្នែកឯកជន និងគ្រប់ភាគីពាក់ព័ន្ធឲ្យយល់ដឹងអំពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ
- ធ្វើសហការជាមួយនឹងក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក និងស្ថាប័នអន្តរជាតិពាក់ព័ន្ធនានាដើម្បីជំរុញការអភិវឌ្ឍឆ្នេរសមុទ្រ
- អប់រំ បណ្តុះបណ្តាលធនធានមនុស្ស ដើម្បីឆ្លើយតបនឹងតម្រូវការក្នុងការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ
- សហការជាមួយនឹងក្រសួង ស្ថាប័ន ផ្នែកឯកជន និងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីសម្របសម្រួលការងារខាងលើឲ្យកាន់តែមានប្រសិទ្ធភាព
- រៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ គ.អ.ឆ.ក
- ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនរាជរដ្ឋាភិបាល
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។[24]

**វាក្យខណ្ឌទី៣៖ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា**

**ក. រចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា**

អគ្គលេខាធិការដ្ឋាន គ.អ.ឆ.ក ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់។ អគ្គលេខាធិការដ្ឋាន គ.អ.ឆ.ក បំពេញភារកិច្ចតាមសេចក្តីសម្រេចពីការបែងចែកភារកិច្ចរបស់អគ្គលេខាធិការ។

អគ្គលេខាធិការដ្ឋាន គ.អ.ឆ.ក មានរចនាសម្ព័ន្ធដូចតទៅ៖[25]

- ផ្នែករៀបចំដែនដី និងនគរូបនីយកម្ម
- ផ្នែកគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ
- ផ្នែកគ្រប់គ្រង និងអភិវឌ្ឍទេសចរណ៍

---

[24] ព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៧៩ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា, ១៦ កុម្ភៈ ២០១២, មាត្រា៥

[25] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា, លេខ១៧១អនក្រ/បក, ០៨ តុលា ២០១២, មាត្រា៤

- ផ្នែកអប់រំ បណ្តុះបណ្តាល ផ្សព្វផ្សាយ និងព័ត៌មានវិទ្យា
- ផ្នែកនីតិកម្ម និងដោះស្រាយវិវាទ
- ផ្នែកទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការ
- ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ។

### ខ. តួនាទី និងភារកិច្ចរបស់អគ្គលេខាធិការនៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា

អគ្គលេខាធិការដ្ឋាន គ.អ.ឆ.ក មានតួនាទីជាសេនាធិការរបស់ គ.អ.ឆ.ក និងមានភារកិច្ចដូចតទៅ៖[26]

- រៀបចំសេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ចាំបាច់នានា ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព កម្មវិធី និងគម្រោងផ្សេងៗ ដែលទាក់ទងទៅនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដើម្បីដាក់ជូន គ.អ.ឆ.ក ដើម្បីពិនិត្យ និងសម្រេច
- រៀបចំគម្រោងអប់រំ បណ្តុះបណ្តាល និងផ្សព្វផ្សាយដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ផ្នែកឯកជន និងគ្រប់ភាគីដែលពាក់ព័ន្ធ អំពីការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- ចាត់វិធានការបង្ការ និងទប់ស្កាត់រាល់សកម្មភាពអសកម្មទាំងឡាយដែលអាចប៉ះពាល់ដល់បរិស្ថាន និងធនធានធម្មជាតិនៅតំបន់ឆ្នេរសមុទ្រកម្ពុជាទៅតាមការណែនាំរបស់ គ.អ.ឆ.ក
- លើកសំណើផ្តល់ការសរសើរដល់ការអភិវឌ្ឍ និងប្រើប្រាស់តំបន់ឆ្នេរសមុទ្រកម្ពុជាប្រកបដោយនិរន្តភាព មានប្រសិទ្ធភាព ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ប្រមូលផ្តុំ និងចងក្រងឯកសារ និងព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- ពិនិត្យ និងផ្តល់យោបល់លើរាល់សំណើសុំវិនិយោគ និងអភិវឌ្ឍនៅតំបន់ឆ្នេរសមុទ្រកម្ពុជាជូន គ.អ.ឆ.ក
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោង និងសកម្មភាពអភិវឌ្ឍនានានៅតាមតំបន់ឆ្នេរសមុទ្រកម្ពុជា តាមការណែនាំរបស់ គ.អ.ឆ.ក
- តាមដាន ត្រួតពិនិត្យ និងសម្របសម្រួលរាល់សកម្មភាពដែលកំពុងអនុវត្ត គ្រោងនឹងអនុវត្តរបស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការជាតិ និងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិលនានា និងផ្នែកឯកជនដែលមាននៅតាមតំបន់ឆ្នេរសមុទ្រកម្ពុជា ដើម្បីឲ្យការងារមានភាពរលូន ប្រកបដោយប្រសិទ្ធភាព និងធានាបាននូវនិរន្តរភាព តាមការណែនាំរបស់ គ.អ.ឆ.ក

---

[26] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា, លេខ១៧១អនក្រ/បក, ០៨ តុលា ២០១២, មាត្រា២

- លើកសំណើធ្វើកិច្ចសហការជាមួយក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក និងស្ថាប័នអន្តរជាតិពាក់ព័ន្ធនានា ដើម្បីជំរុញការអភិវឌ្ឍ និងការអភិរក្សតំបន់ឆ្នេរសមុទ្រកម្ពុជាជូន គ.អ.ឆ.ក
- រៀបចំកិច្ចប្រជុំនានារបស់ គ.អ.ឆ.ក និងរៀបចំរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ អំពីវឌ្ឍនភាពនៃកិច្ចដំណើរការការងាររបស់ គ.អ.ឆ.ក និងធ្វើរបាយការណ៍ផ្សេងៗទៀតជូន គ.អ.ឆ.ក
- ផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំផែនការសកម្មភាពនិងថវិកា ដើម្បីដាក់ជូន គ.អ.ឆ.ក ពិនិត្យ និងសម្រេច ព្រមទាំងគ្រប់គ្រងថវិកា និងធ្វើរបាយការណ៍អំពីស្ថានភាពចំណូលចំណាយរបស់ គ.អ.ឆ.ក
- សិក្សា ស្រាវជ្រាវ និងធ្វើបច្ចុប្បន្នកម្មឯកសារនានាសម្រាប់ដំណើរការអភិវឌ្ឍ និងសាងសង់នៅតំបន់ឆ្នេរសមុទ្រកម្ពុជា ដែលអាចឆ្លើយតបនឹងតម្រូវការសង្គម សេដ្ឋកិច្ច និងបរិស្ថានជូន គ.អ.ឆ.ក ពិនិត្យ និងសម្រេច
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាន គ.អ.ឆ.ក ប្រគល់ជូន។

**គ. តួនាទី និងភារកិច្ចរបស់ផ្នែកនីមួយៗ**

ផ្នែករៀបចំដែនដី និងនគរូបនីយកម្ម មានតួនាទី និងភារកិច្ចដូចខាងក្រោម៖[27]

- រៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ប្លង់គោល និងផែនការប្រើប្រាស់ដី ដែលទាក់ទងនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដើម្បីដាក់ជូន គ.អ.ឆ.ក ពិនិត្យ និងសម្រេច
- ពិនិត្យ និងផ្តល់មតិជូន គ.អ.ឆ.ក លើរាល់គម្រោងអភិវឌ្ឍន៍ និងការអនុវត្តគម្រោងដែលពាក់ព័ន្ធនឹងតំបន់ឆ្នេរសមុទ្រកម្ពុជា លើទិដ្ឋភាពរៀបចំដែនដី និងនគរូបនីយកម្ម
- រៀបចំ និងចូលរួមសិក្សាស្រាវជ្រាវ និងលើកកម្ពស់វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងផ្តល់ប្រឹក្សាបច្ចេកទេស ដែលពាក់ព័ន្ធនឹងតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំ គ្រប់គ្រង និងធ្វើសមាហរណកម្មទិន្នន័យរូបវន្តដែលទទួលបានពីគ្រប់អង្គភាពពាក់ព័ន្ធ
- រៀបចំបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ និងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីឲ្យមានការឯកភាពនៅតំបន់ឆ្នេរសមុទ្រកម្ពុជា
- សិក្សាស្រាវជ្រាវគោលនយោបាយ បទដ្ឋានគតិយុត្ត យុទ្ធសាស្ត្រ និងផែនការរបស់ក្រសួង ស្ថាប័ន និងភាគីពាកព័ន្ធ ដែលទាក់ទងនិងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៅកម្ពុជា

---

[27] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា, លេខ១៧១អនក្រ/បក, ០៨ តុលា ២០១២, មាត្រា៨

- សហការជាមួយផ្នែកនីមួយៗរបស់អគ្គលេខាធិការដ្ឋាន គ.អ.ឆ.ក ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិ ចំពោះការងាររៀបចំដែនដី និងនគរូបនីយកម្មនៃតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំផែនការសកម្មភាព និងធ្វើរបាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការងាររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តំបន់ឆ្នេរសមុទ្រកម្ពុជាតាមការកំណត់
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការដ្ឋាន គ.អ.ឆ.ក ប្រគល់ជូន។

ផ្នែកគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖[28]

- រៀបចំបទដ្ឋានគតិយុត្ត និងគោលការណ៍ចាំបាច់នានា ដើម្បីធានាបាននូវការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍនៅតាមតំបន់ឆ្នេរសមុទ្រកម្ពុជា ប្រកបដោយតម្លាភាព សមធម៌ និងនិរន្តភាពបរិស្ថាន
- រៀបចំលក្ខខណ្ឌ និងចាត់ថ្នាក់ធនធានធម្មជាតិដែលត្រូវអភិរក្សនៅតំបន់ឆ្នេរសមុទ្រកម្ពុជា
- សិក្សា ស្រាវជ្រាវ ប្រមូល និងចងក្រងទិន្នន័យពាក់ព័ន្ធនឹងបរិស្ថាន សេដ្ឋកិច្ច និងសង្គម
- រៀបចំវិធានការនានាសម្រាប់បង្ការ ទប់ស្កាត់សកម្មភាពទាំងឡាយណាដែលប៉ះពាល់ដល់បរិស្ថាន និងធនធានធម្មជាតិនៅតាមតំបន់ឆ្នេរសមុទ្រកម្ពុជា
- តាមដានការអនុវត្តកម្មវិធី គម្រោងអភិវឌ្ឍន៍ និងសកម្មភាពទាំងឡាយណាដែលអាចប៉ះពាល់ដល់បរិស្ថាន និងធនធានធម្មជាតិនៅតាមតំបន់ឆ្នេរសមុទ្រកម្ពុជា
- តាមដានការអនុវត្តកម្មវិធី គម្រោងអភិវឌ្ឍន៍ និងសកម្មភាពនានានៅតំបន់ឆ្នេរសមុទ្រកម្ពុជា ដោយផ្តោតសំខាន់លើទិដ្ឋភាពនៃកិច្ចការពារបរិស្ថាន និងអភិរក្សធនធានធម្មជាតិតំបន់ឆ្នេរសមុទ្រកម្ពុជា
- ត្រួតពិនិត្យ និងវាយតម្លៃផលប៉ះពាល់បរិស្ថានពីគម្រោងវិនិយោគ និងអភិវឌ្ឍទាំងឡាយក្នុងតំបន់ឆ្នេរសមុទ្រកម្ពុជា
- សហការជាមួយផ្នែកនីមួយៗរបស់អគ្គលេខាធិការដ្ឋាន គ.អ.ឆ.ក ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិ ចំពោះកិច្ចការពារបរិស្ថាននិងធនធានធម្មជាតិ និងរៀបចំផែនកាអភិវឌ្ឍបៃតងនៃតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំបទដ្ឋានបច្ចេកទេស និងផ្តល់ប្រឹក្សាពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធានធម្មជាតិនៅតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំផែនការយុទ្ធសាស្ត្រ កម្មវិធីសកម្មភាព និងធ្វើរបាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិតំបន់ឆ្នេរសមុទ្រកម្ពុជាតាមការកំណត់

[28] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា, លេខ១៧១អនក្រ/បក, ០៨ តុលា ២០១២, មាត្រា៩

- ទទួលអនុវត្តការកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការដ្ឋាន គ.អ.ឆ.ក ប្រគល់ជូន។

ផ្នែកគ្រប់គ្រង និងអភិវឌ្ឍទេសចរណ៍ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖[29]

- ផ្សព្វផ្សាយអំពីអត្តសញ្ញាណ និងគំរូល្អនៃការអភិវឌ្ឍ និងការអភិរក្សតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំបទដ្ឋានបច្ចេកទេសទេសចរណ៍តំបន់ឆ្នេរ សម្រាប់ការអនុញ្ញាត និងការអនុវត្តសកម្មភាពទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា ដែលមានជាអាទិ៍ ឆ្នាំសមុទ្រ ទេសចរណ៍ក្នុងទឹកសមុទ្រ ខ្សែទស្សនកិច្ចតំបន់ឆ្នេរទេសចរណ៍តាមនាវា ដើម្បីធានាការគ្រប់គ្រងទេសចរណ៍តំបន់ឆ្នេរឲ្យបានល្អប្រសើរ
- ពិនិត្យ និងផ្តល់មតិទៅលើសកម្មភាពអភិវឌ្ឍទេសចរណ៍ តំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំលក្ខណវិនិច្ឆ័យសម្រាប់គ្រប់គ្រងអាជីវករ និងប្រតិបត្តិករនៅតំបន់ឆ្នេរសមុទ្រកម្ពុជា និងធ្វើការផ្តល់យោបល់លើពាក្យស្នើសុំធ្វើជាប្រតិបត្តិករទេសចរណ៍
- ពិនិត្យ និងផ្តល់យោបល់ ដើម្បីចាត់វិធានការបង្ការ និងទប់ស្កាត់រាល់សកម្មភាពទាំងឡាយដែលអាចប៉ះពាល់ដល់ការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា
- សម្រុះសម្រួល និងដោះស្រាយវិវាទពាក់ព័ន្ធនឹងការអនុវត្តសកម្មភាពទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា
- សហការជាមួយផ្នែកនីមួយៗរបស់អគ្គលេខាធិការដ្ឋាន គ.អ.ឆ.ក ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិ ចំពោះការងារគ្រប់គ្រង និងអភិវឌ្ឍទេសចរណ៍នៃតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំផែនការយុទ្ធសាស្ត្រ កម្មវិធីសកម្មភាព និងធ្វើរបាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការងារទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជាតាមការកំណត់
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ គ.អ.ឆ.ក ប្រគល់ជូន។

ផ្នែកអប់រំ បណ្តុះបណ្តាល ផ្សព្វផ្សាយ និងព័ត៌មានវិទ្យា មានតួនាទី និងភារកិច្ចដូចខាងក្រោម៖[30]

- ផ្សព្វផ្សាយដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ផ្នែកឯកជន និងគ្រប់ភាគីពាក់ព័ន្ធឲ្យយល់ដឹងអំពីការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- អប់រំ និងបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីឆ្លើយតបនឹងតម្រូវការក្នុងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំការបណ្តុះបណ្តាលបំពេញបន្ថែម សិក្ខាសាលា វគ្គបំប៉នខ្លីៗដល់មន្ត្រី បុគ្គលិក ដែលកំពុងបម្រើការងារនៅក្នុងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៅកម្ពុជា

---

29 អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា, លេខ១៧១អនក្រ/បក, ០៨ តុលា ២០១២, មាត្រា១០

30 អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា, លេខ១៧១អនក្រ/បក, ០៨ តុលា ២០១២, មាត្រា១១

- ស្រាវជ្រាវ ចងក្រង បោះពុម្ព និងផ្សព្វផ្សាយព័ត៌មាន និងទិន្នន័យដែលពាក់ព័ន្ធនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំ គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា និងធ្វើបច្ចុប្បន្នកម្មគេហទំព័ររបស់ គ.អ.ឆ.ក
- សហការជាមួយផ្នែកនីមួយៗរបស់អគ្គលេខាធិការដ្ឋាន គ.អ.ឆ.ក ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិ ចំពោះការងារអប់រំ បណ្តុះបណ្តាល ផ្សព្វផ្សាយ និងព័ត៌មានវិទ្យា
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ គ.អ.ឆ.ក ប្រគល់ជូន។

ផ្នែកនីតិកម្ម និងដោះស្រាយវិវាទ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖[31]

- សិក្សា ស្រាវជ្រាវ រៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត និងគោលការណ៍ចាំបាច់នានាពាក់ព័ន្ធនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាដាក់ជូន គ.អ.ឆ.ក ដើម្បីពិនិត្យ និងសម្រេច
- ផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត និងបទដ្ឋានបច្ចេកទេស ដែលពាក់ព័ន្ធនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំបទបញ្ជាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋាន គ.អ.ឆ.ក
- ទទួលពាក្យបណ្តឹងតវ៉ា ធ្វើការស៊ើបអង្កេត និងសម្របសម្រួល ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងបណ្តឹងតវ៉ាទាំងនោះ ស្របតាមច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីជាធរមាន
- ពិនិត្យ និងផ្តល់មតិលើកិច្ចព្រមព្រៀងអន្តរជាតិ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- សហការជាមួយផ្នែកនីមួយៗរបស់អគ្គលេខាធិការដ្ឋាន គ.អ.ឆ.ក ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិ ចំពោះការងារនីតិកម្ម និងដោះស្រាយវិវាទ
- រៀបចំផែនការសកម្មភាព និងរបាយការណ៍សម្រាប់កិច្ចការនីតិកម្ម និងដោះស្រាយវិវាទ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការដ្ឋាន គ.អ.ឆ.ក ប្រគល់ជូន។

ផ្នែកទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួល និងធ្វើទំនាក់ទំនងសហប្រតិបត្តិការជាមួយគ្រប់ភាគីពាក់ព័ន្ធ ក្នុងក្របខណ្ឌជាតិ តំបន់ និងអន្តរជាតិ នូវរាល់សកម្មភាពដែលទាក់ទងនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- សម្របសម្រួល និងធ្វើកិច្ចសហប្រតិបត្តិការជាមួយនិងក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក
- ធ្វើការផ្សព្វផ្សាយ និងរៀបចំដំណើរការប្រឡងប្រណាំងឆ្នេរសមុទ្រស្អាត

[31] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា, លេខ១៧១អនក្រ/បក, ០៨ តុលា ២០១២, មាត្រា១២

- តាមដាន និងវាយតម្លៃលើរាល់សកម្មភាពដែលមានចែងក្នុងកំណត់ហេតុ អនុស្សរណៈ ពិធីសារ និងកិច្ចព្រមព្រៀង ដែលបានចុះហត្ថលេខាជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច ដើម្បីរិះគន់រកវិធានការបង្កើនប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌនៃការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- ធ្វើទំនាក់ទំនងសហប្រតិបត្តិការជាមួយបណ្តាប្រទេសក្នុងតំបន់ និងអន្តរជាតិ ដើម្បីបញ្ជូនមន្ត្រី និងបុគ្គលិកទៅធ្វើការសិក្សា ដកបទពិសោធន៍ការងារពាក់ព័ន្ធនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- សហការជាមួយផ្នែកនីមួយៗរបស់អគ្គលេខាធិការដ្ឋាន គ.អ.ឆ.ក ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិ ចំពោះការងារទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការ
- ធ្វើកិច្ចការឆ្លើយឆ្លងព័ត៌មានជាសាធារណៈ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការដ្ឋាន គ.អ.ឆ.ក ប្រគល់ជូន។[32]

ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖[33]

- សម្របសម្រួលសកម្មភាពគ្រប់ផ្នែករបស់អគ្គលេខាធិការដ្ឋាន គ.អ.ឆ.ក ឲ្យមានភាពរលូន និងមានប្រសិទ្ធភាព
- គ្រប់គ្រងការងាររដ្ឋបាលទូទៅ និងការងារបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន គ.អ.ឆ.ក
- រៀបចំសន្និបាត កិច្ចប្រជុំ សិក្ខាសាលា និងពិធីការនានា
- សម្របសម្រួល និងរៀបចំផែនការសកម្មភាព និងថវិការបស់ គ.អ.ឆ.ក
- ធ្វើលទ្ធកម្មក្នុងការផ្គត់ផ្គង់ផ្នែកនីមួយៗរបស់អគ្គលេខាធិការដ្ឋាន គ.អ.ឆ.ក ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិចំពោះការងាររដ្ឋបាល និងហិរញ្ញវត្ថុ
- បូកសរុបរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ គ.អ.ឆ.ក
- ទទួលការអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ គ.អ.ឆ.ក ប្រគល់ជូន។

## កថាខណ្ឌទី២៖ ស្ថាប័នពាក់ព័ន្ធផ្សេងទៀត

### វាក្យខណ្ឌទី១៖ នាយកដ្ឋានអភិរក្សសមុទ្រនិងតំបន់ឆ្នេរនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន

#### ក. រចនាសម្ព័ន្ធរបស់នាយកដ្ឋានអភិរក្សសមុទ្រនិងតំបន់ឆ្នេរ

---

32 អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា, លេខ១៧១អនក្រ/បក, ០៨ តុលា ២០១២, មាត្រា១៣

33 អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា, លេខ១៧១អនក្រ/បក, ០៨ តុលា ២០១២, មាត្រា១៤

នាយកដ្ឋានអភិរក្សសមុទ្រនិងតំបន់ឆ្នេរមាន ៥(ប្រាំ) ការិយាល័យដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
- ការិយាល័យស្រាវជ្រាវធនធានសមុទ្រ និងតំបន់ឆ្នេរ
- ការិយាល័យអភិរក្សសមុទ្រ
- ការិយាល័យអភិរក្សតំបន់ឆ្នេរ
- ការិយាល័យអភិរក្សកោះ និងទីជម្រាលតំបន់ឆ្នេរ។[34]

### ខ. តួនាទី និងភារកិច្ចរបស់ការិយាល័យនីមួយៗ

ការិយាល័យរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖[35]

- រៀបចំផែនការការងាររបស់ការិយាល័យ
- សម្របសម្រួលការរៀបចំផែនការការងាររបស់នាយកដ្ឋាន និងត្រួតពិនិត្យការអនុវត្តក្នុងនាយកដ្ឋាន
- គ្រប់គ្រងលិខិតចេញ-ចូល
- គ្រប់គ្រងលិខិតរដ្ឋបាលទៅតាមមុខសញ្ញាការងារ
- តម្កល់ឯកសារ និងគ្រប់គ្រងបណ្ណាល័យ
- គ្រប់គ្រងការងារបេសកកម្មក្នុងនាយកដ្ឋាន
- គេហបាលក្នុងនាយកដ្ឋាន (គ្រប់គ្រងត្រា សន្តិសុខសណ្តាប់ធ្នាប់ កសាងបទបញ្ជាផ្ទៃក្នុង និងផ្សព្វផ្សាយសេចក្តីប្រកាស ច្បាប់ អនុក្រឹត្យ សារាចរ លិខិតបទដ្ឋានគតិយុត្ត និងព័ត៌មានផ្សេងៗ ដល់គ្រប់ការិយាល័យក្នុងនាយកដ្ឋាន)
- គ្រប់គ្រងបែបបទសុំតម្លើងកាំប្រាក់ និងបៀវត្ស ឋានន្តរសក្តិ និងសំណុំលិខិតមន្ត្រីរាជការ
- ធ្វើកំណត់បង្ហាញសំណុំឯកសារផ្សេងៗរបស់នាយកដ្ឋាន
- រៀបចំកម្មវិធីប្រជុំ ការណាត់ជួបការងាររបស់ថ្នាក់ដឹកនាំនាយកដ្ឋាន
- ចូលរួមប្រជុំ ធ្វើកំណត់ហេតុ និងចុះបេសកកម្មជាមួយថ្នាក់ដឹកនាំតាមការចាំបាច់
- ទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយ
- ស្រាវជ្រាវ តាមដាន និងចងក្រងរាល់ព្រឹត្តិការណ៍ដែលទាក់ទងការងារនាយកដ្ឋាន
- គ្រប់គ្រងការងារផ្គត់ផ្គង់សម្ភារការិយាល័យ ឧបករណ៍ បរិក្ខារ និងគ្រប់គ្រងសារពើភណ្ឌ

[34] ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានអភិរក្សសមុទ្រនិងតំបន់ឆ្នេរនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ, លេខ៨៥១/ប្រក, ០៣ ធ្នូ ២០១៥, ប្រការ២

[35] ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានអភិរក្សសមុទ្រនិងតំបន់ឆ្នេរនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ, លេខ៨៥១/ប្រក, ០៣ ធ្នូ ២០១៥, ប្រការ៣

- រៀបចំការងារមន្ត្រីរាជការ ការងារស្ថិតិ និងការងារថវិកា
- ទំនាក់ទំនងជាមួយអង្គភាពចំណុះស្ថាប័នពាក់ព័ន្ធ អង្គការជាតិ-អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា
- លើកសំណើ ចាត់ចែង ចែកចាយ និងគ្រប់គ្រងសម្ភារការិយាល័យ និងគ្រឿងបរិក្ខារ
- រៀបចំការងាររដ្ឋបាលក្នុងកិច្ចប្រជុំ សិក្ខាសាលា វេទិកា វគ្គបណ្តុះបណ្តាល យុទ្ធនាការ និងទិវានានា
- រៀបចំគ្រប់គ្រង និងត្រួតពិនិត្យចំណូល-ចំណាយនានា
- រៀបចំរបាយការណ៍របស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

ការិយាល័យស្រាវជ្រាវធនធានសមុទ្រ និងតំបន់ឆ្នេរ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖[36]

- រៀបចំផែនការការងាររបស់ការិយាល័យជូននាយកដ្ឋាន
- សហការជាមួយស្ថាប័ននានាលើការសិក្សាស្រាវជ្រាវពីបញ្ហាបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ និងសេដ្ឋកិច្ចសង្គម ដែលមាននៅក្នុងសមុទ្រ និងតំបន់ឆ្នេរ
- កំណត់តំបន់ និងប្រភេទធនធានសមុទ្រ និងតំបន់ឆ្នេរសំខាន់ៗ ដែលងាយរងគ្រោះសម្រាប់ស្តារ ការពារ និងគ្រប់គ្រង
- រៀបចំចងក្រងទិន្នន័យ និងព័ត៌មានបរិស្ថាន ស្តីពីធនធានសមុទ្រ តំបន់ឆ្នេរ កោះ និងទីជម្រាល
- ធ្វើបច្ចុប្បន្នភាពស្ថានភាពបរិស្ថាន សមុទ្រ តំបន់ឆ្នេរ កោះ និងទីជម្រាល
- សម្របសម្រួល និងចូលរួម ការងារសិក្សាស្រាវជ្រាវ អប់រំ បណ្តុះបណ្តាល ស្តីពីបញ្ហាបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ និងសេដ្ឋកិច្ចសង្គមដល់ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន គ្រឹះស្ថានសិក្សា និងដៃគូអភិវឌ្ឍន៍នានា
- សហការជាមួយនាយកដ្ឋានសេវាព័ត៌មានភូមិសាស្ត្រ នៅក្នុងការរៀបចំផែនការគ្រប់គ្រងទិន្នន័យធនធានសមុទ្រ និងតំបន់ឆ្នេរ
- ពង្រឹងការគ្រប់គ្រងមជ្ឈមណ្ឌលធនធានតំបន់ឆ្នេរសមុទ្រ ក្នុងការផ្សព្វផ្សាយឯកសារសមុទ្រ និងតំបន់ឆ្នេរ
- សហការជាមួយនាយកដ្ឋានផ្សេងៗ មជ្ឈមណ្ឌលព័ត៌មាននិងអប់រំបរិស្ថាន និងស្ថាប័ននានា ដើម្បីធ្វើការផ្សព្វផ្សាយផ្លាស់ប្តូរព័ត៌មាន និងការបង្កើនចំណេះដឹងដល់សាធារណជនអំពីតម្លៃនៃប្រព័ន្ធអេកូឡូស៊ីសមុទ្រ និងតំបន់ឆ្នេរ
- រៀបចំរបាយការណ៍របស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ

---

[36] ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានអភិរក្សសមុទ្រនិងតំបន់ឆ្នេរនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ, លេខ៨៤៥១/ប្រក, ០៣ ធ្នូ ២០១៥, ប្រការ៤

- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

ការិយាល័យអភិរក្សសមុទ្រ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖[37]

- រៀបចំផែនការការងាររបស់ការិយាល័យជូននាយកដ្ឋាន
- រៀបចំលិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធ នឹងការគ្រប់គ្រង និងការអភិរក្សសមុទ្រ
- រៀបចំយន្តការសម្រាប់អនុវត្តផែនការ រួមមាន ការគ្រប់គ្រង ការអភិរក្ស ការស្តារប្រព័ន្ធអេកូឡូស៊ីប្រកបដោយចីរភាព និងការសិក្សា ស្តីពីបរិស្ថាន ធនធានធម្មជាតិ សេដ្ឋកិច្ចសង្គម ដែលមាននៅក្នុងតំបន់សមុទ្រ
- សម្របសម្រួល ចូលរួម និងរៀបចំកម្មវិធីបណ្តុះបណ្តាល អប់រំ ផ្សព្វផ្សាយ ស្តីពីការគ្រប់គ្រង ការអភិរក្ស និងការស្តារប្រព័ន្ធអេកូឡូស៊ី ដល់មន្ត្រីជំនាញថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធ
- អនុវត្តផែនការបរិស្ថានជាតិ ផែនការគ្រប់គ្រងសមុទ្រ និងផែនការនានាដែលពាក់ព័ន្ធសម្រាប់ការគ្រប់គ្រង ការអភិរក្ស និងការស្តារប្រព័ន្ធអេកូឡូស៊ីសមុទ្រ
- ស្រាវជ្រាវសក្តានុពលធនធានសមុទ្រ ក្នុងការរៀបចំឧទ្យានសមុទ្រ
- សម្របសម្រួល និងជម្រុញ ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី សហគមន៍មូលដ្ឋាន និងដៃគូពាក់ព័ន្ធ ក្នុងការរៀបចំផែនការគ្រប់គ្រង អភិរក្ស និងស្តារប្រព័ន្ធអេកូឡូស៊ីសមុទ្រ
- អនុវត្តគម្រោងសមាហរណកម្មគ្រប់គ្រងសមុទ្រ ដោយសហការ សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ និងស្វែងរកជំនួយពីដៃគូអភិវឌ្ឍន៍នានា
- ផ្សព្វផ្សាយ និងជម្រុញឲ្យមានការអនុវត្តតាមវិធាន និងគោលការណ៍អន្តរជាតិនានាដែលពាក់ព័ន្ធនឹងការអភិរក្សជីវៈចម្រុះសមុទ្រ
- សិក្សា និងចងក្រងឯកសារបច្ចេកទេស ស្តីពីជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ីសមុទ្រ និងការគ្រប់គ្រងធនធានសមុទ្រ
- សហការ និងផ្លាស់ប្តូរព័ត៌មាន ជាមួយនឹងស្ថាប័នពាក់ព័ន្ធអំពីសារៈប្រយោជន៍ធនធានសមុទ្រ ដើម្បីតុល្យភាពការអភិរក្ស និងការអភិវឌ្ឍប្រកបដោយចីរភាព
- សហការជាមួយមន្ទីរបរិស្ថាន ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ក្នុងការទប់ស្កាត់ និងដោះស្រាយបទល្មើសបរិស្ថាន និងធនធានធម្មជាតិគ្រប់រូបភាព ដែលកើតមានក្នុងសមុទ្រ
- រៀបចំផែនការ ត្រួតពិនិត្យ តាមដានការអនុវត្តការងារយាមល្បាតសកម្មភាពផ្សេងៗក្នុងសមុទ្រ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

[37] ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានអភិរក្សសមុទ្រនិងតំបន់ឆ្នេរនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ, លេខ៤៥១/ប្រក, ០៣ ធ្នូ ២០១៥, ប្រការ៥

ការិយាល័យអភិរក្សតំបន់ឆ្នេរ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖[38]

- រៀបចំផែនការការងាររបស់ការិយាល័យជូននាយកដ្ឋាន
- រៀបចំលិខិតបទដ្ឋានគតិយុត្តទាំងឡាយណាដែលពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិរក្សតំបន់ឆ្នេរ
- រៀបចំយន្តការសម្រាប់អនុវត្តផែនការរួមមាន ការគ្រប់គ្រង ការអភិរក្ស ការស្តារប្រព័ន្ធអេកូឡូស៊ីប្រកបដោយចីរភាព និងការសិក្សាស្តីពីបរិស្ថាន ធនធានធម្មជាតិ សេដ្ឋកិច្ចសង្គម ដែលមាននៅក្នុងតំបន់ឆ្នេរ
- ទទួលសម្របសម្រួល និងរៀបចំកម្មវិធី បណ្តុះបណ្តាល អប់រំ ផ្សព្វផ្សាយ ស្តីពីការអភិរក្ស និងការស្តារប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរ ដល់មន្ត្រីជំនាញថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធ
- អនុវត្តផែនការបរិស្ថានជាតិ ផែនការគ្រប់គ្រងតំបន់ឆ្នេរ និងផែនការនានាដែលពាក់ព័ន្ធសម្រាប់ការគ្រប់គ្រង ការអភិរក្ស ការអភិវឌ្ឍ និងស្តារប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរ
- សម្របសម្រួល និងជម្រុញស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី សហគមន៍មូលដ្ឋាន និងដៃគូពាក់ព័ន្ធ ក្នុងការរៀបចំផែនការគ្រប់គ្រង អភិរក្ស និងស្តារប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរ
- អនុវត្តគម្រោងសមាហរណកម្មគ្រប់គ្រងតំបន់ឆ្នេរ ដោយសហការ សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ និងស្វែងរកជំនួយពីដៃគូអភិវឌ្ឍន៍នានា
- ផ្សព្វផ្សាយ និងជម្រុញឲ្យមានការអនុវត្តតាមគោលការណ៍អន្តរជាតិនានាដែលពាក់ព័ន្ធទៅនឹងការអភិរក្សជីវៈចម្រុះតំបន់ឆ្នេរ
- សិក្សា និងចងក្រងឯកសារបច្ចេកទេស ស្តីពីជីវៈចម្រុះដែលងាយរងគ្រោះសម្រាប់ស្តារ ការពារ និងគ្រប់គ្រង
- ផ្លាស់ប្តូរព័ត៌មានជាមួយស្ថាប័នពាក់ព័ន្ធអំពីសារៈប្រយោជន៍ធនធានតំបន់ឆ្នេរ ដើម្បីតុល្យភាពការអភិរក្ស និងការអភិវឌ្ឍប្រកបដោយចីរភាព
- សហការជាមួយនឹងស្ថាបន័ពាក់ព័ន្ធ និងអាជ្ញាធរដែនដី ក្នុងការកំណត់ព្រំប្រទល់ កំណត់តំបន់អភិវឌ្ឍន៍ តំបន់អភិរក្ស និងការងារផ្សេងៗទៀតក្នុងតំបន់ឆ្នេរ
- សហការជាមួយនាយកដ្ឋានសេវាព័ត៌មានភូមិសាស្ត្រ ក្នុងការរៀបចំផែនទីសំខាន់ៗសម្រាប់រៀបចំ និងគ្រប់គ្រងតំបន់អភិរក្ស និងតំបន់ប្រើប្រាស់ដោយចីរភាព និងស្តារប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរ
- សហការជាមួយមន្ទីរបរិស្ថាន ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធដែនដី ក្នុងការទប់ស្កាត់ និងដោះស្រាយបទល្មើសបរិស្ថាន និងធនធានធម្មជាតិគ្រប់រូបភាពដែលកើតមានក្នុងតំបន់ឆ្នេរ
- សិក្សាពីសក្តានុពលក្នុងការរៀបចំអេកូឡូស៊ីទេសចរណ៍ក្នុងតំបន់ឆ្នេរ

[38] ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានអភិរក្សសមុទ្រនិងតំបន់ឆ្នេរនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ, លេខ៥៤៩១/ប្រក, ០៣ ធ្នូ ២០១៥, ប្រការ៦

- រៀបចំផែនការ ត្រួតពិនិត្យ តាមដានការអនុវត្តសកម្មភាពផ្សេងៗក្នុងតំបន់ឆ្នេរ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

ការិយាល័យអភិរក្សកោះ និងទីជម្រាលតំបន់ឆ្នេរ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖[39]

- រៀបចំផែនការការងាររបស់ការិយាល័យជូននាយកដ្ឋាន
- រៀបចំយន្តការសម្រាប់អនុវត្តផែនការរួមមាន ការគ្រប់គ្រង ការអភិរក្ស ការស្តារប្រព័ន្ធអេកូឡូស៊ីប្រកបដោយចីរភាព និងការសិក្សាស្តីពីបរិស្ថាន ធនធានធម្មជាតិ សេដ្ឋកិច្ច សង្គម ដែលមាននៅក្នុងកោះ និងទីជម្រាលតំបន់ឆ្នេរ
- សម្របសម្រួល ចូលរួម និងរៀបចំកម្មវិធី បណ្តុះបណ្តាល អប់រំ ផ្សព្វផ្សាយ ស្តីពីការអភិរក្ស និងការស្តារប្រព័ន្ធអេកូឡូស៊ីកោះ និងទីជម្រាលតំបន់ឆ្នេរ ដល់មន្ត្រីជំនាញថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធ
- អនុវត្តផែនការបរិស្ថានជាតិ ផែនការគ្រប់គ្រងកោះ និងទីជម្រាលតំបន់ឆ្នេរ និងផែនការនានាដែលពាក់ព័ន្ធសម្រាប់ការគ្រប់គ្រង ការអភិរក្ស និងស្តារប្រព័ន្ធអេកូឡូស៊ីកោះ និងទីជម្រាលតំបន់ឆ្នេរ
- សម្របសម្រួល និងជម្រុញស្ថាប័ន អាជ្ញាធរដែនដី សហគមន៍មូលដ្ឋាន និងដៃគូពាក់ព័ន្ធក្នុងការរៀបចំផែនការគ្រប់គ្រង អភិរក្ស និងស្តារប្រព័ន្ធអេកូឡូស៊ីកោះ និងទីជម្រាលតំបន់ឆ្នេរ
- អនុវត្តគម្រោងសមាហរណកម្មគ្រប់គ្រងកោះ និងទីជម្រាលតំបន់ឆ្នេរ ដោយសហការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ និងស្វែងរកជំនួយពីដៃគូអភិវឌ្ឍន៍នានា
- ផ្សព្វផ្សាយ និងជម្រុញឲ្យមានការអនុវត្តតាមវិធាន និងគោលការណ៍អន្តរជាតិនានាដែលពាក់ព័ន្ធទៅនឹងការអភិរក្សជីវៈចម្រុះកោះ និងទីជម្រាលតំបន់ឆ្នេរ
- សហការជាមួយស្ថាប័នពាក់ព័ន្ធអំពីសារៈប្រយោជន៍ធនធាននៅលើកោះ និងទីជម្រាលតំបន់ឆ្នេរ ដើម្បីតុល្យភាពការអភិរក្ស និងការអភិវឌ្ឍប្រកបដោយចីរភាព
- សហការជាមួយនាយកដ្ឋានសេវាព័ត៌មានភូមិសាស្ត្រ ក្នុងការរៀបចំផែនទីសំខាន់ៗសម្រាប់រៀបចំ និងគ្រប់គ្រងតំបន់អភិរក្ស និងតំបន់បម្រើប្រាស់ដោយចីរភាព និងស្តារអេកូឡូស៊ីកោះ និងទីជម្រាលតំបន់ឆ្នេរ
- សហការ និងផ្លាស់ប្តូរព័ត៌មានជាមួយស្ថាប័នពាក់ព័ន្ធអំពីសារៈប្រយោជន៍ធនធានកោះ និងទីជម្រាលតំបន់ឆ្នេរ ដើម្បីតុល្យភាពការអភិរក្ស និងការអភិវឌ្ឍប្រកបដោយចីរភាព
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

---

[39] ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានអភិរក្សសមុទ្រនិងតំបន់ឆ្នេរនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ, លេខ៤៥១/ប្រក, ០៣ ធ្នូ ២០១៥, ប្រការ៧

### វាក្យខណ្ឌទី២៖ មន្ទីរទេសចរណ៍នៃខេត្តតំបន់ឆ្នេរសមុទ្រទាំង០៤

#### ក. រចនាសម្ព័ន្ធរបស់មន្ទីរទេសចរណ៍នៃខេត្តតំបន់ឆ្នេរសមុទ្រទាំង០៤

មន្ទីរទេសចរណ៍ខេត្តព្រះសីហនុមានការិយាល័យចំណុះចំនួន០៩ (ប្រាំបួន) ដូចតទៅ៖[40]

- ការិយាល័យរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងសន្តិសុខ សុវត្ថិភាពទេសចរណ៍
- ការិយាល័យផែនការ វិនិយោគ និងអភិវឌ្ឍផលិតផលទេសចរណ៍
- ការិយាល័យគ្រប់គ្រងឧស្សាហកម្មទេសចរណ៍
- ការិយាល័យអប់រំបណ្ដុះបណ្ដាល
- ការិយាល័យព័ត៌មានទេសចរណ៍ និងផ្សព្វផ្សាយទេសចរណ៍
- ការិយាល័យគ្រប់គ្រងមគ្គុទេសទេសចរណ៍
- ការិយាល័យគ្រប់គ្រងឆ្នេរ
- ការិយាល័យទេសចរណ៍កោះរ៉ុង
- ការិយាល័យទីក្រុងស្អាត។

មន្ទីរទេសចរណ៍ខេត្តកំពត ខេត្តកែប និងខេត្តកោះកុង មានការិយាល័យចំណុះចំនួន០៧ (ប្រាំពីរ) ដូចទៅ៖

- ការិយាល័យរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងសន្តិសុខ សុវត្ថិភាពទេសចរណ៍
- ការិយាល័យផែនការ វិនិយោគ និងអភិវឌ្ឍផលិតផលទេសចរណ៍
- ការិយាល័យគ្រប់គ្រងឧស្សាហកម្មទេសចរណ៍
- ការិយាល័យអប់រំបណ្ដុះបណ្ដាល
- ការិយាល័យព័ត៌មានទេសចរណ៍ និងផ្សព្វផ្សាយទេសចរណ៍
- ការិយាល័យគ្រប់គ្រងឆ្នេរ
- ការិយាល័យទីក្រុងស្អាត។

ការរៀបចំ គ្រប់គ្រង ក៏ដូចជាការអភិវឌ្ឍតំបន់ឆ្នេរ យើងឃើញថាមន្ទីរទេសចរណ៍នៃខេត្តតំបន់ឆ្នេរសមុទ្រទាំង០៤ ក៏មានសមត្ថកិច្ចពាក់ព័ន្ធផងដែរ ដែលក្នុងនោះយើងអាចមើលឃើញពីតួនាទី និងភារកិច្ចរបស់ការិយាល័យដែលពាក់ព័ន្ធរួមមាន ការិយាល័យគ្រប់គ្រងតំបន់ឆ្នេរ និងការិយាល័យទេសចរណ៍កោះរ៉ុង។[41]

#### ខ. តួនាទី និងភារកិច្ចរបស់ការិយាល័យគ្រប់គ្រងឆ្នេរ

ការិយាល័យគ្រប់គ្រងឆ្នេរ មានតួនាទី និងភារកិច្ច៖

[40] ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរទេសចរណ៍រាជធានីខេត្ត, លេខ១២៣/ប្រក, ៣០ កក្កដា ២០១៩, ប្រការ៥

[41] ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរទេសចរណ៍រាជធានីខេត្ត, លេខ១២៣/ប្រក, ៣០ កក្កដា ២០១៩, ប្រការ៨

- រៀបចំផែនការ និងសកម្មភាពក្នុងការគ្រប់គ្រងនិងអភិវឌ្ឍរមណីយដ្ឋានឆ្នេរសមុទ្រ និងកោះ ស្របតាមផែនការអភិវឌ្ឍន៍របស់ក្រសួងទេសចរណ៍ និងរដ្ឋបាលខេត្ត
- រៀបចំផែនការ និងចំណាត់ការចាំបាច់នានាក្នុងការគ្រប់គ្រង បង្ការ ការជួយសង្គ្រោះ និងការធានាសុវត្ថិភាពដល់ទេសចរណ៍តាមឆ្នេរសមុទ្រ និងកោះ
- គ្រប់គ្រងទិន្នន័យ និងស្ថិតិភ្ញៀវទេសចរមកកម្សាន្តនៅរមណីយដ្ឋានឆ្នេរសមុទ្រ និងកោះ
- ត្រួតពិនិត្យ និងជួយសង្គ្រោះភ្ញៀវទេសចរមានបញ្ហាពេលហែលទឹកកម្សាន្ត
- ពង្រឹងគុណភាពផលិតផលទេសចរណ៍ សេវាកម្មទេសចរណ៍ និងបដិសណ្ឋារកិច្ចនៅតាមរមណីយដ្ឋានឆ្នេរសមុទ្រ និងកោះ
- ផ្សព្វផ្សាយអប់រំ និងណែនាំដល់អាជីវករតាមឆ្នេរសមុទ្រ និងកោះ អំពីច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានា សំដៅដល់ការគ្រប់គ្រង និងអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព និងការចូលរួមទទួលខុសត្រូវខ្ពស់
- ចូលរួមផ្សព្វផ្សាយ អប់រំ និងណែនាំដល់អាជីវករតាមឆ្នេរសមុទ្រ និងកោះ អំពីគុណភាពចំណីអាហារ ការថែរក្សាអនាម័យ និងបរិស្ថាននៅតាមឆ្នេរសមុទ្រ និងកោះ
- សម្របសម្រួលជម្លោះផ្សេងៗរវាងប្រតិបត្តិករទេសចរណ៍ និងភ្ញៀវទេសចរ និងរាយការណ៍មកមន្ទីរទេសចរណ៍ ដើម្បីមានវិធានការបន្ត
- លើកសំណើ និងផ្តល់យោបល់ជូនថ្នាក់ដឹកនាំមន្ទីរនិងក្រសួងទេសចរណ៍ក្នុងការកែលម្អ និងអភិវឌ្ឍស្តង់ដាររមណីយដ្ឋានឆ្នេរសមុទ្រ
- សហការជាមួយអង្គភាពពាក់ព័ន្ធនឹងផ្នែកឯកជន ដើម្បីរៀបចំសកម្មភាពកម្សាន្តកីឡាទេសចរណ៍ និងព្រឹត្តិការណ៍ទេសចរណ៍នានានៅរមណីយដ្ឋានឆ្នេរសមុទ្រ។

### គ. តួនាទី និងភារកិច្ចរបស់ការិយាល័យទេសចរណ៍កោះរ៉ុង

ការិយាល័យទេសចរណ៍កោះរ៉ុង មានតួនាទី និងភារកិច្ចៈ

- រៀបចំផែនការ និងសកម្មភាពក្នុងការគ្រប់គ្រង និងអភិវឌ្ឍរមណីយដ្ឋានទេសចរណ៍តំបន់កោះរ៉ុងឲ្យស្របតាមផែនការអភិវឌ្ឍន៍របស់ក្រសួងទេសចរណ៍ និងរដ្ឋបាលខេត្តព្រះសីហនុ
- គ្រប់គ្រងទិន្នន័យ និងស្ថិតិភ្ញៀវទេសចរមកកម្សាន្តនៅតំបន់កោះរ៉ុង
- ត្រួតពិនិត្យ និងជួយសង្គ្រោះភ្ញៀវទេសចរមានបញ្ហាពេលហែលទឹកកម្សាន្ត
- រៀបចំផែនការ និងចំណាត់ការចាំបាច់នានាក្នុងការគ្រប់គ្រង បង្ការ ការជួយសង្គ្រោះ និងការធានាសុវត្ថិភាពដល់ទេសចរតាមឆ្នេរសមុទ្រនៅតំបន់កោះរ៉ុង
- ផ្សព្វផ្សាយអប់រំ និងណែនាំដល់អាជីវករនៅតំបន់កោះរ៉ុង អំពីច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោល

ការណ៍ណែនាំនានា សំដៅដល់ការគ្រប់គ្រង និងអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព និងការចូលរួមទទួលខុសត្រូវខ្ពស់

- ចូលរួមផ្សព្វផ្សាយ អប់រំ និងណែនាំដល់អាជីវករ អំពីគុណភាពចំណីអាហារ ការថែរក្សាអនាម័យ និងបរិស្ថាននៅតាមឆ្នេរសមុទ្រ និងកោះនៃតំបន់កោះរ៉ុង
- ពង្រឹងគុណភាពផលិតផលទេសចរណ៍ សេវាកម្មទេសចរណ៍ និងបដិសណ្ឋារកិច្ចនៅតាមរមណីយដ្ឋានទេសចរណ៍តំបន់កោះរ៉ុង
- សម្របសម្រួលជម្លោះផ្សេងៗរវាងប្រតិបត្តិករទេសចរណ៍ និងភ្ញៀវទេសចរ និងរាយការណ៍មកមន្ទីរទេសចរណ៍ ដើម្បីមានវិធានការបន្ត
- លើកសំណើ និងផ្តល់យោបល់ជូនថ្នាក់ដឹកនាំមន្ទីរនិងក្រសួងទេសចរណ៍ក្នុងការកែលម្អ និងអភិវឌ្ឍស្តង់ដាររមណីយដ្ឋានឆ្នេរសមុទ្រ
- សហការជាមួយអង្គភាពពាក់ព័ន្ធនឹងផ្នែកឯកជន ដើម្បីរៀបចំសកម្មភាពកម្សាន្តកីឡាទេសចរណ៍ និងព្រឹត្តិការណ៍ទេសចរណ៍នានានៅរមណីយដ្ឋានទេសចរណ៍តំបន់កោះរ៉ុង
- សហការជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីការងារថែរក្សាធនធានធម្មជាតិលើកោះ និងបាតសមុទ្រ។

ជាសរុបរួមមក ស្ថាប័នដែលមានសមត្ថកិច្ចក្នុងការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជាត្រូវបានកំណត់បែងចែកសមត្ថកិច្ចដាច់ដោយឡែកពីគ្នាដែលរួមមាន សមត្ថកិច្ចរបស់ស្ថាប័នជំនាញក្នុងនោះមាន ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា និងអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដែលមានតួនាទី និងភារកិច្ចយ៉ាងសំខាន់ក្នុងការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជា។ មួយវិញទៀតគឺសមត្ថកិច្ចរបស់ស្ថាប័នពាក់ព័ន្ធផ្សេងទៀតក្នុងនោះមាន នាយកដ្ឋានអភិរក្សសមុទ្រនិងតំបន់ឆ្នេរនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន និងមន្ទីរទេសចរណ៍នៃខេត្តតំបន់ឆ្នេរសមុទ្រទាំង០៤ (មន្ទីរទេសចរណ៍ខេត្តព្រះសីហនុ មន្ទីរទេសចរណ៍ខេត្តកំពត មន្ទីរទេសចរណ៍ខេត្តកែប និងមន្ទីរទេសចរណ៍ខេត្តកោះកុង)។

# ជំពូកទី៣
# បញ្ហាប្រឈម និងដំណោះស្រាយចំពោះការរំលោភបំពានតំបន់ឆ្នេរនៅកម្ពុជា

# ជំពូកទី៣

# បញ្ហាប្រឈម និងដំណោះស្រាយចំពោះការរំលោភបំពានតំបន់ឆ្នេរនៅកម្ពុជា

## ផ្នែកទី១៖ បញ្ហាប្រឈមនៃការអភិវឌ្ឍតំបន់ឆ្នេរ

ជុំវិញការអភិវឌ្ឍ និងការវិនិយោគតំបន់ឆ្នេរនៅកម្ពុជា ក៏បានបង្ហាញពីផលអវិជ្ជមានផងដែរ ដែលទាក់ទងនឹងផលប៉ះពាល់ដែលអាចកើតមានឡើង ពោលគឺ ផលប៉ះពាល់ដល់បរិស្ថានជុំវិញតំបន់ឆ្នេរ និងផលប៉ះពាល់ដល់ប្រយោជន៍របស់ប្រជាជនដែលរស់នៅតំបន់ឆ្នេរ។ មួយវិញទៀត ការអភិវឌ្ឍ និងការវិនិយោគតំបន់ឆ្នេរ ក៏នាំមកនូវវិវាទមួយចំនួនផងដែរ ដោយរួមមាន វិវាទរវាងរដ្ឋជាមួយនឹងវិស័យឯកជន វិវាទរវាងរដ្ឋជាមួយនឹងប្រជាជន និងវិវាទរវាងវិស័យឯកជនជាមួយនឹងប្រជាជនផងដែរ។

### កថាខណ្ឌទី១៖ ផលប៉ះពាល់ដែលអាចកើតមាន

#### វាក្យខណ្ឌទី១៖ ការសិក្សាពីបរិស្ថានជុំវិញ

បញ្ហាបរិស្ថាននៅតំបន់ឆ្នេរកើតមានឡើងជាច្រើន ពោលយើងអាចមើលឃើញជាក់ស្តែងនៅកម្ពុជា ផលប៉ះពាល់នៃបរិស្ថានតំបន់ឆ្នេររួមមាន បញ្ហាសំណល់ប្លាស្ទិកមានបរិមាណស្មើនឹង៨០% នៃកម្ទេចដែលគេរកឃើញនៅតាមឆ្នេរដែលធ្វើឲ្យខូចដល់បរិស្ថានធម្មជាតិតំបន់ឆ្នេរ ប្រព័ន្ធអេកូឡូស៊ីសមុទ្រ និងសោភណភាពតំបន់ឆ្នេរ។[42] លើសពីនេះទៅទៀត ក៏កើតមានឡើងផងដែរនូវបញ្ហាសំរាម និងបញ្ហាការបង្ហូរទឹកស្អុយចូលឆ្នេរសមុទ្រ ដែលវាជាផលប៉ះពាល់យ៉ាងគំហុកដល់បរិស្ថានតំបន់ឆ្នេរ។ ករណីជាក់ស្តែងដែលកើតឡើងនៅខេត្តព្រះសីហនុ៖[43]

ខេត្តព្រះសីហនុ លំហូរទឹកស្អុយត្រូវបានគេឃើញថាបង្ហូរចូលក្នុងសមុទ្រ ក៏ព្រោះតែចំនួនអ្នកវិនិយោគចូលមកច្រើនយ៉ាងគំហុក។ នេះជាការលើឡើងរបស់ លោក នេត្រ ភក្ត្រា រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងបរិស្ថាន នៅក្នុងកិច្ចសម្ភាសន៍ជាមួយសារព័ត៌មានក្នុងស្រុកមួយ លោកបន្តថា បញ្ហាបរិស្ថានក្នុងខេត្តព្រះសីហនុដែលរងការរិះគន់កន្លងមក គឺជាគំរូអវិជ្ជមានមួយសម្រាប់ជាមេរៀនដល់ការអភិវឌ្ឍនៅខេត្តផ្សេងៗទៀត។ តំបន់ឆ្នេរដ៏ល្បីរបស់កម្ពុជាមួយនេះ បានរងការបំផ្លាញបរិស្ថានពីការទុកដាក់សំរាមមិនបានល្អ ការរំខានដល់សមុទ្រដោយការបង្ហូរទឹកសស្អុយ កម្ទេចដីពីការដ្ឋានសំណង់ និងការលុបឆ្នេរជាដើម។ អ្នកនាំពាក្យក្រសួងបរិស្ថានអះអាងថា បញ្ហានេះកើតឡើងក៏ព្រោះតែគំហុកនៃការអភិវឌ្ឍសេដ្ឋកិច្ចនៅតំបន់នោះ ខណៈដែលរដ្ឋាភិបាលមិនទាន់រៀបចំបានរួចរាល់។

---

[42] https://www.kh.undp.org/content/cambodia/km/home/_-news-centre/articles-and-opeds0/2020/_-_-.html, (ចូលទស្សនាថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ៨:៤៥នាទីយប់)

[43] https://peoplenews.asia/64293/, (ចូលទស្សនាថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ៩:០០នាទីយប់)

### វាក្យខណ្ឌទី២៖ ការសិក្សាពីផលប្រយោជន៍ប្រជាជន

ការអភិវឌ្ឍនៅតំបន់ឆ្នេរ បានបង្កផលប៉ះពាល់ទៅដល់ការរស់នៅ និងការប្រកបរបរចិញ្ចឹមជីវិត ព្រមទាំងជីវភាពប្រចាំថ្ងៃរបស់ប្រជាជននៅតាមតំបន់ឆ្នេរ ដែលជាក់ស្តែងមានការប៉ះពាល់ដល់ប្រជាសហគមន៍នេសាទកម្ពុជាតាមរយៈរបាយការណ៍៖[44]

បើតាមរបាយការណ៍ ដែលសិក្សាលម្អិតពីសហគមន៍នេសាទក្នុងខេត្តកំពត និងខេត្តកែប ដែលបានជួបប្រទះបញ្ហា ដោយសារការអភិវឌ្ឍរបស់ក្រុមហ៊ុន ជីង គ័រ អ៊ិមផត អិចផត ខូអិលធីឌី បានបង្ហាញដែរថា សហគមន៍ព្រែកត្នោត និងសហគមន៍ត្រពាំងរពៅ មានផ្ទៃសមុទ្រសរុបប្រមាណ ២៤១៩ហិកតា ក្នុងខេត្តកំពតនោះ បានចាប់ផ្តើមរងផលប៉ះពាល់ពីការអភិវឌ្ឍរបស់ក្រុមហ៊ុនឯកជនតាំងពីឆ្នាំ២០១២មក។ ផលប៉ះពាល់ដែលរួមមាន ការបូមខ្សាច់ ការអភិវឌ្ឍកំពង់ផែសមុទ្រ និងមណ្ឌលកម្សាន្តផ្សេងៗ។ ផលប៉ះពាល់ទាំងនោះបានជះឥទ្ធិពលដល់ជីវភាពប្រជាពលរដ្ឋប្រមាណ ៨០% នៃចំនួន១៤៧០គ្រួសារ ដែលទ្រទ្រង់សេដ្ឋកិច្ចពួកគេដោយការនេសាទត្រី។ លោក វណ្ណ សុផាត អ្នកសម្របសម្រួលគម្រោងធានាសុវត្ថិភាពសិទ្ធិកាន់កាប់ និងគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិនៃ ម.ស.ម.ក បានប្រាប់ឲ្យដឹងថា ការអភិវឌ្ឍនេះនឹងធ្វើឲ្យប្រជាពលរដ្ឋទាំងនោះបាត់បង់ធនធានចំណូលជាប្រចាំថ្ងៃ ដែលប្រជានេសាទទាំងនោះអាចរកបានពី១៥ទៅ២០ដុល្លារក្នុងមួយថ្ងៃ។ ម្យ៉ាងវិញទៀតការអភិវឌ្ឍនេះនឹងបំផ្លាញដល់វិស័យបរិស្ថាន ជាពិសេសការធ្វើឲ្យបាត់បង់ព្រៃកោងកាង ជីវៈចម្រុះ និងមច្ឆាជាតិ ហើយអ្វីដែលប្រឈមខ្លាំងនោះគឺ ការរងនូវការប្រែប្រួលអាកាសធាតុក្រោយការបាត់បង់ព្រៃកោងកាងមួយចំនួន។ ក្រៅតែពីគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន ជីង គ័រ របាយការណ៍ក៏បានបង្ហាញពីគម្រោងអភិវឌ្ឍន៍ ហ្វ្រេន រីវើរ៉ា ម៉ារីណា ដែលជាគម្រោងរមណីយដ្ឋានធំមួយ គម្រោងបង្កើតទីក្រុងថ្មីលើតំបន់ភ្នំបូកគោ ការអភិវឌ្ឍឆ្នេរកែប ព្រមទាំងការសាងសង់ទីក្រុងរណបថ្មីក្នុងខេត្តកំពត ដែលកំពុងបង្កផលអវិជ្ជមានដល់តំបន់ឆ្នេរ និងសហគមន៍នេសាទផ្សេងទៀត។

ជាសរុបរួមមក រាល់ការអភិវឌ្ឍ និងការវិនិយោគនៅតំបន់ឆ្នេរ ត្រូវមានការសិក្សា និងវាយតម្លៃឲ្យបានច្បាស់ចំពោះផលប៉ះពាល់ដែលអាចកើតមានឡើង ពោលគឺការសិក្សាបរិស្ថាននៅតំបន់ឆ្នេរ និងផលប្រយោជន៍របស់ប្រជាជនដែលរស់នៅតាមតំបន់ឆ្នេរ ដើម្បីកាត់បន្ថយផលប៉ះពាល់នានា និងបញ្ហាផ្សេងៗទៀតដែលអាចកើតមានឡើង ព្រមទាំងជម្រុញឲ្យការអភិវឌ្ឍ និងការវិនិយោគប្រកបទៅដោយប្រសិទ្ធភាព និងចីរភាព។

## កថាខណ្ឌទី២៖ ប្រភេទផ្សេងៗនៃវិវាទ

### វាក្យខណ្ឌទី១៖ វិវាទរវាងរដ្ឋ និងវិស័យឯកជន

ការអភិវឌ្ឍ និងការវិនិយោគនៅតំបន់ឆ្នេរ តែងតែកើតមានឡើងនូវវិវាទ ដែលយើងអាចមើលឃើញពីវិវាទ

[44] របាយការណ៍៖ ការអភិវឌ្ឍតាមតំបន់ឆ្នេរបង្កផលប៉ះពាល់ដល់ប្រជាសហគមន៍នេសាទកម្ពុជា (rfi.fr), (ចូលទស្សនាថ្ងៃទី០៤ ខែកក្កដា ឆ្នាំ ២០២១, វេលាម៉ោង ០៩:១៥នាទីព្រឹក)

រវាងរដ្ឋជាមួយនឹងវិស័យឯកជន ជាមួយគ្នានេះដែរយោងទៅតាមស្ថានភាពជាក់ស្តែងនៃតំបន់ឆ្នេរនៅកម្ពុជា គឺកើតមានឡើងនូវបញ្ហារំលោភបំពានតំបន់ឆ្នេរ ដោយការបង្កសកម្មភាពរបស់ក្រុមហ៊ុនឯកជន ដូចនៅក្នុងករណីការធ្វើសកម្មភាពចាក់ដីចូលឆ្នេរសមុទ្រនៅឃុំរាម៖[45]

ទីតាំងភ្នំមួយកន្លែង ស្ថិតក្នុងភូមិសាស្រ្តឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ក្បែរមូលដ្ឋានកងទ័ពជើងទឹករាម កំពុងត្រូវក្រុមហ៊ុនចិនមួយជីកកកាយយ៉ាងអនាធិតេយ្យយកអាចម៍ដីទៅចាក់រំលោភចូលឆ្នេរសមុទ្ររាប់រយម៉ែត្រ។ គួរជម្រាបថា កន្លងមកលោក ជា សុផារ៉ា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ធ្លាប់បានចេញសេចក្តីប្រកាសថា អាជ្ញាធរថ្នាក់ក្រោមជាតិត្រូវតម្រូវឲ្យក្រុមហ៊ុនវិនិយោគទាំងអស់ ស្នើសុំអនុញ្ញាតរួចរាល់ជាមុនសិនទើបឲ្យបើកការដ្ឋានស្ថាបនា។ ប៉ុន្តែពេលនេះ ហេតុអីបានជាក្រុមហ៊ុនវិនិយោគចិន បែរជាពុំទាន់មានច្បាប់គ្រប់គ្រាន់ផង បែរជាអាចជីកកកាយដីភ្នំចាក់លុបសមុទ្ររាប់រយម៉ែត្រហើយ ទើបមានរដ្ឋបាលស្រុកចុះឃាត់ផ្អាកសកម្មភាព។ លោក ប្រាក់ សមប្រាថ្នា ប្រធានមន្ទីររ៉ែ និងថាមពល បានគូសបញ្ជាក់ថា ការដ្ឋានមួយនេះធ្វើសកម្មភាពក្រោមស្លាកវិនិយោគ ប៉ុន្តែមិនទាន់មានច្បាប់ត្រឹមត្រូវពីមន្ទីរនៅឡើយទេ។ តែយ៉ាងណាក៏ដោយ លោក ប្រាក់ សមប្រាថ្នា មិនបានបញ្ជាក់ប្រាប់ថា តើក្រុមហ៊ុនណា ឈ្មោះអ្វីដែលបានធ្វើសកម្មភាពរំលោភបំពានច្បាប់នោះទេ ហើយក៏ដឹងថាគេវិនិយោគលើវិស័យអ្វីនោះដែរ។ លោក សរ កក្កដា អភិបាលស្រុកព្រៃនប់ បានអះអាងថា លោកបានបញ្ជាឲ្យរដ្ឋបាលស្រុក ចុះធ្វើកំណត់ហេតុផ្អាកសកម្មភាពការដ្ឋានមួយនេះរួចហើយ នឹងបានឃាត់គ្រឿងចក្រមួយគ្រឿងយកមករក្សាទុករង់ចាំក្រុមហ៊ុនមានច្បាប់គ្រប់គ្រាន់ទើបឲ្យដំណើរការវិញបាន។

**វាក្យខណ្ឌទី២៖ វិវាទរវាងរដ្ឋ និងប្រជាជន**

ជាការពិតណាស់ ទាក់ទងនឹងការអភិវឌ្ឍនៅតំបន់ឆ្នេរ ក៏បានបង្កឡើងជាវិវាទរវាងរដ្ឋជាមួយនឹងប្រជាជនដែលរស់នៅតាមតំបន់ឆ្នេរផងដែរ៖[46]

តាមរយៈសេចក្តីជូនដំណឹង របស់រដ្ឋបាលខេត្តព្រះសីហនុ នៅថ្ងៃទី០២ ខែកុម្ភៈ នេះលោក គួច ចំរើន បានថ្លែងថា ពលរដ្ឋកំពុងរស់នៅ និងប្រកបអាជីវកម្មត្រង់ចំណុចពយយាយម៉ី និងឆ្នេរតាបារាំង ក្នុងភូមិឫទ្ធិ២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ គឺស្ថិតនៅលើដីចំណីឆ្នេរសាធារណៈរបស់រដ្ឋ ដែលធ្វើឲ្យប៉ះពាល់ដល់បរិស្ថានអនាម័យ សណ្តាប់ធ្នាប់ និងសោភណភាពឆ្នេរ។ លោក គួច ចំរើន អភិបាលខេត្តព្រះសីហនុ បញ្ជាក់ថា “រដ្ឋបាលខេត្តព្រះសីហនុ សូមជូនដំណឹងដល់លោក-លោកស្រី ត្រូវរុះរើសំណង់ និងការ្យផ្សេងៗ ដែលបានសង់នៅលើដីចំណីឆ្នេរសាធារណៈរបស់រដ្ឋ ស្ថិតនៅចំណុចពយយាយម៉ី និងឆ្នេរតាបារាំង ចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹងនេះ

[45] https://mekong-post.com/46924, (ចូលទស្សនាថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១, វេលាម៉ោង ០៩:២៥នាទីយប់)

[46] អភិបាលខេត្តព្រះសីហនុទុកពេលឲ្យអាជីវករ ២៧ថ្ងៃ រុះរើសំណង់រំលោភដីចំណីឆ្នេរ នៅពយយាយម៉ី និងឆ្នេរតាបារាំង – DAP News (dap-news.com), (ចូលទស្សនាថ្ងៃទី០៦ កក្កដា ឆ្នាំ២០២១ វេលាម៉ោង ១០:៣០នាទីយប់)

រហូតដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១ ជាកំហិត" ។ លោកសង្កត់ធ្ងន់ថា ក្នុងករណីមិនរុះរើទេ រដ្ឋបាលខេត្តព្រះសីហនុនឹងសហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលស្រុកស្ទឹងហាវ ចុះអនុវត្តវិធានការរដ្ឋបាល និងវិធានការច្បាប់ដោយមិនទទួលខុសត្រូវរាល់ការខូចខាតសម្ភារៈ ឬបាត់បង់ទ្រព្យសម្បត្តិរបស់បងប្អូនឡើយ។

### វាក្យខណ្ឌទី៣៖ វិវាទរវាងវិស័យឯកជន និងប្រជាជន

បញ្ហាវិវាទនៅតំបន់ឆ្នេរ ក៏បានបង្ហាញផងដែរទាក់ទងនឹងអាជីវកម្មនៅតំបន់ឆ្នេរ ដែលជាក់ស្តែងប្រជាជនប្រកបរបរអាជីវកម្មនៅតំបន់ឆ្នេរទទួលរងផលប៉ះពាល់ក្នុងវិវាទអាជីវកម្មជាមួយនឹងក្រុមហ៊ុនឯកជន។

ករណីជាក់ស្តែងអាជីវករនៅតំបន់ឆ្នេរ លោក ឆាយ ពិសិដ្ឋ ម្ចាស់ភោជនីយដ្ឋាន Nice Ocean ត្រូវបានគេបណ្តេញចេញពីទីតាំងរបស់លោកនៅឆ្នេរអូរឈើទាលដោយសារតែគម្រោងអភិវឌ្ឍន៍។ លោកបានថ្លែងកាលពីម្សិលមិញថាអាជីវកម្មស្ទើរតែទាំងអស់នៅក្រុងព្រះសីហនុហាក់ដូចជាត្រូវបានគ្រប់គ្រងដោយក្រុមវិនិយោគិនជនជាតិចិន ហើយប្រជាជនក្នុងស្រុក និងក្រុមហ៊ុនធម្មតាមិនអាចបន្តបានទេ។ អ្នកស្រី ប៊ី វណ្ណី អាយុ៦១ឆ្នាំ ដែលដំណើរការភោជនីយដ្ឋាន Beautiful Beach 168 បានថ្លែងថាក្រុមវិនិយោគិនជនជាតិចិនបានបណ្តេញក្រុមហ៊ុនក្នុងស្រុកចេញ ហើយអ្នកស្រីមិនជឿជាក់ថាអ្វីៗអាចត្រូវបានធ្វើដើម្បីកែលម្អស្ថានការណ៍នោះទេ។ ការប្រកួតប្រជែងជាមួយក្រុមហ៊ុនចិន អាចមានការពិបាក នេះបើតាម លោក ង៉ែត ជូ ទីប្រឹក្សាជាន់ខ្ពស់នៅក្រុមហ៊ុន Emerging Markets Consulting ដែលបានអំពាវនាវឲ្យរដ្ឋាភិបាលអនុម័តគោលនយោបាយដែលនឹងជួយឲ្យមានការប្រកួតប្រជែងដោយស្មើភាព។[47]

ជាសរុបរួមមក វិវាទនៅតំបន់ឆ្នេរបានសបញ្ជាក់ឲ្យឃើញថារាល់ការអភិវឌ្ឍ និងការវិនិយោគនៅតំបន់ឆ្នេរតែងតែមាននូវបញ្ហាផ្សេងៗកើតមានឡើង ដូច្នេះហើយរាល់ការអភិវឌ្ឍ និងការវិនិយោគទាំងឡាយត្រូវតែប្រព្រឹត្តឡើងដោយមានការគោរពតាមវិធានច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ដើម្បីចៀសវាងការកើតមានឡើងនូវវិវាទដូចបានរៀបរាប់ខាងលើ និងជាពិសេសដើម្បីបញ្ឈប់នូវសកម្មភាពរំលោភបំពានតំបន់ឆ្នេរ និងចូលរួមថែរក្សាការពារតំបន់ឆ្នេរ ម្យ៉ាងវិញទៀតចំពោះបុគ្គលដែលទទួលរងផលប៉ះពាល់ក្នុងវិវាទក៏មានកាតព្វកិច្ចផងដែរក្នុងការសហការ ដើម្បីបញ្ចប់នូវវិវាទ និងថែរក្សាសោភណភាពតំបន់ឆ្នេរ។ ប៉ុន្តែបើសិនជាករណីវិវាទ និងការរំលោភបំពានតំបន់ឆ្នេរនៅតែកើតមានឡើងបន្តទៀតនោះ គឺត្រូវមាននូវការចាត់វិធានការ និងយន្តការដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ។

## ផ្នែកទី២៖ យន្តការនៃការដោះស្រាយវិវាទ

នៅពេលដែលមានការរំលោភបំពាន និងវិវាទកើតឡើងនោះ គឺត្រូវតែមានដំណោះស្រាយចំពោះបញ្ហានេះដែលដំណោះស្រាយនេះត្រូវបានធ្វើឡើងតាមនីតិវិធីពីរយ៉ាងរួមមាន ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និង

---

[47] អាជីវកម្មចិន បង្កក្តីបារម្ភដល់អាជីវករក្នុងស្រុកនៅខេត្តព្រះសីហនុ (postkhmer.com), (ចូលទស្សនាថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ១០:៣៥នាទីយប់)

ដំណោះស្រាយតាមប្រព័ន្ធតុលាការ ប៉ុន្តែត្រង់ចំណុចនេះយើងខ្ញុំសូមផ្តោតសំខាន់តែទៅលើដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការតែប៉ុណ្ណោះ។

**កថាខណ្ឌទី១៖ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ**

ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺជាការដោះស្រាយដោយមិនឆ្លងកាត់នីតិវិធីតុលាការ ឬជាជម្រើសដ៏ល្អប្រសើររបស់គូភាគីវិវាទដែលបានឯកភាពគ្នាធ្វើការដោះស្រាយវិវាទដោយមិនចូល ឬចូលទៅតុលាការ។ នេះគឺជាការដោះស្រាយវិវាទដោយការជ្រើសរើសរបស់គូភាគីវិវាទក្នុងការដោះស្រាយវិវាទណាមួយដោយមិនមានឆ្លងកាត់តុលាការ ហើយទាមទារឲ្យគូភាគីត្រូវតែព្យាយាមដោះស្រាយដោយសន្តិវិធីដើម្បីទទួលបានជោគជ័យ។ ប្រភេទនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ត្រូវបានបែងចែកនូវការប្រើពាក្យខុសគ្នា ប៉ុន្តែសំដៅទៅលើចំណុចរួមតែមួយប៉ុណ្ណោះ ដែលរួមមាន ការចរចា សន្ធានកម្ម និងមជ្ឈត្តការ ប៉ុន្តែត្រង់ចំណុចយើងខ្ញុំសូមលើកតែការចរចា និងសន្ធានកម្មដើម្បីមកធ្វើការបកស្រាយ។ ត្រង់ចំណុចនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះផងដែរ យើងខ្ញុំនឹងសូមលើកបង្ហាញបន្ថែមទាក់ទងនឹងសមត្ថកិច្ចរបស់អាជ្ញាធរពាក់ព័ន្ធ។

**វាក្យខណ្ឌទី១៖ ការចរចា**

ការចរចា គឺជាវិធីដោះស្រាយមួយដែលភាគីទាំងឡាយ ឬតំណាងរបស់គេប្រើការអន្ទង និងការធ្វើសម្បទាន ដើម្បីដោះស្រាយវិវាទដោយផ្ទាល់រវាងពួកគេដោយគ្មានជំនួយពីភាគីទីបីឡើយ។ ការចរចា ជាដំណើរការមួយដែលភាគីពាក់ព័ន្ធក្នុងវិវាទព្យាយាមដោះស្រាយបញ្ហាដោយការពិភាក្សាផ្ទាល់រវាងពួកគេ។ នៅក្នុងដំណើរការនេះភាគីនីមួយៗព្យាយាមពន្យល់ពីអ្វីដែលពួកគេចង់បាន ឬត្រូវការឲ្យភាគីម្ខាងទៀតព្រមព្រៀងដោះស្រាយវិវាទដោយវិធីដ៏ពេញចិត្តបំផុត។ ការចរចា គឺជាវិធីដំបូង និងជាទម្រង់ដ៏ទូទៅបំផុតនៃវិធីដោះស្រាយវិវាទយ៉ាងច្រើនបំផុតត្រូវបានដោះស្រាយ។ ការចរចាមានភាពជោគជ័យយ៉ាងណានោះ គឺអាស្រ័យទៅលើជំនាញនៃការទាក់ទង គឺទាមទារឲ្យគូភាគីវិវាទ ត្រូវធ្វើការដោះស្រាយដោយសន្តិវិធី និងការយោគយល់ដោយឈរលើមូលដ្ឋាននៃការចរចាបែបឈ្នះ-ឈ្នះ ភាគីវិវាទនឹងទទួលនូវផលប្រយោជន៍ដូចគ្នាទោះបីជាផលប្រយោជន៍នោះមិនស្មើគ្នាក៏ដោយ ហើយគេអាចសម្គាល់លក្ខណៈនៃការចរចាបែបឈ្នះ-ឈ្នះបាន ដោយផ្អែកលើលក្ខខណ្ឌរកមើលដំណោះស្រាយនៃប្រយោជន៍ទៅវិញទៅមក និងការចូលរួមបែងចែកព័ត៌មាន និងការចរចាបែបឈ្នះ-ចាញ់ដែលវិធីនេះនឹងធ្វើឲ្យភាគីម្ខាងបាត់ផលប្រយោជន៍។ គេអាចសម្គាល់ការចរចាបែបឈ្នះ-ចាញ់ ដោយផ្អែកលើលក្ខខណ្ឌតម្លៃត្រូវតែនៅក្នុងកម្រិតដែលទាំងអ្នកទិញ និងអ្នកលក់រកឃើញថាអាចទទួលយកបាន ហើយភាគីមួយត្រូវតែជឿជាក់ថាភាគីម្ខាងទៀតនឹងមិនធ្វើសម្បទានបន្ថែមទៀតទេ និងភាគីមួយត្រូវមានបំណងដើរចេញដោយគ្មានការព្រមព្រៀង។

ចំពោះករណីវិវាទជាក់ស្តែងដែលបានកើតឡើងនៅតំបន់ឆ្នេរ ត្រូវបានដោះស្រាយតាមការចរចាដោយអាជ្ញាធរមានសមត្ថកិច្ចគ្រប់គ្រងតំបន់ឆ្នេរបានព្យាយាមដោះស្រាយដោយធ្វើការណែនាំទៅកាន់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានធ្វើសកម្មភាពរំលោភបំពានតំបន់ឆ្នេរ ឲ្យធ្វើការគោរព និងអនុវត្តតាមការណែនាំរបស់អាជ្ញាធរ ដោយពេញចិត្ត និង

មានការព្រមព្រៀងគ្នាដោះស្រាយដោយសន្តិវិធី ព្រមទាំងបញ្ឈប់នូវសកម្មភាពរបស់ខ្លួន មុននឹងឈានដល់ការចាត់វិធានការរដ្ឋបាល និងវិធានការច្បាប់។ ជាក់ស្តែងដូចករណីឆ្នេរព្រែកកំពត នៅខេត្តកំពត៖

ក្រុមការងាររបស់សាលាក្រុងកំពត ដឹកនាំដោយលោក បេង សំណាង ប្រធានការិយាល័យភូមិបាលក្រុង និង លោក ពៅ ធា ប្រធានការិយាល័យអភិវឌ្ឍន៍ក្រុង នៅព្រឹកថ្ងៃទី០២ ខែសីហា ឆ្នាំ ២០១៨ នេះបានចុះពិនិត្យសំណង់ខុសច្បាប់ជាច្រើនកន្លែងដែលសង់ជាលំនៅឋានខាងលើឆ្នេរ ហើយសង់ជាខ្សែសម្រាប់អង្គុយលេងរំលោភទៅក្នុងទឹកព្រែក ដោយចាក់សសរគ្រឹះបេតុងជាច្រើនកន្លែង នៅតាមបណ្តោយមាត់ព្រែកកំពត ដែលស្ថិតនៅភូមិអណ្តូងខ្មែរ សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត។ ក្រុមការងាររបស់សាលាក្រុងដែលចុះមកដល់ទីតាំងសំណង់ខុសច្បាប់ខាងលើបានឲ្យដឹងថា បើតាមតែមន្ត្រីជំនាញ និងអាជ្ញាធរក្រុងនាពេលកន្លងមកបានចុះមកណែនាំជាច្រើនលើកច្រើនសារផងដែរ។ ប៉ុន្តែពេលអាជ្ញាធរហាមឃាត់ ម្ចាស់សំណង់ផ្អាកមួយរយៈ ទើបតែក្រោយពេលបោះឆ្នោតប៉ុន្មានថ្ងៃនេះម្ចាស់សំណង់បានចាប់ផ្តើមសាងសង់បន្តទៀត។ លោក ផូ បូរ៉ា មន្ត្រីសុរិយោដី និងសំណង់ក្រុងបានឲ្យដឹងថា សំណង់ទាំងអស់នៅចំណុចនេះ គឺសុទ្ធតែគ្មានប្លង់ទាំងអស់។ ប៉ុន្តែកន្លងមកប្រជាពលរដ្ឋដែលមកចាប់ដីចំណីព្រែកដើម្បីស្នាក់នៅបណ្តោះអាសន្ននោះ ក៏បានសុំអាជ្ញាធរភូមិសង្កាត់ថាពួកគាត់មិនរំលោភយកដីចំណីព្រែកធ្វើជាកម្មសិទ្ធនោះទេ។ ប៉ុន្តែក្រោយៗមកពួកគាត់បានលក់បន្តទៅឲ្យអ្នកផ្សេង ដែលក្នុងតម្លៃថោកៗ រីឯអ្នកដែលទិញបន្ត ពីប្រជាពលរដ្ឋមិនត្រឹមតែសង់លំនៅឋានលើទួលឆ្នេរព្រែកនោះទេ ផ្ទុយទៅវិញម្ចាស់សំណង់ខុសច្បាប់ទាំងនោះ បានធ្វើនឹងការហាមឃាត់ហើយបានធ្វើសកម្មភាពសាងសង់ រំលោភលើចំណីព្រែកផង និងសង់ដោយចាក់គ្រឹះរឹងមាំចុះទៅក្នុងទឹកព្រែកផង។[48]

### វាក្យខណ្ឌទី២៖ សន្ធានកម្ម

សន្ធានកម្ម គឺជាការដោះស្រាយវិវាទមួយបែបទៀតដោយឈរលើដំណើរការនៃការចរចា។ នៅក្នុងសន្ធានកម្ម ឬយើងអាចហៅម្យ៉ាងទៀតឲ្យងាយស្រួលយល់ថាជា “ការសម្រុះសម្រួល” ភាគីអព្យាក្រឹត្យទីបីម្នាក់ ឬច្រើននាក់ ហៅថា “សន្ធានការីឬអ្នកសម្រុះសម្រួល” ជួយភាគីទាំងឡាយដើម្បីដោះស្រាយវិវាទរបស់ពួកគេផ្ទាល់សន្ធានការី មិនមានអំណាចទៅលើគូភាគីក្នុងការបង្ខិតបង្ខំឲ្យពួកគេទទួលយកនូវដំណោះស្រាយរបស់ខ្លួនឡើយ មានន័យថា អ្នកសម្រុះសម្រួលមិនអាចធ្វើសេចក្តីសម្រេចបានឡើយ។ សន្ធានការី ព្យាយាមបង្កើតនូវស្ថានភាពដែលភាគីទាំងឡាយអាចសម្រេចការដោះស្រាយដោយពួកគេផ្ទាល់។ ដំណើរការសម្រុះសម្រួល គឺស្រដៀងគ្នាណាស់ទៅនឹងការផ្សះផ្សាតាមប្រពៃណី ដែលបានអនុវត្តនៅក្នុងប្រទេសកម្ពុជា (នីតិវិធីផ្សះផ្សារបស់ចៅក្រមតុលាការ)។

ជាទូទៅសន្ធានកម្មកើតឡើងបន្ទាប់ពីភាគីទាំងឡាយព្យាយាមចរចារវាងពួកគេ ប៉ុន្តែមិនអាចសម្រេចរក

---

[48] បញ្ឈប់ការសាងសង់សំណង់ខុសច្បាប់ នៅតំបន់ឆ្នេរព្រែកកំពត – Koh Santepheap Daily, (ចូលទស្សនាថ្ងៃទី០៦ ខែកក្កដា ឆ្នាំ ២០២១ វេលាម៉ោង ១០:៥០នាទីយប់)

ដំណោះស្រាយមួយបាន។ ដូចនេះការសម្រុះសម្រួលនៅក្នុងការដោះស្រាយវិវាទ ត្រូវតែមានការចូលរួមពីភាគីទីបី ដែលជាសន្ទានការី ឬអ្នកសម្រុះសម្រួល។ គោលបំណងខ្ពស់បំផុតរបស់សន្ទានការី គឺជួយភាគីទាំងឡាយដើម្បី ដោះស្រាយវិវាទប្រកបដោយមេត្រីភាព។

ដើម្បីសម្រេចគោលបំណងនេះបាន អ្នកសម្រុះសម្រួលអាចធ្វើតាមចំណុចខ្លះៗដូចខាងក្រោមនេះ៖

- ជួយបន្ថយប្រទូសភាព និងភាពតានតឹងរវាងភាគី ដោយលើកទឹកចិត្តឲ្យមានការសហប្រតិបត្តិការ
- ជួយភាគីទាំងសងខាងឲ្យផ្តោតអារម្មណ៍ទៅលើបញ្ហាទាំងឡាយដែលចាំបាច់ត្រូវដោះស្រាយវិវាទ
- ការទាក់ទងរវាងភាគីទាំងឡាយ ប្រសិនបើភាគីទាំងនោះមិននិយាយផ្ទាល់ទៅវិញទៅមក
- ជួយភាគីម្នាក់ៗឲ្យយល់ពីប្រយោជន៍ទាំងឡាយរបស់ភាគីម្ខាងទៀត
- ជួយភាគីទាំងអស់ឲ្យរកដំណោះស្រាយមួយផ្សេងទៀត
- ផ្តល់ពីវិធីប្រាកដនិយម និងសត្យានុម័តសម្រាប់ឲ្យភាគីទាំងឡាយធ្វើការវិភាគទៅលើផលប្រយោជន៍ និងការផ្តល់ឲ្យរបស់ភាគីទាំងនោះ។

ជាក់ស្តែងយើងអាចមើលទៅលើករណីនៃការដោះស្រាយវិវាទនៅតំបន់ឆ្នេរតាមរយៈសន្ទានកម្ម នៅខេត្តព្រះសីហនុ៖[49]

បញ្ហាវិវាទអាជីវកម្មរវាងអាជីវករនៅតំបន់ឆ្នេរនៃខេត្តព្រះសីហនុ និងជនជាតិចិន ដែលបានកើតឡើងកាលពីអំឡុងឆ្នាំ២០១៨ បាននាំឲ្យអាជីវករក្នុងស្រុកមិនសប្បាយចិត្ត រហូតដល់ជំរុញឲ្យអាជ្ញាធរបង្កើតក្រុមការងាររួមមួយដើម្បីពង្រឹងការចុះបញ្ជី និងការគ្រប់គ្រងអាជីវកម្មសម្រាប់ជនជាតិចិន។ ក្រុមការងាររួមនេះត្រូវបានបង្កើតឡើងកាលពីថ្ងៃពុធនៅថ្ងៃដូចគ្នាដែលលោក យន្ត មីន អភិបាលខេត្តព្រះសីហនុ (បច្ចុប្បន្នលោកជារដ្ឋលេខាធិការក្រសួងការពារជាតិ) បានសរសេរលិខិតមួយទៅលោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃដោយបញ្ជាក់ពីបញ្ហាជាមួយការវិនិយោគរបស់ជនជាតិចិននៅក្នុងខេត្តព្រះសីហនុ។ ក្រុមការងារមួយនេះ ត្រូវបានបង្កើតឡើងបន្ទាប់ពីកិច្ចប្រជុំមួយរវាងមន្ត្រីក្រសួងពាណិជ្ជកម្មជាមួយនឹងភាគីពាក់ព័ន្ធផ្សេងទៀត ដែលមានបំណងដោះស្រាយការការពារដ៏ល្អបំផុតនៃអត្ថប្រយោជន៍អាជីវកម្មក្នុងស្រុក។ លោក តាំង សុជាតិគ្រីស្នា ប្រធានមន្ទីរទេសចរណ៍ខេត្ត និងជាអ្នកចូលរួមក្នុងកិច្ចប្រជុំនេះបានថ្លែងកាលពីម្សិលមិញថាគោលបំណងនៃក្រុមការងារពិសេសនេះនឹងត្រូវអនុវត្តច្បាប់ និងបទប្បញ្ញត្តិដែលមានស្រាប់។ លោកបានថ្លែងដោយលើកឡើងជាពិសេសដល់ភាគីពាក់ព័ន្ធកាស៊ីណូ ការចុះបញ្ជីអាជីវកម្ម និងការរំលោភបំពានដែលអាចកើតឡើងលើសន្ធិសញ្ញាអង្គការពាណិជ្ជកម្មពិភពលោកថា៖ “ក្រុមការងារនេះ

[49] អាជីវកម្មចិន បង្កក្តីបារម្ភដល់អាជីវករក្នុងស្រុកនៅខេត្តព្រះសីហនុ | ភ្នំពេញ ប៉ុស្តិ៍ , (ចូលទស្សនាថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ០៩:០៥នាទីយប់)

នឹងជួយអាជីវកម្មក្នុងស្រុក និងជួយកាត់បន្ថយបញ្ហាប្រឈមរបស់ពួកគេដោយសារយើងនឹងត្រួតពិនិត្យលើការគ្រប់គ្រង និងប្រតិបត្តិការអាជីវកម្មជនជាតិចិន" ។

### វាក្យខណ្ឌទី៣៖ សមត្ថកិច្ចរបស់អាជ្ញាធរពាក់ព័ន្ធ

ការដោះស្រាយចំពោះករណីរំលោភបំពានលើតំបន់ឆ្នេរ អាជ្ញាធរដែលមានសមត្ថកិច្ចគ្រប់គ្រងតំបន់ឆ្នេរត្រូវបំពេញសមត្ថកិច្ចដូចខាងក្រោម៖

- ធ្វើការត្រួតពិនិត្យ និងចាត់វិធានការទៅលើរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ ដែលធ្វើការរំលោភបំពានតំបន់ឆ្នេរ
- ពិនិត្យអំពីទិដ្ឋភាពច្បាប់ និងកំណត់ឲ្យរូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើការរំលោភបំពានតំបន់ឆ្នេរបញ្ឈប់នូវសកម្មភាពជាបន្ទាន់
- ធ្វើចំណាត់ការតឹងរឹងក្នុងការថែរក្សាតំបន់ឆ្នេរ ដោយមិនបណ្តោយឲ្យមាននូវការសាងសង់រំលោភ និងទន្រ្ទានផ្សេងៗនៅតំបន់ឆ្នេរ
- អនុវត្តវិធានការរដ្ឋបាល ក្នុងករណីមានការមិនព្រមអនុវត្តតាមគោលការណ៍របស់រដ្ឋបាលខេត្តចំពោះការចូលរួមសហការថែរក្សាតំបន់ឆ្នេរ
- ដាក់ចេញនូវសេចក្តីជូនដំណឹងជាដាច់ខាតដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានធ្វើសកម្មភាពរំលោភបំពានឲ្យចូលមកទទួលខុសត្រូវ
- ធ្វើការរុះរើនូវសំណង់ខុសច្បាប់នៅតំបន់ឆ្នេរ ដោយមានសេចក្តីសម្រេចពីស្ថាប័នមានសមត្ថកិច្ច។

ករណីដែលបានកើតឡើងនៅខេត្តព្រះសីហនុ និងខេត្តកោះកុង៖[50]

រដ្ឋបាលខេត្តព្រះសីហនុ និងរដ្ឋបាលខេត្តកោះកុង ប្រកាសចាត់វិធានការក្តៅ ក្រោយមានករណីលុបសមុទ្រ និងដីព្រៃក ដើម្បីយកដីមកប្រើប្រាស់ផ្ទាល់ខ្លួនដោយគ្មានការអនុញ្ញាតកាលពីពេលថ្មីៗនេះ។ រដ្ឋបាលខេត្តព្រះសីហនុ កាលពីថ្ងៃទី១៥ មីនា កន្លងទៅ បានចេញលិខិតស្តីអំពីការចាក់ដីចូលឆ្នេរសមុទ្រ នៅចំណុចទីតាំងមុខក្រុមហ៊ុនកម្ពុជាតេលា ស្ថិតនៅភូមិ៤ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ដោយគ្មានការអនុញ្ញាត។ លិខិតដដែលនេះ ក៏បានស្នើឲ្យបុគ្គល ដែលជាអ្នកចាក់ដីចូលសមុទ្រនៅទីតាំងខាងលើ កាយចេញវិញជាបន្ទាន់ និងចេញមុខមកដោះស្រាយជាមួយរដ្ឋបាលស្រុក ពុំនោះទេរដ្ឋបាលស្រុកនឹងចាត់វិធានការកាយដីនេះចេញ និងបន្តស្វែងរកអ្នកដែលបានចាក់ដីចូលឆ្នេរសមុទ្រនេះ មកទទួលទោសតាមផ្លូវច្បាប់។

ដោយឡែក នៅថ្ងៃដដែលនេះ អភិបាលស្រុកមណ្ឌលសីមា លោក ប្រាក់ វិចិត្រ ក៏បានដឹកនាំក្រុមការងារ និង

---

[50] រដ្ឋប្រកាសចាត់វិធានការធ្ងន់លើអ្នកលុបសមុទ្រយកដី នៅខេត្តចំនួន ២ នៅកម្ពុជា - Construction & Property News (construction-property.com), (ចូលទស្សនាថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ០៩:៣០នាទីយប់)

មន្ត្រីពាក់ព័ន្ធ ដើម្បីចុះពិនិត្យការចាក់អាចម៍ដីចូលចំណីព្រៃកសាធារណៈ ដែលស្ថិតនៅភូមិទួលគគីរក្រោម ស្រុកមណ្ឌលសីមាផងដែរ។ លោក សុខ សុធី អភិបាលរងខេត្តកោះកុង បានប្រាប់កាសែតភ្នំពេញប៉ុស្តិ៍ថា លោកកំពុងចាត់ឱ្យមន្ត្រីពាក់ព័ន្ធស្វែងរកបុគ្គលដែលបានលុបដីព្រៃក និងកំពុងវាស់វែងទំហំនៃការលុបយកចំណីព្រៃក ដើម្បីធ្វើរបាយការណ៍ ឬអនុវត្តទៅតាមបទប្បញ្ញត្តិជាធរមានផងដែរ។

ខេត្តព្រះសីហនុ នៅរសៀលថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩ ក្រុមការងារនៃគណៈកម្មការឆ្នេររបស់សាលាខេត្តព្រះសីហនុ បានចុះរុះរើសំណង់ដែលធ្វើទីគ្រោងដែកនៅលើទីតាំងដីតំបន់ឆ្នេរអូរត្រេះ១ ក្រុងព្រះសីហនុ បានចំនួន ០២កន្លែងផ្សេងពីគ្នា ដែលគេបានលបលួចសាងសង់ដោយគ្មានការអនុញ្ញាត ហើយដែលធ្វើឲ្យប៉ះពាល់ដល់បរិស្ថាន និងសណ្តាប់ធ្នាប់នៃតំបន់ឆ្នេរ។ សំណង់នេះបើតាមមន្ត្រីជំនាញបញ្ជាក់ថា កន្លងមកធ្លាប់បានចុះធ្វើការហាមឃាត់មិនឲ្យធ្វើការសាងសង់ទេ និងបានទុករយៈពេលឲ្យរុះរើចេញវិញដោយខ្លួនឯងក៏ប៉ុន្តែម្ចាស់សំណង់នៅតែលួចបន្តធ្វើការសាងសង់មិនស្តាប់តាមការណែនាំឡើយ ទើបនៅរសៀលថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩ នេះក្រុមការងារចម្រុះសម្រេចដឹកនាំកម្លាំងចុះយកគ្រឿងចក្ររុះរើចេញចេញតែម្តង។ បើតាមលោក តាំង សុចិត្តគ្រឹស្នា ប្រធានមន្ទីរទេសចរណ៍ខេត្តព្រះសីហនុ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មការគ្រប់គ្រងនិងអភិវឌ្ឍឆ្នេរសមុទ្រខេត្តព្រះសីហនុ បានបញ្ជាក់ថាសំណង់រឹងមាំមិនត្រូវបានអនុញ្ញាតឲ្យសាងសង់លើតំបន់ឆ្នេរនេះបានទេ។ ចំណែកសំណង់ដែលបានសង់ចាស់យូរហើយនោះ ត្រូវរក្សាស្ថានភាពដើមសិនរងចាំចំណាត់ការជាក្រោយស្រមតាមគោលការណ៍របស់គណៈកម្មាធិការគ្រប់គ្រងនិងអភិវឌ្ឍឆ្នេរកម្ពុជា គ.អ.ឆ.ក (ថ្នាក់ជាតិ)។ លោក តាំង សុចិត្តគ្រឹស្នា បន្ថែមថា ឆ្នេរអូរត្រេះនេះគ្រោងនឹងរៀបចំជាឆ្នេរគំរូ មួយវិញទៀតឆ្នេរនេះគ្រោងនឹងយកជាកន្លែងធ្វើពិធីបុណ្យសមុទ្រនៅឆ្នាំក្រោយផង។ ដូច្នេះខេត្តត្រូវត្រៀមរៀបចំសណ្តាប់ធ្នាប់ បរិស្ថាន សោភណភាពឆ្នេរឲ្យបានល្អប្រសើរ មិនអាចឲ្យសាងសង់សំណង់មិនរៀបរយផ្តេសផ្តាសថ្មីទៀតបានទេ។ តែលោកថា អាចឲ្យសង់ជាប្រភេទតូបស្បូវ ឬខ្ទមសម្រាប់ធ្វើប្រតិបត្តិការទេសចរណ៍បានស្របតាមការណែនាំពីមន្ត្រីជំនាញ។ លោកក៏បានស្នើប្រតិបត្តិករទេសចរណ៍ទាំងអស់ត្រូវចូលរួមសហការជាមួយរដ្ឋបាលខេត្ត ដើម្បីរៀបចំឆ្នេរនេះឲ្យកាន់តែមានការទាក់ទាញភ្ញៀវមកកំសាន្តកាន់តែច្រើនថែមទៀតនៅថ្ងៃអនាគត។ ទន្ទឹមនេះដែរ លោក អៀម សារិន អភិបាលរងក្រុងព្រះសីហនុ ក៏បានបញ្ជាក់ក្នុងនាមរដ្ឋបាលក្រុង សូមស្នើម្ចាស់តូបទាំងអស់នៅតាមឆ្នេរនេះត្រូវរួមសហការជាមួយអាជ្ញាធរកុំនាំគ្នាលួចសង់សំណង់រឹងមាំខុសច្បាប់លើឆ្នេរទៀត ព្រោះទីនេះរដ្ឋកំពុងរៀបចំឲ្យបានស្អាត ដើម្បីទាក់ទាញភ្ញៀវមកលេងកំសាន្តមិនអាចបណ្តែតបណ្តោយឲ្យមានការសាងសង់សំណង់គ្រឹះលើឆ្នេរបានទេ (សារ៉ុន)។[51]

### កថាខណ្ឌទី២៖ ដំណោះស្រាយវិវាទតាមប្រព័ន្ធតុលាការ

ការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ ត្រូវបានដោះស្រាយទៅតាមប្រភេទនៃរឿងក្តីវិវាទ ដែលជាក់ស្តែង

[51] https://www.khemaradaily.com/p/148085, (ចូលទស្សនាថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ១០:៣៥នាទីយប់)

ការដោះស្រាយនេះត្រូវបានស្តែងឡើងតាមប្រភេទនៃបណ្តឹង គឺបណ្តឹងរដ្ឋប្បវេណី និងបណ្តឹងព្រហ្មទណ្ឌ។

**វាក្យខណ្ឌទី១៖ បណ្តឹងរដ្ឋប្បវេណី**

បណ្តឹងរដ្ឋប្បវេណី គឺជាបណ្តឹងមួយដែលមានគោលបំណងជួសជុលព្យសនកម្មដល់ជនរងគ្រោះ ដែលបណ្តាលមកពីបទល្មើសដែលបំពានលើ ឬកើតចេញពីការមិនគោរពកាតព្វកិច្ច ឬការទាមទារសិទ្ធិអ្វីមួយ។ បណ្តឹងរដ្ឋប្បវេណី មានគោលបំណងធ្វើឲ្យបាននូវការជួសជុលការខូចខាតដែលបណ្តាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះឲ្យអ្នករងគ្រោះបានទទួលសំណងជម្ងឺចិត្តជួនល្មមនឹងព្យសនកម្មដែលខ្លួនបានទទួល ហើយព្យសនកម្មអាចជាព្យសនកម្មខាងសម្ភារ ខាងរូបកាយ ឬខាងផ្លូវចិត្ត។

នីតិវិធីនៃការដំណើរការរឿងក្តីរដ្ឋប្បវេណីមានដំណាក់កាលដូចតទៅ៖

- **ការដាក់ពាក្យបណ្តឹង** បណ្តឹងរដ្ឋប្បវេណីត្រូវរៀបចំដាក់ពាក្យបណ្តឹងនៅការិយាល័យរដ្ឋបាលនៃសាលាដំបូងរាជធានី-ខេត្ត ហើយចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង គឺចំពោះការប្តឹងត្រូវធ្វើដោយដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ ហើយនៅក្នុងលិខិតនៃពាក្យបណ្តឹងនោះត្រូវសរសេរបញ្ជាក់ពីឈ្មោះ ឬនាមករណ៍ និងអាស័យដ្ឋានរបស់ភាគី ព្រមទាំងឈ្មោះ និងអាស័យដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។ ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ និងអង្គហេតុចាំបាច់ ដើម្បីបញ្ជាក់នូវការទាមទារក្នុងពាក្យបណ្តឹងនោះ។ ក្រៅពីចំណុចទាំងអស់នេះ ដើមចោទគប្បីសរសេរបញ្ជាក់ឲ្យច្បាស់លាស់នូវអង្គហេតុ ដែលជាមូលហេតុនៃការទាមទារ និងចំណុចដែលត្រូវការបញ្ជាក់ភស្តុតាង គប្បីសរសេរបញ្ជាក់នូវអង្គហេតុសំខាន់ៗក្នុងចំណោមអង្គហេតុទាំងមូលនៃការទាមទារ និងភស្តុតាង។ ពាក្យបណ្តឹងដែលមានសរសេរអំពីមធ្យោបាយតទល់ ឬ ការការពារខ្លួន ត្រូវចាត់ជាឯកសារត្រៀមផងដែរ។
- **ការសាកល្បងផ្សះផ្សា** ក្នុងដំណាក់កាលនេះតុលាការសាកល្បងធ្វើការផ្សះផ្សារវាងគូភាគីក្នុងការបញ្ចប់បណ្តឹង ដែលភាគីទាំងពីរទទួលស្គាល់ការទាមទារ ឬលះបង់នូវការទាមទាររបស់ខ្លួននៅចំពោះមុខតុលាការ។ នៅក្នុងករណីដែលភាគីទាំងពីរបានយល់ព្រមក្នុងការផ្សះផ្សា តុលាការនឹងធ្វើកំណត់ហេតុសះជា ដែលមានអានុភាពដូចសាលក្រមស្ថាពរ។
- **ការស៊ើបសួរ** ក្នុងករណីដែលតុលាការមិនអាចផ្សះផ្សាបានទេ តុលាការនឹងធ្វើការកោះហៅគូភាគីដើម្បីធ្វើការសាកសួរ ក្នុងគោលដៅរៀបចំនូវការអះអាងរបស់ភាគី រៀបចំនូវចំណុចវិវាទ និងរៀបចំនូវភស្តុតាងដែលពាក់ព័ន្ធនឹងចំណុចវិវាទ ដើម្បីធ្វើការពិនិត្យភស្តុតាងជាសមូហវិធីដូចជា ការសាកសួរសាក្សី និងការសាកសួរសាមីភាគីជាដើម។
- **ការបញ្ចប់បណ្តឹង** បន្ទាប់ពីបញ្ចប់នីតិវិធីរួចរាល់ហើយ តុលាការនឹងធ្វើការជំនុះជម្រះសម្រេចបញ្ចប់រឿងក្តី ដោយមានចៅក្រមជាអ្នកវិនិច្ឆ័យលើរឿងក្តី និងចេញនូវសាលក្រម ដែលជាសេចក្តីសម្រេចចុងក្រោយបង្អស់របស់តុលាការ។

ដូចនេះនៅក្នុងករណីដែលនៅតំបន់ឆ្នេរ កើតមានឡើងនូវវិវាទដែលធ្វើឲ្យប៉ះពាល់ដល់ភាគីរងគ្រោះ និងកើតមានឡើងនូវព្យសនកម្មសម្ភារៈ ព្យសនកម្មផ្លូវកាយ ឬព្យសនកម្មផ្លូវចិត្តដល់ភាគីរងគ្រោះ ដោយសារគម្រោងវិនិយោគ ឬការអភិវឌ្ឍនោះ ភាគីរងគ្រោះអាចធ្វើការដាក់ពាក្យបណ្តឹងដើម្បីទាមទារនូវដំណោះស្រាយតាមរយៈនីតិវិធីដូចបានរៀបរាប់ខាងលើ និងដើម្បីទទួលបានការសងជម្ងឺចិត្តសមល្មមនឹងព្យសនកម្មដែលសាមីខ្លួនទទួលរង។

**វាក្យខណ្ឌទី២៖ បណ្តឹងព្រហ្មទណ្ឌ**

បណ្តឹងព្រហ្មទណ្ឌ គឺជាបណ្តឹងមួយប្រភេទដែលមានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឲ្យឃើញអំពីការមានពិរុទ្ធភាព ឬគ្មានពិរុទ្ធភាពនៃជនណាម្នាក់ ឬច្រើននាក់។ បណ្តឹងព្រហ្មទណ្ឌ ឬអាចហៅម្យ៉ាងទៀតថាជាបណ្តឹងអាជ្ញា ដែលអនុវត្តទៅលើបុគ្គលគ្រប់រូបដោយឥតប្រកាន់ពូជសាសន៍ សញ្ជាតិ សាសនា ភេទ ឬឋានៈក្នុងសង្គមឡើយ។

ដំណើរការរឿងក្តីព្រហ្មទណ្ឌមានបួនដំណាក់កាល៖

- **ដំណាក់កាលស៊ើបអង្កេត** មន្ត្រីនគរបាលយុត្តិធម៌ជាសេនាធិការ និងស្ថិតក្រោមការសម្របសម្រួលរបស់ព្រះរាជអាជ្ញា ដោយមន្ត្រីនគរបាលយុត្តិធម៌មានតួនាទីក្នុងការធ្វើការស៊ើបអង្កេតជាក់ស្តែង និងបឋម ក្នុងគោលដៅពិនិត្យស្វែងរកបទល្មើស និងស្វែងរកភស្តុតាង រួចធ្វើកំណត់ហេតុ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាធ្វើចំណាត់ការបន្ត។
- **ដំណាក់កាលចោទប្រកាន់** ក្រោយពេលទទួលបានសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌ ឬទទួលបានបណ្តឹង (បណ្តឹងទាមទារ ឬបណ្តឹងបរិហារដែលខ្លួនបានទទួលដោយផ្ទាល់) ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការ។ មុននឹងសម្រេចធ្វើការចោទប្រកាន់ ឬមិនចោទប្រកាន់ (តម្កល់រឿងទុកឥតចាត់ការ) ព្រះរាជអាជ្ញាបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឲ្យស្រាវជ្រាវបន្ថែម។ ក្នុងការសម្រេចការចោទប្រកាន់ ព្រះរាជអាជ្ញាអាចធ្វើឡើងតាមមធ្យោបាយបីយ៉ាងគឺ ការបើកធ្វើការស៊ើបសួរ (RI) ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ (CD) និងតាមនីតិវិធីបង្ហាញខ្លួនភ្លាម (CI) ។
- **ដំណាក់កាលចៅក្រមស៊ើបសួរ** ចៅក្រមស៊ើបសួរបន្តចំណាត់ការដោយទទួលបន្ទុកស៊ើបសួរ ដើម្បីស្វែងរកប្រមូលភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ក្នុងគោលដៅធានានូវសមភាពរវាងគូភាគី និងស្វែងរកឲ្យឃើញនូវការពិតមុននឹងសម្រេចឃុំខ្លួន ឬមិនឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ។
- **ដំណាក់កាលជំនុំជម្រះ** ជាដំណាក់កាលចុងក្រោយក្នុងការជម្រះក្តីដោយសម្រេចសេចក្តីថាជននោះមានទោស ឬមិនមានទោសដែលជាសមត្ថកិច្ចរបស់ចៅក្រមជំនុំជម្រះ ហើយនៅក្នុងសវនាការមានសមាសភាពចូលរួមដោយចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី មេធាវី ជនត្រូវចោទ ដើមចោទ និងសាក្សី។

ចំពោះករណីដែលមានការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬធ្វើឲ្យខូចខាតទ្រព្យសម្បត្តិសាធារណៈ ឬក៏ប៉ះពាល់កម្មសិទ្ធិនៃទ្រព្យសម្បត្តិសាធារណៈ ក៏ត្រូវបានចាត់ចូលក្នុងរឿងក្តីព្រហ្មទណ្ឌផងដែរ ជាក់ស្តែងតំបន់ឆ្នេរនៃ

ព្រះរាជាណាចក្រកម្ពុជា គឺជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដូច្នេះនៅក្នុងករណីដែលមានការរំលោភបំពាន និងធ្វើឲ្យខូចខាតតំបន់ឆ្នេរនោះនឹងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ដោយយោងតាមច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា ២៥៩ ចែងថា ការប៉ះពាល់កម្មសិទ្ធិនៃទ្រព្យសម្បត្តិសាធារណៈ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ៥.០០០.០០០ (ប្រាំលាន) រៀល ដល់ ៥០.០០០.០០០ (ហាសិបលាន) រៀល ឬ/និងផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ។

ជាសរុបរួមកយើងឃើញថាការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងការដោះស្រាយតាមរយៈប្រព័ន្ធតុលាការចំពោះករណីរំលោភបំពាននៅតំបន់ឆ្នេរ ត្រូវបានកំណត់ និងបែងចែកទៅតាមនីតិវិធី ដែលរួមមានការដោះស្រាយដោយសន្តិវិធីដោយមានការចរចា និងការសម្រុះសម្រួល ព្រមទាំងការដាក់ចេញនូវវិធានការតឹងរឹងរបស់អាជ្ញាធរមានសមត្ថកិច្ច ការសងសំណងជម្ងឺចិត្ត និងការផ្តន្ទាទោសទៅតាមច្បាប់ដែលបានចែងជាធរមាន ដើម្បីចាត់ការលើសកម្មភាពរំលោភបំពានទាំងឡាយនៅតំបន់ឆ្នេរ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ដោយយោងតាមការបកស្រាយខាងលើរួចមក យើងសង្កេតឃើញថាការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជា ទាមទារឲ្យមាននូវការកំណត់លក្ខណៈនៃតំបន់ឆ្នេរឲ្យបានត្រឹមត្រូវ និងច្បាស់លាស់ ដែលតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានកំណត់លក្ខណៈជា ដែនគោក កោះ និងដែនទឹក ដែលយើងអាចសម្គាល់ទីតាំងភូមិសាស្ត្រនៃតំបន់ឆ្នេរបាន ដោយមានកាបញ្ជាក់យ៉ាងច្បាស់នូវទំហំ និងប្រវែងកំណត់របស់តំបន់ឆ្នេរ។ ការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជា ត្រូវបានធ្វើឡើងដោយមាននូវការរៀបចំសោភណភាពនៃតំបន់ឆ្នេរ ការពិនិត្យតាមដានទៅលើផ្នែកអនាម័យ និងការថែរក្សាបរិស្ថានតំបន់ឆ្នេរ រួមទាំងគ្រប់គ្រងនូវសណ្តាប់ធ្នាប់ដោយមិនឲ្យមាននូវការធ្វើអាជីវកម្ម ឬសាងសង់សំណង់រឹងមាំផ្សេងៗដោយគ្មានការអនុញ្ញាតពីអាជ្ញាធរសមត្ថកិច្ចឡើយ ហើយដើម្បីឲ្យការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរប្រកបទៅដោយប្រសិទ្ធភាពនោះ ត្រូវអនុវត្តទៅតាមផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍប៉ៃតងផងដែរ។ ចំពោះការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរ ក៏បានបង្ហាញពីការកំណត់នូវការប្រើប្រាស់តំបន់ឆ្នេរ ដែលលើកឡើងពីការកំណត់នូវការប្រើប្រាស់ដែលមានលក្ខណៈពិសេសដាច់ដោយឡែកពីគ្នាទៅតាមទីតាំងនីមួយៗ ដោយនៅក្នុងការកំណត់នូវការប្រើប្រាស់តំបន់ឆ្នេរនេះ បានបង្កប់នូវលក្ខខណ្ឌ និងចំណុចសំខាន់ៗ និងចាំបាច់ជាច្រើនសម្រាប់ការប្រើប្រាស់តំបន់ឆ្នេរឲ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព។ ម្យ៉ាងវិញទៀត អាជ្ញាធររៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរ មានតួនាទី និងភារកិច្ចយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យតាមដានលើសកម្មភាពនានានៅតំបន់ឆ្នេរ និងរក្សាសណ្តាប់ធ្នាប់ បរិស្ថាន សោភណភាពតំបន់ឆ្នេរ និងធានាសុវត្ថិភាពដល់អ្នកទេសចរ ក៏ដូចជាសាធារណជន ព្រមទាំងការពារមិនឲ្យមានសកម្មភាពខុសច្បាប់ និងការរំលោភបំពាននៅតំបន់ឆ្នេរឡើយ។ ទាក់ទិននឹងការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនេះទៀតសោត បានរំលេចឡើងនូវសកម្មភាពនៃការអភិវឌ្ឍ និងការវិនិយោគដែលជាផ្នែកមួយដ៏សំខាន់សម្រាប់វិស័យសេដ្ឋកិច្ចរបស់កម្ពុជា ជាការពិតណាស់សម្រាប់ការអភិវឌ្ឍតំបន់ឆ្នេរ ចាំបាច់ត្រូវអនុវត្តទៅតាមផែនការសម្រាប់ការអភិវឌ្ឍ ដែលតម្រូវឲ្យមាននូវការផ្តួចផ្តើមគម្រោងរៀបចំកសាងសំណង់នានា រួមទាំងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗដែលត្រូវដាក់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យភាពសមស្របតាមគោលនយោបាយ និងបទដ្ឋានបច្ចេកទេសរៀបចំដែនដី និងនគរូបនីយកម្ម ក្នុងគោលដៅថែរក្សាការពារ និងលើកកម្ពស់សោភណភាពបរិស្ថានតំបន់ឆ្នេរ។ រីឯការវិនិយោគតំបន់ឆ្នេរវិញ ក៏ជាចំណុចមួយដ៏សំខាន់ផងដែរ ដែលបានបង្ហាញឲ្យឃើញពីកិច្ចសហប្រតិបត្តិការវិនិយោគជាតិ និងអន្តរជាតិ បាននាំមកនូវការរីកចម្រើនវិស័យសេដ្ឋកិច្ច រួមទាំងវិស័យទេសចរណ៍របស់កម្ពុជា ដែលជាការរួមចំណែកដល់ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន និងការកាត់បន្ថយនូវភាពក្រីក្រតាមរយៈការបង្កើនប្រាក់ចំណូលជាដើម។ ហើយការវិនិយោគនេះ ក៏មានការកំណត់នូវក្របខណ្ឌគតិយុត្តសម្រាប់ការវិនិយោគផងដែរ ដែលតម្រូវឲ្យមានអាជ្ញាបណ្ណវិនិយោគ ដើម្បីទទួលបានសិទ្ធិស្របច្បាប់សម្រាប់ការវិនិយោគ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងបង្កើតការវិនិយោគនៅតំបន់ឆ្នេរ ត្រូវគោរពតាមលក្ខខណ្ឌ និងបទប្បញ្ញត្តិជាធរមាន ទើបអាចទទួលបានសិទ្ធិក្នុងការដំណើរការ

ការវិនិយោគរបស់ខ្លួនបាន។ លើសពីនេះទៅទៀត អាជ្ញាធរដែលមានសមត្ថកិច្ចគ្រប់គ្រងលើការវិនិយោគតំបន់ឆ្នេរត្រូវបានបែងចែកតួនាទី និងភារកិច្ចដាច់ដោយឡែកពីគ្នា ដែលយើងអាចមើលឃើញពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាទទួលភារកិច្ចក្នុងការចុះបញ្ជីឲ្យគម្រោងវិនិយោគដែលមានទុនចាប់ពី២.០០០.០០០ (ពីរលាន) ដុល្លាអាមេរិក រហូតដល់ ៥០.០០០.០០០ (ហាសិបលាន) ដុល្លាអាមេរិក អនុគណៈកម្មការវិនិយោគទទួលភារកិច្ចចុះបញ្ជីឲ្យគម្រោងវិនិយោគដែលមានទុនទាបជាង២.០០០.០០០ (ពីរលាន) ដុល្លាអាមេរិក និងចំពោះគម្រោងដែលមានទុនចាប់ពី ៥០.០០០.០០០ (ហាសិបលាន) ដុល្លាអាមេរិកឡើងទៅជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា។ មួយវិញទៀត ការអភិវឌ្ឍ និងការវិនិយោគតំបន់ឆ្នេរ បានរំលេចឡើងទាក់ទងនឹងការសាងសង់សំណង់នានាផងដែរ ការសាងសង់នៅតំបន់ឆ្នេរត្រូវមានការស្នើសុំនូវលិខិតអនុញ្ញាតសាងសង់ ដែលស្ថាប័នជំនាញបានតម្រូវឲ្យបុគ្គលបំពេញនូវលក្ខខណ្ឌមួយចំនួនដោយបែងចែកទៅតាមកម្មវត្ថុនៃពាក្យសុំសាងសង់ និងប្រភេទនៃបុគ្គលដែលជាអ្នកដាក់ពាក្យសុំ ហើយការគ្រប់គ្រងទៅលើការសាងសង់នេះ ក៏បានកំណត់អំពីសមត្ថកិច្ចផ្សេងៗពីគ្នាផងដែររួមមានសមត្ថកិច្ចរបស់សាលាខេត្ត សាលាក្រុង និងសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល។

ដើម្បីឲ្យការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរប្រកបទៅដោយប្រសិទ្ធភាព និងចីរភាពបន្ថែមទៀត គឺចាំបាច់ត្រូវអនុលោមទៅតាមបទប្បញ្ញត្តិដែលរួមមាន គោលការណ៍រដ្ឋធម្មនុញ្ញ គោលការណ៍ទូទៅនៃនីតិនគរូបនីយកម្ម និងសំណង់ ជាពិសេសគឺសារាចរណែនាំលេខ០១/សរណន ស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជាដែលទាំងអស់នេះជាវិធាន និងលិខិតបទដ្ឋានគតិយុត្តដ៏សំខាន់ និងមានអានុភាពសម្រាប់ការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជា។ តាមរយៈការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជាយើង គឺមានការវិវត្តជាច្រើនទៅតាមដំណាក់កាល ក៏ដូចជាសម័យកាលនីមួយៗរួមមាន នៅឆ្នាំ១៩៩៣ គឺយើងមាននូវរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្រោយមកនៅឆ្នាំ២០១២ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវសារាចរណែនាំលេខ០១/សរណន ស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា បន្តមកដល់ឆ្នាំ២០១៦ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវសេចក្តីសម្រេចលេខ១៣១/សសរ ស្តីពីការដាក់ឲ្យអនុវត្តគោលការណ៍ណែនាំអភិវឌ្ឍន៍រមណីយដ្ឋានឆ្នេរសមុទ្រ ហើយបន្តរហូតមកដល់ឆ្នាំ២០១៨ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវអនុក្រឹត្យលេខ៨១/អនក្រ/បក ស្តីពីការដាក់ឲ្យប្រើប្រាស់នូវផែនការរៀបចំដែនដីខេត្តព្រះសីហនុ ដែលមានចក្ខុវិស័យដល់ឆ្នាំ២០៣០ ប្លង់គោលប្រើប្រាស់ដីក្រុងកែប ចក្ខុវិស័យឆ្នាំ ២០៣០ ដែលត្រូវបានអនុម័ត និងដាក់ឲ្យប្រើប្រាស់ជាផ្លូវការដោយសេចក្តីសម្រេចលេខ ០០១/សសរ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ សម្រាប់ការអភិវឌ្ឍទីក្រុងកែបរហូតដល់ឆ្នាំ២០៣០ និងប្លង់គោលប្រើប្រាស់ដីក្រុងកំពត ចក្ខុវិស័យឆ្នាំ២០៣០ ត្រូវបានអនុម័ត និងដាក់ឲ្យប្រើប្រាស់ជាផ្លូវការដោយសេចក្តីប្រកាសសម្រេចលេខ០០៣/សសរ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ សម្រាប់ការអភិវឌ្ឍក្រុងកំពតរហូតដល់ឆ្នាំ២០៣០។ ថ្វីត្បិតតែលិខិតបទដ្ឋានគ្រប់គ្រងតំបន់ឆ្នេរមានការវិវត្តក៏ពិតមែន ប៉ុន្តែលិខិតបទដ្ឋាននេះនៅតែមានអានុភាពអនុវត្តចំពោះកិច្ចការរៀបចំ គ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ ដោយនៅក្នុងគោលដៅ និងគោលបំណងដើម្បីថែរក្សា ការពារ

បរិស្ថានតំបន់ឆ្នេរ ជម្រុញវិស័យទេសចរណ៍ វិស័យសេដ្ឋកិច្ច និងសង្គមនៅតំបន់ឆ្នេរឲ្យមានការរីកចម្រើនលូតលាស់ ប្រកបដោយប្រសិទ្ធភាព និងចីរភាព។ ស្ថាប័នមានសមត្ថកិច្ចរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរ ត្រូវបានបែងចែករចនាសម្ព័ន្ធ តួនាទី និងភារកិច្ចដាច់ដោយឡែកពីគ្នាដោយក្នុងនោះរួមមាន ស្ថាប័នជំនាញ គឺក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា និងអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ហើយចំពោះស្ថាប័នពាក់ព័ន្ធផ្សេងទៀតរួមមាន នាយកដ្ឋានអភិរក្សសមុទ្រនិងតំបន់ឆ្នេរនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន និងមន្ទីរទេសចរណ៍នៃខេត្តតំបន់ឆ្នេរសមុទ្រទាំង០៤ (មន្ទីរទេសចរណ៍ខេត្តព្រះសីហនុ មន្ទីរទេសចរណ៍ខេត្តកំពត មន្ទីរទេសចរណ៍ខេត្តកែប និងមន្ទីរទេសចរណ៍ខេត្តកោះកុង) ។

នៅក្នុងការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជា ក៏បានចង្អុលបង្ហាញពីបញ្ហាប្រឈម និងដំណោះស្រាយចំពោះការបំពានតំបន់ឆ្នេរផងដែរ។ ជុំវិញការអភិវឌ្ឍ និងការវិនិយោគតំបន់ឆ្នេរនៅកម្ពុជា ក៏បានបង្ហាញពីផលអវិជ្ជមានផងដែរ ដែលទាក់ទងនឹងផលប៉ះពាល់ដែលអាចកើតមានឡើង ពោលគឺ ផលប៉ះពាល់ដល់បរិស្ថានជុំវិញតំបន់ឆ្នេរ និងផលប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាជនដែលរស់នៅតំបន់ឆ្នេរ។ មួយវិញទៀត ការអភិវឌ្ឍ និងការវិនិយោគតំបន់ឆ្នេរ ក៏នាំមកនូវវិវាទមួយចំនួនផងដែររួមមាន វិវាទរវាងរដ្ឋជាមួយនឹងវិស័យឯកជន វិវាទរវាងរដ្ឋជាមួយនឹងប្រជាជន និងវិវាទរវាងវិស័យឯកជនជាមួយនឹងប្រជាជនផងដែរ។ ទាក់ទងនឹងយន្តការនៃការដោះស្រាយវិវាទវិញ នៅពេលដែលមាននូវការរំលោភបំពាន និងវិវាទកើតឡើងនោះ គឺត្រូវតែមានដំណោះស្រាយចំពោះបញ្ហានេះ ដែលដំណោះស្រាយត្រូវបានធ្វើឡើងតាមនីតិវិធីពីរយ៉ាងរួមមាន ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងដំណោះស្រាយតាមប្រព័ន្ធតុលាការ។

ជាសរុបរួមមក យើងអាចសន្និដ្ឋានបានថា របបគតិយុត្តនៃការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនេះពិតជាមានសារៈសំខាន់ណាស់សម្រាប់វិស័យតំបន់ឆ្នេរនៅកម្ពុជា ដែលមានសន្ទុះទាក់ទងនឹងការអភិវឌ្ឍ និងការវិនិយោគជាតិ និងអន្តរជាតិលើតំបន់ឆ្នេរនៅកម្ពុជា។ ហើយការរីកចម្រើននៃវិស័យសេដ្ឋកិច្ច ទេសចរណ៍ និងកំណើនប្រជាជនក្នុងតំបន់ឆ្នេរសមុទ្រ ក៏ដូចជាក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូលទាមទារឲ្យមានការអភិវឌ្ឍផ្អែករូបវន្តសមស្រប ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង ដោយក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជា មានផែនការគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរឲ្យបានត្រឹមត្រូវ ប្រកបដោយប្រសិទ្ធភាព និងចីរភាព ដើម្បីចៀសវាង និងទប់ស្កាត់ផលប៉ះពាល់ដល់ការអភិវឌ្ឍទេសចរណ៍ សេដ្ឋកិច្ច សង្គម បរិស្ថាន វប្បធម៌ និងប្រពៃណីក្នុងតំបន់ឆ្នេរសមុទ្រ។ ដូច្នេះចំពោះការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរ បានផ្តល់នូវគុណសម្បត្តិ ក៏ដូចជាអត្ថប្រយោជន៍ដែលយើងអាចមើលឃើញទាក់ទងនឹងការរីកចម្រើននៃវិស័យទេសចរណ៍នៅតំបន់ឆ្នេរ ដែលបានទាក់ទាញនូវភ្ញៀវទេសចរជាតិ និងអន្តរជាតិជាច្រើនមកកាន់តំបន់ឆ្នេរ ជាពិសេសការរីកចម្រើននៃវិស័យសេដ្ឋកិច្ច ដែលនៅតំបន់ឆ្នេរបានជួយជម្រុញដល់សេដ្ឋកិច្ចជាតិដោយការទាក់ទាញវិនិយោគិនចូលមកធ្វើការវិនិយោគ អភិវឌ្ឍ និងកសាងហេដ្ឋារចនាសម្ព័ន្ធនានានៅតំបន់ឆ្នេរ ប៉ុន្តែ

យើងឃើញថានៅពីក្រោយការរីកចម្រើននេះ ក៏មានលេចឡើងនូវគុណវិបត្តិ ក៏ដូចជាផលអវិជ្ជមានមួយចំនួនផង ដែរទាក់ទងនឹងបញ្ហាប៉ះពាល់ដល់បរិស្ថាន ធនធាននៅតំបន់ឆ្នេរ ការរស់នៅ និងការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាជនរស់នៅតាមតំបន់ឆ្នេរ រួមទាំងបញ្ហាទំនាស់វិវាទនានា និងការរំលោភបំពាននៅតំបន់ឆ្នេរ ដែលទាមទារឲ្យមានការដោះស្រាយចំពោះបញ្ហាទាំងអស់នេះ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានធ្វើការសិក្សាអំពីរបបគតិយុត្តនៃការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជារួចមក យើងសង្កេតឃើញថាសន្ទុះនៃការរីកចម្រើននៃវិស័យសេដ្ឋកិច្ច និងវិស័យទេសចរណ៍នៅតំបន់ឆ្នេរហាក់មានការកើនឡើងជាលំដាប់ ឯការអនុវត្តនូវគោលការណ៍គតិយុត្តលើការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជាក៏កាន់តែមានភាពប្រសើរឡើងផងដែរ។ ទាំងអស់នេះគឺដោយសារតែការប្រកាន់ខ្ជាប់នូវគោលការណ៍របស់រាជរដ្ឋាភិបាល និងការរៀបចំនូវផែនការ រួមទាំងការផ្តួចផ្តើមគម្រោងសម្រាប់តំបន់ឆ្នេររបស់រាជរដ្ឋាភិបាល ជាពិសេសគឺការសហការពីប្រជាជននៅតំបន់ឆ្នេរ ដើម្បីឲ្យប្រទេសជាតិឈានទៅរកភាពរុងរឿង និងសម្បូរបែប។ ម្យ៉ាងវិញទៀត ដោយសារតែមានការអភិវឌ្ឍ និងការវិនិយោគនៅតំបន់ឆ្នេរក៏កាន់តែមានសន្ទុះកើនឡើងផងដែរនោះ ជាចំណុចសំខាន់មួយផងដែរដែលធ្វើឲ្យតំបន់ឆ្នេរនៅកម្ពុជាកាន់តែមានភាពទាក់ទាញ និងល្បីល្បាញ នាំមកនូវការទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិកុះករ រួមទាំងវិនិយោគិនជាតិ និងអន្តរជាតិចាប់អារម្មណ៍លើការវិនិយោគនៅតំបន់ឆ្នេរកាន់តែច្រើន។

ស្របពេលដែលប្រទេសកម្ពុជាយើងកាន់តែមានការរីកចម្រើនខាងវិស័យតំបន់ឆ្នេរ និងមាននូវបទប្បញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាច្រើនដែលបានអនុម័ត និងដាក់ឲ្យប្រើប្រាស់ជាធរមាន ដើម្បីការពារផលប៉ះពាល់ដែលអាចកើតមាន ករណីរំលោភបំពានផ្សេងៗ និងវិវាទនានានៅតំបន់ឆ្នេរ យើងក៏មើលឃើញនូវភាពខ្វះចន្លោះមួយចំនួនចំពោះការអនុវត្តបទប្បញ្ញត្តិច្បាប់ដែលមានជាធរមាន ដូចជាការអនុញ្ញាតឲ្យធ្វើសកម្មភាពវិនិយោគនៅតំបន់ឆ្នេរ ដោយមិនបានត្រួតពិនិត្យឲ្យបានច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយថាតើបុគ្គលដែលធ្វើសកម្មភាពវិនិយោគនោះ មានគោលបំណងវិនិយោគក្រោមរូបភាពណាខ្លះ ហើយអាចបង្កផលប៉ះពាល់បែបណាខ្លះ ទាំងនេះហើយដែលជាហេតុនាំឲ្យមានការកើតមានឡើងនូវផលប៉ះពាល់ និងបញ្ហាប្រឈមជាច្រើន ដែលយើងអាចមើលឃើញពីទិដ្ឋភាពជាក់ស្តែងកើតមានឡើងនៅតំបន់ឆ្នេរនៃព្រះរាជាណាចក្រកម្ពុជាយើង ដែលយើងបានឃើញពីផលប៉ះពាល់ដល់បរិស្ថានធម្មជាតិ ផលប៉ះពាល់ដល់ប្រជាជនដែលរស់នៅតាមតំបន់ឆ្នេរ ជាពិសេសតម្លៃអេកូឡូស៊ី។ មិនត្រឹមតែប៉ុណ្ណោះ យើងក៏បានឃើញអំពីបញ្ហាវិវាទដែលកើតមានឡើងនៅតំបន់ឆ្នេរផងដែរជាក់ស្តែងគឺ បញ្ហារំលោភបំពានរបស់ប្រជាជនមួយចំនួនដែលនៅតែបន្តសកម្មភាពរំលោភបំពាន និងមិនព្រមអនុវត្តតាមគោលការណ៍ណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ច និងបញ្ហារំលោភបំពានរបស់ក្រុមហ៊ុនឯកជនដែលតែងតែធ្វើសកម្មភាពក្រោមរូបភាពវិនិយោគ ហើយបំពានតំបន់ឆ្នេរដោយខុសច្បាប់។

ជាមួយគ្នានេះដែរ ក្រុមយើងខ្ញុំសូមធ្វើការផ្តល់នូវមតិយោបល់ និងសំណូមពរបន្ថែមទៅលើការរៀបចំ និងគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជា ទាក់ទិននឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋាននានា ព្រោះតែការអនុវត្តនេះនៅមានលក្ខណៈធូររលុង និងខ្វះចន្លោះនូវការរឹតបន្តឹងរបស់អាជ្ញាធរមានសមត្ថកិច្ច រួមទាំងការតាមដានត្រួតពិនិត្យឲ្យបានគ្រប់ជ្រុងជ្រោយលើសកម្មភាពនានានៅតំបន់ឆ្នេរ។ ជាចុងក្រោយយើងខ្ញុំទាំងពីរនាក់សូមសំណូមពរដល់រាជរដ្ឋាភិបាលកម្ពុជា អនុម័តបន្ថែមទាក់ទងនឹងវិធានច្បាប់សម្រាប់វិស័យតំបន់ឆ្នេរ ព្រមទាំងការដាក់ចេញនូវវិធានការ

យ៉ាងតឹងរឹងសម្រាប់អនុវត្ត និងណែនាំដល់បុគ្គលដែលមានបំណងធ្វើការវិនិយោគតំបន់ឆ្នេរ និងអភិវឌ្ឍតំបន់ឆ្នេរក្នុងគោលដៅនានា រួមទាំងចាត់វិធានការអប់រំ ណែនាំដល់ប្រជាជនដែលរស់នៅតំបន់ឆ្នេរឲ្យចូលរួមសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ជាពិសេសសូមសំណូមពរឲ្យមានការដាក់ចេញនូវវិធានការច្បាប់អនុវត្តទៅលើជនខិលខូចទាំងឡាយដែលព្យាយាមធ្វើការបំផ្លិចបំផ្លាញ និងរំលោភបំពានតំបន់ឆ្នេរ ដើម្បីថែរក្សា ការពារ អភិរក្ស និងទប់ស្កាត់រាល់សកម្មភាពទាំងឡាយដែលធ្វើឲ្យប៉ះពាល់ដល់តំបន់ឆ្នេរ និងធានាបាននូវគុណភាពបរិស្ថាន និងសោភណភាពតំបន់ឆ្នេរឲ្យកាន់តែមានភាពល្អប្រសើរជាងមុនថែមទៀត។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា,២៤ កញ្ញា ១៩៩៣, មាត្រា៣៥ ៣៦ ៤៤ ៥៨ និងមាត្រា៥៩
- ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា,០៤ សីហា ១៩៩៤
- ច្បាប់ភូមិបាលនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា២៥៩
- ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣, មាត្រា៦ និងមាត្រា៧
- ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ,លេខ នស/រកម/០២០៨/០០៧, ១៥ កុម្ភៈ ២០០៨

## ព្រះរាជក្រឹត្យ

- ព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៧៩ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៅកម្ពុជា, ១៦ កុម្ភៈ ២០១២, មាត្រា២ និងមាត្រា៥

## អនុក្រឹត្យ

- អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់, លេខ៨៦អនក្រ/បក, ១៩ ធ្នូ ១៩៩៧, មាត្រា៤ និងមាត្រា៥
- អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ៦២ អនក្រ/បក, ២០ កក្កដា ១៩៩៩, មាត្រា៨ ១២ ១៥ និងមាត្រា១៦
- អនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មការវិនិយោគក្រុងព្រះសីហនុ, លេខ១៦អនក្រ/បក, ០៩ កុម្ភៈ ២០០៥
- អនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មការវិនិយោគខេត្តកំពត, លេខ៣១អនក្រ/បក, ០៩ កុម្ភៈ ២០០៥
- អនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មការវិនិយោគខេត្តកោះកុង, លេខ៣២អនក្រ/បក, ០៩ កុម្ភៈ ២០០៥
- អនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មការវិនិយោគក្រុងកែប, លេខ៣៨អនក្រ/បក, ០៩ កុម្ភៈ ២០០៥
- អនុក្រឹត្យស្តីពីការអនុវត្តច្បាប់វិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១១១ អនក្រ/បក, ២៧ កញ្ញា ២០០៥, មាត្រា៤
- អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៅកម្ពុជា, លេខ១៧១អនក្រ/បក, ០៨ តុលា ២០១២
- អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, លេខ៤៨៦អនក្រ/បក, ១៤ តុលា ២០១៣, មាត្រា ១០ ១១ ១៤ និងមាត្រា១៧
- អនុក្រឹត្យស្តីពីការដាក់ឲ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តព្រះសីហនុ, លេខ៨១អនក្រ/បក, ១៣ មិថុនា ២០១៨

**ប្រកាស**

- ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានអភិរក្សសមុទ្រនិងតំបន់ឆ្នេរនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ, លេខ៤៥១/ប្រក, ០៣ ធ្នូ ២០១៥
- ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរទេសចរណ៍រាជធានីខេត្ត, លេខ១២៣/ប្រក, ៣០ កក្កដា ២០១៩, ប្រការ៥ និងប្រការ៨

**សារាចរណែនាំ**

- សារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា, លេខ០១/សរណន, ០៣ កុម្ភៈ ២០១២

**សេចក្តីសម្រេច**

- សេចក្តីសម្រេចស្តីពីការដាក់ឲ្យអនុវត្តគោលការណ៍ណែនាំអភិវឌ្ឍន៍រមណីយដ្ឋានឆ្នេរសមុទ្រ, លេខ១៣១/សសរ, ២២ ធ្នូ ២០១៦
- សេចក្តីសម្រេចស្តីពីការដាក់ឲ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងកែប ខេត្តកែប, លេខ០០១/សសរ, ០៥ កក្កដា ២០០៨
- សេចក្តីសម្រេចស្តីពីការដាក់ឲ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងកំពត ខេត្តកំពត, លេខ០០៣/សសរ, ០៥ កក្កដា ២០០៨

**សេចក្តីព្រាង**

- ក្រមបរិស្ថាននិងធនធានធម្មជាតិ កំណែ៩.១, ២៥ កក្កដា ២០១៧, មាត្រា៥១៥

**របាយការណ៍**

- របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំប្រចាំខែកុម្ភៈ ឆ្នាំ២០២១ និងលើកទិសដៅការងារបន្តរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**សេចក្តីជូនដំណឹង**

- សេចក្តីជូនដំណឹងរបស់រដ្ឋបាលខេត្តព្រះសីហនុ, លេខ០៣២/២១/សជណ, ០២ កុម្ភៈ ២០២១
- សេចក្តីជូនដំណឹងរបស់រដ្ឋបាលស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ, លេខ០១៨/២១/សជណ, ១៥ មីនា ២០២១

**សៀវភៅ**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍បៃតង, ២០១៣, ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍន៍បៃតងឆ្នាំ២០១៣~២០៣០, ភ្នំពេញ៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍បៃតង

**មេរៀន**

- ប៉ូលី បញ្ញា, "នីតិនគរូបនីយកម្ម និងសំណង់",(មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច, ឆ្នាំសិក្សា២០២០-២០២១), លិខិតអនុញ្ញាតសាងសង់ និងលិខិតអនុញ្ញាតរុះរើ

**គេហទំព័រ**

- www.nationalgeographic.org/encyclopedia/beach, (ចូលទស្សនាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង ១៣:៣៥នាទីរសៀល)
- https://www.tnaot.com/km/m/detail/article/994242 ,(ចូលទស្សនាថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង ២០:៤៣នាទីយប់)
- https://www.kohkong.gov.kh/archives/70981 ,(ចូលទស្សនាថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង ២០:៥៦នាទីយប់)
- https://www.kh.undp.org/content/cambodia/km/home/_-news-centre/articles-and-opeds0/2020/_-_-.html, (ចូលទស្សនាថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ៨:៤៥នាទីយប់)
- https://peoplenews.asia/64293/ ,(ចូលទស្សនាថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ៩:០០ នាទីយប់)
- របាយការណ៍៖ ការអភិវឌ្ឍតាមតំបន់ឆ្នេរបង្កផលប៉ះពាល់ដល់ប្រជាសហគមន៍នេសាទកម្ពុជា (rfi.fr), (ចូលទស្សនាថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២១, វេលាម៉ោង ០៩:១៥នាទីព្រឹក)
- https://mekong-post.com/46924, (ចូលទស្សនាថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១, វេលាម៉ោង ០៩:២៥ នាទីយប់)
- អភិបាលខេត្តព្រះសីហនុទុកពេលឲ្យអាជីវករ ២៧ថ្ងៃ រុះរើសំណង់រំលោភដីចំណីឆ្នេរ នៅពយាយម៉ី និងឆ្នេរតាបារាំង – DAP News (dap-news.com), (ចូលទស្សនាថ្ងៃទី០៦ កក្កដា ឆ្នាំ២០២១ វេលាម៉ោង ១០:៣០នាទីយប់)
- អាជីវកម្មចិន បង្កក្ដីបារម្ភដល់អាជីវករក្នុងស្រុកនៅខេត្តព្រះសីហនុ (postkhmer.com), (ចូលទស្សនាថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ១០:៣៥នាទីយប់)
- បញ្ឈប់ការសាងសង់សំណង់ខុសច្បាប់ នៅតំបន់ឆ្នេរព្រែកកំពត – Koh Santepheap Daily, (ចូលទស្សនាថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ១០:៥០នាទីយប់)

- រដ្ឋប្រកាសចាត់វិធានការធ្ងន់លើអ្នកលុបសមុទ្រយកដី នៅខេត្តចំនួន ២ នៅកម្ពុជា - Construction & Property News (construction-property.com), (ចូលទស្សនាថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ០៩:៣០នាទីយប់)
- https://www.khemaradaily.com/p/148085, (ចូលទស្សនាថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ១០:៣៥នាទីយប់)
- http://www.khmerlaws.com, (ចូលទស្សនាថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ២០:៣៥នាទីយប់)
- https://youtu.be/U6_SDFYiTY4, (ចូលទស្សនាថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ២១:៤៥ នាទីយប់)
- http://m.freshnewsasia.com/index.php/en/localnews/154208-2020-04-05-05-51-53.html, (ចូលទស្សនាថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ១៥:៣៤នាទីរសៀល)
- https://www.ggi.law/4973, (ចូលទស្សនាថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ១៥:៥០នាទីរសៀល)

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១៖** អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ លេខ៦២អនក្រ/បក, ២០ កក្កដា ១៩៩៩

**ឧបសម្ព័ន្ធទី២៖** ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣

**ឧបសម្ព័ន្ធទី៣៖** អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រ,លេខ ១១១អនក្រ/បក, ២៧ កញ្ញា ២០០៥

**ឧបសម្ព័ន្ធទី៤៖** សារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា, លេខ០១/សរណន, ០៣ កុម្ភៈ ២០១២

**ឧបសម្ព័ន្ធទី៥៖** ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា,លេខ នស/រកត/០២១២/០៧៩, ១៦ កុម្ភៈ ២០១២

**ឧបសម្ព័ន្ធទី៦៖** អនុក្រឹត្យស្តីពីការរៀបចំ  និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា, លេខ១៧១អនក្រ/បក, ០៨ តុលា ២០១២

**ឧបសម្ព័ន្ធទី៧៖** ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានអភិរក្សសមុទ្រ និងតំបន់ឆ្នេរ នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ, លេខ៤៥/ប្រក, ០៣ ធ្នូ ២០១៥

**ឧបសម្ព័ន្ធទី៨៖** ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរទេសចរណ៍រាជធានីខេត្ត, លេខ១២៣/ប្រក, ៣០ កក្កដា ២០១៩

# ឧបសម្ព័ន្ធទី ១

# អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ៦២អនក្រ/បក, ២០ កក្កដា ១៩៩៩

មាត្រា ៣._ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

# II- រាជរដ្ឋាភិបាល

## អនុក្រឹត្យ

### អនុក្រឹត្យលេខ៦២ អនក្រ/បក ស្តីពី

### ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង

### រៀបចំដែនដី នគរូបនីយកម្ម និង សំណង់

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន

- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៩៩

**សំរេច :**

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១._**

អនុក្រឹត្យនេះកំណត់ការរៀបចំបណ្តាអង្គភាពរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងកំណត់បេសកកម្មរបស់ក្រសួង និងមុខការរបស់បណ្តាអគ្គនាយកដ្ឋាន នាយកដ្ឋាននានា និងអង្គភាពមូលដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ២

## បេសកកម្ម និង រចនាសម្ព័ន្ធ

**មាត្រា ២._**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់បេសកកម្មឲ្យដឹកនាំ និងគ្រប់គ្រងការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ ភូមិយោធី និងភូមិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែតំបន់ណា ឬសមត្ថកិច្ចណា ដែលរាជរដ្ឋាភិបាលប្រគល់ឲ្យស្ថាប័នមួយផ្សេងទៀត ។

**មាត្រា ៣._**

ដើម្បីអនុវត្តបេសកកម្មរបស់ខ្លួន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានភារកិច្ចដូចតទៅ ៖

១- ក្នុងបេសកកម្មរៀបចំដែនដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ត្រូវ :

- លើកសំណើ និងដាក់ឲ្យអនុវត្តនូវនយោបាយរៀបចំដែនដី ដែលធានាតុល្យភាពនៃ កិច្ចអភិវឌ្ឍន៍ទីក្រុងនិងជនបទ និងការបែងចែកផលនៃការរីកចំរើន
- ធ្វើការសិក្សា និង ការវិភាគសំរាប់អនាគតទាក់ទងនឹងការរៀបចំដែនដី ។ លើកសំណើ និងដាក់ឲ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តទាំងឡាយក្នុងការអនុវត្តន៍នយោបាយរៀបចំដែនដី ។ លើកសំណើនយោបាយផែនការសកម្មភាព និងវិធានការសមស្រប ដែលអនុគ្រោះដល់ការអភិវឌ្ឍន៍ដែនដី
- យកចិត្តទុកដាក់ដល់ភាពសុខដុមនៃនយោបាយអភិវឌ្ឍន៍លើវិស័យនានា និងដល់ចំណងផ្សារភ្ជាប់ផ្ការវាងសកម្មភាពនៅថ្នាក់ក្រសួង និងនៅថ្នាក់ខេត្ត-ក្រុង ។ ការងាររៀបចំដែនដី ជាការងារមានចរិតអន្តរវិស័យ ដែលទាមទារអោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ធ្វើជាលេខាធិការក្នុងការប្រមែប្រមូល

ទិន្នន័យរូបវន្ត ទិន្នន័យសេដ្ឋកិច្ច ទិន្នន័យសង្គមកិច្ច ប្រជាសាស្ត្រ .... ដើម្បីរៀបចំយុទ្ធសាស្ត្រ កំណត់តំបន់សំខាន់ៗ ដូចជាតំបន់អភិវឌ្ឍន៍សេដ្ឋកិច្ច តំបន់អភិវឌ្ឍន៍ឧស្សាហកម្ម តំបន់ទីក្រុង តំបន់ជនបទ តំបន់អភិរក្សធម្មជាតិ តំបន់ទេសចរណ៍ តំបន់ការពារបេតិកភ័ណ្ឌ ព្រមទាំងទីតាំងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច សង្គមកិច្ច គមនាគមន៍ ទីតាំងរដ្ឋបាលសាធារណៈ និង តំបន់ឯទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល

- អនុវត្តនយោបាយរៀបចំដែនដី ដែលមានភាពអនុគ្រោះដល់តំបន់ជនបទ និង តំបន់អាទិភាពរបស់រាជរដ្ឋាភិបាល

- យកចិត្តទុកដាក់ចំពោះសេចក្តីសំរេចស្តីពីការកសាងហេដ្ឋារចនាសម្ព័ន្ធ ឲ្យស្របទៅតាមអាទិភាពនៃនយោបាយរៀបចំដែនដី

- យកចិត្តទុកដាក់ចំពោះការបោះទីតាំងសកម្មភាព និងសេវាសាធារណៈឲ្យស្របទៅតាមនយោបាយរៀបចំដែនដី និងនយោបាយវិសហមជ្ឈការរដ្ឋបាល

- ជំរុញនយោបាយលើកទឹកចិត្តការវិនិយោគទៅរកតំបន់ជនបទ និងតំបន់អាទិភាពរបស់រាជរដ្ឋាភិបាល ដោយសហការជាមួយក្រសួងអភិវឌ្ឍន៍ជនបទ និងស្ថាប័នពាក់ព័ន្ធដទៃទៀត

- ចូលរួមអនុវត្តការងារពាក់ព័ន្ធនឹងអាងទន្លេមេគង្គស្របតាមភារកិច្ចរបស់ក្រសួង

២- ក្នុងបេសកកម្មការងារនគរូបនីយកម្មនិងសំណង់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវ ៖

- ធ្វើការស្រាវជ្រាវ និងការវិភាគសំរាប់អនាគត និងចងក្រងស្ថិតិទាំងឡាយទាក់ទងនឹងការងារនគរូបនីយកម្ម និងសំណង់ ។ លើកសំណើ និង ដាក់ឲ្យអនុវត្តនូវលិខិតបទដ្ឋានចាំបាច់ ទាំងឡាយក្នុងការអនុវត្តន៍នយោបាយនគរូបនីយកម្ម និង សំណង់

- លើកសំណើនយោបាយ ផែនការសកម្មភាព និងវិធានការសំរាប់ការដោះ-ស្រាយសំណង់អនាធិបតេយ្យ និងការសាងសង់លំនៅស្ថាន ដោយរក្សាទេសភាព រមណីយដ្ឋាន នៅក្នុងទីក្រុងនិងទីប្រជុំជនជនបទ និងការពារបរិស្ថាន

- កំណត់វិធានទាំងឡាយ និងរៀបចំបទបញ្ញាទាក់ទងនឹងការកាន់កាប់ដីធ្លី នគរូបនីយកម្មសំណង់ អស្សាមិករណ៍ ការកំណត់ដីបំរុង

-ចេញលិខិតអនុញ្ញាត និងការយល់ព្រមទាំងឡាយទាក់ទងនឹងនគរូបនីយកម្ម និងសំណង់

- ជំរុញការសាងសង់លំនៅដ្ឋាន សង្គមកិច្ច ធ្វើប្រតិបត្តិការរៀបចំទីក្រុង ធ្វើការបែងចែកដីជាឡូតិ៍ ជាតំបន់អភិវឌ្ឍន៍

- ពិនិត្យបញ្ជាក់ផលការសាងសង់ និងការថែទាំអគារសាធារណៈ
- រួមជាមួយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដើម្បីការពារបេតិកភ័ណ្ឌ និង រមណីយដ្ឋានប្រវត្តិសាស្ត្រ
- រួមជាមួយអាជ្ញាធរអប្សរា ដើម្បីការពារបេតិកភ័ណ្ឌនិងរមណីយដ្ឋានប្រវត្តិសាស្ត្រក្នុងតំបន់ជាសមត្ថកិច្ចរបស់អាជ្ញាធរ
- រួមជាមួយក្រសួងបរិស្ថាន ដើម្បីថែរក្សាការពារបរិស្ថាន ទេសភាព រមណីយដ្ឋានធម្មជាតិ និងប្រព័ន្ធអេកូ ។

៣-ក្នុងបេសកកម្មការងារសុរិយោដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានភារកិច្ចធ្វើការស្រាវជ្រាវ កសាងលិខិតបទដ្ឋានទាំងឡាយ ដែលទាក់ទងនឹងការងារគ្រប់គ្រងប្រើប្រាស់ដីធ្លីតាមប្រព័ន្ធព័ត៌មានវិទ្យា ។ ធ្វើការវាស់វែង គូរប្លង់សុរិយោដី និងចេញប័ណ្ណសំគាល់សិទ្ធិលើដីធ្លីទូទាំងព្រះរាជាណាចក្រកម្ពុជា ។ធ្វើការងារអភិរក្សសុរិយោដី ។

៤-ក្នុងបេសកកម្មការងារភូមិសាស្ត្រ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានភារកិច្ចគ្រប់គ្រង និងផ្សព្វផ្សាយផែនទី ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធដែល ផលិតផែនទីជំនាញ ដើម្បីអោយផែនទីទាំងអស់ប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រឯកភាពគ្នា ។

៥-គ្រប់គ្រង ត្រួតពិនិត្យ កំណត់សមត្ថភាពបច្ចេកទេសវិជ្ជាជីវៈ និងចេញលិខិតអនុញ្ញាតអាជីវកម្ម ដល់រូបវន្តបុគ្គល និងនីតិបុគ្គល ដែលធ្វើអាជីវកម្មទាក់ទងនឹងលំនៅដ្ឋាន ការប្រើប្រាស់ដីធ្លី ការសាងសង់ និងការសិក្សាធ្វើគំរោងប្លង់ ។

៦-តំរង់ទិស ណែនាំ តាមដាន ត្រួតពិនិត្យរាល់កិច្ចការលើវិស័យរៀបចំដែនដី នគរូបនីយកម្មសំណង់ សុរិយោដី និងភូមិសាស្ត្រ ។

៧-ផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាល ច្បាប់ បទប្បញ្ញត្តិ និង បច្ចេកទេសវិជ្ជាជីវៈ ដែលទាក់ទងនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និង ភូមិសាស្ត្រ ។

៨-ធ្វើសហប្រតិបត្តិការជាមួយអន្តរជាតិ និង អង្គការនានា ដើម្បីដំណើរការល្អនៃវិស័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និង ភូមិសាស្ត្រ ។

៩-សហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការប្រមូលពន្ធពីបេតិកភ័ណ្ឌ ។

មាត្រា ៤._

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ មានរចនាសម្ព័ន្ធដូចតទៅ ៖

១- ថ្នាក់កណ្តាល ៖

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អធិការដ្ឋាន

- អគ្គនាយកដ្ឋានរដ្ឋបាល រួមមាន :
  - នាយកដ្ឋានរដ្ឋបាល និង កិច្ចការទូទៅ
  - នាយកដ្ឋានបុគ្គលិក
  - នាយកដ្ឋាន ផែនការ សេដ្ឋកិច្ច និងហិរញ្ញកិច្ច
  - នាយកដ្ឋាននីតិកម្ម
  - នាយកដ្ឋាន អភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការវិនិយោគ និងទំនាក់ទំនងអន្តរជាតិ
- អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្មរួមមាន :
  - នាយកដ្ឋាន ស្រាវជ្រាវ និង បទប្បញ្ញត្តិ
  - នាយកដ្ឋាន រៀបចំដែនដី
  - នាយកដ្ឋាន នគរូបនីយកម្ម
- អគ្គនាយកដ្ឋានសំណង់រួមមាន :
  - នាយកដ្ឋាន ស្រាវជ្រាវបច្ចេកទេសសំណង់
  - នាយកដ្ឋាន សិក្សាគំរោងប្លង់
  - នាយកដ្ឋាន សំណង់
- អគ្គនាយកដ្ឋាន សុរិយោដី និងភូមិសាស្ត្រ រួមមាន :
  - នាយកដ្ឋាន គ្រប់គ្រងដីធ្លី
  - នាយកដ្ឋាន អធិការកិច្ចភូមិបាល
  - នាយកដ្ឋាន បច្ចេកទេស
  - នាយកដ្ឋាន អភិរក្សសុរិយោដី
  - នាយកដ្ឋាន ភូមិសាស្ត្រ
- មន្ទីរពិសោធន៍
- មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ
- គ្រឹះស្ថាន និង សហគ្រាសក្រោមឳវាទ
- អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

២- អង្គភាពមូលដ្ឋាន :

- មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់និងសុរិយោដី ខេត្ត-ក្រុង
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ខ័ណ្ឌ-ស្រុក

អង្គការលេខរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ ។

## ជំពូកទី ៣
## ខុទ្ទកាល័យរដ្ឋមន្ត្រី

មាត្រា ៥._

ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលកំណត់តាមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ដូចមានចែងក្នុងមូលបទខាងលើស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

## ជំពូកទី ៤
## អធិការដ្ឋាន

មាត្រា ៦._

អធិការដ្ឋានរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានភារកិច្ចជាសេនាធិការឲ្យក្រសួងក្នុងការងារ :

- ធ្វើអធិការកិច្ចជាប្រចាំទៅលើគ្រប់អង្គភាពក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ធ្វើរបាយការណ៍ជាប្រចាំជូនរដ្ឋមន្ត្រីអំពីការប្រព្រឹត្តិទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ច ហើយ និងអំពីមធ្យោបាយកែលំអការប្រព្រឹត្តិទៅរបស់អង្គភាពនោះ
- ពិនិត្យ សំរុះសំរួល និងដោះស្រាយវិវាទរដ្ឋបាល ដែលពាក់ព័ន្ធដល់សមត្ថកិច្ច និងសកម្មភាពរបស់មន្ត្រី និងភ្នាក់ងាររបស់ក្រសួង
- ប្រតិបត្តិកិច្ចការតាមការដែលរដ្ឋមន្ត្រីបានប្រគល់ជូន

អធិការដ្ឋានដឹកនាំដោយអធិការមួយរូប និងអមដោយអធិការរងជាជំនួយការតាមការចាំបាច់ ។

## ជំពូកទី ៥
## អគ្គនាយកដ្ឋានរដ្ឋបាល

មាត្រា ៧._

អគ្គនាយកដ្ឋាន រដ្ឋបាល មានភារកិច្ចជាសេនាធិការឲ្យក្រសួងក្នុងការងារ :

- គ្រប់គ្រងការងារដូចជា : រដ្ឋបាល បូកសរុបរបាយការណ៍ ឯកសារ បុគ្គលិក ផែនការហិរញ្ញវត្ថុ សំភារៈបរិក្ខារ ក្របខ័ណ្ឌក្រសួង និងការងារសិក្សាស្រាវជ្រាវនីតិកម្ម
- សំរបសំរួលរាល់សកម្មភាពរដ្ឋបាលក្នុងក្រសួងជាមួយបណ្តាអង្គភាពមូលដ្ឋានខេត្ត-ក្រុង និងជាមួយក្រសួងស្ថាប័ននានា
- រៀបចំកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច និងវិនិយោគ ស្របតាមនយោបាយរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយសហការជាមួយក្រសួង អង្គការ ស្ថាប័នជាតិ និងអន្តរជាតិ

- ធ្វើទំនាក់ទំនងជាមួយសាធារណជន និងអន្តរជាតិ

អគ្គនាយកដ្ឋានរដ្ឋបាល ដឹកនាំដោយអគ្គនាយកមួយរូប និងមានអគ្គនាយករងជាជំនួយការតាមការចាំបាច់ ។ អគ្គនាយកដ្ឋាននេះមាននាយកដ្ឋានចំណុះចំនួន ៥ គឺ :

- នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
- នាយកដ្ឋានបុគ្គលិក
- នាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញកិច្ច
- នាយកដ្ឋាន នីតិកម្ម
- នាយកដ្ឋាន អភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការពិភពលោក និងទំនាក់ទំនងអន្តរជាតិ ។

**មាត្រា ៨._**

នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ មានតួនាទី និងភារកិច្ចដូចតទៅ :

- សំរបសំរួលសកម្មភាពការងារគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្តាល រវាងថ្នាក់កណ្តាល និង អង្គភាពមូលដ្ឋានចំណុះក្រសួង
- កសាងផែនការការងាររបស់ក្រសួង
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗ របស់ក្រសួង
- រៀបចំខ្លឹមសារប្រជុំ សន្និបាត សិក្ខាសាលា និងពិធីបុណ្យផ្សេងៗ
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល ក្នុងទីស្តីការក្រសួង
- បូកសរុប និងធ្វើរបាយការណ៍ការងារនិងសកម្មភាពផ្សេងៗ របស់ក្រសួង
- ធ្វើទំនាក់ទំនងអន្តរក្រសួង និងសាធារណជន
- សរុបពត៌មាន អត្ថបទសារពត៌មានដែលពាក់ព័ន្ធនឹងក្រសួង

នាយកដ្ឋានរដ្ឋបាលដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់ ។

**មាត្រា ៩._**

នាយកដ្ឋានបុគ្គលិក មានតួនាទី និងភារកិច្ចដូចតទៅ :

- គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈរបស់ក្រសួង ដោយធ្វើទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- រៀបចំលិខិតរដ្ឋបាល សំរាប់គ្រប់គ្រងអាជីព
- ធ្វើកម្មវិធីអំពីតំណែងឯកទេស និងធនធានមនុស្សរបស់ក្រសួង
- វាយតំលៃតំរូវការ ក្នុងការបណ្តុះបណ្តាលបុគ្គលិក
- តាមដាន វាយតំលៃ សមត្ថភាពបច្ចេកទេសរបស់មន្ត្រីរាជការក្នុងក្រសួង
- រៀបចំការងារបៀវត្ស ពលកម្ម ប្រាក់កំរៃ និងគ្រប់គ្រងការងារសង្គមរបស់ក្រសួង

- រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និង តារាងពត៌មានប្រតិបត្តិ ។

នាយកដ្ឋានបុគ្គលិកដឹកនាំដោយប្រធានមួយរូប និង អនុប្រធានជាជំនួយការតាមការ ចាំបាច់ ។

**មាត្រា១០._**

នាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានតួនាទី និងភារកិច្ចដូចតទៅ ៖

- ចូលរួមការងាររៀបចំផែនការជាមួយមន្ត្រីនាយកដ្ឋាន អង្គភាព អង្គការចំណុះក្រសួង ដើម្បីកសាង ផែនការសម្រាប់អភិវឌ្ឍវិស័យរបស់ក្រសួង និងអង្គភាពខេត្ត-ក្រុង
- ប្រមូលគំរោងថវិកាឲ្យបានសមស្របតាមច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ
- ប្រមូលផ្តុំ និងពិនិត្យឯកសារថវិកាហិរញ្ញវត្ថុ
- តាមដានលើការគ្រប់គ្រងចំណាយថវិការដ្ឋ
- ប្រមូលផ្តុំសំណើរ ធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំផ្គត់ផ្គង់សំភារៈ និងបរិក្ខាររបស់ ក្រសួង និងខេត្ត-ក្រុង
- បំពេញការងារជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ឬស្ថាប័នផ្សេងទៀតដែល ពាក់ព័ន្ធ និងធ្វើការចំណាយថវិកាលើកិច្ចប្រតិបត្តិការរបស់ក្រសួង និងខេត្ត-ក្រុង
- ចូលរួមពិនិត្យ គុណភាព បរិមាណភាពនៃសំភារៈ ឱ្យការផ្គត់ផ្គង់ត្រូវបញ្ចូលបញ្ជី
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ
- ធ្វើកម្មវិធីចំណាយលើអគ្គិសនីប្រើប្រាស់ និងទឹកស្អាត
- ធ្វើកិច្ចព្រមព្រៀងប្រាក់ចំណូលសហគមន៍ និងគណនេយ្យរួមជាតិ
- ពត៌មានវិទ្យាគណនេយ្យហិរញ្ញវត្ថុ និងបន្ទុកគណនី
- ត្រួតពិនិត្យបច្ចេកទេសនៃប្រតិបត្តិការឬកម្មសិទ្ធសាធារណៈ
- រៀបចំ និង គ្រប់គ្រងប្រព័ន្ធទិន្នន័យរបស់ក្រសួង និងកំណត់កម្មវិធីចំណាយអភិវឌ្ឍន៍ សេដ្ឋកិច្ច លើគ្រប់ផ្នែកទាំងអស់
- សិក្សា និងវាយតំលៃលើផ្នែកហិរញ្ញវត្ថុ និងផ្នែកសេដ្ឋកិច្ចលើគំរោងការវិនិយោគដែល មានប្រភពចំណាយក្នុង ឬក្រៅប្រទេសក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍
- សំរបសំរួលជំនួយពីបរទេស និងត្រួតពិនិត្យការអនុវត្តន៍
- ដឹកនាំការងារជំនាញ ផែនការដល់គ្រប់បណ្តាអង្គភាពខេត្ត-ក្រុង ដែលមានថវិការបស់ ក្រសួងទៅប្រើប្រាស់តាមគោលការណ៍ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍បូកសរុបការងារប្រចាំត្រីមាស និងប្រចាំឆ្នាំ ។

នាយកដ្ឋាននេះ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់ ។

**មាត្រា ១១.-**

នាយកដ្ឋាននីតិកម្ម មានតួនាទី និងភារកិច្ចដូចតទៅ ៖

- ជាសេនាធិការរបស់ក្រសួង ក្នុងកិច្ចការនីតិកម្ម
- កសាងសេចក្ដីព្រាងច្បាប់ អនុក្រឹត្យ ប្រកាស សារាចរ បទបញ្ជា លិខិតបទដ្ឋាន និងឯកសារផ្សេងៗទៀតរបស់ក្រសួង
- ពិនិត្យ កែសម្រួលអត្ថបទច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋាន របស់នាយកដ្ឋាន និងបណ្ដាអង្គភាព មន្ទីរចំណុះឲ្យស្របតាមច្បាប់ជាធរមាន
- ផ្ដល់យោបល់ផ្នែកគតិយុត្តដល់បណ្ដានាយកដ្ឋាន អង្គភាព មន្ទីរចំណុះ ក្នុងការអនុវត្តន៍សមត្ថកិច្ចរបស់ខ្លួនឲ្យសមស្រប
- ចូលរួមបណ្ដុះបណ្ដាល ផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋាន ស្ដីពីការរៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រ
- ពិនិត្យ និងផ្ដល់យោបល់អំពីលក្ខណៈគតិយុត្តលើ សំណុំលិខិតសុំអនុញ្ញាតកាន់កាប់ដីធ្លី សំណុំលិខិតអនុញ្ញាតសាងសង់ សំណុំលិខិតសុំធ្វើអាជីវកម្មសិក្សាគំរោងប្លង់ សំណុំលិខិតសុំអនុញ្ញាតធ្វើអាជីវកម្មសាងសង់ សំណុំលិខិតសុំអនុញ្ញាតបើក និងបិទការដ្ឋានសាងសង់ ដែលស្ថិតនៅក្នុងថ្នាក់កណ្ដាល
- សហការជាមួយអធិការដ្ឋានរបស់ក្រសួងក្នុងការអង្កេតនូវរាល់ការអនុវត្តន៍ច្បាប់ និងដោះស្រាយវិវាទដែលពាក់ព័ន្ធដីធ្លី និងសំណង់
- គ្រប់គ្រងបណ្ណាល័យសំរាប់ក្រសួង ។

នាយកដ្ឋាននីតិកម្មដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់ ។

**មាត្រា ១២.-**

នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការវិនិយោគ និង ទំនាក់ទំនងអន្តរជាតិ មានតួនាទី និងភារកិច្ចដូចតទៅ ៖

- រៀបចំកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច និងវិនិយោគ ស្របតាមនយោបាយរៀបចំដែនដី និងនគរូបនីយកម្ម ដោយធ្វើទំនាក់ទំនងជាមួយបណ្ដាអ្នកផ្ដល់ទុនជាប្រាក់ខ្ចី ឬជាជំនួយអន្តរជាតិ អ្នកវិនិយោគ ទុនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង ទីស្ដីការគណៈរដ្ឋមន្ត្រី
- វិភាគបណ្ដាគំរោងវិនិយោគទុន អំពីគុណភាព និងចំណុចខ្វះខាតឬភាពមិនប្រក្រតីរបស់គំរោងក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខេត្ត-ក្រុង
- តាមដានរាល់ការអនុវត្តន៍គំរោងដែលបានអនុម័តហើយ

- សំរបសំរួលជំនួយបរទេស
- ធ្វើផែនការទំនាក់ទំនងបរទេស
- ធ្វើជាសេនាធិការអោយក្រសួងក្នុងការធ្វើទំនាក់ទំនង សហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងធ្វើសហប្រតិបត្តិការអន្តរជាតិ ។

នាយកដ្ឋាននេះ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់ ។

## ជំពូកទី ៦

## អគ្គនាយកដ្ឋានរៀបចំដែនដី និង នគរូបនីយកម្ម

មាត្រា ១៣._

អគ្គនាយកដ្ឋាន រៀបចំដែនដី នគរូបនីយកម្ម មានភារកិច្ចជាសេនាធិការឲ្យក្រសួងក្នុងការងារ :

- លើកសំណើ និងអនុវត្តនយោបាយយុទ្ធសាស្ត្រ រៀបចំដែនដី និងនគរូបនីយកម្ម ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គម ប្រកបដោយគុណភាព និងចីរភាព សំដៅការពារផលប្រយោជន៍ទូទៅ និងធ្វើអោយមានសណ្តាប់ធ្នាប់សាធារណៈ សោភណភាព ការពារបរិស្ថាន ការពារធនធានធម្មជាតិ សម្បត្តិវប្បធម៌និងបេតិកភ័ណ្ឌ
- ចងក្រងពត៌មាន ទិន្នន័យ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការសិក្សាវិភាគសំរាប់អនាគត រៀបចំកសាងគោលនយោបាយ ផែនការ កម្មវិធី នីតិវិធី ច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋាន ស្តង់ដារ និងវិធានការដែលទាក់ទងនឹងការរៀបចំដែនដី និងនគរូបនីយកម្ម
- ណែនាំ តាមដាន ត្រួតពិនិត្យ និងជំរុញការអនុវត្តន៍នយោបាយរៀបចំដែនដី និងនគរូបនីកម្ម ឲ្យបានសមស្របទូទាំងប្រទេស
- ពិនិត្យគំរោងស្នើសុំទីតាំងសាងសង់
- លើកផែនការបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់បុគ្គលិកក្រសួង និងបណ្តាមន្ទីរខេត្ត-ក្រុង
- សហការជាមួយអង្គការអន្តរជាតិ និងអង្គការនានា ។

-អគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្មដឹកនាំដោយអគ្គនាយកមួយរូប និងមានអគ្គនាយករងជាជំនួយការតាមការចាំបាច់ ។ អគ្គនាយកដ្ឋាននេះមាននាយកដ្ឋានចំណុះចំនួន ៣ ដូចតទៅ ៖

- នាយកដ្ឋាន ស្រាវជ្រាវ និងបទប្បញ្ញត្តិ
- នាយកដ្ឋាន រៀបចំដែនដី
- នាយកដ្ឋាន នគរូបនីយកម្ម

**មាត្រា ១៤.-**

នាយកដ្ឋានស្រាវជ្រាវ និង បទប្បញ្ញត្តិ មានតួនាទី និងភារកិច្ចដូចតទៅ :

- ធ្វើទំនាក់ទំនង សហការជាមួយក្រសួង-ស្ថាប័ន និងអង្គភាពខេត្ត-ក្រុង ដើម្បីស្រាវជ្រាវ ប្រមូលពត៌មាន ស្ថិតិ ទិន្នន័យ សំរាប់ជាមូលដ្ឋានក្នុងការតាក់តែងច្បាប់ស្តីពីការគ្រប់គ្រង ប្រើប្រាស់ដីធ្លី អស្សាមិករណ៍ កំណត់ដីបំរុង និងធ្វើសេចក្តីណែនាំតាក់តែង បទប្បញ្ញត្តិ លិខិតបទដ្ឋាន ដែលទាក់ទងនឹង ការរៀបចំដែនដី និងនគរូបនីយកម្ម
- ត្រួតពិនិត្យផលប៉ះពាល់អេកូឡូស៊ីនៃការរៀបចំដែនដី និងនគរូបនីយកម្ម ដែលបណ្តាលមកពី គំរោងវិនិយោគក្នុង និងក្រៅប្រទេស
- កំណត់លក្ខណៈវិនិច្ឆ័យចំពោះ និងរបៀបរៀបចំអាជីវកម្មនៃគំរោងអភិវឌ្ឍន៍ ដែលប្រើប្រាស់ ហិរញ្ញវត្ថុជាតិ អន្តរជាតិ រដ្ឋ និងឯកជន ។

នាយកដ្ឋានស្រាវជ្រាវ និងបញ្ញត្តិដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជា ជំនួយការតាមការចាំបាច់ ។

**មាត្រា ១៥.-**

នាយកដ្ឋានរៀបចំដែនដី មានតួនាទី និងភារកិច្ចដូចតទៅ :

- រៀបចំគោលនយោបាយ ផែនការ និងកម្មវិធីរៀបចំដែនដី តាមការប្រើប្រាស់ធនធានធម្មជាតិឲ្យបានសមស្របប្រកបដោយតុល្យភាព និងចីរភាព
- រៀបចំឯកសារបច្ចេកទេសសំរាប់ប្រជុំអន្តរក្រសួង
- ធ្វើសេនាធិការជូនក្រសួងក្នុងការកសាងនីតិវិធី សំរាប់ធ្វើគំរោងថ្នាក់ជាតិ គំរោងតាមវិស័យ គំរោងថ្នាក់តំបន់ និងថ្នាក់ខេត្ត-ក្រុង
- ធ្វើវិភាគសំរាប់អនាគត និងកសាងទំរង់គំរោង ផែនការ កម្មវិធី ក្នុងការរៀបចំ កែលំអ បណ្តាញហេដ្ឋារចនាសម្ព័ន្ធកំរិតជាតិ ដើម្បីអភិវឌ្ឍន៍ដោយសហការជាមួយក្រសួង ស្ថាប័ន ពាក់ព័ន្ធ ក្នុងការកំណត់បណ្តាញគមនាគមន៍ ប្រព័ន្ធធារាសាស្ត្រ អាងទឹក កំពង់ផែ អាកាសយានដ្ឋាន និងកំណត់ការរៀបចំដែនដី ចែកជាតំបន់សកម្មភាពផ្សេងៗ ដូចជា : តំបន់ ឧស្សាហកម្ម កសិកម្ម ពាណិជ្ជកម្ម លំនៅដ្ឋាន ទេសចរណ៍ និងតំបន់ធម្មជាតិដូចជា : ព្រៃ ភ្នំ បឹង ជ្រោះ ទន្លេ សមុទ្រ ឆ្នេរសមុទ្រ តំបន់រក្សាទុកជាដើម
- តាមដានការអនុវត្តន៍ការងាររបស់បណ្តាក្រសួង និងអាជ្ញាធរដែនដីខេត្ត-ក្រុង ទាក់ទងនឹង ការរៀបចំដែនដីឲ្យស្របតាមអាទិភាពដែលបានកំណត់ក្នុងក្របខ័ណ្ឌគោលនយោបាយ រៀបចំដែនដី
- តាមដានកត់ត្រាជាប្រចាំរាល់ទិន្នន័យសេដ្ឋកិច្ចសង្គមនៃគំរោងផែនទីជាតិ ។

នាយកដ្ឋានរៀបចំដែនដី ដឹកនាំដោយប្រធាននាយកដ្ឋាន និងមានអនុប្រធានជាជំនួយការតាមការចាំបាច់ ។

**មាត្រា ១៦.-**

នាយកដ្ឋាននគរូបនីយកម្ម មានតួនាទី និងភារកិច្ចដូចតទៅ ៖

- លើកគំរោងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាន ស្តីពីនគរូបនីយកម្ម

អនុវត្តគោលនយោបាយនគរូបនីយកម្ម ដើម្បីអភិវឌ្ឍទីក្រុង ទីប្រជុំជន ជនបទ និងតំបន់ផ្សេងៗ ស្របតាមតម្រូវការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម វប្បធម៌ ប្រវត្តិសាស្ត្រ សុវត្ថិភាព និង គុណភាពបរិស្ថាន

- សិក្សារៀបចំប្លង់មេ និងប្លង់គោលដៅ ដោយពិចារណាលើលក្ខណៈទីក្រុង ជាតំបន់សំរាប់ប្រើប្រាស់ដីក្នុងការរៀបចំទីតាំង សម្រាប់ អគារ ទីលំនៅដ្ឋាន ការងារ តំបន់ឧស្សាហកម្ម ពាណិជ្ជកម្ម តំបន់ការពារ តំបន់បៃតង ទីសាធារណៈ តំបន់ប្រវត្តិសាស្ត្រ វប្បធម៌ ធម្មជាតិ ទេសចរណ៍ និងតំបន់សេវាសាធារណៈជាដើម

- ចូលរួមការពារសម្បត្តិបេតិកភណ្ឌ ប្រវត្តិសាស្ត្រ និងវប្បធម៌ ប្រព័ន្ធអេកូឡូស៊ី និងធនធានធម្មជាតិ ប្រព័ន្ធធារាសាស្ត្រ សួនច្បារ សួនកុមារ ព្រៃឈើ ឬតំបន់ធម្មជាតិ និងតំបន់ផ្សេងៗទៀតដែលត្រូវការការពារក្នុងទីក្រុង

- រៀបចំកែលម្អគុណភាពទីក្រុង និងតំបន់ថ្មីក្នុងទីក្រុង

- រៀបចំគំរោងបង្កើតទីក្រុងថ្មី និងតំបន់អភិវឌ្ឍន៍សេដ្ឋកិច្ចថ្មី

- តាមដានកំណើន វិភាគបម្រែបម្រួល សេដ្ឋកិច្ច សង្គម សមត្ថភាពផ្គត់ផ្គង់ ដឹកជញ្ជូន ស្ថិតិដំឡើងផលិតកម្ម កំណើនប្រជាជន និងកត្តាផ្សេងទៀត ដែលមានឥទ្ធិពលទៅលើការអភិវឌ្ឍន៍ទីក្រុង ។

- ពិនិត្យ និងផ្តល់យោបល់លើគំរោងសាងសង់

- ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយនគរូបនីយកម្មឲ្យមានប្រសិទ្ធភាព ។

នាយកដ្ឋាននគរូបនីយកម្ម ដឹកនាំដោយប្រធាននាយកដ្ឋាន និងមានអនុប្រធានជាជំនួយការតាមការចាំបាច់ ។

## ជំពូកទី ៧

## អគ្គនាយកដ្ឋានសំណង់

**មាត្រា ១៧.-**

អគ្គនាយកដ្ឋានសំណង់ មានភារកិច្ចជាសេនាធិការឲ្យក្រសួងក្នុងការងារ ៖

- លើកស្ទួយនិងរៀនស្ថាបត្យកម្មក្នុងវិស័យសំណង់ឲ្យមានលក្ខណៈជាតិ និងទំនើបទាន់សម័យ

- ស្រាវជ្រាវ រៀបចំ បទប្បញ្ញត្តិ ទំរង់បែបបទ ក្បួនខ្នាត លក្ខណៈវិនិច្ឆ័យបច្ចេកទេស បច្ចេកវិទ្យា បទដ្ឋានបច្ចេកទេសផ្នែកសំណង់ និងស្ថាបត្យកម្ម រួមទាំងស្តង់ដារសំភារៈបរិក្ខារសំណង់ឲ្យបានឯកភាព
- តម្រង់ទិស ណែនាំ តាមដាន ត្រួតពិនិត្យការសាងសង់ ការជួសជុល ការថែទាំ ការរុះរើរាល់បណ្តាំរោងសំណង់អគាររបស់រដ្ឋ ឯកជន អង្គការនានា រួមទាំងសំណង់បេតិកភ័ណ្ឌ និងសំណង់ផ្សេងៗទៀត ។ សំណង់ផ្សេងៗទៀតនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង ។
- គ្រប់គ្រង ពិនិត្យ កំណត់សមត្ថភាពបច្ចេកវិជ្ជាជីវៈ និងចេញលិខិតអនុញ្ញាតអាជីវកម្មដល់រូបវន្តបុគ្គល និងនីតិបុគ្គល ដែលធ្វើអាជីវកម្មទាក់ទងនឹងការសាងសង់ និងការសិក្សាគំរោងប្លង់
- ត្រួតពិនិត្យ និងដាក់ឲ្យធ្វើការពិសោធន៍ សំភារៈសំណង់
- កំណត់ស្តង់ដារ គុណភាព សំភារៈ បរិក្ខារសំណង់ ដែលនាំចូលមកពីបរទេស និងផលិតក្នុងប្រទេស
- លើកផែនការបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់បុគ្គលិកក្រសួង និងមន្ទីរខេត្ត-ក្រុង និងធ្វើទំនាក់ទំនង ណែនាំបច្ចេកទេសដល់បណ្តាគ្រឹះស្ថានបណ្តុះបណ្តាលមុខវិជ្ជាសំណង់ និងស្ថាបត្យកម្ម
- សំរបសំរួលជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីត្រួតពិនិត្យបណ្តាគំរោងវិនិយោគសំណង់ ។

អគ្គនាយកដ្ឋានសំណង់ដឹកនាំដោយអគ្គនាយកមួយរូប និងមានអគ្គនាយករងជាជំនួយការតាមការចាំបាច់ ។ អគ្គនាយកដ្ឋានសំណង់មាននាយកដ្ឋានចំណុះចំនួន ៣ :

- នាយកដ្ឋាន ស្រាវជ្រាវបច្ចេកទេសសំណង់
- នាយកដ្ឋាន សិក្សាគំរោងប្លង់
- នាយកដ្ឋាន សំណង់

មាត្រា ១៨._

នាយកដ្ឋានស្រាវជ្រាវបច្ចេកទេស និងសំណង់ មានតួនាទី និងភារកិច្ច ដូចតទៅ :

- ស្រាវជ្រាវ កសាង បទបញ្ញត្តិ ទំរង់បែបបទ ក្បួនខ្នាត លក្ខណៈវិនិច្ឆ័យបច្ចេកទេស បច្ចេកវិទ្យា បទដ្ឋានបច្ចេកទេសផ្នែកសំណង់ និងស្ថាបត្យកម្ម រួមទាំងសំភារៈ បរិក្ខារសំណង់
- កំណត់ស្តង់ដារ ប្រភេទ សំភារៈ បរិក្ខារសំណង់ និងលក្ខណៈវិនិច្ឆ័យបច្ចេកទេស គុណភាពការងារសំណង់ និងចូលរួមផ្តល់យោបល់អំពីគុណភាពសំណង់ តំរូវការគុណភាពសំភារៈបរិក្ខារគ្រឿងចក្រសំណង់ ដែលនាំចូលពីបរទេសតាមការផ្លាស់ប្តូរពាណិជ្ជកម្ម និងផលិត-ផលក្នុងស្រុក

- តាមដានបណ្ដាញទីផ្សារនៃសម្ភារៈសំណង់ គ្រឿងចក្រសំណង់ និងពលកម្ម ដែលប្រែប្រួលតាមខេត្ត-ក្រុង និងតាមដានជាប្រចាំនូវការប្រែប្រួលថ្លៃនៅតាមទីផ្សារទាំងនោះ
- ត្រួតពិនិត្យ និងដាក់ឲ្យធ្វើការពិសោធន៍សម្ភារៈសំណង់ គ្រឿងផ្គុំសំណង់ ដី ព្រមទាំងស្រាវជ្រាវបង្កើតមុខសម្ភារៈសំណង់ថ្មីៗ ដោយប្រើប្រាស់វត្ថុធាតុដើមក្នុងប្រទេសបំពេញឲ្យលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ ។ ស្រាវជ្រាវជាប្រចាំមុខសម្ភារៈផលិតចេញថ្មីៗ គ្រឿងចក្រ បរិក្ខារបំពេញការងារសាងសង់ទំនើបៗ លើទីផ្សារជាតិ និងអន្តរជាតិ
- សហការជាមួយនាយកដ្ឋានបុគ្គលិក និងមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្នុងការបណ្ដុះបណ្ដាលជំនាញបច្ចេកទេសដល់បុគ្គលិកក្រសួង និងបណ្ដាមន្ទីរខេត្ត-ក្រុង ។ ចាត់ចែងអប់រំផ្សព្វផ្សាយឯកសារបច្ចេកទេសសំណង់ដល់គ្រប់មូលដ្ឋាន ដើម្បីលើកស្ទួយប្រសិទ្ធភាពសេដ្ឋកិច្ច សុវត្ថិភាព និងសុខុមាលភាពសាធារណៈ ព្រមទាំងណែនាំបច្ចេកទេសដល់បណ្ដាគ្រឹះស្ថានបណ្ដុះបណ្ដាលមុខវិជ្ជាសំណង់ និងស្ថាបត្យកម្ម ។

នាយកដ្ឋាននេះដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់ ។

មាត្រា ១៩._

នាយកដ្ឋានសិក្សាគំរោងប្លង់ មានតួនាទី និងភារកិច្ច ដូចតទៅ :

- សិក្សាគំរោងប្លង់សាងសង់ថ្មី ជួសជុល កែលំអពង្រីកលើកទួលឡើងអគាររបស់បណ្ដាក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីខេត្ត-ក្រុង ដែលប្រើប្រាស់ថវិការបស់រដ្ឋ ឯកជន អង្គការនានា អ្នកវិនិយោគទុនក្នុងប្រទេស ឬក្រៅប្រទេស និងអង្គការអន្តរជាតិ ។ សិក្សា ស្រាវជ្រាវធ្វើគំរោងប្លង់ ដែលចែកចេញជាផ្នែកឯកសារបច្ចេកទេស ស្ថាបត្យកម្ម និងផ្នែកគំនូរប្លង់
- សិក្សាស្រាវជ្រាវគំរោងប្លង់ និងធ្វើបញ្ជីប៉ាន់ស្មានសម្ភារៈនៃគំរោងសំណង់សាធារណៈ
- ត្រួតពិនិត្យគំរោងប្លង់ស្ថាបត្យកម្ម និងបច្ចេកទេសសំណង់អគារ
- ត្រួតពិនិត្យសៀវភៅបន្ទុកនៃការដ្ឋានសាងសង់
- ត្រួតពិនិត្យបណ្ដាគំរោងប្លង់អ្នកវិនិយោគនានា អំពីតម្រូវការពិតនៃសម្ភារៈសំណង់នាំចូលជារូបិយប័ណ្ណ
- គ្រប់គ្រង ត្រួតពិនិត្យ និងកំណត់សមត្ថភាពបច្ចេកទេស និងចេញលិខិតអនុញ្ញាតបើកអាជីវកម្មដល់រូបវន្តបុគ្គល និងនីតិបុគ្គល ដែលធ្វើអាជីវកម្មទាក់ទងនឹងការសិក្សាធ្វើគំរោងប្លង់ និងការសាងសង់ ។

នាយកដ្ឋានសិក្សាគំរោងប្លង់ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់ ។

**មាត្រា ២០.-**

នាយកដ្ឋានសំណង់ មានតួនាទី និងភារកិច្ច ដូចតទៅ :

- ដឹកនាំ តាមដាន ត្រួតពិនិត្យរាល់ការងារបច្ចេកទេសក្នុងការសាងសង់ រុះរើ តាមគំរោងការនីមួយៗ ដើម្បីធានាសុវត្ថិភាព សម្របទៅតាមសាធារណៈ គុណភាពសំណង់
- ចេញលិខិតអនុញ្ញាតបើក និងបិទការដ្ឋានរបស់បណ្តាសហគ្រាស ក្រុមហ៊ុន អង្គភាពសាងសង់នានា
- ចូលរួមធ្វើកោសល្យវិច័យនានា ផ្តល់សំណើលើបច្ចេកទេសដល់ស្ថាប័នមានសមត្ថកិច្ច ក្នុងការដោះស្រាយបញ្ហាសាងសង់ រុះរើ ជួសជុល និង ការពិសោធសម្ភារផ្សេងទៀត ដែលទាក់ទងនឹងបទដ្ឋានបច្ចេកទេស
- សិក្សាស្រាវជ្រាវបច្ចេកទេសសាងសង់ទំនើប រឹងមាំ មានប្រសិទ្ធភាព ចំណេញ និងធានាស្តង់ដារ ដែលកំពុងត្រូវប្រើប្រាស់នៅប្រទេសនានា ពិសេសនៅបណ្តាប្រទេស អាស៊ាន
- ស្រាវជ្រាវបទប្បញ្ញត្តិ គោលការណ៍ទាក់ទងក្នុងការជួសជុលថែទាំ ប្រើប្រាស់ សំណង់អគារសាធារណៈ និងបេតិកភ័ណ្ឌ
- ចាត់ចែងកម្មវិធី និងគំរោងផែនការជួសជុល ថែទាំផ្សេងៗ ព្រមទាំងតាមដានពិនិត្យលើបច្ចេកទេសសំណង់តាមកិច្ចសន្យា
- គ្រប់គ្រងស្ថិតិ វិភាគទិន្នន័យសេដ្ឋកិច្ច និងវប្បធម៌ ក្នុងការប្រើប្រាស់អគារសាធារណៈ និង បេតិកភ័ណ្ឌ
- ដឹកនាំត្រួតពិនិត្យរាល់ការងារបច្ចេកទេសក្នុងការជួសជុល កែលម្អ ដើម្បីធានាសុវត្ថិភាព សម្របទៅតាមសាធារណៈ ប្រសិទ្ធភាពសេដ្ឋកិច្ច សោភ័ណភាព គុណភាព សំណង់នៃគ្រប់បណ្តាសំណង់សាធារណៈ និងគ្រប់បណ្តាសំណង់បេតិកភ័ណ្ឌ ។

នាយកដ្ឋានសំណង់ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការ តាមការចាំបាច់ ។

## ជំពូកទី ៨

## អគ្គនាយកដ្ឋានឧតុនិយម និង ជលសាស្ត្រ

**មាត្រា ២១.-** អគ្គនាយកដ្ឋានឧតុនិយម និងជលសាស្ត្រ មានភារកិច្ចជាសេនាធិការឲ្យក្រសួងក្នុងការងារ :

- ជាសេនាធិការរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ លើកិច្ចការសុរិយោដី និងភូមិសាស្ត្រ
- សិក្សាស្រាវជ្រាវ រៀបចំគោលនយោបាយ និងបទដ្ឋានទាំងឡាយដែលពាក់ព័ន្ធនឹងការងារ គ្រប់គ្រង និងប្រើប្រាស់ដីធ្លី
- រៀបចំទិសដៅ និងផែនការ ដើម្បីអភិវឌ្ឍការងារលើវិស័យសុរិយោដី និងភូមិសាស្ត្រ
- ធ្វើការវាស់វែង និងគូរផែនទីសុរិយោដី
- ចេញប័ណ្ណសំគាល់សិទ្ធិដីធ្លីទូទាំងព្រះរាជាណាចក្រកម្ពុជា
- ធ្វើការងារអភិរក្សសុរិយោដី និង ធ្វើអធិការកិច្ចក្នុងតួនាទីភារកិច្ច និងសកម្មកិច្ច របស់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ
- កំណត់ព្រំប្រទល់ក្បាលដី
- អភិរក្សបញ្ជីសម្បត្តិរដ្ឋ
- សហការជាមួយនាយកដ្ឋានបុគ្គលិក និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការបណ្តុះបណ្តាលបច្ចេកទេស និងមុខជំនាញដល់មន្ត្រីរាជការក្រោមឱវាទ
- ធ្វើជាសេនាធិការឲ្យក្រសួងក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ និងបណ្តាប្រទេសនានាលើផ្នែកបច្ចេកទេស វិទ្យាសាស្ត្រលើវិស័យសុរិយោដីនិងភូមិសាស្ត្រ
- សហការជាមួយក្រសួង និងស្ថាប័ននានា ក្នុងការគ្រប់គ្រងនិងប្រើប្រាស់ដីធ្លី ។

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រដឹកនាំដោយអគ្គនាយកម្នាក់ និងមានអគ្គនាយករងជាជំនួយការតាមការចាំបាច់ ។ អគ្គនាយកដ្ឋាននេះមាននាយកដ្ឋានចំណុះចំនួន៥ គឺ :

- នាយកដ្ឋាន គ្រប់គ្រងដីធ្លី
- នាយកដ្ឋាន អធិការកិច្ចភូមិបាល
- នាយកដ្ឋាន បច្ចេកទេស
- នាយកដ្ឋាន អភិរក្សសុរិយោដី
- នាយកដ្ឋាន ភូមិសាស្ត្រ ។

មាត្រា ២២.-

នាយកដ្ឋានគ្រប់គ្រងដីធ្លី មានតួនាទី និងភារកិច្ច ដូចតទៅ :

- សិក្សាស្រាវជ្រាវច្បាប់ លិខិតបទដ្ឋាន ពាក់ព័ន្ធនឹងដីធ្លី

- ចងក្រង គោលការណ៍ វិធានការ និងការណែនាំពាក់ព័ន្ធនឹងការងារសុរិយោដី
- កសាងផែនការ និងកម្មវិធីការងារសុរិយោដី
- លើកគំរោងសហប្រតិបត្តិការ លើវិស័យបច្ចេកទេសវិទ្យាសាស្ត្រ
- កំណត់តំណភ្ជាប់ដី និងវាយតំលៃដី
- លើកសំណើអំពីនយោបាយដីធ្លី និងរបបដីធ្លី ។

នាយកដ្ឋានគ្រប់គ្រងដីធ្លីដឹកនាំដោយប្រធានមួយរូប និង អាចមានអនុប្រធានជាជំនួយការតាមការចាំបាច់ ។

មាត្រា ២៣.-

នាយកដ្ឋានអធិការកិច្ចភូមិបាល មានតួនាទី និងភារកិច្ច ដូចតទៅ :

- ត្រួតពិនិត្យការអនុវត្តន៍ច្បាប់ គោលការណ៍ ការណែនាំ តាមបណ្តាអង្គភាពចំណុះ អគ្គនាយកដ្ឋាន
- ត្រួតពិនិត្យការងារបច្ចេកទេស ក្នុងការកំណត់វិធីសាស្ត្រវាស់វែង ការធានាការងារសុរិយោដីខេត្ត-ក្រុង និងស្រុក-ខ័ណ្ឌ
- ត្រួតពិនិត្យកាន់កាប់ឯកសារសុរិយោដី
- ត្រួតពិនិត្យការគ្រប់គ្រងហិរញ្ញវត្ថុ ។

នាយកដ្ឋានធិការកិច្ចភូមិបាល ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់ ។

មាត្រា ២៤.-

នាយកដ្ឋានអភិរក្សសុរិយោដី មានតួនាទី និងភារកិច្ច ដូចតទៅ :

- កាន់កាប់ និងគ្រប់គ្រងឯកសារសុរិយោដី
- ពិនិត្យ ផ្ទៀងផ្ទាត់ សំណុំលិខិតសញ្ញាផ្សេងៗ ពាក់ព័ន្ធនឹងអចលនវត្ថុ
- ធ្វើការអភិរក្សទ្រព្យសម្បត្តិរដ្ឋ
- ចុះបញ្ជីដីធ្លី ធ្វើលេខចារឹក និងចរន្តការ រាល់ការវិវត្តន៍អំពីលក្ខណៈរូប និង គតិយុត្តរបស់អចលនវត្ថុ
- រក្សាឯកសារ និងបណ្ណសារដ្ឋានភូមិបាល
- ផ្តល់ពត៌មានដីធ្លី

នាយកដ្ឋានអភិវឌ្ឍគម្រោងសុរិយោដីដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធាន ជាជំនួយការតាមការចាំបាច់ ។

មាត្រា ២៥.-នាយកដ្ឋានបច្ចេកទេស មានតួនាទី និងភារកិច្ច ដូចតទៅ :

- សិក្សា កំណត់វិធីសាស្ត្រវាស់វែង និងស្តង់ដារបច្ចេកទេស
- ណែនាំ បច្ចេកទេស ការងារសុរិយោដីខេត្ត-ក្រុង
- គ្រប់គ្រងបច្ចេកវិទ្យាថ្មី តាមប្រព័ន្ធសុរិយោដីទំនើប
- ធ្វើការវាស់វែង កំណត់ព្រំក្បាលដី និងគូរប្លង់ក្បាលដី
- បកស្រាយរូបថត ធ្វើអត្តសញ្ញាណក្បាលដី
- សិក្សា និងកំណត់និតិវិធី នៃការកសាងប្លង់សុរិយោដី ។

នាយកដ្ឋានបច្ចេកទេស ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់ ។

មាត្រា ២៦.-

នាយកដ្ឋានភូមិសាស្ត្រ មានតួនាទី និងភារកិច្ចដូចតទៅ :

- ចាត់តាំង អនុវត្តការកិច្ចវាស់វែង ដាំបង្គោលបណ្តាញត្រីកោណ និងគូរផែនទី គោលជាមូលដ្ឋានទូទាំងប្រទេស
- គ្រប់គ្រងផែនទីគ្រប់ប្រភេទរបស់ព្រះរាជាណាចក្រកម្ពុជា សំដៅឲ្យឯកភាពទូទាំងប្រទេស
- ចាត់តាំង ស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេសវាស់វែង ថតរូប គូរ និងបោះពុម្ព ផ្សាយផែនទីគ្រប់ប្រភេទ
- សហការជាមួយនាយកដ្ឋានបុគ្គលិក និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការបណ្តុះបណ្តាលមន្ត្រី បុគ្គលិកផ្នែកភូមិសាស្ត្រ
- ធ្វើជាសេនាធិការឲ្យគណៈកម្មការកំណត់ព្រំដែនរាជរដ្ឋាភិបាល អំពីការងារខណ្ឌព្រំសីមា និងបោះបង្គោលព្រំដែនរដ្ឋ
- ធ្វើជាសេនាធិការឲ្យរាជរដ្ឋាភិបាលក្នុងការវាស់វែង កំណត់ និងកែតម្រូវព្រំប្រទល់រដ្ឋបាលក្នុងប្រទេស
- ជាមជ្ឈមណ្ឌលប្រមូលផ្តុំពត៌មានភូមិសាស្ត្រ និងធ្វើសកម្មភាពចាត់ចែងការងារខាងវិទ្យាសាស្ត្រវាស់វែង និងផ្តល់ប្រព័ន្ធពត៌មានភូមិសាស្ត្រ

- បង្កើតប្រព័ន្ធព័ត៌មានភូមិសាស្ត្រជាតិ ឯកភាពតែមួយសំរាប់ព្រះរាជាណាចក្រកម្ពុជា
- កសាងផែនទី ជាពិសេសផែនទីគោល ផែនទីកំណត់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជា
- គ្រប់គ្រង និងត្រួតពិនិត្យ ក្នុងការបោះពុម្ព ផលិតផែនទីគ្រប់ប្រភេទសំរាប់ធ្វើអាជីវកម្ម ។

នាយកដ្ឋានភូមិសាស្ត្រដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានជាជំនួយការតាមការចាំបាច់ ។

## ជំពូកទី ៩
## មន្ទីរពិសោធន៍

**មាត្រា ២៧.-**

មន្ទីរពិសោធន៍ មានតួនាទី និងភារកិច្ចដូចតទៅ :

- ត្រួតពិនិត្យ និងទទួលពិសោធន៍រាល់បញ្ហាសំភារៈសំណង់ គ្រឿងចក្រសំណង់ និងភូគព្ភសាស្ត្រ ពីតាំងការងាររបស់ក្រសួង និងអតិថិជន
- ស្រាវជ្រាវ បង្កើតសំភារៈសំណង់ដែលប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក
- ធ្វើរបាយការណ៍បច្ចេកទេសអំពីលទ្ធផលនៃការពិសោធន៍
- ណែនាំនិងត្រួតពិនិត្យកិច្ចការបច្ចេកទេសពិសោធន៍សំរាប់គ្រប់មន្ទីរពិសោធន៍ឯកជន ។

មន្ទីរពិសោធន៍ដឹកនាំដោយប្រធានមួយរូបថ្នាក់ស្មើប្រធាននាយកដ្ឋាន និងមានអនុប្រធាន ជាជំនួយការតាមការចាំបាច់ ។

## ជំពូកទី ១០
## មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ

**មាត្រា ២៨.-** មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ មានភារកិច្ចជាសេនាធិការ ឲ្យក្រសួងក្នុងការងារ :

- រៀបចំផែនការ និងកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ស្របតាមគោលនយោបាយរបស់ក្រសួង
- បណ្តុះបណ្តាលមុខជំនាញបច្ចេកទេស បច្ចេកវិទ្យាថ្មីៗ
- បង្រៀន ព័ត៌មានវិទ្យា ការគ្រប់គ្រងព័ត៌មានតាមប្រព័ន្ធកុំព្យូទ័រទៅតាមមុខជំនាញរបស់ក្រសួង
- ធ្វើវិក្រឹតការ និងសក្រឹតការចំពោះមន្ត្រីរាជការរបស់ក្រសួង
- ផ្សព្វផ្សាយ អប់រំ ណែនាំ អំពីនយោបាយ ច្បាប់ បទប្បញ្ញត្តិ និងបច្ចេកទេស ពាក់ព័ន្ធនឹងការងារ រៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និង ភូមិសាស្ត្រ

- សហការជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំ ត្រួតពិនិត្យការងារបណ្តុះបណ្តាល បច្ចេកទេសវិជ្ជាជីវៈ នៅគ្រប់កម្រិត ពាក់ព័ន្ធនឹងការងាររៀបចំ ដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រ
- ធ្វើជាសេនាធិការ ឱ្យក្រសួងក្នុងការធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល សហគមន៍មូលដ្ឋាន និងបណ្តាប្រទេសនានា ។

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដឹកនាំដោយប្រធានមួយរូប ដែលមានឋានៈស្មើប្រធាននាយកដ្ឋាន និងមានអនុប្រធានជាជំនួយការតាមការចាំបាច់ ។

## ជំពូកទី ១១

## គ្រឹះស្ថាន និង សហគ្រាសក្រោមឱវាទ

**មាត្រា ២៩.-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ មានគ្រឹះស្ថាន និងសហគ្រាសក្រោមឱវាទដូច ខាងក្រោម :

- សហគ្រាសសំណង់ភ្នំពេញ
- សហគ្រាសគ្រឿងចក្រសំណង់ជួសជុល
- សហគ្រាសសិក្សាស្រាវជ្រាវគូរប្លង់
- សហគ្រាសសំណង់កំពង់ចាម
- សហគ្រាសសំភារៈដឹកជញ្ជូន
- រោងចក្រឥដ្ឋពណ៌
- រោងចក្រអារឈើ
- រោងចក្រឡឥដ្ឋ
- រោងចក្រប៊្លុកស៊ីម៉ង់ត៍

សហគ្រាសទាំងនេះស្ថិតនៅក្នុងបញ្ជីការពើភ័ណ្ឌរបស់ក្រសួង និងក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានផែនការ សេដ្ឋកិច្ចនិងហិរញ្ញកិច្ច ។

## ជំពូកទី ១២

## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា ៣០.-** អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមក្របខ័ណ្ឌនៃបទបញ្ញត្តិក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុង បណ្តាក្រសួង ។

## ជំពូកទី ១៣

## អង្គភាពមូលដ្ឋាន

មាត្រា ៣១.-

នៅតាមខេត្ត-ក្រុងនីមួយៗមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិសាស្ត្រ និងនៅតាមខ័ណ្ឌ ស្រុក នីមួយៗ មានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ដែលទទួលបន្ទុកអនុវត្ត និង សំរបសំរួលសកម្មភាពការងាររបស់ក្រសួង ។

## ជំពូកទី ១៤

## អវសានប្បញ្ញត្តិ

មាត្រា ៣២.-

ការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងនៅរដ្ឋបាលថ្នាក់កណ្ដាល ពាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

មាត្រា ៣៣.-

ភារកិច្ចទាំងឡាយណាដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ស្ថាប័នដទៃ ប្រធានស្ថាប័ន នៃស្ថាប័នដទៃទាំងនោះ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ត្រូវសហការគ្នា ដើម្បីបែងចែកការងារទទួលខុសត្រូវ និងអនុវត្តការងារទាំងនោះ តាមរយៈប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងប្រធានស្ថាប័នទាំងនោះ ។

មាត្រា ៣៤.- បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣៥.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការទាំងអស់ដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៣៦.- អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានជំរាបជូន

សម្ដេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ហត្ថលេខា

**អ៊ឹម ឈុនលឹម**

អង្គការលេខ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់



# ឧបសម្ព័ន្ធទី ២

# ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣

# ព្រះរាជក្រម

នស/រកម/០៣០៣/០០៩

អគ្គលេខាធិការដ្ឋាន (ព្រឹទ្ធសភា)
លេខ ៣៤០
ថ្ងៃទី ០២.០៣.២០០៣

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាល ទី ២ ហើយដែលព្រឹទ្ធសភាបានយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៣ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុង ដូចតទៅ :

**មាត្រាថែមមួយ .-**

ត្រូវបានកែប្រែមាត្រា ១, មាត្រា ២, មាត្រា ៦, មាត្រា ៧, មាត្រា ៨, មាត្រា ១០, មាត្រា ១២, មាត្រា ១៤, មាត្រា ១៥, មាត្រា ១៦, មាត្រា ១៨, មាត្រា ២០, មាត្រា ២១, មាត្រា ២២, មាត្រា ២៣ ជំពូកទី ៩ មាត្រា ២៤ និងជំពូកទី ១០ មាត្រា ២៥ មាត្រា ២៦ និងមាត្រា ២៧ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដូចតទៅ :

**មាត្រា ១.-ថ្មី**

ច្បាប់នេះមានវិសាលភាពចំពោះរាល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងកំណត់នីតិវិធីនៃការបង្កើតគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលធ្វើឡើងដោយបុគ្គលណាមួយ ។

មានតែគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទេ ដែលមានសិទ្ធិទទួលបាននូវផលប្រយោជន៍ដែលស្ថិតក្នុងក្របខ័ណ្ឌនៃច្បាប់នេះ ។

**មាត្រា ២.-ថ្មី**

ក្នុងន័យនៃច្បាប់នេះ វាក្យសព្ទដូចខាងក្រោម :

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់** ហៅកាត់ **គ.ល.គ** មានន័យថា គម្រោងវិនិយោគដែលទទួលបានវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញ** មានន័យថា ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលផលិតផលរបស់គម្រោងត្រូវបាននាំចេញ ដែលនឹងកំណត់ដោយអនុក្រឹត្យ

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាប្រភេទឧស្សាហកម្មគាំទ្រ** មានន័យថា គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលផលិតផលរបស់ខ្លួន ១០០% (មួយរយភាគរយ) ត្រូវផ្គត់ផ្គង់ដល់ឧស្សាហកម្មនាំចេញជិនូវវត្ថុធាតុដើម ឬសម្ភារៈបន្ទាប់បន្សំដែលតែងតែនាំចូល

**ថ្ងៃធ្វើការ** មានន័យថា ថ្ងៃប្រតិទិនដែលជាថ្ងៃធ្វើការជាផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជា

**នីតិបុគ្គលសញ្ជាតិខ្មែរ** មានន័យថា ក្រុមហ៊ុនដែលមានទីកន្លែងធ្វើអាជីវកម្ម និងដែលបានធ្វើការចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជានិងភាគហ៊ុន ៥១%(ហាសិបមួយភាគរយ) ឬលើសក្នុងក្រុមហ៊ុន ត្រូវបានកាន់កាប់ដោយបុគ្គលមានសញ្ជាតិជាខ្មែរ

**បុគ្គល** មានន័យថា រូបវន្តបុគ្គល ឬនីតិបុគ្គល

**វិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌ** មានន័យថា ឯកសារដែលចេញដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដូចមានចែងក្នុងកថាខណ្ឌ ៣ មាត្រា ៧ ថ្មី នៃច្បាប់នេះ

**វិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ** មានន័យថា ឯកសារដែលចេញដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដូចមានចែងក្នុងកថាខណ្ឌ ៧ មាត្រា ៧ ថ្មី នៃច្បាប់នេះ

**សំណើវិនិយោគ** មានន័យថា សំណើដែលបានដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដោយបុគ្គលណាមួយក្នុងគោលបំណងបង្កើតគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

**អ្នកដាក់ពាក្យសុំ** មានន័យថា បុគ្គលឬក្រុមបុគ្គលដែលដាក់សំណើវិនិយោគនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**អ្នកវិនិយោគ** មានន័យថា បុគ្គលដែលអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

## មាត្រា ៦.–ថ្មី

រាល់បុគ្គលដែលមានបំណងបង្កើតគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវដាក់សំណើវិនិយោគនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាតាមទម្រង់និងតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់នេះនិងអនុក្រឹត្យ ។

## មាត្រា ៧.–ថ្មី

ក្នុងរយៈពេល ០៣(បី)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាទទួលបានសំណើវិនិយោគ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញវិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌឬលិខិតបដិសេធទៅឱ្យអ្នកស្នើសុំ ។

ប្រសិនបើសំណើវិនិយោគផ្ដល់ជូននូវពត៌មានទាំងអស់ដែលតម្រូវដោយអនុក្រឹត្យ និងប្រសិនបើសកម្មភាពដែលបានស្នើសុំពុំមានបញ្ជាក់នៅក្នុងបញ្ជីគម្រោងហាមឃាត់ដែលមានចែងនៅក្នុងអនុក្រឹត្យទេនោះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ។ ផ្ទុយទៅវិញ បើសំណើវិនិយោគនោះពុំឆ្លើយតបតាមលក្ខខណ្ឌខាងលើនោះទេ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញលិខិតបដិសេធជូនទៅអ្នកស្នើសុំ ។

វិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ពីការយល់ព្រម ការអនុញ្ញាត ការជិះបញ្ជី អាជ្ញាប័ណ្ណ លិខិតអនុញ្ញាតឬបញ្ជិកានានា ដែលត្រូវជាតម្រូវការសម្រាប់ដំណើរការគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់រួមទាំងបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលដែលទទួលបន្ទុកក្នុងការចេញលិខិតយល់ព្រមការជិះបញ្ជី អាជ្ញាប័ណ្ណលិខិតអនុញ្ញាតឬបញ្ជិកាទាំងនោះផង ។ វិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌត្រូវបញ្ជាក់ផងដែរនូវការលើកទឹកចិត្តនានា ដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានសិទ្ធិទទួល ដូចមានចែងក្នុងមាត្រា ១៤ ថ្មី នៃច្បាប់នេះ និងការទទួលស្គាល់លើលក្ខន្តិកៈនៃនីតិបុគ្គលដែលជាអ្នកអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

ប្រសិនបើក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាខកខានពុំបានចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌឬលិខិតបដិសេធក្នុងរយៈពេល ៣ថ្ងៃ(បី) នៃថ្ងៃធ្វើការទេ វិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌត្រូវបានចាត់ទុកថា បានយល់ព្រមដោយស្វ័យប្រវត្តិ តាមទម្រង់ដូចមានកំណត់ដោយអនុក្រឹត្យ ។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវទទួលយកនូវអាជ្ញាប័ណ្ណទាំងអស់ពីក្រសួងស្ថាប័នពាក់ព័ន្ធ ដូចមានចែងក្នុងវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ជំនួសមុខឱ្យអ្នកស្នើសុំ ។

រាល់ស្ថាប័នមានសមត្ថកិច្ចរបស់រដ្ឋាភិបាលដែលទទួលបន្ទុកចេញលិខិតអនុញ្ញាតការជិះបញ្ជី អាជ្ញាប័ណ្ណ លិខិតយល់ព្រមឬបញ្ជិកាដែលមានរាយបញ្ជាក់នៅក្នុងវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ត្រូវចេញឯកសារទាំងនេះ យ៉ាងយូរបំផុតអោយបានមុន ២៨ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទនៃវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ។

មន្ត្រីរាជការណាមួយដែលខកខានពុំបានឆ្លើយតបទៅនឹងពាក្យស្នើសុំដោយគ្មានមូលហេតុត្រឹមត្រូវតាមកាលកំណត់ ត្រូវផ្តន្ទាទោសតាមច្បាប់ ។

ក្នុងរយៈពេល ២៨ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ។ ការចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ មិនមែនជាការលើកលែងឱ្យគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់រួចផុតពីការទទួលនូវលិខិតអនុញ្ញាតនានាដែលក្រសួងស្ថាប័នមានសមត្ថកិច្ចបានកំណត់ឡើយ ។ ទោះបីផុតរយៈពេល ២៨ថ្ងៃ ដូចមានចែងក្នុងកថាខណ្ឌ ៦ ខាងលើក៏ដោយ រាល់ស្ថាប័នមានសមត្ថកិច្ចត្រូវតែចេញលិខិតអនុញ្ញាតតាមការកំណត់ដោយច្បាប់និងបទប្បញ្ញត្តិនានា ។ កាលបរិច្ឆេទនៃការចេញជូននូវវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរគឺជាកាលបរិច្ឆេទនៃការចាប់ផ្តើមគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

រាល់លិខិតបដិសេធត្រូវមានបញ្ជាក់មូលហេតុច្បាស់លាស់ពីការមិនអាចទទួលសំណើវិនិយោគរួមទាំងព័ត៌មានបន្ថែម ដើម្បីផ្តល់លទ្ធភាពឱ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាអាចចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌបាន ។

## មាត្រា ៨.–ថ្មី

អ្នកវិនិយោគបរទេសត្រូវបានទទួលស្គាល់និងមិនត្រូវជាកម្មវត្ថុនៃការរើសអើងដោយសារតែមូលហេតុសញ្ជាតិបរទេសទេ លើកលែងតែចំពោះដីធ្លី ដូចដែលមានចែងនៅក្នុងច្បាប់ភូមិបាល ។

## មាត្រា ១០.–ថ្មី

រាជរដ្ឋាភិបាលមិនកំណត់ថ្លៃផលិតផលឬថ្លៃសេវានានានៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នោះឡើយ ។

## មាត្រា ១២.–ថ្មី

រាជរដ្ឋាភិបាលផ្តល់ការលើកទឹកចិត្តដែលមានចែងក្នុងជំពូកនេះ ដល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

មាត្រា ១៤.–ថ្មី

ការលើកទឹកចិត្តដែលមានចែងក្នុងមាត្រា ១៣ រួមមានដូចខាងក្រោម :

១-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានសិទ្ធិទទួលការលើកលែងពន្ធលើប្រាក់ចំណេញដែលមានកំណត់ក្នុងច្បាប់ស្តីពីសារពើពន្ធ ដោយទទួលបាននូវរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ ។ រយៈពេលលើកលែងពន្ធរួមមាន : រយៈពេលគន្លឹះបូករយៈពេល ៣(បី)ឆ្នាំបូករយៈពេលអាទិភាព ។ រយៈពេលអាទិភាពនឹងត្រូវកំណត់ក្នុងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ។ រយៈពេលគន្លឹះជាអតិបរមាគឺជាឆ្នាំទី ១ ដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបានប្រាក់ចំណេញ ឬរយៈពេល ៣(បី)ឆ្នាំ បន្ទាប់ពីគម្រោងវិនិយោគនោះបានទទួលប្រាក់ចំណូលដំបូងរបស់ខ្លួនដោយជ្រើសយកជម្រើសណាមួយដែលឆាប់ជាង ។

២-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានសិទ្ធិទទួលបាននូវការលើកទឹកចិត្តផ្អែកតាមកថាខណ្ឌ ១ ខាងលើ លុះត្រាតែគម្រោងនោះទទួលបានពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានូវវិញ្ញាបនប័ត្រប្រចាំឆ្នាំបញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៣-បន្ទាប់ពីផុតរយៈពេលលើកលែងពន្ធ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវជាប់ពន្ធលើប្រាក់ចំណេញ ។

៤-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលប្រើប្រាស់សិទ្ធិទទួលបាននូវការលើកទឹកចិត្តផ្អែកតាមកថាខណ្ឌ ១ ខាងលើ ពុំមានសិទ្ធិធ្វើការទាមទារការរំលោះពិសេសណាមួយឡើយ ។

៥-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលបម្រើទីផ្សារក្នុងស្រុក មានសិទ្ធិនាំចូលដោយរួចពន្ធគយនូវគ្រឿងសម្ភារៈបរិក្ខាផលិតកម្ម សម្ភារៈសាងសង់ បម្រើផលិតកម្ម ដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៦-ក្រៅពីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញដែលជ្រើសរើសឬបានជ្រើសរើសយកឃ្លាំង ភណ្ឌាគារផលិតកម្មក្រោមការគ្រប់គ្រងរបស់គយ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញផងទៀត មានសិទ្ធិនាំចូលដោយរួចពន្ធគយនូវគ្រឿងសម្ភារៈបរិក្ខាផលិតកម្ម សម្ភារៈសាង

សង់ វត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេចនិងសម្ភារៈបន្ទាប់បន្សំបម្រើផលិត-កម្ម ដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៧-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាប្រភេទឧស្សាហកម្មគាំទ្រមានសិទ្ធិនាំចូល ដោយរួចពន្ធគយ នូវគ្រឿងសម្ភារៈបរិក្ខាផលិតកម្មសម្ភារៈសាងសង់ វត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេចនិងសម្ភារៈបន្ទាប់បន្សំបម្រើផលិតកម្មដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៨-បុគ្គលណាដែលបានទិញឬវិនិយោគដែលបានរំលាយបញ្ចូលគ្នាជាមួយអ្នកវិនិយោគណាមួយ អាចទទួលស្នងពីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយធ្វើសំណើទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានូវរាល់ការធានា សិទ្ធិ បុព្វសិទ្ធិ និងកាតព្វកិច្ចទាំងអស់ ដោយយោងទៅតាមនីតិវិធីនៃការទិញឬការរំលាយបញ្ចូលគ្នាដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៩-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលមានទីតាំងនៅក្នុងតំបន់អភិវឌ្ឍន៍ពិសេសឬតំបន់ផលិតកែច្នៃនាំចេញដែលមានក្នុងបញ្ជីអាទិភាពសម្រាប់អភិវឌ្ឍន៍ ប្រកាសដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានសិទ្ធិទទួលបាននូវការលើកទឹកចិត្តនិងបុព្វសិទ្ធិដូចគ្នានឹងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ផ្សេងៗទៀតដូចមានចែងនៅក្នុងច្បាប់នេះ ។

១០-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានសិទ្ធិទទួលបាននូវការលើកលែងពន្ធនាំចេញ ១០០%(មួយរយភាគរយ) លើកលែងតែចំពោះសកម្មភាពទាំងឡាយ ដូចមានចែងនៅក្នុងច្បាប់ជាធរមាន ។

១១-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានសិទ្ធិទទួលបាននូវទិដ្ឋាការនិងប័ណ្ណការងារ ដើម្បីធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ជនបរ-ទេសដែលធ្វើជាអ្នកគ្រប់គ្រង អ្នកបច្ចេកទេសនិងកម្មករជំនាញ រួមទាំងទិដ្ឋាការស្នាក់នៅសម្រាប់សហព័ទ្ធនិងអ្នកនៅក្នុងបន្ទុករបស់ជនបរទេសទាំងនោះ ដែលអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្របតាមច្បាប់ស្តីពីអន្តោប្រវេសន៍និងច្បាប់ស្តីពីការងារ ។

## មាត្រា ១៥.–ថ្មី

សិទ្ធិ បុព្វសិទ្ធិនិងសិទ្ធិដទៃទៀតដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បានទទួល មិនអាចផ្ទេរឬប្រគល់ជូនទៅតតិយជនណាមួយឡើយ លើកលែងតែក្នុងករណីទិញ ឬរំលាយបញ្ចូលគ្នា ដូចមានចែងនៅក្នុងកថាខណ្ឌ ៨ នៃមាត្រា ១៤ ថ្មី ។

## មាត្រា ១៦.–ថ្មី

កម្មសិទ្ធិដីធ្លីរបស់អ្នកវិនិយោគសម្រាប់មប្រើឱ្យគោលដៅអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានអនុញ្ញាតចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរ ។

អ្នកវិនិយោគអាចប្រើប្រាស់ដីធ្លីតាមរយៈដីសម្បទានឬការជួលរយៈពេលមិនកំណត់ និងការជួលរយៈពេលមានកំណត់ដែលអាចបន្តជាថ្មីបាន ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់ភូមិបាល ។

អ្នកវិនិយោគមានសិទ្ធិកាន់កាប់និងដាក់បញ្ចាំសម្រាប់ធានានិងផ្ទេរនូវចលនទ្រព្យនិងអចលនទ្រព្យដែលស្ថិតនៅលើដីនិងដីដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ប្រើប្រាស់ តាមរយៈពេលមិនលើសពីរយៈពេលដែលមានកំណត់ក្នុងកិច្ចសន្យាសម្បទានដី ឬកិច្ចសន្យាជួល ដូចដែលបានអនុញ្ញាតដោយច្បាប់ ។

ចំពោះដីសម្បទានណាដែលពុំទាន់បានដំណើរការ អ្នកវិនិយោគមិនអាចផ្ទេរឬបញ្ចាំបន្តទៀតជាដាច់ខាត ។

## មាត្រា ១៨.–ថ្មី

អ្នកវិនិយោគត្រូវបានអនុញ្ញាតឱ្យជួលនិយោជិតបរទេសតាមលក្ខខណ្ឌដូចតទៅ :

- គុណភាព សមត្ថភាពនិងជំនាញមិនអាចរកបាននៅព្រះរាជាណាចក្រកម្ពុជាក្នុងចំណោមប្រជាពលរដ្ឋខ្មែរ ។ ក្នុងករណីមានការជួលនិយោជិតប្រភេទនេះ ត្រូវផ្ញើជូនមកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានូវឯកសាររួមមាន សេចក្តីចម្លងលិខិតឆ្លងដែន សញ្ញាប័ត្រនិងប្រវត្តិរូបសង្ខេបរបស់និយោជិតនោះ

- ត្រូវមានលិខិតអះអាងពីតម្រូវការជួលនិយោជិតបរទេស ។ អ្នកវិនិ-យោគត្រូវមានការយល់ព្រម និងលិខិតអនុញ្ញាតពីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា

- មុននឹងចូលបម្រើការងារឱ្យអ្នកវិនិយោគ និយោជិតបរទេសត្រូវមានលិខិតអនុញ្ញាតឱ្យធ្វើការនៅព្រះរាជាណាចក្រកម្ពុជាពីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា ។

អ្នកវិនិយោគមានកាតព្វកិច្ចដូចតទៅ :

- ធ្វើការបណ្តុះបណ្តាលសមស្របជូននិយោជិតខ្មែរជាប្រចាំ

- ជំរុញលើកកំពស់ដល់និយោជិតខ្មែរដើម្បីអាចក្លាយទៅជាអ្នកមានតួនាទីដែលមានកម្រិតខ្ពស់ ត្រូវធ្វើជាប្រចាំ ។

## មាត្រា ២០.–ថ្មី

វិវាទដែលទាក់ទងទៅនឹងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ពាក់ព័ន្ធទៅនឹងសិទ្ធិនិងកាតព្វកិច្ចដែលមានចែងនៅក្នុងច្បាប់នេះ លើកលែងតែករណីទាក់ទងនឹងវិវាទដីធ្លី ត្រូវដោះស្រាយដោយសម្រុះសម្រួលតាមដែលអាចធ្វើទៅបាន តាមរយៈការពិគ្រោះគ្នារវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អ្នកវិនិយោគ និងភាគីណាមួយផ្សេងទៀតដែលពាក់ព័ន្ធក្នុងវិវាទ ។

ក្នុងរយៈពេលពីរខែ បន្ទាប់ពីកាលបរិច្ឆេទនៃសំណើជាលាយលក្ខណ៍អក្សរដំបូងដែលស្នើសុំធ្វើការពិគ្រោះគ្នានេះ ប្រសិនបើភាគីមានវិវាទពុំអាចដោះស្រាយតាមការសម្រុះសម្រួលគ្នាទេ ភាគីណាមួយអាចលើកយកវិវាទនោះទៅ :

- សុំការផ្សះផ្សាសម្រុះសម្រួលនៅចំពោះមុខក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬ

- សុំធ្វើមជ្ឈត្តវិនិច្ឆ័យពីក្នុង ឬក្រៅប្រទេសកម្ពុជាតាមការព្រមព្រៀងរបស់គូភាគី ឬ

សុំការជំនុំជំរះពីសាលាជំរះក្តីនៃព្រះរាជាណាចក្រកម្ពុជា ។

## មាត្រា ២១.–ថ្មី

ក្នុងករណីអ្នកវិនិយោគមានបំណងចង់បញ្ចប់សកម្មភាពរបស់ខ្លួននៅក្នុងព្រះ-រាជាណាចក្រកម្ពុជា អ្នកវិនិយោគនោះត្រូវជូនពត៌មានទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមរយៈលិខិតអនុសិដ្ឋឬលិខិតប្រគល់ផ្ទាល់ដៃ ដោយបញ្ជាក់អំពីមូលហេតុនៃការបញ្ចប់សកម្មភាពនោះ និងចុះហត្ថលេខាដោយអ្នកវិនិយោគ ឬមេធាវីតំណាងផ្ទាល់របស់ខ្លួន ។

## មាត្រា ២២.–ថ្មី

ប្រសិនបើអ្នកវិនិយោគមានបំណងចង់បញ្ឈប់សកម្មភាពនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់របស់ខ្លួនក្រៅផ្លូវតុលាការ អ្នកវិនិយោគត្រូវផ្តល់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានូវភ័ស្តុតាងបញ្ជាក់ថា គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បានដោះស្រាយជំរះបំណុលរបស់ខ្លួនយ៉ាងត្រឹមត្រូវ រួមមានអ្នកប្តឹងឬការទាមទារណាមួយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទើបអ្នកវិនិយោគនោះត្រូវបានអនុញ្ញាតឱ្យបញ្ឈប់សកម្មភាពនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាផ្លូវការឬរំលាយដោយយោងទៅតាមច្បាប់ជាធរមានពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម ។

## មាត្រា ២៣.–ថ្មី

ក្នុងករណីដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវបានអនុញ្ញាតឱ្យបញ្ឈប់សកម្មភាពរបស់ខ្លួន ទោះតាមផ្លូវតុលាការក្តីឬក្រៅផ្លូវតុលាការក្តី អ្នកវិនិយោគអាចផ្ទេរនូវទ្រព្យសម្បត្តិដែលសេសសល់ទៅក្រៅប្រទេសឬមួយប្រើនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ប៉ុន្តែក្នុងករណីដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បានប្រើគ្រឿងម៉ាស៊ីននិងសម្ភារៈបរិក្ខាដែលបាននាំចូលដោយរួចពន្ធ ក្នុងអំឡុងពេលតិចជាង ៥(ប្រាំ)ឆ្នាំ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានកាតព្វកិច្ចបង់ពន្ធលើគ្រឿងម៉ាស៊ីននិងសម្ភារៈបរិក្ខាទាំងនោះ យោងតាមការកំណត់របស់អនុក្រឹត្យ ។

## ជំពូកទី ៩ ថ្មី
## អន្តរប្បញ្ញត្តិ

**មាត្រា ២៤.–ថ្មី**

ការវិនិយោគទាំងឡាយដែលបានទទួលការអនុញ្ញាតដោយច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ និងអនុក្រឹត្យនានា ត្រូវបានចាត់ទុកថាជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដូចមានចែងក្នុងច្បាប់នេះនិងអនុក្រឹត្យពាក់ព័ន្ធ ។

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលមានសិទ្ធិទទួលបាននូវអត្រាពន្ធលើប្រាក់ចំណេញ ៩%(ប្រាំបួនភាគរយ) មុនពេលប្រកាសឱ្យប្រើនូវច្បាប់នេះ និងដែលបានចាប់ផ្ដើមសកម្មភាពវិនិយោគដោយទទួលបានការយល់ព្រមអនុម័ត មានសិទ្ធិទទួលបានអត្រាពន្ធ ៩%(ប្រាំបួនភាគរយ)នេះ សម្រាប់រយៈពេល ៥(ប្រាំ)ឆ្នាំ ដោយចាប់ផ្ដើមពីឆ្នាំសារពើពន្ធ បន្ទាប់ពីការប្រកាសឱ្យប្រើនូវច្បាប់នេះ លុះត្រាតែអ្នកវិនិយោគនោះបានដាក់ជាប្រចាំរាល់ឆ្នាំសារពើពន្ធនូវវិញ្ញាបនប័ត្រប្រចាំឆ្នាំ បញ្ជាក់ពីការបំពេញកាតព្វកិច្ចចំពោះរដ្ឋដែលត្រូវកំណត់ដោយអនុក្រឹត្យ ដូចមានចែងក្នុងកថាខណ្ឌ ២ មាត្រា ១៤ ថ្មីបន្ទាប់ពីការប្រកាសឱ្យប្រើច្បាប់នេះ ។

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលមានសិទ្ធិត្រូវបានការលើកលែងពន្ធលើប្រាក់ចំណេញ តាមការយល់ព្រមជាលាយលក្ខណ៍អក្សររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មុនពេលប្រកាសឱ្យប្រើច្បាប់នេះ មានសិទ្ធិទទួលបន្តការលើកលែងពន្ធលើប្រាក់ចំណេញ លុះត្រាតែអ្នកវិនិយោគនោះ បានដាក់ជាប្រចាំរាល់ឆ្នាំសារពើពន្ធនូវវិញ្ញាបនប័ត្រប្រចាំឆ្នាំ បញ្ជាក់ពីការបំពេញកាតព្វកិច្ចចំពោះរដ្ឋដែលត្រូវកំណត់ដោយអនុក្រឹត្យ ដូចមានចែងក្នុងកថាខណ្ឌ ២ មាត្រា ១៤ ថ្មី បន្ទាប់ពីការប្រកាសឱ្យប្រើច្បាប់នេះ ។

## ជំពូកទី ១០ថ្មី
## អវសានប្បញ្ញត្តិ

**មាត្រា ២៥.-ថ្មី**

ក្នុងករណីដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់រឺលោភឬមិនអនុវត្តតាមលក្ខខណ្ឌទាំងឡាយដែលបានកំណត់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នោះក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានសិទ្ធិអំណាចដកហូតសិទ្ធិផ្សេងៗនិងផលប្រយោជន៍ទាំងអស់ឬមួយផ្នែកដែលបានផ្ដល់ជូនអ្នកវិនិយោគកន្លងមក ។

**មាត្រា ២៦.-ថ្មី**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៧.-ថ្មី**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣
ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់
**ប្រមុខរដ្ឋស្ដីទី**

ពរល.០៣.០៣.១៣៤

**ហត្ថលេខា និង ត្រា**

**ជា ស៊ីម**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្ដេចនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ហត្ថលេខា**

**គាត ឈន់**

លេខ: ១០៧ ច ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
[illegible] តាន់

# ឧបសម្ព័ន្ធទី ៣

# អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១១១អនក្រ/បក, ២៧ កញ្ញា ២០០៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១១១...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

*****

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៥ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ/បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង អនុក្រឹត្យវិសោធនកម្ម លេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងលេខ១៣០ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្ម លើអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩

- បានឃើញអនុក្រឹត្យលេខ៧០អនក្រ/បកចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង អនុក្រឹត្យវិសោធនកម្មលេខ ១១២ អនក្រ. បក ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០២ និងលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការធ្វើវិសោធនកម្ម លើអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៥

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### មាត្រា ១: វិសាលភាពនៃអនុក្រឹត្យ

១.១ គោលដៅ: អនុក្រឹត្យនេះ បំពេញបន្ថែម និង ចាត់ចែង គ្រប់គ្រងការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង មានគោលដៅ ជំរុញការលើកទឹកចិត្ត និង ធ្វើនិយ័តកម្មលើការវិនិយោគទាំងឡាយរបស់នីតិបុគ្គលសញ្ជាតិខ្មែរ និង នីតិបុគ្គលសញ្ជាតិបរទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

១.២ ការអនុវត្ត: អនុក្រឹត្យនេះ អនុវត្តទៅលើរាល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ "គ.ល.គ" ទាំងអស់ ដែលបានចុះបញ្ជីនៅក្រុមប្រឹក្សា និងនៅអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ។

### មាត្រា ២: វិស័យសម្រាប់វិនិយោគ

សកម្មភាពវិនិយោគ: អនុក្រឹត្យនេះអនុវត្តលើគ្រប់សកម្មភាពវិនិយោគ លើកលែងតែសកម្មភាពនោះបានកំណត់នៅក្នុងបញ្ជីអវិជ្ជមានដែលមានក្នុងឧបសម្ព័ន្ធទី១ ផ្នែកទី១ នៃអនុក្រឹត្យនេះ ដូចដែលមានចែងក្នុងមាត្រា ៧ ថ្មី នៃច្បាប់ស្តីពីវិនិយោគ ។

### មាត្រា ៣: ការវិនិយោគរបស់បុគ្គលសញ្ជាតិបរទេស និង បុគ្គលសញ្ជាតិខ្មែរ

៣.១ ការវិនិយោគរបស់បុគ្គលសញ្ជាតិបរទេស និង បុគ្គលសញ្ជាតិខ្មែរ: រាជរដ្ឋាភិបាលស្វាគមន៍ចំពោះការវិនិយោគពីសំណាក់បុគ្គលសញ្ជាតិបរទេស និងបុគ្គលសញ្ជាតិខ្មែរលើគ្រប់វិស័យសេដ្ឋកិច្ចទាំងអស់ លើកលែងតែសកម្មភាពដែលស្ថិតនៅក្រោមការដាក់កំហិតដូចមានចែងនៅក្នុងមាត្រា ២ នៃអនុក្រឹត្យនេះ ។

៣.២ ការប្រើប្រាស់អ្នកតំណាង: គ្មានបុគ្គលសញ្ជាតិខ្មែរណា អាចធ្វើសកម្មភាព ឬ ធ្វើតំណាងដោយផ្ទាល់ ឬ ដោយប្រយោលឱ្យបុគ្គលសញ្ជាតិបរទេស ក្នុងគោលបំណងដើម្បីពង្វាងនូវការអនុវត្តបទប្បញ្ញត្តិណាមួយនៃអនុក្រឹត្យនេះ ដែលដាក់កំហិត ឬ ហាមឃាត់ ចំពោះសកម្មភាពរបស់បុគ្គលសញ្ជាតិបរទេសនោះបានឡើយ ។

**មាត្រា ៤: និយមន័យ**

ក្នុងន័យនៃអនុក្រឹត្យនេះ វាក្យស័ព្ទ:

ក្រុមប្រឹក្សាៈ សំដៅដល់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលបានបង្កើតឡើងតាមមាត្រា ៣ នៃ ច្បាប់ស្តីពីវិនិយោគ។

ការធានាលើការវិនិយោគ: សំដៅដល់ ការធានាដែលបានកំណត់នៅក្នុងជំពូក ៤ នៃច្បាប់ស្តីពីវិនិយោគ ហើយដែលមានចែងក្នុងអនុក្រឹត្យនេះ សម្រាប់ផ្តល់ជូនដល់អ្នកវិនិយោគណា ដែលបំពេញតាមលក្ខខណ្ឌទាំងឡាយនៃអនុក្រឹត្យនេះ។

ការលើកទឹកចិត្តវិនិយោគ: សំដៅដល់ ការលើកទឹកចិត្តដែលមានកំណត់នៅក្នុងជំពូកទី៥ នៃច្បាប់ស្តីពីវិនិយោគហើយដែលមានចែងក្នុងអនុក្រឹត្យនេះ សម្រាប់ផ្តល់ជូនអ្នកវិនិយោគណា ដែលបំពេញតាមលក្ខខណ្ឌទាំងឡាយ នៃអនុក្រឹត្យនេះ។

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ : សំដៅដល់ គម្រោងវិនិយោគដែលទទួលបានវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ។

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានទិសដៅបម្រើតម្រូវការក្នុងស្រុក: សំដៅដល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលមិនបម្រើឱ្យការនាំចេញ។

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញ: សំដៅដល់ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលបានលក់ ឬបានផ្ទេរសមាមាត្រណាមួយនៃផលិតផលរបស់ខ្លួន ទៅឱ្យអ្នកទិញ ឬអ្នកទទួលនៅក្រៅព្រះរាជាណាចក្រកម្ពុជា ។

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាប្រភេទឧស្សាហកម្មគាំទ្រ: សំដៅដល់ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលផលិតផលរបស់ខ្លួន ១០០ (មួយរយ) ភាគរយ ត្រូវផ្គត់ផ្គង់ដល់ឧស្សាហកម្មនាំចេញ ជំនួសវត្ថុធាតុដើម ឬ សម្ភារៈបន្ទាប់បន្សំដែលតែងតែនាំចូល។

ច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ: សំដៅដល់ ច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

ច្បាប់ស្តីពីវិនិយោគ: សំដៅដល់ ច្បាប់ស្តីពីវិនិយោគដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ ០៣/នស៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ និង ដែលបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣។

ច្បាប់ស្តីពីសារពើពន្ធ: សំដៅដល់ ច្បាប់ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ និង ដែលបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសារពើពន្ធ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣។

ថ្ងៃធ្វើការ: សំដៅដល់ ថ្ងៃប្រតិទិន ដែលជាថ្ងៃធ្វើការជាផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជា ។

ទុនវិនិយោគ: សំដៅដល់ តម្លៃវិនិយោគដែលបង្ហាញជា រូបិយប័ណ្ណ ដុល្លារអាមេរិក ដោយមិនរាប់បញ្ចូល ថ្លៃដីធ្លី និង ទុនបង្វិលទេ។

ធាតុចូលផលិតកម្ម: សំដៅដល់ ទំនិញ រួមបញ្ចូលទាំងវត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេច និង សម្ភារៈបន្ទាប់បន្សំបម្រើផលិតកម្មដែលត្រូវបានបំប្លែង ឬ ត្រូវបានប្រើប្រាស់យ៉ាងពេញលេញនៅក្នុងកិច្ចដំណើរការផលិតកម្មរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មិនអោយហួសពីរយៈពេល ២(ពីរ) ឆ្នាំ បន្ទាប់ពីបាននាំចូល ។

និយមន័យនេះ មិនគិតបញ្ចូលផងទេ នូវសម្ភារៈ និង គ្រឿងសង្ហារឹមសម្រាប់ប្រើប្រាស់ក្នុងការិយាល័យ ផលិតផលគេលសិលា យានយន្ត និង គ្រឿងបន្លាស់យានយន្ត ។

ធាតុចេញផលិតកម្ម: សំដៅដល់ ទំនិញ ដែលបានផលិតចេញពីធាតុចូលផលិតកម្ម ដែលត្រូវបានបំប្លែង ។

នីតិបុគ្គលសញ្ជាតិខ្មែរ: សំដៅដល់ ក្រុមហ៊ុនដែលមានទីកន្លែងធ្វើអាជីវកម្ម និង ដែលបានធ្វើការចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងភាគហ៊ុន ៥១ (ហាសិបមួយ) ភាគរយ ឬ លើសក្នុងក្រុមហ៊ុន ត្រូវបានកាន់កាប់ដោយបុគ្គលមានសញ្ជាតិជាខ្មែរ ។

នីតិបុគ្គលសញ្ជាតិបរទេស: សំដៅដល់ នីតិបុគ្គលដែលមិនមែនសញ្ជាតិខ្មែរ ឬ ដែលមិនបានបង្កើតឡើងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

បុគ្គល: សំដៅដល់ រូបវន្តបុគ្គល ឬនីតិបុគ្គល ។

បញ្ជីអវិជ្ជមាន: សំដៅដល់ បញ្ជីគម្រោងវិនិយោគ ដែលកំណត់នៅក្នុងឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យនេះ និង ដែលតាមមាត្រា ៧ ថ្មី នៃច្បាប់ស្តីពីវិនិយោគ ជាបញ្ជីនៃសកម្មភាពវិនិយោគ ដែលមិនអាចចាត់ទុកថាជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

បំណែកនៃម៉ាស៊ីន: សំដៅដល់ បំណែកនៃសម្ភារៈបរិក្ខារផលិតកម្ម ដែលមានរយៈពេលប្រើប្រាស់តិចជាង ២ (ពីរ) ឆ្នាំ ដោយរួមបញ្ចូលទាំងគ្រឿងបន្លាស់នៃបំណែកសម្ភារៈទាំងនោះផង ។

ពន្ធគយ: សំដៅដល់ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស ដែលបានដាក់ឱ្យប្រើប្រាស់នៅក្នុងតារាងពន្ធគយ ចំពោះទំនិញដែលត្រូវបង់នាពេលនាំចូលដែនគយ ឬ នាំចេញពីដែនគយ ។

វិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ: សំដៅដល់ ឯកសារដែលចេញដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ដូចមានចែងក្នុងកថាខ័ណ្ឌ ៣ មាត្រា ៧ថ្មី នៃច្បាប់ស្តីពីវិនិយោគ និងមាត្រា ៦ ចំណុច ៦.៣ នៃអនុក្រឹត្យនេះ ។

វិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ: សំដៅដល់ ឯកសារដែលចេញដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ដូចមានចែងក្នុងកថាខ័ណ្ឌ ៧ មាត្រា៧ថ្មី នៃច្បាប់ស្តីពីវិនិយោគ និងមាត្រា ៧ ចំណុច ៧.៣ នៃអនុក្រឹត្យនេះ ។

វិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ: សំដៅដល់ វិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចដែលតម្រូវឱ្យបំពេញតាមមាត្រា ១៤ ថ្មី ចំណុច ២ ឬ មាត្រា ២៤ ថ្មី នៃច្បាប់ស្តីពីវិនិយោគ ហើយចេញជូន តាមមាត្រា ១៨ ចំណុច ១៨.២ នៃអនុក្រឹត្យនេះ ។

សំណើវិនិយោគ: សំដៅដល់ សំណើដែលបានដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ដោយបុគ្គលណាមួយ ក្នុងគោលបំណង បង្កើតគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

សម្ភារៈសាងសង់: សំដៅដល់ សម្ភារៈសំណង់ រួមទាំងឧបករណ៍ បរិក្ខារ បំពាក់ឱ្យសំណង់ ដែលបានបំប្លែង ឬ បានប្រើប្រាស់ទាំងស្រុង នៅក្នុងការសាងសង់សំណង់នានា សម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ប្រើប្រាស់ ដើម្បីដំណើរការសកម្មភាពវិនិយោគរបស់ខ្លួន នៅក្នុងដំណាក់កាលសាងសង់ដំបូង ឬ ពង្រីក ។

សកម្មភាពវិនិយោគ: សំដៅដល់ សកម្មភាពអាជីវកម្មដែលដំណើរការនៅក្នុងប្រទេសកម្ពុជា ក្រោមរូបភាពជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

សម្ភារៈបរិក្ខារផលិតកម្ម: សំដៅដល់ គ្រឿងម៉ាស៊ីន ឧបករណ៍ ដែលបានប្រើប្រាស់ជាមូលដ្ឋានសំខាន់ក្នុងការបំប្លែងធាតុចូលផលិតកម្ម ហើយដែលវត្ថុទាំងនោះ មិនអាចបំប្លែងដោយខ្លួនឯង ឬ មិនត្រូវបានប្រើប្រាស់អស់ក្នុងរយៈពេល ២ (ពីរ) ឆ្នាំបន្ទាប់ពីបាននាំចូល ។ គ្រឿងម៉ាស៊ីន និង ឧបករណ៍ទាំងនោះ មិនត្រូវគិតបញ្ចូលផងទេនូវឧបករណ៍ផ្នែកព័ត៌មានវិទ្យា ឬ យានយន្ត ដែលប្រើប្រាស់សម្រាប់គោលបំណងផ្សេង ក្រៅពីកិច្ចដំណើរការផលិតកម្មរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

សេវាកម្មវិជ្ជាជីវៈ: សំដៅដល់ សេវាទាំងឡាយ ដែលមានជាអាទិ៍ សេវាកម្មច្បាប់ ហិរញ្ញវត្ថុ គណនេយ្យ សវនកម្ម ទីប្រឹក្សាសារពើពន្ធ ស្ថាបត្យកម្ម វិស្វកម្ម សេវាកម្មបច្ចេកវិទ្យាព័ត៌មាន ផ្សព្វផ្សាយពាណិជ្ជកម្ម សេវាកម្មគ្រប់គ្រង ។

អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង: សំដៅដល់ អនុគណៈកម្មាធិការវិនិយោគរបស់ខេត្ត ក្រុង ដែលបានបង្កើតឡើងដោយអនុក្រឹត្យ ដើម្បីពិនិត្យសម្រេចចុះបញ្ជីវិនិយោគតាមខេត្ត ក្រុង ដែលមានទុនវិនិយោគចាប់ពី ២.០០០.០០០ (ពីរលាន) ដុល្លារអាមេរិក ចុះក្រោម ។

អ្នកដាក់ពាក្យសុំ: សំដៅដល់ បុគ្គល ឬ ក្រុមបុគ្គលដែលដាក់សំណើវិនិយោគនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ។

អ្នកវិនិយោគ: សំដៅដល់ បុគ្គលដែលអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

អ្នកវិនិយោគសញ្ជាតិខ្មែរ: សំដៅដល់ អ្នកវិនិយោគសញ្ជាតិខ្មែរ ឬ នីតិបុគ្គលសញ្ជាតិខ្មែរ ។

អនុក្រឹត្យរបស់ក្រុមប្រឹក្សា: សំដៅដល់ អនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង អនុក្រឹត្យវិសោធនកម្ម លេខ ១១២ អនក្រ.បក ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០២ និង លេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ។

## ជំពូកទី ២

## សំណើវិនិយោគ និង វិញ្ញាបនប័ត្រចុះបញ្ជីវិនិយោគ

### មាត្រា ៥: ការស្នើសុំវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ

៥.១ ពាក្យសុំ និង ថ្ងៃចុះបញ្ជី: បុគ្គលណាមួយដែលមានបំណងស្នើសុំការលើកទឹកចិត្ត និង ការធានាលើការវិនិយោគ ឬ តែការធានាលើការវិនិយោគ ត្រូវដាក់ជូនក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង

នូវសំណើវិនិយោគ តាមទម្រង់បែបបទនៃការដាក់ពាក្យសុំ ដែលបានបំពេញសព្វគ្រប់ ហើយចុះហត្ថលេខាត្រឹមត្រូវដោយម្ចាស់គម្រោងដែលមានសិទ្ធិ ឬអ្នកតំណាងឱ្យអ្នកដាក់ពាក្យសុំដែលមានការប្រគល់សិទ្ធិត្រឹមត្រូវ និងត្រូវបង់ថ្លៃចុះបញ្ជី ចំនួន ៧.០០០.០០០ (ប្រាំពីរលាន) រៀល នៅក្រុមប្រឹក្សា ឬនៅអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ដែលជាថ្លៃសេវារដ្ឋបាលដើម្បីទទួលបាននូវ រាល់ការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ ឬ បញ្ជីការនានាពីគ្រប់ក្រសួង ស្ថាប័ន មន្ទីរមានសមត្ថកិច្ចពាក់ព័ន្ធទាំងអស់រួមទាំងពន្ធប្រថាប់ត្រាផងដែរ ។

៥.២ ទម្រង់បែបបទនៃពាក្យសុំ: ទម្រង់បែបបទសម្រាប់សំណើវិនិយោគ មានកំណត់នៅក្នុងឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ ។

៥.៣ ភស្តុតាងស្តីពីសិទ្ធិអំណាចក្នុងការចុះហត្ថលេខា: ប្រសិនបើសំណើវិនិយោគនោះ ចុះហត្ថលេខាដោយតំណាងរបស់អ្នកដាក់ពាក្យសុំ ឯកសារភស្តុតាងស្តីពីការទទួលសិទ្ធិអោយចុះហត្ថលេខានេះ ត្រូវដាក់ជូនទៅក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ដោយភ្ជាប់ជាមួយនឹងសំណើវិនិយោគ ។

៥.៤ គម្រោងពហុសកម្មភាព: ប្រសិនបើបុគ្គលមានបំណងធ្វើការវិនិយោគ និង ដំណើរការលើសពីសកម្មភាពវិនិយោគមួយឡើងទៅ ហើយប្រសិនបើគម្រោងត្រូវបានចុះបញ្ជី ដើម្បីដំណើរការជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ បុគ្គលនោះត្រូវដាក់សំណើវិនិយោគដាច់ដោយឡែកពីគ្នាសម្រាប់សកម្មភាពវិនិយោគនីមួយៗ ។

៥.៥ ការជ្រើសរើសការលើកលែងពន្ធលើប្រាក់ចំណេញ: អ្នកដាក់ពាក្យសុំ ដែលចង់ទទួលបានការលើកលែងពន្ធលើប្រាក់ចំណេញតាមមាត្រា ១៤ ចំណុច ១៤.១ នៃច្បាប់ស្តីពីវិនិយោគ ដោយអនុលោមទៅតាមមាត្រា ១៥ នៃអនុក្រឹត្យនេះនៅពេលទទួលវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ត្រូវធ្វើការជ្រើសរើសជាលាយលក្ខណ៍អក្សរនូវការលើកទឹកចិត្តដែលខ្លួនចង់បាននៅក្នុងសំណើវិនិយោគ ។

៥.៦ ការជ្រើសរើសដោយបដិសេធនូវរំលោះពិសេសផ្អែកសារពើពន្ធផ្សេងៗ : ក្នុងការជ្រើសរើសតាមកថាខណ្ឌ ៥.៥ អ្នកដាក់ពាក្យសុំទទួលស្គាល់ថា. ការជ្រើសរើសដើម្បីប្រើប្រាស់រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ ដែលមានចែងនៅក្នុងមាត្រា ១៤ ចំណុច ១៤.១ នៃច្បាប់ស្តីពីវិនិយោគ នឹងធ្វើឱ្យអ្នកវិនិយោគគ្មានសិទ្ធិក្នុងការទាមទាររំលោះពិសេសផ្នែកវិនិយោគ ដែលអនុវត្តសម្រាប់អ្នកវិនិយោគតាមច្បាប់ស្តីពីសារពើពន្ធទាក់ទងទៅនឹងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នោះឡើយ ។

៥.៧ ការជ្រើសរើសយកតែការធានាលើការវិនិយោគ: អ្នកដាក់ពាក្យសុំ ដែលមានបំណងចង់ទទួលបាននូវផលប្រយោជន៍តែការធានាលើការវិនិយោគ អាចធ្វើការជ្រើសរើសជាលាយលក្ខណ៍អក្សរនៅក្នុងទម្រង់បែបបទនៃពាក្យស្នើសុំ ដោយអ្នកដាក់ពាក្យសុំនោះមិនមែនជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទេ តែស្ថិតនៅក្រោមការធានាលើការវិនិយោគនៃច្បាប់ស្តីពីវិនិយោគ ។ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវចេញនូវអាជ្ញាប័ណ្ណមួយដោយឡែក ដើម្បីបញ្ជាក់ជូនអ្នកដាក់ពាក្យសុំសម្រាប់ករណីនេះ ។

## មាត្រា ៦: ការចុះបញ្ជី ឬ ការបដិសេធពាក្យសុំ

៦.១ កិច្ចដំណើរការចុះបញ្ជីពាក្យសុំ: ក្នុងរយៈពេល ៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបាននូវសំណើវិនិយោគ

តាមមាត្រា ៥ ចំណុច ៥.១ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគ ខេត្ត ក្រុងត្រូវ ៖

(ក) ចុះបញ្ជីសំណើវិនិយោគ និង ជូនដំណឹងទៅអ្នកដាក់ពាក្យសុំ អនុលោមទៅតាមកថាខណ្ឌ ៦.៣ ប្រសិនបើមិនស្ថិតក្នុងកថាខណ្ឌ (ខ) ឬ (គ)ទេ ឬ

(ខ) បដិសេធសំណើវិនិយោគនោះ ហើយជូនដំណឹងទៅអ្នកដាក់ពាក្យសុំវិញ អនុលោមទៅតាមកថាខណ្ឌ ៦.៦ ប្រសិនបើសំណើវិនិយោគ ដែលលើកឡើងនោះ ពាក់ព័ន្ធទៅនឹងសកម្មភាពវិនិយោគ

(១) ដែលមាននៅក្នុងបញ្ជីអវិជ្ជមាន ឬ

(២) ដែលពីមុនបាន ឬ បច្ចុប្បន្នកំពុងដំណើរការដោយអ្នកវិនិយោគ ឬបុគ្គលផ្សេង ហើយដែលបានទទួលរួចហើយនូវការលើកទឹកចិត្តតាមច្បាប់ស្តីពីវិនិយោគ

(គ) បដិសេធសំណើវិនិយោគ ហើយជូនដំណឹងទៅអ្នកដាក់ពាក្យសុំវិញ ដោយអនុលោមទៅតាមកថាខណ្ឌ ៦.៦ ប្រសិនបើសំណើវិនិយោគ មិនបានផ្តល់ជូននូវព័ត៌មានគ្រប់គ្រាន់ ដែលតម្រូវដោយកថាខណ្ឌ ៥.១ ទេនោះ ។

(ឃ) ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង មានសិទ្ធិក្នុងការពន្យាពេលចុះបញ្ជីសំណើវិនិយោគទាំងឡាយដែលមានលក្ខណៈពិសេស ពាក់ព័ន្ធដល់ផលប្រយោជន៍ជាតិ និងផលប៉ះពាល់ដល់បរិស្ថាន ដែលតម្រូវដាក់គម្រោងឆ្លងយន្តការច្រកចេញចូលតែមួយនៃក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ដោយត្រូវផ្តល់នូវហេតុផលច្បាស់លាស់ដល់អ្នកដាក់ពាក្យសុំឱ្យបានដឹង ក្នុងរយៈពេល ០៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយថ្ងៃទទួលបានសំណើវិនិយោគ។

៦.២ ការកែតម្រូវសំណើវិនិយោគៈ ប្រសិនបើសំណើវិនិយោគដែលបានដាក់ជូនក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង មិនស្របទៅតាមមាត្រា៥នៃអនុក្រឹត្យនេះទេ ក្នុងរយៈពេល ០៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីថ្ងៃទទួលសំណើនោះ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យសុំ ដោយស្នើសុំឱ្យកែតម្រូវសំណើវិនិយោគ ហើយដាក់សំណើនោះជាថ្មីជូនក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ។

៦.៣ ការចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ : ប្រសិនបើក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង យល់ព្រមចុះបញ្ជីសំណើវិនិយោគតាមកថាខណ្ឌ ៦.១ (ក) ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ តាមគំរូដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធទី ៣ នៅក្នុងរយៈពេល ០៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលសំណើវិនិយោគ ហើយវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌនោះ ត្រូវធ្វើការបញ្ជាក់លើចំណុចដូចខាងក្រោម ៖

(ក) បញ្ជីស្តីពីរាល់ការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬ បញ្ជីការសំខាន់នានាដែលជាតម្រូវការស្របច្បាប់សម្រាប់ដំណើរការរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ រួមទាំងការបញ្ជាក់ពីក្រសួង នាយកដ្ឋាន អាជ្ញាធរ មន្ទីរនានាចំណុះខេត្ត ក្រុង ឬភ្នាក់ងាររបស់រាជរដ្ឋាភិបាល ដែលទទួលបន្ទុកការងារទាំងនេះ នៅពេលដែលអ្នកដាក់ពាក្យសុំមានលក្ខណៈវិនិច្ឆ័យសម្រាប់ទទួលបានលិខិតទាំងនោះ។

(ខ) ការជ្រើសរើសដោយអ្នកដាក់ពាក្យសុំ អនុលោមតាមកថាខ័ណ្ឌ ៥.៥ ឬ ៥.៦ ឬ ៥.៧ ។

(គ) ការលើកទឹកចិត្តវិនិយោគ និង ការធានាលើការវិនិយោគ ដែលគម្រោងវិនិយោគមានសិទ្ធិទទួលបាន ប្រសិនបើវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរនឹងត្រូវចេញជូន ដោយរាប់បញ្ចូលទាំងរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ តាមមាត្រា ១៤ ចំណុច ១៤.១ នៃច្បាប់ស្ដីពីវិនិយោគ ។

(ឃ) ការជ្រើសរើសដោយអ្នកដាក់ពាក្យសុំតាមមាត្រា ៥ ចំណុច ៥.៧ នៃអនុក្រឹត្យនេះ ប្រសិនបើមាន និងផលបច្ច័យនៃភាពគ្មានសិទ្ធិ លើការទទួលបាននូវការលើកទឹកចិត្តវិនិយោគ ។

(ង) ការទទួលស្គាល់លើលក្ខន្តិកៈនៃនីតិបុគ្គល ដែលជាអ្នកអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

៦.៤ ការខកខានមិនបានចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ: ប្រសិនបើក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ខកខានពុំបានចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ តាមកថាខ័ណ្ឌ ៦.៣ ឬ ខកខានមិនបានចេញលិខិតបដិសេធ អនុលោមតាម កថាខ័ណ្ឌ ៦.៦ ក្នុងរយៈ ពេល ០៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការទេ សំណើវិនិយោគត្រូវបានចាត់ទុកថាបានចុះបញ្ជី ហើយក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ជូនអ្នកដាក់ពាក្យសុំជាបន្ទាន់ ។

៦.៥ ព័ត៌មានដែលអមជាមួយវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ: ក្នុងវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវចេញផងដែរនូវគោលការណ៍ណែនាំវិនិយោគ និងលក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃលើការទទួលបាននូវ ការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬ បញ្ជីការ ដូចមានយោងនៅក្នុងកថាខ័ណ្ឌ ៦.៣ (ក) ។

៦.៦ លិខិតបដិសេធ: ប្រសិនបើក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង បដិសេធចំពោះសំណើវិនិយោគណាមួយតាមកថាខ័ណ្ឌ ៦.១ (ខ) ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវចេញលិខិតបដិសេធជូនទៅអ្នកដាក់ពាក្យសុំ ដោយលិខិតនោះត្រូវបញ្ជាក់ ÷

(ក) មូលហេតុស្ដីពីការមិនអាចទទួលសំណើវិនិយោគនោះបាន ។

(ខ) ព័ត៌មានបន្ថែម ដើម្បីផ្ដល់លទ្ធភាពឱ្យក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង អាចចុះបញ្ជីសំណើវិនិយោគ ដែលបានកែតម្រូវនោះ ។

## មាត្រា ៧: ការចេញជូនអ្នកវិនិយោគនូវវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ

៧.១ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវជួយសុំការយល់ព្រម ការអនុញ្ញាតផ្សេងៗ: នៅពេលដែលក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ដោយអនុលោមទៅតាមកថាខ័ណ្ឌ ៦.៣ រួចហើយ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវទទួលយកជំនួសមុខឱ្យ អ្នកដាក់ពាក្យសុំ នូវការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬ បញ្ជីការនានា ដែលមានចែងនៅក្នុងកថាខ័ណ្ឌ ៦.៣ (ក) ពីក្រសួង នាយកដ្ឋាន អាជ្ញាធរ មន្ត្រីនានា ចំណុះខេត្ត ក្រុង ឬ ភ្នាក់ងារ ដែលមានការពាក់ព័ន្ធផ្សេងៗ របស់រាជរដ្ឋាភិបាល ។

៧.២ ការបង់ប្រាក់កក់: អ្នកវិនិយោគ មិនត្រូវបានកំណត់ឱ្យបង់ប្រាក់កក់សម្រាប់ធានាការវិនិយោគឡើយ លើកលែងតែករណីសម្បទានលើវិស័យហេដ្ឋារចនាសម្ព័ន្ធ ដែលកិច្ចសន្យាសម្បទាននោះបានតម្រូវឱ្យបង់ ។

៧.៣ ការចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ: ប្រសិនបើអ្នកមានវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ទទួលបាននូវរាល់ការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬ បញ្ជីការនានា ដែលមានចែងក្នុងកថាខ័ណ្ឌ ៦.៣ (ក) រួចហើយនោះ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគ ខេត្ត ក្រុង ត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ។

៧.៤ រយៈពេលចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ: ប្រសិនបើអ្នកមានវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ មិនបានទទួលនូវរាល់ ការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬ បញ្ជីការនានា ដែលមានចែងនៅក្នុងកថាខ័ណ្ឌ ៦.៣ (ក) នៅក្នុងរយៈពេល ២៨ (ម្ភៃប្រាំបី) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌមកទេនោះ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ។

៧.៥ ការសុំការយល់ព្រមនានាពីស្ថាប័នពាក់ព័ន្ធ: ការចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរដោយក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង អនុលោមទៅតាមកថាខ័ណ្ឌ ៧.៤ មិនមែនជាការលើកលែងឱ្យអ្នកដាក់ពាក្យសុំរួចផុតពីកាតព្វកិច្ច ដែលត្រូវទទួលបាននូវរាល់ ការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬបញ្ជីការនានា ដើម្បីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដំណើរការដោយស្របច្បាប់នោះទេ ។

៧.៦ ការចាប់ផ្ដើមគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់: គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ចាប់ផ្ដើមនៅថ្ងៃចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរសម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នោះ ហើយចាប់ផ្ដើមរយៈពេលគន្លឹះសម្រាប់ការគណនារយៈពេលលើកលែងពន្ធលើប្រាក់ចំណេញតាមមាត្រា ១៤ ចំណុច ១៤.១ នៃច្បាប់ស្ដីពីវិនិយោគ និង កថាខ័ណ្ឌ ១៥.១ នៃអនុក្រឹត្យនេះតែម្ដង ។

៧.៧ កាតព្វកិច្ចស្នើសុំការយល់ព្រមផ្សេងៗ: គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវដាក់ពាក្យស្នើសុំការសម្រេចជាលាយលក្ខណ៍អក្សរជូន ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង តាមនីតិវិធី ដើម្បីទទួលបាននូវការយល់ព្រម លើរាល់ការប្ដូរ អាស័យដ្ឋាន ទីស្នាក់ការ ការប្ដូរទីតាំងអាជីវកម្ម ការប្ដូរនាមករណ៍ ការប្ដូរភាគហ៊ុន ឬការផ្លាស់ប្ដូរលម្អិតផ្សេងៗទៀត ដែលមាននៅក្នុងសំណើវិនិយោគ និងនៅក្នុងលក្ខន្តិកៈរបស់អ្នកវិនិយោគ ក្នុងរយៈពេលមុនធ្វើការប្ដូរ ១០(ដប់) ថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង សម្រេចជូនយ៉ាងយូរក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ ។

**មាត្រា ៨: ការដកហូត ឬ លុបចោលវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ**

៨.១ ការដកហូតវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ: វិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរត្រូវបានដកហូតវិញ ចាប់ពីថ្ងៃចេញផ្ដល់ជូនដោយក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ប្រសិនបើអ្នកវិនិយោគ ៖

(ក) ទទួលបាននូវវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ឬ វិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ តាមរយៈឯកសារក្លែងបន្លំ ឬ មិនត្រឹមត្រូវ ឬ

(ខ) មិនបានចាប់ផ្តើមធ្វើសកម្មភាពក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែ ក្រោយពេលទទួលបាននូវឯកសារទាំងអស់ដោយយោងទៅ តាមកថាខ័ណ្ឌ ៧.៣ លើកលែងករណីកិច្ចសន្យាសម្បទាន ដែលរយៈពេលនិងកំណត់ជាក់ស្តែង តាមការព្រមព្រៀងគ្នាក្នុងកិច្ចសន្យា ។

៨.២ ការលុបចោលវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរៈ ប្រសិនបើអ្នកវិនិយោគស្នើសុំអោយក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង លុបចោលវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ អនុលោមតាមមាត្រា ២១ថ្មី នៃច្បាប់ស្តីពីវិនិយោគ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវលុបចោលវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរនោះតែនៅពេលដែលអ្នកវិនិយោគបានអនុវត្ត ស្របទៅតាមមាត្រា ២២ថ្មី និងមាត្រា ២៣ថ្មី នៃច្បាប់ស្តីពីវិនិយោគប៉ុណ្ណោះ ។

៨.៣ ការជូនដំណឹងអំពីការដកហូតវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរៈ ប្រសិនបើក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ដកហូតវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ដោយអនុលោមទៅតាមមាត្រានេះ ក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ស្តីពីការដកហូតនោះ ជូនទៅអ្នកវិនិយោគ។

៨.៤ ការតវ៉ា ៖ អ្នកវិនិយោគដែលវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពររបស់ខ្លួន ត្រូវបានដកហូតដោយក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង តាមមាត្រានេះ អាចតវ៉ាជាលាយលក្ខណ៍អក្សរទៅសហប្រធានក្រុមប្រឹក្សាក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរ ពីក្រុមប្រឹក្សា ឬ ពីអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុងតាមកថាខ័ណ្ឌ ៨.៣ ។

៨.៥ ការបាត់បង់ការលើកទឹកចិត្តវិនិយោគ ៖ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពររបស់ខ្លួន ត្រូវបានដកហូត ឬលុបចោល មិនមានសិទ្ធិទាមទារការលើកទឹកចិត្តវិនិយោគណាមួយ ដែលមានចែងនៅក្នុងវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរទេ គិតចាប់ពីកាលបរិច្ឆេទដកហូត ឬលុបចោលនោះមក ។

## ជំពូកទី ៣

## ការទិញ និង ការរំលាយបញ្ចូលគ្នានៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

### មាត្រា ៩៖ ការរំលាយបញ្ចូលគ្នានៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

៩.១ ប្រសិនបើ អ្នកវិនិយោគ ពីរ ឬ ច្រើន ឬអ្នកវិនិយោគ និង ជនណាមួយ ព្រមព្រៀងរំលាយបញ្ចូលគ្នា បង្កើតជានីតិបុគ្គលថ្មី ហើយនីតិបុគ្គលថ្មីនោះមានបំណងអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់របស់អ្នកវិនិយោគ និងមានសិទ្ធិទទួលបាននូវការលើកទឹកចិត្ត និងការធានាលើការវិនិយោគដែលមានចែងនៅក្នុងវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នីតិបុគ្គលថ្មីនោះ ត្រូវស្នើសុំការ

សម្រេចជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង តាមនីតិវិធី ដើម្បីចុះបញ្ជីជាអ្នកវិនិយោគ និង ស្នើសុំផ្ទេរវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មកអោយនីតិបុគ្គលថ្មីក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ មុនធ្វើការរំលាយបញ្ចូលគ្នា និង មុនការផ្ទេរវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ។

៩.២ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវពិនិត្យពាក្យស្នើសុំដែលមានចែងនៅក្នុងកថាខ័ណ្ឌ ៩.១ មាត្រា ៩ នៃអនុក្រឹត្យនេះ ហើយត្រូវផ្តល់ទៅនីតិបុគ្គលថ្មីជាលាយលក្ខណ៍អក្សរនូវការយល់ព្រម ឬមិនយល់ព្រមនៃការចុះបញ្ជី និងការផ្ទេរវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃទទួលបានពាក្យស្នើសុំនោះ ។

**មាត្រា ១០: ការទិញយកគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដោយបុគ្គលដែលមិនបានចុះបញ្ជី**

១០.១ ប្រសិនបើបុគ្គលដែលមិនបានចុះបញ្ជី ទិញយកគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយចង់ដំណើរការអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៃអ្នកវិនិយោគ និង ទទួលបាននូវសិទ្ធិលើការលើកទឹកចិត្ត និង ការធានាលើការវិនិយោគ ដែលមានបញ្ជាក់នៅក្នុងវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ បុគ្គលដែលទិញត្រូវស្នើសុំការសម្រេចជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង តាមនីតិវិធីដើម្បីចុះបញ្ជីជាអ្នកវិនិយោគ និងស្នើសុំផ្ទេរវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មកឱ្យនីតិបុគ្គលថ្មី ក្នុងរយៈពេល ១០ (ដប់ ) ថ្ងៃ នៃថ្ងៃធ្វើការ មុនការផ្ទេរវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ។

១០.២ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវពិនិត្យពាក្យស្នើសុំ ដែលមានចែងនៅក្នុងកថាខ័ណ្ឌ ១០.១ មាត្រា ១០ នៃអនុក្រឹត្យនេះ ហើយត្រូវផ្តល់ជូនទៅនីតិបុគ្គលអ្នកទិញជាលាយលក្ខណ៍អក្សរនូវការយល់ព្រម ឬមិនយល់ព្រមនៃការចុះបញ្ជី និងការផ្ទេរវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃទទួលបានពាក្យស្នើសុំនោះ ។

១០.៣ ប្រសិនបើការផ្ទេរភាគហ៊ុនរបស់អ្នកវិនិយោគបណ្តាលអោយការ "គ្រប់គ្រង" ត្រូវបានទទួលដោយអ្នកត្រូវទទួលការផ្ទេរ អ្នកវិនិយោគត្រូវស្នើសុំទៅក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង តាមនីតិវិធីនូវការផ្ទេរឈ្មោះ និងអាស័យដ្ឋាននៃអ្នកត្រូវទទួលការផ្ទេរ ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ មុនធ្វើការផ្ទេរភាគហ៊ុននោះ ដើម្បីក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង សម្រេចជូនយ៉ាងយូរក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ ។

១០.៤ ចំពោះកថាខ័ណ្ឌ ១០.៣ មាត្រា ១០ នៃអនុក្រឹត្យនេះ ពាក្យថា "គ្រប់គ្រង" សំដៅដល់ អ្នកកាន់កាប់ភាគហ៊ុនយ៉ាងតិច ២០ (ម្ភៃ) ភាគរយ នៃភាគហ៊ុនរបស់អ្នកវិនិយោគ ។

### មាត្រា ១១: ការទិញយកគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយអ្នកវិនិយោគផ្សេងទៀត

១១.១ ប្រសិនបើអ្នកវិនិយោគដែលបានចុះបញ្ជីមួយមានបំណង ទិញយកភាពជាម្ចាស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ របស់អ្នកវិនិយោគផ្សេងទៀត ហើយចង់ទទួលបាននូវការលើកទឹកចិត្តវិនិយោគ និងការធានាលើការវិនិយោគនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលដំណើរការដោយអ្នកវិនិយោគនោះ អ្នកវិនិយោគដែលជាអ្នកទិញ ត្រូវស្នើសុំការសម្រេចជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង តាមនីតិវិធី នូវការទិញយក ក្នុងរយៈពេល ១០ (ដប់ ) ថ្ងៃ នៃថ្ងៃធ្វើការ មុនការទិញយកនោះ ដើម្បីទទួលបាននូវសិទ្ធិទាំងនោះ ។

១១.២ ក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវពិនិត្យពាក្យស្នើសុំដែលមានចែងនៅក្នុងកថាខ័ណ្ឌ ១១.១ មាត្រា ១១ នៃអនុក្រឹត្យនេះ ហើយត្រូវផ្តល់ជូនទៅអ្នកវិនិយោគជាអ្នកទិញនោះ ជាលាយលក្ខណ៍អក្សរនូវការយល់ព្រម ឬមិនយល់ព្រមនៃការចុះបញ្ជី និងការផ្ទេរវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃទទួលបានពាក្យស្នើសុំនោះ ។

### មាត្រា ១២: ការខកខានមិនបានចុះបញ្ជី ឬ សុំការសម្រេច

ប្រសិនបើ បុគ្គលថ្មី ឬអ្នកវិនិយោគដែលជាអ្នកទិញ ខកខានមិនបានស្នើសុំមកក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ដើម្បីចុះបញ្ជីវិនិយោគ អនុលោមទៅតាមមាត្រា ៩ ឬមាត្រា ១០ នៃអនុក្រឹត្យនេះ ឬអ្នកវិនិយោគដែលជាអ្នកទិញ ខកខានមិនបានសុំការសម្រេចទៅក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង អនុលោមទៅតាមមាត្រា ១១ នៃអនុក្រឹត្យនេះ បុគ្គលថ្មី ឬអ្នកវិនិយោគដែលជាអ្នកទិញនោះ មិនមានសិទ្ធិទទួលបាននូវការលើកទឹកចិត្ត និងការធានាលើការវិនិយោគណាមួយរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឡើយ ។

## ជំពូកទី ៤

## សម្ព័ន្ធអាជីវកម្ម

### មាត្រា ១៣: សម្ព័ន្ធអាជីវកម្ម

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អាចមានទ្រង់ទ្រាយជាសម្ព័ន្ធអាជីវកម្ម។ សម្ព័ន្ធអាជីវកម្មអាចបង្កើតឡើងរវាងនីតិបុគ្គលសញ្ជាតិខ្មែរនឹងនីតិបុគ្គលសញ្ជាតិខ្មែរ នីតិបុគ្គលសញ្ជាតិខ្មែរជាមួយនឹងនីតិបុគ្គលសញ្ជាតិបរទេស និង នីតិបុគ្គលសញ្ជាតិបរទេសជាមួយនឹងនីតិបុគ្គលសញ្ជាតិបរទេស រួមបញ្ចូលផងដែរជាសម្ព័ន្ធអាជីវកម្ម ជាមួយស្ថាប័ននានានៃរាជរដ្ឋាភិបាល។ មិនមានការដាក់កម្រិតកំណត់ដោយផ្អែកលើសញ្ជាតិ ឬសមាមាត្រនៃការដាក់ភាគហ៊ុនរបស់ ម្ចាស់ភាគហ៊ុននីមួយៗឡើយ លើកលែងតែសម្ព័ន្ធអាជីវកម្មនោះ ជាកម្មសិទ្ធិករ ឬ មានបំណងធ្វើជាកម្មសិទ្ធិករលើដីធ្លី ឬដើម្បីផលប្រយោជន៍លើដីធ្លីនៅក្នុងព្រះរាជាណាចក្រ

ចក្រកម្ពុជា។ ក្នុងករណីនេះ ការចូលរួមភាគហ៊ុន អតិបរមានៃបុគ្គលទាំងអស់ ដែលមិនមែនជានីតិបុគ្គលសញ្ជាតិខ្មែរនោះ មិនត្រូវអោយលើសពី ៤៥ (សែសិបប្រាំបួន) ភាគរយឡើយ ។

## ជំពូកទី ៥
## សារពើពន្ធ

### មាត្រា ១៤: គោលការណ៍ទូទៅ

១៤.១ ការទទួលខុសត្រូវចំពោះពន្ធអាករ: អ្នកវិនិយោគត្រូវមានកាតព្វកិច្ចចំពោះពន្ធ និង ត្រូវប្រតិបត្តិតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ច្បាប់ស្តីពីសារពើពន្ធ ច្បាប់ស្តីពីវិនិយោគ និងបទប្បញ្ញត្តិពាក់ព័ន្ធ ។

១៤.២ ធនធានធម្មជាតិ: អត្រាពន្ធលើប្រាក់ចំណេញ អនុវត្តចំពោះប្រាក់ចំណេញដែលសម្រេចបានក្រោមកិច្ចសន្យាបែងចែកផលិតផលប្រេងកាត និងឧស្ម័នធម្មជាតិ ឬសម្រេចបានពីការធ្វើអាជីវកម្មលើធនធានធម្មជាតិ មានជាអាទិ៍ ព្រៃឈើ រ៉ែ មាស ឬត្បូងថ្មមានតម្លៃនានា ត្រូវកំណត់តាមកថាខ័ណ្ឌ ២ មាត្រា ២០ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ ។

១៤.៣ ការដាក់កម្រិត: ការលើកលែងទាំងស្រុង ឬ មួយផ្នែកនៃពន្ធអាករ និង ពន្ធគយ ត្រូវអនុវត្តចំពោះតែពន្ធលើប្រាក់ចំណេញ និងពន្ធគយ ដូចមានចែងនៅក្នុងអនុក្រឹត្យនេះតែប៉ុណ្ណោះ។ ការលើកលែងនេះ ពុំរាប់បញ្ចូលនូវពន្ធអាករដូចខាងក្រោមនេះទេ ÷

ក- ពន្ធលើប្រាក់បៀវត្ស ពន្ធកាត់ទុក ដូចបានកំណត់ក្នុងមាត្រា ២៥ និង ២៦ ថ្មីនៃច្បាប់ស្តីពីសារពើពន្ធ និង ពន្ធ លើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ និង

ខ- អាករលើតម្លៃបន្ថែម អាករពិសេសលើទំនិញ និងសេវាមួយចំនួន អាករដែលត្រូវបង់នៅពេលនាំចូល និង ពន្ធអាករដទៃទៀត ដូចមានចែងក្នុងច្បាប់មានសុពលភាពជាធរមាន ។

### មាត្រា ១៥: ពន្ធលើប្រាក់ចំណេញ

១៥.១ រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ : យោងតាមមាត្រា ១៤ ចំណុច ១៤.១ នៃច្បាប់ស្តីពីវិនិយោគ រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ ដែលរួមមាន រយៈពេលគន្លឹះ បូក រយៈពេល ០៣ (បី) ឆ្នាំ បូករយៈពេលអាទិភាព គឺត្រូវបានកំណត់ដូចមានចែងក្នុងមាត្រានេះ ។

១៥.២ រយៈពេលគន្លឹះ: សម្រាប់មាត្រា ១៤ ចំណុច ១៤.១ នៃច្បាប់ស្តីពីវិនិយោគ រយៈពេលគន្លឹះនៃរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ គឺជារយៈពេលចាប់ផ្តើមពីថ្ងៃចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ និង បញ្ចប់នៅថ្ងៃចុងក្រោយនៃឆ្នាំសារពើពន្ធណាមួយដែលឆាប់ជាង ÷

ក- ប្រសិនបើ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានប្រាក់ចំណេញ គឺជាឆ្នាំសារពើពន្ធមុនឆ្នាំដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានប្រាក់ចំណេញដំបូង និង

ខ- ប្រសិនបើ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានប្រាក់ចំណូលពីសកម្មភាពវិនិយោគ ចំពោះការលក់ទំនិញឬសេវា គឺជាឆ្នាំសារពើពន្ធទី៣ បន្ទាប់ពីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ទទួលបានប្រាក់ចំណូលដំបូង ។

សម្រាប់គោលដៅនៃកថាខ័ណ្ឌនេះ និងមាត្រា១៤ ចំណុច ១៤.១ នៃច្បាប់ស្តីពីវិនិយោគ ប្រាក់ចំណេញគឺសំដៅ ដល់ប្រាក់ចំណេញជាប់ពន្ធ ដែលគណនាទៅតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធដោយពុំគិតពីបទប្បញ្ញត្តិនៃ ការយោងការខាត ដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់ស្តីពីសារពើពន្ធ ។

១៥.៣ រយៈពេល ០៣ (បី) ឆ្នាំ: គឺចាប់ផ្តើមគិតភ្លាមពីឆ្នាំសារពើពន្ធ បន្ទាប់ពីរយៈពេលគន្លឹះ និង ០២ (ពីរ)ឆ្នាំ បន្តបន្ទាប់មកទៀត ។

១៥.៤ រយៈពេលអាទិភាព: រយៈពេលអាទិភាព ត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុដោយចាប់ ផ្តើមគិតភ្លាមបន្ទាប់ពីឆ្នាំសារពើពន្ធទី៣ នៃរយៈពេល ០៣ (បី) ឆ្នាំ ដូចមានចែងនៅក្នុងកថាខ័ណ្ឌ ១៥.៣ ខាងលើ ។

១៥.៥ ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ សម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលបានចុះបញ្ជី ក្រោយថ្ងៃប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគ: ប្រាក់រំដោះពន្ធលើប្រាក់ចំណេញមិនត្រូវ អនុវត្តចំពោះគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលទទួលបានការលើកលែងពន្ធលើប្រាក់ ចំណេញ ដូចមានចែងក្នុងមាត្រា១៤ ចំណុច ១៤.១ នៃច្បាប់ស្តីពីវិនិយោគទេ ។

១៥.៦ ប្រាក់រំដោះពន្ធលើប្រាក់ចំណេញសម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលបានទទួលការ អនុញ្ញាតមុនពេលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ: គម្រោងវិនិយោគមានលក្ខណៈ សម្បត្តិគ្រប់គ្រាន់ណាដែលត្រូវអនុវត្តតាមកថាខ័ណ្ឌទី២ នៃមាត្រា ២៤ ថ្មីនៃច្បាប់ស្តីពីវិនិយោគ ត្រូវមាន កាតព្វកិច្ចបង់ប្រាក់រំដោះប្រចាំខែ សម្រាប់ពន្ធលើប្រាក់ចំណេញតាមអត្រា ០១ (មួយ) ភាគរយនៃផលរបរ គិតរួមបញ្ចូលទាំងពន្ធអាករទាំងអស់ លើកលែងតែអាករលើតម្លៃបន្ថែម ដែលបានសម្រេចក្នុងខែមុន ដូចមាន ចែងនៅក្នុងមាត្រា ២៨ ថ្មីនៃច្បាប់ស្តីពីសារពើពន្ធ។ ផលរបររបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិ គ្រប់គ្រាន់ ក្នុងរយៈពេលលើកលែងពន្ធ ដែលកំណត់ដោយច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃ ព្រះរាជាណាចក្រកម្ពុជា ត្រូវលើកលែងពីការបង់ប្រាក់រំដោះនេះ ។

១៥.៧ ដោយអនុលោមតាមមាត្រា ២៤ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មិនត្រូវជាប់ពន្ធអប្បបរមាទេ ។

## មាត្រា ១៦: ការលើកលែងពន្ធគយលើសម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ និង ធាតុចូលផលិតកម្ម

១៦.១ ការលើកលែងពន្ធគយ លើសម្ភារៈបរិក្ខារផលិតកម្ម និងសម្ភារៈសាងសង់របស់គម្រោងវិនិយោគមានលក្ខណៈ សម្បត្តិគ្រប់គ្រាន់ ដែលបម្រើទីផ្សារក្នុងស្រុក : អនុលោមទៅតាមមាត្រា ១៤ ចំណុច ១៤.៥ នៃច្បាប់ស្តីពី...

វិនិយោគ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលបម្រើទីផ្សារក្នុងស្រុក ត្រូវបានលើកលែងពន្ធគយ លើការនាំចូលសម្ភារៈបរិក្ខារផលិតកម្ម និងសម្ភារៈសាងសង់តែប៉ុណ្ណោះ ក្នុងករណីដែលគម្រោងប្រភេទនេះ មានលទ្ធភាពនាំចេញនូវផ្នែកណាមួយនៃផលិតផលដែលផលិតបានដោយផ្ទាល់ ឬ បានផ្គត់ផ្គង់ដល់ឧស្សាហកម្មនាំចេញ បរិមាណធាតុចូលផលិតកម្មដែលបានបង់ពន្ធនាំចូលរួយកទៅផលិតបម្រើការនាំចេញដោយផ្ទាល់ ឬដោយប្រយោលនោះ ត្រូវបានទទួលការលើកលែងពន្ធគយក្រោយពីការត្រួតពិនិត្យរបាយការណ៍ប្រចាំត្រីមាស ។

១៦.២ ការលើកលែងពន្ធគយ លើសម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ និងធាតុចូលផលិតកម្មរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បំរើឱ្យការនាំចេញ : អនុលោមតាមមាត្រា ១៤ ចំណុច ១៤.៦ នៃច្បាប់ស្តីពីវិនិយោគ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលបម្រើឱ្យការនាំចេញត្រូវបានលើកលែងពន្ធគយលើការនាំចូល សម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ និងធាតុចូលផលិតកម្ម ។ ដោយឡែកគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញ ដែលស្ថិតនៅក្រោមយន្តការឃ្លាំងផលិតកម្ម ក្រោមការគ្រប់គ្រងរបស់គយ ការលើកលែងពន្ធគយត្រូវអនុវត្តទៅតាមច្បាប់ និង បទប្បញ្ញត្តិគយជាធរមានរបស់យន្តការនេះ។ ធាតុចូលផលិតកម្មដែលកែច្នៃហើយមិនបាននាំចេញ ត្រូវបង់ពន្ធគយ និង អាករឡើងវិញលើធាតុចូលផលិតកម្មនាពេលនាំចូល ក្រោយពីការត្រួតពិនិត្យរបាយការណ៍ប្រចាំត្រីមាស ។

១៦.៣ ការលើកលែងពន្ធគយ លើសម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ និង ធាតុចូលផលិតកម្ម របស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលជាប្រភេទឧស្សាហកម្មគាំទ្រ អនុលោមតាមមាត្រា ១៤ ចំណុច ១៤.៧ នៃច្បាប់ស្តីពីវិនិយោគ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលជាឧស្សាហកម្មគាំទ្រ ត្រូវបានលើកលែងពន្ធគយ លើការនាំចូលសម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ និង ធាតុចូលផលិតកម្ម។ ប៉ុន្តែក្នុងករណី ដែលគម្រោងទាំងនោះមិនបានធ្វើការផ្គត់ផ្គង់ ១០០ (មួយរយ) ភាគរយ នៃផលិតផលដែលផលិតបានទៅដល់ឧស្សាហកម្មនាំចេញ ឬនាំចេញដោយផ្ទាល់ទេនោះ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទាំងនោះ ត្រូវបង់ពន្ធគយនិងអាករឡើងវិញលើធាតុចូលផលិតកម្មនាពេលនាំចូលនូវបរិមាណដែលមិនបានផ្គត់ផ្គង់ឱ្យឧស្សាហកម្មនាំចេញ ឬ នាំចេញដោយផ្ទាល់ ក្រោយពីការត្រួតពិនិត្យរបាយការណ៍ប្រចាំត្រីមាស។

១៦.៤ នីតិវិធីលើកលែងពន្ធគយៈ ក្រុមប្រឹក្សាត្រូវរៀបចំ ÷

ក-បង្កើតយន្តការអន្តរស្ថាប័ន ដែលមានសមាសភាពមកពីក្រុមប្រឹក្សា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសម្រាប់ពិនិត្យតាមដានការលើកទឹកចិត្ត លើការនាំចូល និង ការប្រើប្រាស់នូវសម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ និងធាតុចូលផលិតកម្មរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ តាមវិស័យវិនិយោគនីមួយៗ។

ខ-សេចក្តីណែនាំលម្អិតស្តីពីនីតិវិធីសម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលត្រូវបានទទួលការលើកលែងពន្ធគយ ។

១៦.៥ ការផ្ទេរ ការលក់ សម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ ធាតុចូលផលិតកម្មៈ ប្រសិនបើ សម្ភារៈបរិក្ខារ ផលិតកម្ម សម្ភារៈសាងសង់ ធាតុចូលផលិតកម្ម ដែលបាននាំចូលក្រោមការលើកលែងពន្ធគយ អាករ ត្រូវបាន លក់ ឬ ប្រើប្រាស់មិនចំគោលដៅតាមរូបភាពណាមួយ អ្នកវិនិយោគត្រូវ ÷

ក- ធ្វើការបង់ពន្ធគយ អាករ ក្នុងរយៈពេល ២៨ (ម្ភៃប្រាំបី) ថ្ងៃ នៃថ្ងៃធ្វើការ ទៅតាមចំនួនទឹកប្រាក់ដែល គណនាផ្អែកតាមច្បាប់ និង បទប្បញ្ញត្តិគយ ជាធរមាន ក្នុងករណីដែលការផ្ទេរ ឬការលក់ បានទទួលការ អនុញ្ញាតជាមុនពីក្រុមប្រឹក្សា ។

ខ- ធ្វើការបង់ពន្ធគយ អាករ និង ពិន័យ ក្នុងរយៈពេល ២៨ (ម្ភៃប្រាំបី) ថ្ងៃ នៃថ្ងៃធ្វើការ ទៅតាមចំនួន ទឹកប្រាក់ដែលគណនាផ្អែកតាមច្បាប់ និងបទប្បញ្ញត្តិគយ ជាធរមាន ក្នុងករណីដែលការផ្ទេរ ឬការលក់ នោះ មិនបានទទួលការអនុញ្ញាតជាមុន ពីក្រុមប្រឹក្សា ។

គ- ទទួលរងការផ្អាកជាបណ្តោះអាសន្ននូវ ការអនុញ្ញាតឱ្យនាំចូល ការពិនិត្យលើសំណើសុំលើកលែងពន្ធគយ ដែលបានផ្តល់ឱ្យ នៅក្រោមច្បាប់ស្តីពីវិនិយោគ រួមទាំងការពិន័យផ្អែកគយផ្សេងៗទៀត ក្នុងករណីមាន ការខកខាន ការយឺតយូរ ក្នុងការបង់ពន្ធគយ អាករ និងការពិន័យ ដូចមានចែងក្នុងកថាខ័ណ្ឌ ក និង ខ នៃកថាខ័ណ្ឌ ១៦.៥ មាត្រា ១៦ នៃអនុក្រឹត្យនេះ ។

១៦.៦ ការផ្ទេរ ការលក់ សម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ ធាតុចូលផលិតកម្ម ទៅឱ្យអ្នកវិនិយោគផ្សេង ទៀត : អ្នកវិនិយោគ ឬ តំណាងរបស់អ្នកវិនិយោគ អាចដាក់សំណើជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សា ដើម្បីសុំការសម្រេច លើការផ្ទេរ ការលក់ ដោយគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នូវ សម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ ធាតុចូលផលិតកម្ម ដែលបាននាំចូលដោយលើកលែងពន្ធគយ ទៅឱ្យអ្នកវិនិយោគផ្សេងទៀត សម្រាប់ប្រើប្រាស់ក្នុងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

## ជំពូកទី ៦

## កាតព្វកិច្ចរាយការណ៍ និង វិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ

### មាត្រា ១៧: កាតព្វកិច្ចរាយការណ៍

១៧.១ កាតព្វកិច្ចរាយការណ៍ស្តីពីសារពើពន្ធៈ ដូចបានកំណត់ក្នុងមាត្រា ១០៤ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ចាប់ពីថ្ងៃ ចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ទាំងអស់ត្រូវដាក់លិខិត ប្រកាសសារពើពន្ធប្រចាំខែសម្រាប់ខែនីមួយៗ និងលិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំសម្រាប់ឆ្នាំសារពើពន្ធនោះ និងបង់ពន្ធអាករទាំងអស់តាមបទប្បញ្ញត្តិនៃពន្ធនីមួយៗ ជូននាយកដ្ឋានពន្ធដារ ដោយត្រូវដាក់ភ្ជាប់នូវវិញ្ញា បនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋសម្រាប់ឆ្នាំសារពើពន្ធ ។

១៧.២ កាតព្វកិច្ចរាយការណ៍ពីការលើកលែងពន្ធគយៈ រាល់សម្ភារៈបរិក្ខារផលិតកម្ម និងសម្ភារៈសាងសង់នាំចូលដោយ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវតែមានការបំពេញបែបបទគយឱ្យបានសព្វគ្រប់ត្រឹម ត្រូវ ។ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយការនាំចូល គម្រោងវិនិយោគមានលក្ខណៈ

សម្បត្តិគ្រប់គ្រាន់ ត្រូវដាក់ជូនក្រុមប្រឹក្សា និង នាយកដ្ឋានពន្ធដារ នូវច្បាប់ចម្លង ដែលមានការបញ្ជាក់ត្រឹមត្រូវលើឯកសារបំពេញបែបបទគយ ក្នុងនោះមានទាំងឯកសារបញ្ជាក់តម្លៃទំនិញពីភ្នាក់ងារដែលរដ្ឋាភិបាលបានជ្រើសតាំងឱ្យទទួលភារកិច្ចផង ។

**មាត្រា ១៨: វិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ**

១៨.១ វិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ: រៀងរាល់ឆ្នាំសារពើពន្ធនីមួយៗគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មិនអាចទាមទារ និងមិនមានសិទ្ធិទទួលបាននូវការលើកទឹកចិត្តវិនិយោគណាមួយទេ លុះត្រាណា គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មិនទទួលបាននូវវិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ ។

១៨.២ ការចេញជាស្វ័យប្រវត្តិ: យោលទៅតាមការដកហូតដោយក្រុមប្រឹក្សាតាមកថាខ័ណ្ឌ ១៨.៤ និង ១៨.៥ ក្រុមប្រឹក្សា ត្រូវចេញវិញ្ញាបនបត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋជូន គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងរយៈពេល ៩០ (កៅសិប )ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីផុតឆ្នាំសារពើពន្ធនីមួយៗ ។

១៨.៣ ការខកខានមិនបានចេញ: ប្រសិនបើក្រុមប្រឹក្សា ខកខានមិនបានចេញវិញ្ញាបនបត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ ដូចបានតម្រូវក្នុងកថាខ័ណ្ឌ ១៨.២ ទេនោះ វិញ្ញាបនបត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋនឹងត្រូវចាត់ទុកថា បានចេញជូនគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ប៉ុន្តែអាចនឹងត្រូវបានដកហូតវិញតាម កថាខ័ណ្ឌ ១៨.៤ និង ១៨.៥។

១៨.៤ សិទ្ធិពិនិត្យឡើងវិញ: ក្រុមប្រឹក្សាមានសិទ្ធិពិនិត្យឡើងវិញដើម្បីកំណត់ច្បាស់ថា គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលកាន់កាប់វិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋនោះ បានផ្តល់រាល់ព័ត៌មានដែលតម្រូវ ស្របតាមកថាខ័ណ្ឌ ១៨.៦ ។

១៨.៥ ការបាត់បង់ការលើកទឹកចិត្តវិនិយោគ: ក្រុមប្រឹក្សាអាចដកហូតវិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ប្រសិនបើក្រុមប្រឹក្សាយល់ថា គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មិនបានផ្តល់នូវព័ត៌មានដែលតម្រូវដោយមាត្រានេះ បន្ទាប់ពីការពិនិត្យសមហេតុផលឡើងវិញ តាមកថាខ័ណ្ឌ ១៨.៤ ហើយគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នោះនឹងបាត់បង់នូវសិទ្ធិនៃការទទួលរាល់ការលើកទឹកចិត្តវិនិយោគ ចាប់ពីថ្ងៃដកហូតវិញ្ញាបនប័ត្រនេះតទៅ ។

១៨.៦ ព័ត៌មានដែលត្រូវប្រគល់ជូន: គ្រប់អ្នកវិនិយោគទាំងអស់ ត្រូវដាក់ជូនទៅក្រុមប្រឹក្សានូវ ÷

(ក) របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ រួមមាន តារាងតុល្យការ របាយការណ៍លទ្ធផល តារាងចលនា សាច់ប្រាក់ និង កំណត់សម្គាល់ ដោយមិនឱ្យហួសពីថ្ងៃទី ៣១ ខែ មីនា នៃឆ្នាំបន្ទាប់ ។

(ខ) លិខិតបញ្ជាក់ពីការបំពេញកាតព្វកិច្ចសារពើពន្ធពីនាយកដ្ឋានពន្ធដារ ដែលបញ្ជាក់ថាអ្នកវិនិយោគបាន :

(១) បំពេញត្រឹមត្រូវ និងដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែគ្រប់គ្រាន់ទាន់ពេលវេលា លើកលែងតែលិខិតប្រកាសប្រចាំឆ្នាំនោះ ដែលតម្រូវដោយច្បាប់ស្តីពីសារពើពន្ធ ។

(ខ) បង់ពន្ធទាំងអស់ ប្រាក់ពន្ធ ការប្រាក់ និងប្រាក់ពន្ធបន្ថែម ដែលបានកំណត់សម្រាប់រយៈពេលជាប់ពន្ធ ដែលបានធ្វើសវនកម្មរួចដោយនាយកដ្ឋានពន្ធដារ ។

(គ) របាយការណ៍ប្រចាំត្រីមាសស្តីពីការនាំចូលជាក់ស្តែងនូវ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម ដែលបម្រើឱ្យផលិតកម្ម និងរបាយការណ៍ប្រចាំត្រីមាសស្តីពីការនាំចេញជាក់ស្តែងនូវផលិតផលសម្រេច របស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ព្រមទាំងតារាងអចលនៈទ្រព្យប្រចាំឆ្នាំ ។

(ឃ) បញ្ជីអង្កេតព័ត៌មានវិនិយោគទម្រង់ CIB 01S ។

## ជំពូកទី ៧
## កម្មសិទ្ធិ និង ការប្រើប្រាស់ដីធ្លី

### មាត្រា ១៩: កម្មសិទ្ធិ

១៩.១ កម្មសិទ្ធិ: កម្មសិទ្ធិដីធ្លី សម្រាប់បម្រើឱ្យគោលដៅនៃសកម្មភាពវិនិយោគ ដែលត្រូវផ្តល់ជូនរូបវន្តបុគ្គល ឬ នីតិបុគ្គលសញ្ជាតិខ្មែរ ត្រូវអនុលោមទៅតាមច្បាប់ជាធរមាន ។

១៩.២ ការចុះបញ្ជីកម្មសិទ្ធិ: ក្នុងការចុះបញ្ជីកម្មសិទ្ធិដីធ្លី អ្នកវិនិយោគត្រូវទៅបំពេញរាល់ទម្រង់បែបបទចុះបញ្ជីនៅរដ្ឋបាលសុរិយោដី ក្នុងមូលដ្ឋានដែលអចលនវត្ថុនោះតាំងនៅ ។

១៩.៣ ការកំណត់សិទ្ធិលើកម្មសិទ្ធិ: អនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា រូបវន្តបុគ្គល ឬ នីតិបុគ្គលសញ្ជាតិបរទេស មិនអាចធ្វើជាកម្មសិទ្ធិករនៃដីធ្លីក្នុងព្រះរាជាណាចក្រកម្ពុជាបានឡើយ ។

### មាត្រា ២០ : ការប្រើប្រាស់ដីធ្លី

២០.១ នីតិបុគ្គលសញ្ជាតិខ្មែរ: ក្រៅពីសិទ្ធិកម្មសិទ្ធិ អ្នកវិនិយោគសញ្ជាតិខ្មែរមានសិទ្ធិប្រើប្រាស់ដីធ្លីតាមរូបភាពផ្សេងៗ ដែលមានជាធរមានដូចជា:.សម្បទាន ការជួល ការផ្ទេរ ការដាក់ប្រាតិភោគជាដើម ។

២០.២ នីតិបុគ្គលសញ្ជាតិបរទេស: នីតិបុគ្គលសញ្ជាតិបរទេសអាចប្រើប្រាស់ដីធ្លីតាមរូបភាពផ្សេងៗដូចជា សម្បទាន ការជួលរយៈពេលវែង ១៥ (ដប់ប្រាំ) ឆ្នាំឡើង ឬ លើស និងការជួលរយៈពេលខ្លី ហើយអាចបន្តជាថ្មីបាន។ ការប្រើប្រាស់ដីធ្លីនេះរាប់បញ្ចូលទាំងសិទ្ធិលើសំណង់ ការរៀបចំឬ ការកែលំអទាំងឡាយ ដែលបានធ្វើដោយអ្នកជួលក្នុងរយៈពេលកំណត់នៃកិច្ចសន្យា តែត្រូវអនុវត្តតាមច្បាប់ជាធរមាន។

២០.៣ ការជួលដីរបស់រដ្ឋ: រូបវន្តបុគ្គលឬ នីតិបុគ្គល ដែលបានជួលដីពីរដ្ឋ ត្រូវអនុវត្តទៅតាមបទប្បញ្ញត្តិ ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

២០.៤ ការជួលបន្ត: រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានទទួលការអនុញ្ញាតអោយជួលដីធ្លីពីរដ្ឋ អាចធ្វើការជួលបន្តទៅអោយតតិយជនបាន លុះត្រាតែមានការយល់ព្រមដោយជាក់លាក់ ឬ ការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចជាមុនសិន។

## ជំពូកទី ៨

## កម្លាំងពលកម្ម

### មាត្រា ២១ : ការប្រើប្រាស់កម្លាំងពលកម្ម

ក្រុមប្រឹក្សា មានភារកិច្ចណែនាំ និង សម្រួលដល់អ្នកវិនិយោគ ដើម្បីនាំមកជាមួយនូវសហព័ទ្ធ ជាជនបរទេស ដើម្បីទទួលបាននូវទិដ្ឋាការ សិទ្ធិស្នាក់នៅ និង លិខិតធ្វើដំណើរនានាត្រឹមត្រូវ ស្របទៅតាមច្បាប់ និង បទប្បញ្ញត្តិស្តីពីអន្តោប្រវេសន៍ ។

រាល់ការនាំមកនូវ បុគ្គលិក និង អ្នកជំនាញការខាងការគ្រប់គ្រង បុគ្គលិកបច្ចេកទេស កម្មករជំនាញ ដែលជាជនបរទេសរបស់អ្នកវិនិយោគដែលមិនអាចរកបាននៅក្នុងចំណោមប្រជាជនកម្ពុជា ក្រុមប្រឹក្សាត្រូវបង្ការងាយស្រួលជូនដល់អ្នកវិនិយោគ ដើម្បីអាចមានសិទ្ធិនាំនិយោជិតបរទេសទាំងនោះមកបំពេញការងារតាមតម្រូវការ ស្របតាមច្បាប់ស្តីពីការងារ ច្បាប់ស្តីពីអន្តោប្រវេសន៍ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ។

## ជំពូកទី ៩

## ទោសប្បញ្ញត្តិ

### មាត្រា ២២: ទោសប្បញ្ញត្តិ

ប្រសិនបើអ្នកវិនិយោគ មិនអនុវត្តតាមកាតព្វកិច្ចណាមួយដែលបានកំណត់ឱ្យខ្លួន តាមអនុក្រឹត្យនេះ ឬតាមច្បាប់ស្តីពីវិនិយោគ អ្នកវិនិយោគត្រូវទទួលរងនូវទោសប្បញ្ញត្តិ ដែលបានកំណត់ដោយមាត្រា ៨ ចំណុច ៨.១ មាត្រា ១២ មាត្រា ១៨ ចំណុច ១៨.៥ នៃអនុក្រឹត្យនេះ ឬ ច្បាប់ដទៃទៀត ស្តីពីការមិនបំពេញនូវកាតព្វកិច្ច។

## ជំពូកទី ១០

## អន្តរប្បញ្ញត្តិ

### មាត្រា ២៣: ការទទួលស្គាល់ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នៃគម្រោងវិនិយោគដែលទទួលបានការអនុញ្ញាតមុនច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ

២៣.១ គម្រោងវិនិយោគទាំងឡាយ ដែលបានទទួលការអនុញ្ញាតដោយច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ និងដែលកំពុងធ្វើសកម្មភាពបច្ចុប្បន្ន មុនថ្ងៃចូលជាធរមាននៃអនុក្រឹត្យនេះ នឹងត្រូវបានទទួលស្គាល់ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្រោយពេលដែលអ្នកវិនិយោគនោះ បានដាក់សំណើជាលាយលក្ខណ៍អក្សរជូនមកក្រុមប្រឹក្សា ដើម្បីកំណត់ថាជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយទទួលអនុវត្តនូវកាតព្វកិច្ចទាំងឡាយដូចមានចែងក្នុងច្បាប់ស្តីពីវិនិយោគ និង អនុក្រឹត្យនេះ ។



ក្រុមប្រឹក្សា ត្រូវចេញលិខិតទទួលស្គាល់គម្រោងវិនិយោគខាងលើនោះ ថាជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី)ថ្ងៃ នៃថ្ងៃធ្វើការ ជូនទៅអ្នកវិនិយោគវិញ។ ចំពោះគម្រោងវិនិយោគ ដែលពីមុនបានទទួលគោលការណ៍ឱ្យវិនិយោគកន្លងមក តែមិនបានធ្វើសកម្មភាពអ្វីឡើយ ឬបានធ្វើមួយរយៈ តែបានផ្អាកសកម្មភាពទៅវិញ ហើយមិនបានជូនដំណឹងពីការបញ្ឈប់ ឬផ្អាកសកម្មភាពនោះមកក្រុមប្រឹក្សា គម្រោងវិនិយោគនោះ ត្រូវធ្វើនិយ័តកម្មឯកសារបន្ថែមដើម្បីអាចទទួលបានសិទ្ធិជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មុននឹងចាប់ផ្តើមអនុវត្តគម្រោងជាបន្តទៅទៀត។

២៣.២ ការលើកទឹកចិត្តនានា របស់គម្រោងវិនិយោគ ដែលទទួលការអនុញ្ញាតមុនច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគៈ គម្រោងវិនិយោគ ដែលទទួលការអនុញ្ញាតមុនច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ ហើយបានទទួលស្គាល់ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលមានសិទ្ធិទទួលបាននូវអត្រាពន្ធលើប្រាក់ចំណេញ ០៩ (ប្រាំបួន) ភាគរយ មុនពេលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិទទួលបានអត្រាពន្ធ ០៩ (ប្រាំបួន) ភាគរយនេះ សម្រាប់រយៈពេលអន្តរកាលមិនលើសពី ០៥ (ប្រាំ) ឆ្នាំ ដោយចាប់ផ្តើមពីឆ្នាំសារពើពន្ធបន្ទាប់ពីការប្រកាសចូលជាធរមាននូវច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យនេះ លុះត្រាតែអ្នកវិនិយោគនោះ បានបំពេញត្រឹមត្រូវនូវ កាតព្វកិច្ចទាំងឡាយ ដូចមានចែងក្នុងជំពូកទី ៦ នៃអនុក្រឹត្យនេះ។

គម្រោងវិនិយោគដែលទទួលការអនុញ្ញាតមុនច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ ហើយបានទទួលស្គាល់ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និង ដែលទទួលបាននូវការលើកទឹកចិត្តជាលាយលក្ខណ៍អក្សរពីក្រុមប្រឹក្សា អាចបន្តទទួលការលើកទឹកចិត្តលើកលែងពន្ធលើប្រាក់ចំណេញ ពន្ធគយលើការនាំចូលសម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ និងធាតុចូលផលិតកម្មបានទៀត លុះត្រាតែអ្នកវិនិយោគនោះ បានបំពេញត្រឹមត្រូវនូវកាតព្វកិច្ចទាំងឡាយ ដូចមានចែងក្នុង ជំពូកទី ៦ នៃអនុក្រឹត្យនេះ។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

### មាត្រា ២៥: និរាករណ៍

អនុក្រឹត្យលេខ ៨៨ អនក្រ/បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យវិសោធនកម្ម លេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ១៩៩៩ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃ ទី ២៦ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ និង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៥:**

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់ អភិបាលគ្រប់ខេត្ត ក្រុង ត្រូវទទួលអនុវត្ត អនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

***កន្លែងទទួល:***

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ដូចមាត្រា ២៥
-ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី ១

នៃអនុក្រឹត្យលេខ.១១១.អនក្រ.បក.ចុះថ្ងៃទី.២៧...ខែ.កញ្ញា.ឆ្នាំ ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម
នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

## បញ្ជីអវិជ្ជមាន (មាត្រា ៦.១)

**ផ្នែកទី ១ : សកម្មភាពវិនិយោគដែលហាមឃាត់ ដោយច្បាប់ និង អនុក្រឹត្យពាក់ព័ន្ធ:**

១- ផលិតកម្ម កែច្នៃសារធាតុប្រព័ន្ធសរសៃប្រសាទ (Psychotropic Substances) និង សារធាតុ (Narcotic) ។

២- ផលិតកម្មគ្រឿងគីមីពុល ថ្នាំពុលកសិកម្ម និង ទំនិញផ្សេងទៀត តាមរយៈការប្រើប្រាស់ សារធាតុគីមី ដែលហាមឃាត់ ដោយបទប្បញ្ញត្តិអន្តរជាតិនានា ឬ អង្គការសុខភាពពិភពលោក ដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ និង បរិស្ថាន។

៣- ការកែច្នៃ ការផលិតអគ្គិសនី ដោយប្រើប្រាស់ កាកសំណល់គ្រប់ប្រភេទ ដែលនាំចូលពីបរទេស ។

៤- ការធ្វើអាជីវកម្ម ព្រៃឈើ ដែលច្បាប់ស្តីពីព្រៃឈើហាមឃាត់ ។

៥- សកម្មភាពវិនិយោគផ្សេងៗទៀត ដែលច្បាប់ហាមឃាត់ ។

**ផ្នែកទី ២ : សកម្មភាពវិនិយោគដែលមិនទទួលបាននូវការលើកទឹកចិត្ត:**

១- សកម្មភាពពាណិជ្ជកម្ម អាហរ័ណ នីហរ័ណ លក់ដុំ លក់រាយ គ្រប់ប្រភេទ រួមទាំងហាងលក់ទំនិញរួចពន្ធ ។

២- សេវាកម្មដឹកជញ្ជូនគ្រប់ប្រភេទ ទាំងផ្លូវទឹក ផ្លូវគោក និងផ្លូវអាកាស លើកលែងតែការវិនិយោគផ្នែករថភ្លើង ។

៣- ភោជនីយដ្ឋាន ការ៉ាអូខេ រង្គសាល បាកដ្ឋាន កន្លែងធ្វើសរៃ កន្លែងហាត់កីឡា ដែលស្ថិតនៅក្រៅបរិវេណសណ្ឋាគារ ខ្នាតអន្តរជាតិ ។ ប៉ុន្តែ ទោះបីស្ថិតនៅក្នុងបរិវេណសណ្ឋាគារខ្នាតអន្តរជាតិក៏ដោយ ប្រសិនបើអ្នកវិនិយោគបានយកទីតាំងខាងលើនោះ ជួលបន្តឱ្យតតិយជនធ្វើអាជីវកម្ម អ្នកជួលដែលមិនមែនជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងមិនទទួលបាននូវការលើកលែងពន្ធលើប្រាក់ចំណេញ ដែលសម្រាប់ផ្តល់ដល់អ្នកវិនិយោគ ស្របតាមច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគនោះឡើយ ។

៤- សេវាកម្ម ការទេសចរណ៍ ភ្នាក់ងារទេសចរណ៍ ព័ត៌មាន និង ផ្សព្វផ្សាយទេសចរណ៍ ។

៥- អាជីវកម្ម សេវាកម្ម និង អាជីវកម្ម កាស៊ីណូ និង ល្បែងស៊ីសង គ្រប់ប្រភេទ ។

៦- សេវាកម្ម និង អាជីវកម្ម រូបិយវត្ថុ និង ហិរញ្ញវត្ថុ រួមមាន ធនាគារ ស្ថាប័នហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង និង ប្រតិបត្តិការ ហិរញ្ញវត្ថុអន្តរការីយកម្ម គ្រប់ប្រភេទ ។

៧- សកម្មភាពដែលទាក់ទងទៅនឹង សារព័ត៌មាន និងប្រព័ន្ធឃោសនា មានជាអាទិ៍ វិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្តី ភាពយន្ត ផលិត ឬថតចម្លងវីដេអូ ល្ខោន ស្ទូឌីយោថត និង សកម្មភាពពាក់ព័ន្ធ ។

៨- សេវាកម្មវិជ្ជាជីវៈ ។

៩- សារពាង្គកាយកែច្នៃរស់ (LMOs) ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់ជីវចំរុះ សុខភាពមនុស្ស និង បរិស្ថាន។

១០- ការផលិត ឬការកែច្នៃផលិតផលឈើ ដែលប្រើប្រាស់ឈើមូលពីព្រៃឈើធម្មជាតិមានប្រភពផ្គត់ផ្គង់ស្របច្បាប់ក្នុងស្រុកជាវត្ថុធាតុដើម។

១១- ការផលិត ផលិតផលពីថ្នាំជក់គ្រប់ប្រភេទ។

១២- ការផលិត ផលិតផលម្ហូបអាហារ និង ភេសជ្ជៈ ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក។

១៣- ការផលិត ផលិតផលសម្រាប់រោងចក្រវាយនភ័ណ្ឌ ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក។

១៤- ការផលិត សំលៀកបំពាក់ វាយនភ័ណ្ឌ ស្បែកជើង មួក ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក។

១៥- ការផលិត គ្រឿងសង្ហារឹម និង គ្រឿងភ្ជាប់ មិនប្រើប្រាស់ឈើធម្មជាតិ ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក។

១៦- ការផលិត ក្រដាស និងផលិតផលធ្វើពីក្រដាស ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក។

១៧- ការផលិត ធាតុគីមី ស៊ីម៉ងត៍ ជីកសិកម្ម គីមីកែច្នៃពីប្រេងកាត ដែលមានទុនវិនិយោគសមមូលទាបជាង ១.០០០.០០០ (មួយលាន) ដុល្លារអាមេរិក។

១៨- ការផលិត ផលិតផលពីកៅស៊ូ និង ផលិតផលធ្វើពីជ័រប្លាស្ទិក ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក។

១៩- ការផលិត ផលិតផលស្បែក និង ផលិតផលពាក់ព័ន្ធផ្សេងៗទៀត ដែលមានទុនវិនិយោគសមមូលទាបជាង ៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក។

២០- ការផលិត ផលិតផលធ្វើពីលោហៈគ្រប់ប្រភេទ ដែលមានទុនវិនិយោគសមមូលទាបជាង ៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក។

២១- ការផលិត សម្ភារៈបរិក្ខារអគ្គិសនី និង អេឡិចត្រូនិច និងសម្ភារៈការិយាល័យ ដែលមានទុនវិនិយោគសមមូលទាបជាង ៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក។

២២- ការផលិត ប្រដាប់ក្មេងលេង និង សម្ភារៈកីឡា ដែលមានទុនវិនិយោគសមមូលទាបជាង ៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក។

២៣- ការផលិត បំណែកយានយន្ត និង គ្រឿងបន្លាស់យានយន្ត ដែលមានទុនវិនិយោគសមមូលទាបជាង ៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក។

២៤- ការផ្គត់ផ្គង់ទឹកស្អាត ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក។

២៥- ឧស្សាហកម្មគាំទ្រដែលផលិតផល ១០០ (មួយរយ) ភាគរយ ផ្គត់ផ្គង់ឱ្យឧស្សាហកម្មនាំចេញ ដែលមានទុនវិនិយោគសមមូលទាបជាង ១០០.០០០ (មួយរយពាន់) ដុល្លារអាមេរិក។

២៦- មជ្ឈមណ្ឌលតាំងពិពណ៌ពាណិជ្ជកម្មអន្តរជាតិ និងសាលសន្និសីទ ដែលមានទុនវិនិយោគសមមូលទាបជាង ៨.០០០.០០០ (ប្រាំបីលាន) ដុល្លារអាមេរិក។

២៧- ការសាងសង់ផ្សារទំនើប ឬ មជ្ឈមណ្ឌលពាណិជ្ជកម្ម ដែលមានទុនវិនិយោគសមមូលទាបជាង ២.០០០.០០០ (ពីរលាន) ដុល្លារអាមេរិក មានទំហំតិចជាង ១០.០០០ (ដប់ពាន់) ម៉ែត្រក្រឡា និងមិនមានកន្លែងចតរថយន្តគ្រប់គ្រាន់។

២៨- ការផលិត ចំណីសត្វ ដែលមានទុនវិនិយោគសមមូលទាបជាង ២០០.០០០ (ពីររយពាន់) ដុល្លារអាមេរិក។

២៩- ការផលិត សម្ភារៈធ្វើពីកុលាលភាជន៍ ដែលមានទុនវិនិយោគសមមូលទាបជាង ៣០០.០០០ (បីរយពាន់)ដុល្លារអាមេរិក។

៣០- វិទ្យាស្ថានបង្ហាត់បង្រៀន និងអប់រំ ដែលធ្វើការបំពាក់បំប៉នលើមុខជំនាញ បច្ចេកវិទ្យា ឬ ពហុបច្ចេកទេស ចំពោះវិស័យ ឧស្សាហកម្ម កសិកម្ម ទេសចរណ៍ ហេដ្ឋារចនាសម្ព័ន្ធ បរិស្ថាន វិស្វកម្ម វិទ្យាសាស្ត្រ និង សេវាកម្មផ្សេងទៀត ដែលមានទុនវិនិយោគសមមូលទាបជាង ៤.០០០.០០០ (បួនលាន) ដុល្លារអាមេរិក។

៣១- សណ្ឋាគារក្រោមកម្រិតផ្កាយ ៣ (បី)។

៣២- មជ្ឈមណ្ឌលទេសចរណ៍ ដែលមានសណ្ឋាគារមានបន្ទប់តិចជាង ១០០ (មួយរយ) បន្ទប់ ឬ មានសណ្ឋាគារបែបលំនៅដ្ឋាន តិចជាង ៣០ (សាមសិប) លំនៅដ្ឋាន និងមានរមណីយដ្ឋានដែលមានសេវាកម្មចម្រុះ ដែលមានទំហំតិចជាង ១០ (ដប់)ហិកតា។

៣៣- ទេសចរណ៍ធម្មជាតិ និង ការបង្កើតតំបន់ទេសចរណ៍ធម្មជាតិ ដែលមានផ្ទៃដីតិចជាង ១.០០០ (មួយពាន់)ហិកតា និងមានទុន វិនិយោគសមមូលទាបជាង ១.០០០.០០០ (មួយលាន) ដុល្លារអាមេរិក។

៣៤- រមណីយដ្ឋានដែលមានសេវាកម្មចម្រុះ រួមមាន សណ្ឋាគារ សួនកំសាន្ត កន្លែងហាត់កីឡា សួនសត្វ ដែលមានទំហំតិចជាង ៥០ (ហាសិប) ហិកតា។

៣៥- ចំណតរថយន្ត។

៣៦- មណ្ឌលឃ្លាំងទំនិញ។

៣៧- មន្ទីរពហុព្យាបាលជម្ងឺ ដែលមានគ្រែតិចជាង ៥០ (ហាសិប)គ្រែ មិនមានការបំពាក់នូវឧបករណ៍ទំនើប បន្ទប់ពិសោធន៍ បន្ទប់វះកាត់ បន្ទប់កាំរស្មីអ៊ិច បន្ទប់សង្គ្រោះបន្ទាន់ ឱសថស្ថាន ជណ្ដើរយន្ត (ក្នុងករណីមានអាគារលើសពី ៣ (បី)ជាន់) រថយន្តសង្គ្រោះបន្ទាន់ សាលដាក់ដំកល់សព និងដែលមានទុនវិនិយោគសមមូលទាបជាង ១.០០០.០០០ (មួយលាន) ដុល្លារអាមេរិក។

៣៨- ផលិតកម្មឱសថសម័យ ដែលមានទុនវិនិយោគសមមូលទាបជាង ១.០០០.០០០ (មួយលាន) ដុល្លារអាមេរិក។

៣៩- ផលិតកម្មឱសថបុរាណ ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក។

៤០- ផលិតកម្មកសិកម្ម

| | |
|---|---|
| ៤០.១ ដំណាំស្រូវ | តិចជាង ១.០០០ (មួយពាន់) ហិកតា។ |
| ៤០.២ ដំណាំរួបីយវត្ថុគ្រប់ប្រភេទ | តិចជាង ៥០០ (ប្រាំរយ) ហិកតា។ |
| ៤០.៣ បន្លែ | តិចជាង ៥០ (ហាសិប) ហិកតា។ |

៤១- ផលិតកម្មបសុសត្វ

| | |
|---|---|
| ៤១.១ ការចិញ្ចឹមសត្វចតុបាទ | តិចជាង ១.០០០ (មួយពាន់) ក្បាល។ |

៤១.២ កសិដ្ឋានចិញ្ចឹមគោយកទឹកដោះ តិចជាង ១០០ (មួយរយ) ក្បាល។

៤១.៣ កសិដ្ឋានចិញ្ចឹម បសុបក្សីយកសាច់ និង ស៊ុត តិចជាង ១០.០០០ (ដប់ពាន់) ក្បាល។

៤២- ផលិតកម្មជលផល

៤២.១ កសិដ្ឋានវារីវប្បកម្ម ទឹកសាប តិចជាង ៥ (ប្រាំ) ហិកតា។

៤២.២ កសិដ្ឋានវារីវប្បកម្ម សមុទ្រ តិចជាង ១០ (ដប់) ហិកតា។

៤៣- ការដាំឈើ រុក្ខជាតិ និង ការចិញ្ចឹមសត្វព្រៃផ្សេងៗ ÷

៤៣.១ ការដាំដើមឈើ តិចជាង ១.០០០ (មួយពាន់) ហិកតា។

៤៣.២ ការដាំរុក្ខជាតិផ្សេងៗ តិចជាង ២០០ (ពីររយ) ហិកតា។

៤៣.៣ ការចិញ្ចឹមថនិកសត្វព្រៃ តិចជាង ១០០ (មួយរយ) ក្បាល។

៤៣.៤ ការចិញ្ចឹមបក្សីព្រៃ តិចជាង ៥០០ (ប្រាំរយ) ក្បាល។

៤៣.៥ ការចិញ្ចឹមឧរង្គសត្វព្រៃ តិចជាង ១.០០០ (មួយពាន់) ក្បាល។

និយមន័យនៃចំណុច ៤៣ ខាងលើ នឹងកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

៤៤- ការបង្កក និង ការកែច្នៃនាំចេញ នូវជលផល និង កសិផល ÷

៤៤.១ ការកែច្នៃ និង បង្កកផលិតផលជលផល សំរាប់នាំចេញ ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក។

៤៤.២ ការកែច្នៃកសិផលគ្រប់ប្រភេទ ដើម្បីនាំចេញ ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក។

៤៥- ការផ្គត់ផ្គង់សេវាតម្លៃបន្ថែម នៃវិស័យសេវាទូរគមនាគមន៍គ្រប់ប្រភេទ ។

៤៦-ការអភិវឌ្ឍន៍ផ្នែកអចលនវត្ថុ។

<u>ផ្នែកទី ៣ : សកម្មភាពវិនិយោគដែលមានលក្ខណៈពិសេស ហើយដែលត្រូវទទួលការលើកទឹកចិត្តផ្នែកពន្ធគយលើការនាំចូល តែមិនទទួលបានការលើកទឹកចិត្តផ្នែកពន្ធលើប្រាក់ចំណេញ :</u>

១- សេវាទូរគមនាគមន៍មូលដ្ឋាន។

២- សិក្សាស្រាវជ្រាវ ឧស្ម័ន ប្រេងកាត និងរ៉ែគ្រប់ប្រភេទ រួមទាំងមូលដ្ឋានផ្គត់ផ្គង់សំរាប់ឧស្ម័ន និងប្រេងកាត។

## ឧបសម្ព័ន្ធទី ២

នៃអនុក្រឹត្យលេខ១១១.អនក្រ.បក.ចុះថ្ងៃទី២៧.ខែកញ្ញា...ឆ្នាំ ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម
នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

## ពាក្យស្នើវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា (មាត្រា ៥.២)

### I- **ទេនាសម្ព័ន្ធក្រុមហ៊ុន** :

*ក.ព័ត៌មានទូទៅ*

- ឈ្មោះ បុគ្គល មានរូបវ័ន្ត ឬ នីតិបុគ្គល) :.................................................................................

- អាសយដ្ឋាន:-ទីស្នាក់ការបុគ្គល :.......................................................................Tel:......................

Fax:......................................E-mail :....................................................................

-ឈ្មោះបុគ្គលមេ :.................................................អាសយដ្ឋាន..............................................

.................................................Tel:..................................Fax:......................

Website:......................................E-mail:....................................................................

- ទ្រង់ទ្រាយក្រុមហ៊ុន : ( *សូមគូស ✓ ក្នុងប្រអប់☐* )

☐ ក្រុមហ៊ុនមូលធន (Corporation) ☐ ក្រុមហ៊ុនសហកម្មសិទ្ធិ (Partnership)

☐ ក្រុមហ៊ុនពាណិជ្ជកម្មបរទេស (Foreign Company)

*កំណត់សម្គាល់* : ក្រុមហ៊ុនមូលធនរួមមាន : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនឯកបុគ្គលទទួលខុសត្រូវមានកម្រិត (Single Member Private Limited Company)

- ទុនចុះបញ្ជី.........................................................................បរទេស...........% ក្នុងស្រុក................%

- លិខិតបញ្ជាក់ប្រាក់តម្កល់នៅធនាគារ ២៥%លេខ.........................................

*ខ.សមាសភាពក្រុមហ៊ុន*

<u>ម្ចាស់ភាគហ៊ុន</u>

| នាមត្រកូល និងនាមខ្លួន | សញ្ជាតិ | លេខ និងកាលបរិច្ឆេទអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន | អាសយដ្ឋាន | អត្រាភាគហ៊ុន% |
|---|---|---|---|---|
| ១......................<br>២......................<br>៣......................<br>៤...................... | | | | |

<u>សមាសភាពក្រុមប្រឹក្សាភិបាល (រួមទាំងតតិយជន)</u>

| នាមត្រកូល និងនាមខ្លួន | សញ្ជាតិ | លេខ និងកាលបរិច្ឆេទ អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន | អាសយដ្ឋាន | តួនាទីក្នុងក្រុមហ៊ុន | អ្នកដែលមានសិទ្ធិចុះហត្ថលេខា សម្រាប់កិច្ចការ |
|---|---|---|---|---|---|
| ១......................<br>២......................<br>៣...................... | | | | | |

## II- ពាក្យស្នើសុំវិនិយោគ :

### *ក. ព័ត៌មានទូទៅ*

- សកម្មភាពវិនិយោគ : ....................................................................................................................................

- វិស័យវិនិយោគ : ( *សូមគូស ✓ ក្នុងប្រអប់☐* )

☐ កសិកម្ម-កសិ-ឧស្សាហកម្ម ☐សំណង់ស៊ីវិល ☐ ថាមពល ☐ ហិរញ្ញវត្ថុ ☐ ឧស្សាហកម្ម ☐ ធនធានរ៉ែ
☐ ទេសចរណ៍ ☐ ដឹកជញ្ជូន ☐ទូរគមនាគមន៍ ☐ទីកស្អាត ☐តំបន់ឧស្សាហកម្ម ☐ផ្សេងៗ

- អ្នកដាក់ពាក្យសុំ :
  - ឈ្មោះ.......................................................អាស័យដ្ឋាន :...................................................................................
  - តួនាទីក្នុងក្រុមហ៊ុន : ...............................................................Tel :............................................Fax : ..............................
  - លិខិតប្រគល់សិទ្ធិ ( *បើសិនមិនមានតួនាទីក្នុងក្រុមហ៊ុន* ) : លេខ ................ ចុះថ្ងៃទី.........ខែ.........ឆ្នាំ............

- ទុនវិនិយោគសរុប : ...................................................................ក្នុងនោះទុនលើ :
  - សំណង់អាគារ/រៀបចំការដ្ឋាន .........................ម² តម្លៃ:............................USD អាគារមានស្រាប់ ☐ អាគារថ្មី ☐
  - សម្ភារៈបរិក្ខាផលិតកម្ម (គ្រឿងចក្រ-គ្រឿងម៉ាស៊ីនផលិតកម្ម-សម្ភារៈបរិក្ខាផ្សេងៗ) តម្លៃ(USD) :..............................
  ( មានបញ្ជីជូនភ្ជាប់ តាមទម្រង់ដូចមានចែងក្នុងឧបសម្ព័ន្ធ )
  - សម្ភារៈការិយាល័យតម្លៃ (USD) :......................................................................................................................
  - ផ្សេងៗតម្លៃ (USD) : ....................................................................................................................................

- ដីធ្លី (ទំហំ ម²) : .........................................................................តម្លៃ ..................................USD

- ប្រភពទុនវិនិយោគ : ទុនផ្ទាល់:....................................ឥណទានធនាគាររយៈពេលវែង :..............................
ឥណទានធនាគាររយៈពេលខ្លី :...................................................

- ទីតាំងវិនិយោគ : ដីឡូត៍លេខ...................ផ្លូវលេខ.........................ភូមិ :........................ឃុំ សង្កាត់ :................................
ស្រុក/ខណ្ឌ :................................ខេត្ត ក្រុង :.............................ទំហំ :.................................ម²

- កម្មវិធីអនុវត្តគម្រោង :
  - ចាប់ផ្តើមសាងសង់ : .................................... ព្យាករណ៍បញ្ចប់ការសាងសង់......................................
  - ពេលបំពាក់គ្រឿងម៉ាស៊ីន :............................. ចាប់ផ្តើមដំណើរការផលិតកម្ម.......................................

- ព័ត៌មានស្តីពីផលិតផល :

| ប្រភេទផលិតផល | ឯកតា | សមត្ថភាពផលិតប្រចាំឆ្នាំ | | | | ទីផ្សារ | |
|---|---|---|---|---|---|---|---|
| | | ឆ្នាំដំបូង | | ពេញផលិតកម្ម | | ក្នុងស្រុក | នាំចេញ |
| | | បរិមាណ | តម្លៃ | បរិមាណ | តម្លៃ | គិតជា % | គិតជា % |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

-តម្រូវការពលកម្ម

| ប្រភេទពលកម្ម | ពេលចាប់ផ្ដើម | | ពេលពេញសមត្ថភាព | |
|---|---|---|---|---|
| | ក្នុងស្រុក | បរទេស | ក្នុងស្រុក | បរទេស |
| - អ្នកគ្រប់គ្រង | | | | |
| - វិស្វករ | | | | |
| - អ្នកបច្ចេកទេស | | | | |
| - ទីប្រឹក្សា | | | | |
| - បុគ្គលិកការិយាល័យ | | | | |
| - កម្មករជំនាញ | | | | |
| - កម្មករគ្មានជំនាញ | | | | |
| សរុប | | | | |

- តម្រូវការធាតុចូលផលិតកម្ម (វត្ថុធាតុដើម) ប្រចាំឆ្នាំ : *បំពេញតាមទម្រង់ដូចមានចែងក្នុងឧបសម្ព័ន្ធភ្ជាប់មកជាមួយ*
- តម្រូវការថាមពល និង ទឹក :
  - ធ្យូងថ្ម ឬអុសប្រចាំឆ្នាំ :..................................ម៣/ឆ្នាំ, ឧស្ម័ន:........................................តោន/ឆ្នាំ
  - ប្រេងឥន្ធនៈ :.....................................................តោន ឬលីត្រ/ឆ្នាំ
  - អគ្គិសនី (អនុភាពតម្លើង) :...........................MW តម្រូវការប្រចាំឆ្នាំ :................................KWH
  - ប្រើប្រាស់ទឹក :..................................................ម៣/ឆ្នាំ

*ខ.ការជ្រើសរើសរបប* :
□ ការលើកលែងពន្ធលើប្រាក់ចំណេញ និងការធានាលើការវិនិយោគ
□ ការរំលោះពិសេស និង ការធានាលើការវិនិយោគ
□ ការធានាលើការវិនិយោគ (មិនទាមទារការលើកទឹកចិត្ត)

*(ក្នុងចំណោមជម្រើសទាំងបីនេះ អ្នកវិនិយោគមានសិទ្ធិទទួលបានតែមួយប៉ុណ្ណោះ)*

*គ.ព័ត៌មានស្ដីពីបរិស្ថាន* :

- រូបភាពនៃការដឹកជញ្ជូនវត្ថុធាតុដើម និងផលិតផលសម្រេចចេញ-ចូល ទីតាំងវិនិយោគ :

........................................................................................................................................

........................................................................................................................................

........................................................................................................................................

..........................................................................ប៉ាន់ស្មានបរិមាណ :

សំណល់រាវ :............................ ម៣/ខែ សំណល់រឹង :........................ម៣ ឬ តោន/ ខែ

ឧស្ម័នដែលត្រូវបញ្ចេញ : ......................................................./ ថ្ងៃ

- តារាងប៉ាន់ស្មាននៃកំហាប់ក្នុង :

*ដំណើរការបញ្ចេញទឹកស្អុយ*

- pH:........................................ - អាម៉ូញាក់ Ammonia ($NH_3$)........................................
- នីត្រាតអាសូត Nitrate Nitrogen........................ - លោហៈធ្ងន់ Heavy Metal........................................
- ផេណុល Phenol ($C_6H_5OH$)........................ - ប្រេង និងខ្លាញ់ Oil and Grease........................................
- ភាពល្អក់ Turbidity........................................ - ភាពចម្លងអគ្គិសនី Conductivity........................................
- ចំនួនសរុបនៃសារធាតុរឹងដែលរលាយក្នុងទឹក ........................................
- ចំនួនសរុបនៃសារធាតុរឹងដែលរងកករចុះទៅក្នុងទឹក........................................

*ការបំភាយភាគល្អិតតូចៗនៃឧស្ម័នក្នុងខ្យល់*

- កាបូនម៉ូណូអុកស៊ីត Carbon mono-oxide........................ - អាសូតឌីអុកស៊ីត Nitrogen dioxide........................
- អុកស៊ីតស៊ុលផួរិច Sulfur Oxide........................................ - អូស៊ូន Ozone........................................
- សំណរ Lead........................................

- ទីតាំងដែលប្រើសម្រាប់បោះបង់សំណល់រឹង បង្ហូរសំណល់រាវ និងការបញ្ចេញឧស្ម័ន

........................................................................................................................
........................................................................................................................
........................................................................................................................
........................................

- ប្រភពដែលមានសម្លេង និងភាពរំញ័រខ្ពស់កើនឡើង

........................................................................................................................
........................................................................................................................
........................................................................................................................
........................................

- ទំហំផ្ទៃដីដែលនឹងគ្រប់ដណ្តប់ សម្ទេងករណីចាក់ដីបំពេញ-ការឈូសឆាយ និងការរានដីថ្មី

........................................................................................................................
........................................................................................................................
........................................................................................................................
........................................

- ស្ថានភាពស្នាក់នៅរបស់បុគ្គលិក-កម្មករ

- ផ្គត់ផ្គង់ទឹកស្អាត :........................................................................................
- សុខភាព-សុវត្ថិភាព : ........................................................................................
- អនាម័យ : ........................................................................................
- ការគ្រប់គ្រងសំណល់រឹង :........................................................................................

*ឃ. ព័ត៌មានស្តីពីពន្ធដារ*

បំពេញតាមទម្រង់បែបបទ ( Form ) ដូចមានឧបសម្ព័ន្ធជូនភ្ជាប់។

*ង. ព័ត៌មានស្តីពីលក្ខន្តិកៈ*

ជូនភ្ជាប់មកជាមួយនូវលក្ខន្តិកៈរបស់ក្រុមហ៊ុន រូបថត លិខិតថតចម្លងលិខិតឆ្លងដែន ឬ អត្តសញ្ញាណប័ណ្ណ របស់ម្ចាស់ភាគហ៊ុននិមួយៗ។

III- ការធានា : ខ្ញុំបាទនាមម្ចាស់គម្រោងសូមធានាអះអាងថា

- គម្រោងនេះមិនស្ថិតក្នុងបញ្ជីអវិជ្ជមាន ដូចមានចែងក្នុងឧបសម្ព័ន្ធទី ១ ផ្នែកទី១ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាទេ។
- ព័ត៌មានខាងលើនេះ គឺពិតជាត្រឹមត្រូវ ដោយមិនមានចេតនាក្លែងបន្លំឡើយ ។

ធ្វើនៅ............ថ្ងៃទី.........ខែ ...............ឆ្នាំ..............

ហត្ថលេខា



## ឧបសម្ព័ន្ធទី ២-១

នៃអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា....ឆ្នាំ ២០០៥

ស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

### តារាងតម្រូវការសម្ភារៈបរិក្ខារផលិតកម្ម

សម្រាប់គម្រោងវិនិយោគ.......................................................................................

| ល.រ | រាយមុខទំនិញ | ឯកតា | បរិមាណ | តម្លៃឯកត្តា (USD) | តម្លៃសរុប (USD) | ប្រភព | |
|---|---|---|---|---|---|---|---|
| | | | | | | ក្នុងស្រុក | នាំចូល |
| | 1 | 2 | 3 | 4 | 5 | 6 | 7 |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | សរុប | | | | | | |

## <u>ឧបសម្ព័ន្ធទី ២-២</u>

នៃអនុក្រឹត្យលេខ១១១.អនក្រ.បក.ចុះថ្ងៃទី២៧..ខែកញ្ញា....ឆ្នាំ ២០០៥

ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

### តារាងតម្រូវការធាតុចូលផលិតកម្ម

សម្រាប់គម្រោងវិនិយោគ.................................................................

| ល.រ | រាយមុខទំនិញ | ឯកតា | តម្លៃឯកត្តា (USD) | តម្រូវការប្រចាំឆ្នាំ | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | ក្នុងស្រុក | | នាំចូល | | |
| | | | | បរិមាណ | តម្លៃសរុប (USD) | បរិមាណ | តម្លៃសរុប (USD) | |
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | សរុប | | | | | | | |

## ឧបសម្ព័ន្ធទី ៣

នៃអនុក្រឹត្យលេខ១១១.អនក្រ.បក.ចុះថ្ងៃទី២៧.ខែកញ្ញា....ឆ្នាំ ២០០៥ ស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្ម
នៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

(មាត្រា ៦.៣)

បញ្ជីមានលក្ខខណ្ឌ នៃគម្រោងវិនិយោគ អនុលោមទៅតាមច្បាប់ស្ដីពីវិនិយោគ និង អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

ឈ្មោះ អ្នកវិនិយោគ :........................................................................................................

អាសយដ្ឋាន នៃអ្នកវិនិយោគ :..............................................................................................

ការរាយលម្អិតអំពីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

...........................................................................................................................................

...........................................................................................................................................

ឈ្មោះ អាសយដ្ឋាន និង លេខទំនាក់ទំនងលម្អិត របស់បុគ្គលតំណាងអ្នកវិនិយោគនៅកម្ពុជា..............................

...........................................................................................................................................

លិខិតយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬ ការចុះបញ្ជីដែលជាតម្រូវការ សម្រាប់ឱ្យគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានលក្ខណៈស្របច្បាប់ក្នុងការអនុវត្តន៍ និងក្រសួង នាយកដ្ឋាន អាជ្ញាធរ ឬភ្នាក់ងាររាជរដ្ឋាភិបាល ដែលទទួលបន្ទុកចេញលិខិតទាំងនេះ នៅពេលអ្នកដាក់ពាក្យសុំបានបំពេញស្របតាមលក្ខណៈវិនិច្ឆ័យនៃសមត្ថកិច្ចពាក់ព័ន្ធ ។

ការអនុម័ត....... ក្រសួង លក្ខណៈវិនិច្ឆ័យ

ជម្រើសរបស់អ្នកវិនិយោគផ្អែកតាមមាត្រា ៥.៥ នៃអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ...........................................................................................................

ជម្រើសរបស់អ្នកវិនិយោគផ្អែកតាមមាត្រា ៥.៧ នៃអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ...........................................................................................................

ការលើកទឹកចិត្ត និងការធានាលើការវិនិយោគ ដែលអ្នកវិនិយោគមានសិទ្ធិទទួល ប្រសិនបើវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរត្រូវបានចេញជូន រួមទាំងរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ តាមមាត្រា ១៤.១ នៃច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ..............................................................................

...........................................................................................................................................

...........................................................................................................................................

លក្ខខ័ណ្ឌ:របស់អ្នកវិនិយោគដែលនឹងដំណើរការគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់.................................

...........................................................................................................................................

# ឧបសម្ព័ន្ធទី ៤

# សារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ នៃព្រះរាជាណាចក្រកម្ពុជា, លេខ០១/សរណន, ០៣ កុម្ភៈ ២០១២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០១. សរណន

# សារាចរណែនាំ
# ស្តីពី
# ការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា

ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបញ្ចូលជាសមាជិកក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក កាលពីថ្ងៃទី២៥និងទី២៦ ខែឧសភា ឆ្នាំ២០១១ នៅទីក្រុងទូបាគូតា ប្រទេសសេណេហ្គាល់ ដោយក្លឹបឆ្នេរស្អាតបំផុតលើពិភពលោក ដោយសារភាពសម្បូរបែបនៃជីវៈចម្រុះ ភាពប្រណីតនៃបរិស្ថានធម្មជាតិ តម្លៃអេកូឡូស៊ីសេដ្ឋកិច្ចសង្គម វប្បធម៌ និងប្រពៃណីក្នុងតំបន់ ព្រមទាំងភាពទាក់ទាញផ្នែកទេសចរណ៍។ ការរីកចម្រើននៃវិស័យសេដ្ឋកិច្ច ទេសចរណ៍ និងកំណើនប្រជាជននៅក្នុងតំបន់ឆ្នេរសមុទ្រ ក៏ដូចជានៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូលទាមទារឲ្យមានការអភិវឌ្ឍផ្នែករូបវន្តសមស្រប ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជា មានផែនការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរឲ្យបានត្រឹមត្រូវ មានប្រសិទ្ធភាពនិងចីរភាព ដើម្បីចៀសវាងនិងទប់ស្កាត់ផលប៉ះពាល់ដល់ការអភិវឌ្ឍទេសចរណ៍ សេដ្ឋកិច្ចសង្គម បរិស្ថានវប្បធម៌ និងប្រពៃណីក្នុងតំបន់ឆ្នេរសមុទ្រ។

រាជរដ្ឋាភិបាលកម្ពុជាដាក់ចេញនូវសារាចរនេះ ដើម្បីណែនាំដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិឲ្យអនុវត្តនូវគោលការណ៍គ្រប់គ្រង ប្រើប្រាស់ ថែរក្សា ការពារ និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ដែលរួមមានដែនគោក កោះ និងដែនទឹកដូចខាងក្រោម៖

## ១. ឆ្នេរសមុទ្រ

ឆ្នេរសមុទ្រត្រូវកំណត់ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតនៃទឹកសមុទ្រឡើងមកលើ រហូតដល់ខ្សែបន្ទាត់ហាមឃាត់ការកាន់កាប់ឬសាងសង់នានាជាថ្មី ដី ឬខ្សាច់ដែលបានកំណត់ទុកជាតំបន់សម្រាប់ប្រើប្រាស់ជាសាធារណៈ និងត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ។ ទំហំឆ្នេរសមុទ្រត្រូវកំណត់ដូចខាងក្រោម៖

- ឆ្នេរជម្រាលត្រូវកំណត់យ៉ាងតិច៣០(សាមសិប)ម៉ែត្រ ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតទៅខាងដីគោក។
- ឆ្នេរចោតត្រូវកំណត់យ៉ាងតិច២០(ម្ភៃ)ម៉ែត្រចាប់ពីចំណុចកំពូលនៃផ្ទៃចោតមកខាងដីគោក។

ក្នុងករណីដែលស្ថានភាពទីតាំងជាក់ស្តែងនៃឆ្នេរជម្រាលមិនអាចកំណត់តាមទំហំខាងលើបាន ទំហំឆ្នេរសមុទ្រត្រូវកែច្នៃឬពង្រីកបន្ថែមដើម្បីបង្កើតជាឆ្នេរសម្រាប់ដើរលេងកម្សាន្តប្រសិនបើអាចធ្វើទៅបាន។

នៅលើឆ្នេរសមុទ្រ អាចអនុញ្ញាតឲ្យដាក់ឆត្រ កៅអី និងតុតូចៗតាមចំនួនសមស្រប ដែលអាចផ្លាស់ប្តូរទីតាំងបាន សម្រាប់គោលដៅសម្រាកលំហែកាយនិងត្រូវរៀបចំដាក់តូបឆ្មាំឆ្នេរសមុទ្រ ដោយបំពាក់សម្ភារៈ និងឧបករណ៍ចាំបាច់តាមតម្រូវការ ដើម្បីឃ្លាំមើលនិងការពារសុវត្ថិភាពជូនសាធារណជននិងអ្នកទេសចរ។

## ២- ដីចំណីឆ្នេរសមុទ្រនិងការប្រើប្រាស់

ដីចំណីឆ្នេរសមុទ្រ ជាទូទៅប្រើប្រាស់សម្រាប់ជាសួនបៃតងនិងបណ្តាញទេសភាពឬសម្រាប់ដាំដើមឈើសម្គាល់ព្រំឆ្នេរនិងចំណីឆ្នេរដោយបន្តទៅជាប់នឹងផ្លូវសាធារណៈដែលស្ថិតក្នុងទិសខាងដីគោក។

### ២.១- ដីចំណីឆ្នេរសមុទ្រ

ដីចំណីឆ្នេរសមុទ្រ គឺជាផ្ទៃដីដែលចាប់រាប់ពីខ្សែបន្ទាត់ឆ្នេរខាងលើមកទិសខាងដីគោក។ ដីចំណីឆ្នេរសមុទ្រជាដីសាធារណៈរបស់រដ្ឋ លើកលែងតែមានការកាន់កាប់ស្របច្បាប់។

ប្រវែងឬទំហំដីចំណីឆ្នេរសមុទ្រ ត្រូវកំណត់ដូចខាងក្រោម៖

- ប្រវែងទទឹងដីចំណីឆ្នេរសមុទ្រ ត្រូវកំណត់យ៉ាងតិច៥០(ហាសិប)ម៉ែត្រគិតពីខ្សែបន្ទាត់ឆ្នេរខាងលើទៅខាងដីគោក
- ក្នុងករណីដែលតាមបណ្តោយឆ្នេរសមុទ្រមានផ្លូវសាធារណៈរួចហើយ ដីចំណីឆ្នេរសមុទ្រអាចកំណត់មកទល់នឹងផ្លូវសាធារណៈនេះ។

### ២.២- ការប្រើប្រាស់ដីចំណីឆ្នេរសមុទ្រ

ការប្រើប្រាស់ដីចំណីឆ្នេរសមុទ្រមានលក្ខណៈពិសេសដោយឡែកៗពីគ្នា តាមស្ថានភាពទីតាំងនីមួយៗ៖

**ទី១- ដីចំណីឆ្នេរសមុទ្រដែលមានមនុស្សរស់នៅច្រើននិងមានលក្ខណៈជាទីប្រជុំជនឬមានសកម្មភាពទេសចរណ៍ ការប្រើប្រាស់ ត្រូវបានកំណត់ដូចខាងក្រោម៖**

- អាចអនុញ្ញាតឲ្យសាងសង់ជាសំណង់តូបតូចៗសម្រាប់បម្រើដល់សេវាកម្មទេសចរណ៍នៅចន្លោះដើមឈើដែលមានចម្ងាយពីតូបមួយទៅតូបមួយទៀតយ៉ាងតិច១៥(ដប់ប្រាំ)ម៉ែត្រ ដើម្បីសម្រួលដល់ការឆ្លងកាត់របស់សាធារណជននិងអ្នកទេសចរ និងរក្សាគំហើញទៅលំហសមុទ្រ។ សំណង់តូបតូចៗនេះត្រូវរៀបចំឲ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសនិងមានច្រកដើរចេញចូលច្បាស់លាស់ដើម្បីចៀសវាងផលប៉ះពាល់ដល់សួនច្បារនិងទេសភាពបៃតង
- អាចអនុញ្ញាតឲ្យមានសំណង់ជានិមិត្តរូបផ្សេងៗ ជាលក្ខណៈរូបចម្លាក់ស្តូប ឬសិល្បៈសាធារណៈ
- អាចអនុញ្ញាតឲ្យមានចំណតយានយន្តទេសចរគ្រប់ប្រភេទចូលចតក្នុងបរិវេណដីចំណីឆ្នេរសមុទ្រ ដែលមិនប៉ះពាល់ដល់សួនច្បារ និងទេសភាពបៃតង
- អាចអនុញ្ញាតឲ្យសាងសង់ជាបង្គន់អនាម័យសាធារណៈដែលមានលក្ខណៈសោភណភាព និងចំនួនសមស្រប សម្រាប់បម្រើដល់សាធារណជននិងអ្នកទេសចរ ដោយស្ថិតនៅតាមទីតាំងសមស្របនិងមិនប៉ះពាល់ដល់ទស្សនីយភាពតំបន់
- មិនអាចអនុញ្ញាតឲ្យមានសំណង់កំពង់ផែពាណិជ្ជកម្ម លើកលែងតែកំពង់ផែដែលមានស្រាប់ និងទីតាំងដែលមានសក្តានុពលខ្លាំងនិងចាំបាច់សម្រាប់សាងសង់កំពង់ផែ

- មិនអាចអនុញ្ញាតឲ្យមានសំណង់រឹងមាំនៅលើដីចំណីឆ្នេរសមុទ្រ លើកលែងតែសំណង់នោះត្រូវសាងសង់ឡើងក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈនិងទេសចរណ៍ដូចជា៖
  - ច្រកចូលឬស្ពានសម្រាប់តភ្ជាប់ទៅកំពង់ផែ ដែលមានទូកទេសចរណ៍ឬទូកម៉ាស៊ីនតូចៗសម្រាប់ភ្ញៀវទេសចរឬសាធារណជនប្រើប្រាស់។ កំពង់ផែទាំងនេះត្រូវមានទីតាំងសមស្រប និងមិនរំខានដល់សកម្មភាពឆ្លងកាត់ឆ្នេរសមុទ្រ
  - សារមន្ទីរជីវៈចម្រុះ រុក្ខជាតិសមុទ្រ ត្រីសមុទ្រ(Aquariums) ដែលនៅផ្នែកខាងមុខសំណង់ស្ថាបត្យកម្មនេះអាចឲ្យភ្ញៀវទេសចរឬសាធារណជនអាចឆ្លងកាត់បាន
  - ទីតាំងផ្សេងទៀតដែលរាជរដ្ឋាភិបាលអនុញ្ញាត។

**ទី២- ដីចំណីឆ្នេរសមុទ្រស្ថិតក្នុងតំបន់ដែលមិនមានមនុស្សរស់នៅច្រើននិងមិនមែនជាទីប្រជុំជន ការប្រើប្រាស់ត្រូវបានកំណត់ដូចខាងក្រោម៖**

- អាចអនុញ្ញាតឲ្យមានសំណង់កំពង់ផែ ពាណិជ្ជកម្ម ឬកំពង់ផែនេសាទ។ ចំពោះកំពង់ផែដែលមានស្រាប់ ត្រូវរៀបចំឲ្យមានការគ្រប់គ្រងអនាម័យនិងបរិស្ថាន ជាពិសេស កាកសំណល់រាវនិងកាកសំណល់រឹង។ ក្នុងករណីចាំបាច់ ត្រូវធ្វើការសិក្សាពីផលប៉ះពាល់បរិស្ថាននិងភាពសមស្របនៃទីតាំង ដើម្បីធានាសុវត្ថិភាពសុខុមាលភាពនិងការកាត់បន្ថយហានិភ័យផ្សេងៗ
- អាចអនុញ្ញាតឲ្យមានការរៀបចំជាតំបន់ទេសចរណ៍លើទឹក កំពង់ផែទេសចរណ៍ ឬតំបន់កម្សាន្តថ្មីដោយមានការគ្រប់គ្រងអនាម័យនិងបរិស្ថាន ជាពិសេស កាកសំណល់រាវនិងកាកសំណល់រឹងស្របតាមបទដ្ឋានបច្ចេកទេស ដើម្បីការពារធនធានទឹក ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះ
- អាចអនុញ្ញាតឲ្យមានការរៀបចំជាភូមិទេសចរណ៍នៅក្នុងទីតាំងភូមិឋានថ្មីឬដែលមានស្រាប់ទៅតាមស្ថានភាពនិងសក្តានុពលជាក់ស្តែងនៃទីតាំងនីមួយៗ
- ត្រូវធ្វើការសិក្សាទីតាំងនិងវាយតម្លៃហេតុប៉ះពាល់បរិស្ថានឲ្យបានត្រឹមត្រូវ ស្របតាមបទដ្ឋានបច្ចេកទេស នូវរាល់សំណើសុំធ្វើការអភិវឌ្ឍសំណង់នានា ដូចជា សំណង់រោងចក្រ ឧស្សាហកម្ម រោងជាង និងស្ថានីយផ្សេងៗជាដើម ដែលអាចមានកម្រិតបញ្ចេញផ្សែងពុលខ្ពស់ទៅក្នុងបរិយាកាសនិងបញ្ចេញសំឡេងរំខានខ្លាំងដល់តំបន់ជិតខាង
- អាចអនុញ្ញាតឲ្យមានការអភិវឌ្ឍឬឲ្យមានសំណង់ផ្សេងទៀតស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល។

## ៣- ផ្លូវសាធារណៈតាមបណ្តោយដីចំណីឆ្នេរសមុទ្រ

ផ្លូវសាធារណៈតាមបណ្តោយដីចំណីឆ្នេរសមុទ្រ គឺជាផ្លូវដែលសាងសង់ឡើងនៅជាប់ខ្សែបន្ទាត់ខាងក្រៅនៃដីចំណីឆ្នេរសមុទ្រ ដែលខណ្ឌចែកដីចំណីឆ្នេរសមុទ្រជាមួយតំបន់រណប។ ផ្លូវនេះជារបាំងទប់ស្កាត់ការរំលោភបំពានកាន់កាប់ដីចំណីឆ្នេរសមុទ្រ។

ក្នុងករណីដែលពុំទាន់មានផ្លូវសាធារណៈនេះ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវផ្តួចផ្តើមរៀបចំគម្រោងកសាងផ្លូវនេះនិងដាក់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យភាពសមស្របតាមគោលនយោបាយនិងបទដ្ឋានបច្ចេកទេសរៀបចំដែនដីនិងនគរូបនីយកម្មក្នុងគោលដៅ

ថែរក្សា ការពារ និងលើកកម្ពស់សោភណភាពបរិស្ថានក្នុងតំបន់ឆ្នេរសមុទ្រ។ ផ្លូវនេះត្រូវមានចំណីផ្លូវទំហំយ៉ាងតិច១៥ (ដប់ប្រាំ)ម៉ែត្រពីសងខាងអ័ក្សផ្លូវ។

## ៤- តំបន់រណបតាមបណ្តោយផ្លូវសាធារណៈ

តំបន់រណប គឺជាតំបន់មួយប្លុកស្ថិតនៅចន្លោះផ្លូវសាធារណៈតាមបណ្តោយឆ្នេរសមុទ្រនិងផ្លូវស្របបន្ទាប់មួយទៀត ដែលស្ថិតក្នុងទិសខាងដីគោក។

ការអភិវឌ្ឍនិងការសាងសង់សំណង់នានាក្នុងតំបន់នេះ ត្រូវគោរពតាមប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី និងបទប្បញ្ញត្តិជាធរមាន។ ចំពោះទីតាំងដែលពុំទាន់មានប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់សេចក្តីណែនាំលម្អិតសម្រាប់អនុវត្ត។

ដើម្បីលើកកម្ពស់សោភណភាពបរិស្ថានធម្មជាតិនិងសំណង់ ការអភិវឌ្ឍសំណង់អគារក្នុងតំបន់រណបនេះ ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ត្រូវមានសន្ទស្សន៍ទាប សម្រាប់គ្រប់ប្រភេទសំណង់អគារ ដូចមានចែងក្នុងបទដ្ឋាននគរូបនីយកម្ម
- ត្រូវរៀបចំឲ្យមានសួនច្បារ ដាំស្មៅ ដាំដើមឈើ និងមានផ្លូវថ្មើរជើងនៅលើចិញ្ចើមផ្លូវ ស្របតាមបទដ្ឋានបច្ចេកទេស
- ត្រូវរៀបចំជាលំហសាធារណៈ សួនច្បារ សួនកម្សាន្ត ឬឧទ្យានសាធារណៈជាដើម ដើម្បីលើកកម្ពស់សោភណភាពតំបន់ឆ្នេរសមុទ្រ
- ត្រូវមានលិខិតអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចជាមុនសម្រាប់រាល់ការដាក់តាំងស្លាកសញ្ញាពាណិជ្ជកម្ម។

## ៥- ផ្លូវសាធារណៈ ផ្លូវថ្មើរជើង និងសួនច្បារ ឬបណ្តាញបៃតងក្នុងទិសឆ្ពោះទៅមាត់សមុទ្រ

ផ្លូវសាធារណៈ ផ្លូវថ្មើរជើង និងសួនច្បារ ឬបណ្តាញបៃតងក្នុងទិសឆ្ពោះទៅមាត់សមុទ្រដែលតភ្ជាប់ទៅចំណុចប្រសព្វនឹងផ្លូវដែលជាប់នឹងដីចំណីឆ្នេរសមុទ្រត្រូវ៖

- រក្សាទុកចិញ្ចើមសងខាងយ៉ាងតិច៦(ប្រាំមួយ)ម៉ែត្រ ចំពោះកំណាត់ផ្លូវសាធារណៈនៅក្នុងតំបន់រណប ដើម្បីរៀបចំឲ្យមានសួនច្បារ ការដាំស្មៅ ការដាំដើមឈើព្រមទាំងផ្លូវថ្មើរជើងស្របតាមបទដ្ឋានបច្ចេកទេស
- រៀបចំឲ្យមានសួនច្បារ ការដាំស្មៅ និងការដាំដើមឈើអមសងខាងតាមស្ថានភាពជាក់ស្តែងនិងស្របតាមបទដ្ឋានបច្ចេកទេសចំពោះផ្លូវថ្មើរជើងដែលមានស្រាប់ឬបង្កើតថ្មី
- ត្រូវរៀបចំឲ្យមានសួនច្បារ វាលស្មៅ និងផ្ទៃដីដាំដើមឈើឲ្យបានច្រើនបង្កើតជាបណ្តាញបៃតងភ្ជាប់ទៅនឹងដីចំណីឆ្នេរសមុទ្រ ចំពោះផ្ទៃដីឬលំហសាធារណៈដែលស្ថិតនៅជាប់ផ្លូវសាធារណៈដែលមានស្រាប់ឬបង្កើតថ្មី ដើម្បីលើកកម្ពស់សោភណភាពបរិស្ថាននិងជាការបើកច្រកខ្យល់ជំនោរសមុទ្រ។

## ៦- ដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលតភ្ជាប់ទៅនឹងសមុទ្រ

ដៃសមុទ្រគឺជាផ្ទៃទឹកដែលតភ្ជាប់ទៅនឹងផ្ទៃទឹកសមុទ្រ។ ទំហំផ្ទៃដៃសមុទ្រ ត្រូវកំណត់យកត្រឹមខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុត។ ទំហំដីចំណីដៃសមុទ្រ ត្រូវកំណត់ចម្ងាយ៣០(សាមសិប)ម៉ែត្រយ៉ាងតិចពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុត។

ស្ទឹង ព្រែក ផ្លូវទឹកដែលនាវា ឬកប៉ាល់ចេញចូលបាន បណ្តែតបានគឺជាផ្ទៃទឹកសាបដែលតភ្ជាប់ទៅនឹងផ្ទៃទឹកសមុទ្រ។ ទំហំទទឹងស្ទឹង ព្រែក ផ្លូវទឹកដែលនាវាឬកប៉ាល់ចេញចូលបាន បណ្តែតបាន ត្រូវកំណត់ត្រឹមខ្សែបន្ទាត់កម្រិតទឹកខ្ពស់បំផុតទាំងសងខាងនៅរដូវវស្សា លើកលែងតែមានទឹកជំនន់ខុសធម្មតា។ ទំហំដីចំណីស្ទឹង ព្រែក ផ្លូវទឹកដែលនាវាឬកប៉ាល់ចេញចូលបាន បណ្តែតបាន ត្រូវកំណត់ចម្ងាយ២០(ម្ភៃ)ម៉ែត្រយ៉ាងតិចពីខ្សែបន្ទាត់ទឹកខ្ពស់បំផុតនៅរដូវវស្សា។

ផ្លូវសាធារណៈតាមបណ្តោយដីចំណីដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលនាវាឬកប៉ាល់ចេញចូលបាន បណ្តែតបាន គឺជាផ្លូវដែលសាងសង់ឡើងនៅជាប់ខ្សែបន្ទាត់ខាងក្រៅនៃដីចំណីដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលនាវាឬកប៉ាល់ចេញចូលបាន បណ្តែតបានទាំងនោះ ដែលខណ្ឌចែកដីចំណីដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹក ដែលនាវាឬកប៉ាល់ចេញចូលបាន បណ្តែតបានជាមួយតំបន់រណប។ ផ្លូវនេះជារបាំងទប់ស្កាត់ការរំលោភបំពានកាន់កាប់ដីចំណីដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលនាវាឬកប៉ាល់ចេញចូលបានឬបណ្តែតបាន។

ក្នុងករណីដែលពុំទាន់មានផ្លូវសាធារណៈខាងលើនេះ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្តួចផ្តើមរៀបចំគម្រោងកសាងផ្លូវនេះ និងដាក់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យភាពសមស្របតាមគោលនយោបាយនិងបទដ្ឋានបច្ចេកទេសរៀបចំដែនដីនិងនគរូបនីយកម្ម ក្នុងគោលដៅថែរក្សាការពារនិងលើកកម្ពស់សោភណភាពបរិស្ថានក្នុងតំបន់ឆ្នេរសមុទ្រ។ ផ្លូវនេះត្រូវមានដីចំណីផ្លូវយ៉ាងតិច១០(ដប់)ម៉ែត្រពីសងខាងអ័ក្សផ្លូវ។

នៅតាមបណ្តោយផ្លូវសាធារណៈនេះត្រូវរៀបចំឲ្យមានសួនច្បារ វាលស្មៅ និងផ្ទៃដីដាំដើមឈើឲ្យបានច្រើនបង្កើតជាបណ្តាញបៃតង ដើម្បីលើកកម្ពស់សោភណភាពនិងបរិស្ថាន។

ការអភិវឌ្ឍជាសំណង់អគារផ្សេងៗនៅជាប់ផ្លូវសាធារណៈនេះ ត្រូវមានសន្ទស្សន៍ទាបដូចក្នុងតំបន់រណបតាមបណ្តោយផ្លូវជាប់នឹងដីចំណីឆ្នេរសមុទ្រដែរ។

## ៧- កោះ

កោះ ជាផ្ទៃដីដែលហ៊ុមព័ទ្ធដោយទឹកសមុទ្រ។ ព្រំប្រទល់ដីកោះក្នុងសមុទ្រ ត្រូវកំណត់ត្រឹមខ្សែទឹកជោរអតិបរមាឡើងលើ។ កោះអាចមានទំហំតូច ធំខុសៗគ្នា ដែលអាចប្រើប្រាស់ក្នុងគោលដៅផ្សេងៗ លើកលែងតែមានការកំណត់ដោយឡែក។ កោះអាចជាកម្មវត្ថុសម្រាប់ការរស់នៅនិងការអភិវឌ្ឍ ស្របតាមគោលដៅនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ការពារជាតិ និងទេសចរណ៍។

### ៧.១- ការប្រើប្រាស់និងការអភិវឌ្ឍកោះក្នុងកម្មវត្ថុសម្រាប់ការរស់នៅ

លើកលែងតែមានការហាមឃាត់ដោយច្បាប់ កោះមួយចំនួនអាចត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ជាមណ្ឌលអាសន្ននិងមិនទៀងតាមរយៈកិច្ចសន្យាច្បាស់លាស់។ ការអភិវឌ្ឍកោះក្នុងកម្មវត្ថុនេះ ត្រូវគោរពតាមប្លង់គោលប្រើ

ប្រាស់ដី និងផែនការប្រើប្រាស់ដីព្រមទាំងបទប្បញ្ញត្តិជាធរមានឬតាមផែនការអភិវឌ្ឍដែលរាជរដ្ឋាភិបាលឬក្រសួង ស្ថាប័នមានសមត្ថកិច្ចបានអនុញ្ញាត។

ចំពោះកោះដែលអនុញ្ញាតឲ្យប្រើប្រាស់ក្នុងកម្មវត្ថុនេះ តែពុំទាន់មានប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំសេចក្តីណែនាំលម្អិតសម្រាប់ការអនុវត្ត ស្របតាមស្ថានភាពជាក់ស្តែងនិងគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ត្រូវរក្សានិងការពារធនធានធម្មជាតិ ព្រៃឈើដែលមានស្រាប់ឲ្យបានយ៉ាងតិច៦០%(ហុកសិប)ភាគរយ
- ត្រូវមានសន្ទស្សន៍ទាប ដោយមានផលធៀបក្រឡាផ្ទៃបាតសំណង់ទាបជាង៣៥%(សាមសិបប្រាំ) ភាគរយ ហើយផ្ទៃដីដែលនៅសល់ត្រូវរៀបចំដាំដើមឈើនិងធ្វើជាសួនបៃតងយ៉ាងតិច៥០% (ហាសិប) ភាគរយ
- ត្រូវសាងសង់សំណង់ដែលមានលក្ខណៈជាខ្មែរ
- ត្រូវរៀបចំឲ្យមានលំហសាធារណៈនិងតំបន់កម្សាន្តនានាឲ្យបានច្រើនជាអតិបរមាដើម្បីជំរុញការមកលេងកម្សាន្តរបស់សាធារណជននិងអ្នកទេសចរ
- ត្រូវរៀបចំឲ្យមានកំពង់ផែនាវាចម្លងខ្នាតតូចឬកំពង់ផែទេសចរណ៍ ដែលអាចអនុញ្ញាតឲ្យសាធារណជនទូទៅឬអ្នកទេសចរចេញចូលបាន
- ត្រូវរៀបចំឲ្យមានតំបន់កម្សាន្តនានាក្នុងករណីមានឆ្នេរខ្សាច់ និងរៀបចំកសាងផ្លូវសាធារណៈនៅក្បែរឆ្នេរនេះ ស្របតាមស្ថានភាពនៃទីតាំងរបស់កោះ។ ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធត្រូវផ្តួចផ្តើមរៀបចំគម្រោងកសាងផ្លូវនេះ និងដាក់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យភាពសមស្របតាមគោលនយោបាយនិងបទដ្ឋានបច្ចេកទេសរៀបចំដែនដីនិងនគរូបនីយកម្ម។ ផ្លូវសាធារណៈ ត្រូវមានទំហំសមស្របតាមបទដ្ឋានបច្ចេកទេសនិងតម្រូវការនៃការប្រើប្រាស់យូរអង្វែង
- ត្រូវរៀបចំឲ្យមានការគ្រប់គ្រងកាកសំណល់រឹងនិងរាវ តាមបទដ្ឋានបច្ចេកទេស ដើម្បីចៀសវាងការប៉ះពាល់ដល់បរិស្ថាន
- ត្រូវធ្វើការថែរក្សា ការពារ កែច្នៃ និងប្រើប្រាស់ធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះគ្រប់ប្រភេទដូចជាផ្កាថ្ម ត្រី និងរុក្ខជាតិសមុទ្រជាដើម ដែលមាននៅជុំវិញកោះសម្រាប់គោលដៅទេសចរណ៍។

### ៧.២- ការអភិវឌ្ឍនិងការសាងសង់នៅលើកោះក្នុងកម្មវត្ថុផ្សេងក្រៅពីការរស់នៅ

រាជរដ្ឋាភិបាលកម្ពុជាអាចធ្វើការអភិវឌ្ឍកោះដោយផ្ទាល់ ឬសហការជាមួយវិស័យឯកជនឬផ្តល់សិទ្ធិឲ្យឯកជនធ្វើការអភិវឌ្ឍ ស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល។ បន្ទាប់ពីមានការសម្រេចពីរាជរដ្ឋាភិបាល បុគ្គលដែលទទួលបានសិទ្ធិត្រូវរៀបចំផែនការអភិវឌ្ឍកោះ ជាលក្ខណៈរូបវន្តឲ្យបានសមស្រប និងដាក់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ពិនិត្យភាពសមស្របតាមគោលនយោបាយ និងបច្ចេកទេសរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ការអភិវឌ្ឍនេះ ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ត្រូវមានសន្ទស្សន៍ទាបឬមធ្យម
- ត្រូវការពារធនធានធម្មជាតិនិងរក្សាព្រៃឈើដែលមានស្រាប់ឲ្យបានយ៉ាងតិច៦០%(ហុកសិបភាគរយ)
- ត្រូវសាងសង់សំណង់ដែលមានលក្ខណៈជាខ្មែរ

- ត្រូវរៀបចំប្លង់អភិវឌ្ឍន៍រួបវន្ត ដែលបង្ហាញពីការប្រើប្រាស់ដីតំបន់សាធារណៈ សួនច្បារ សួនឧទ្យាន បណ្តាញបៃតង ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធដូចជាផ្លូវសាធារណៈ ផ្លូវថ្មើរជើង ប្រព័ន្ធលូបង្ហូរ ប្រព័ន្ធចម្រោះទឹកកខ្វក់ ជាដើម ឲ្យបានត្រឹមត្រូវស្របតាមបទដ្ឋានបច្ចេកទេសនិងស្ថានភាពភូមិសាស្ត្រ
- ត្រូវរៀបចំឲ្យមានកំពង់ផែនាវាចម្លងខ្នាតតូចឬកំពង់ផែទេសចរណ៍ ដែលអាចឲ្យអ្នកទេសចរនិងសាធារណជនទូទៅចេញចូលបាន តាមស្ថានភាពជាក់ស្តែងនិងមានទីតាំងសមស្រប
- ត្រូវរៀបចំឲ្យមានការគ្រប់គ្រងកាកសំណល់រឹងនិងរាវ តាមបទដ្ឋានបច្ចេកទេស ដើម្បីចៀសវាងការបោះសំរាម និងការបង្ហូរទឹកកខ្វក់ចូលក្នុងសមុទ្រ មុនពេលធ្វើប្រព្រឹត្តកម្ម
- ត្រូវធ្វើការថែរក្សា ការពារ កែច្នៃ និងប្រើប្រាស់ធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះគ្រប់ប្រភេទ ដូចជាផ្កាថ្ម ត្រី និងរុក្ខជាតិសមុទ្រ ដែលមាននៅជុំវិញកោះ ដើម្បីគោលដៅទេសចរណ៍

៧.៣- ចំពោះកោះដែលមិនមានភាពអំណោយផលដល់ការប្រើប្រាស់និងមិនអាចធ្វើការអភិវឌ្ឍផ្សេងៗបាន ត្រូវរក្សាទុកសភាពដើមសម្រាប់ជាប្រយោជន៍ដល់ការលើកកម្ពស់ទេសភាពសមុទ្រ។

## ៨. ដែនទឹកសមុទ្រ

ដែនទឹកសមុទ្រ សំដៅដល់ផ្ទៃទឹកខាងលើនិងក្នុងទឹក។ នៅក្នុងទឹកមានធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះគ្រប់ប្រភេទ។

ដែនទឹកសមុទ្រ ដែលមានធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះនានា ដូចជា ផ្កាថ្ម ត្រីធំតូចចម្រុះពណ៌ និងរុក្ខជាតិសមុទ្រត្រូវគ្រប់គ្រង ការពារ អភិរក្ស និងអភិវឌ្ឍឲ្យបានត្រឹមត្រូវ មានប្រសិទ្ធភាព និងប្រកបដោយចីរភាព។

ការជិះនាវាឬទូកទេសចរណ៍គ្រប់ប្រភេទ ដូចជាទូកម៉ាស៊ីន អូប័រ ម៉ូតូទឹក ជាដើម អាចធ្វើឡើងតែក្នុងបរិវេណអនុញ្ញាតប៉ុណ្ណោះដើម្បីសុវត្ថិភាពអ្នកទេសចរនិងជីវៈចម្រុះ។

ការអភិវឌ្ឍកំពង់ផែទេសចរណ៍ឬទីតាំងកម្សាន្តបណ្តែតទឹកនិងក្នុងទឹកនានា ត្រូវស្នើសុំការអនុញ្ញាតពីគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍឆ្នេរសមុទ្រកម្ពុជា ដើម្បីពិនិត្យភាពសមស្របនៃទីតាំង តាមគោលនយោបាយ និងបទដ្ឋានបច្ចេកទេសរៀបចំដែនដីនិងនគរូបនីយកម្ម។

ការនេសាទក្នុងតំបន់ដែលមានធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះត្រូវហាមឃាត់ លើកលែងតែការនេសាទជាលក្ខណៈទេសចរណ៍ដោយប្រើប្រាស់ឧបករណ៍នេសាទគ្រួសារ។

ការបូមខ្សាច់និងការសាងសង់សំណង់ផ្សេងៗនៅក្នុងដែនទឹកសមុទ្រ ដូចជាស្ថានីយសិក្សាស្រាវជ្រាវអំពីសមុទ្រ ស្ថានីយរុករករ៉ែជាដើម ត្រូវមានការយល់ព្រមពីរាជរដ្ឋាភិបាល។

រាល់ទីតាំងសំណង់លើទឹកទាំងអស់ ត្រូវរក្សាច្រកផ្លូវនាវាធំៗចេញចូលកំពង់ផែ។

## ៩. ការអភិវឌ្ឍនិងការសាងសង់ក្នុងតំបន់ឆ្នេរសមុទ្រ

៩.១- រាល់ការប្រគល់សិទ្ធិឲ្យឯកជនធ្វើការវិនិយោគនិងអភិវឌ្ឍក្នុងតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- រៀបចំឲ្យមានច្រកចេញចូលនៅតាមបណ្តោយឆ្នេរសមុទ្រ ដើម្បីអាចឲ្យភ្ញៀវទេសចរនិងសាធារណជនចេញចូលដើរលេងកម្សាន្តនិងប្រើប្រាស់បាន

- អនុវត្តតាមប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី និងបទប្បញ្ញត្តិជាធរមាន។ ចំពោះទីតាំងដែលពុំទាន់មានប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវរៀបចំសេចក្តីណែនាំលម្អិតសម្រាប់អនុវត្ត
- ត្រូវរៀបចំឲ្យមានប្រព័ន្ធគ្រប់គ្រងកាកសំណល់រាវ ដោយរៀបចំឲ្យមានអាងចម្រោះ ប្រព័ន្ធលូ និងប្រព័ន្ធគ្រប់គ្រងគុណភាពទឹក និងគ្រប់គ្រងកាកសំណល់រឹង ស្របតាមបទដ្ឋានបច្ចេកទេស ចំពោះរាល់ការអភិវឌ្ឍ
- ត្រូវធ្វើការសិក្សាទីតាំងនិងវាយតម្លៃផលប៉ះពាល់បរិស្ថាន ឲ្យបានត្រឹមត្រូវម៉ត់ចត់ស្របតាមបទដ្ឋានបច្ចេកទេស នូវរាល់សំណើសុំធ្វើការអភិវឌ្ឍសំណង់នានា ដូចជាសំណង់រោងចក្រ ឧស្សាហកម្ម រោងជាងនិងស្ថានីយផ្សេងៗជាដើម ដែលអាចមានកម្រិតបញ្ចេញផ្សែងបំពុលខ្ពស់ទៅក្នុងបរិយាកាស និងកម្រិតបញ្ចេញសំឡេងរំខានខ្លាំងដល់តំបន់ជិតខាង។

៩.២- រាល់ការអភិវឌ្ឍក្នុងតំបន់ឆ្នេរសមុទ្រនិងកោះនិងការធ្វើសកម្មភាពសេដ្ឋកិច្ចនិងទេសចរណ៍ ត្រូវធានាដល់សុវត្ថិភាពសាធារណៈ សង្គម និងបរិស្ថាន ដោយត្រូវគោរពតាមច្បាប់ បទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេសជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

១០- សារាចរណែនាំនេះមិនមានផលប្រតិសកម្មទេ។

១១- សារាចរណែនាំនេះមិនពាក់ព័ន្ធទៅនឹងអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីច្បាប់សមុទ្រ ឆ្នាំ១៩៨២ ទេ។

អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធនឹងតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ព្រមទាំងផែនការគ្រប់គ្រងការអភិវឌ្ឍក្នុងតំបន់ឆ្នេរសមុទ្រជាបន្ទាន់នូវរាល់ទីតាំងទាំងឡាយណាដែលពុំទាន់មានប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ដើម្បីសុំការសម្រេចពីស្ថាប័នមានសមត្ថកិច្ចនិងដាក់ឲ្យប្រើប្រាស់ជាផ្លូវការ។

ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធនៃបណ្តាខេត្តតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តខ្លឹមសារនៃសារាចរណែនាំនេះឲ្យមានប្រសិទ្ធភាពនិងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍ពីលទ្ធផលនៃការអនុវត្តមករាជរដ្ឋាភិបាលវិញ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន**

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី ៥

# ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា,

# លេខ នស/រកត/0២១២/0៧៩, ១៦ កុម្ភៈ ២០១២

# ព្រះរាជក្រឹត្យ

នស/រកត/០២១២/០៣៦៩

## ស្ដីពី

## ការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីទេសចរណ៍
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៣ ខែមករា ឆ្នាំ២០១២

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# គ្រាស់បន្ទាប់

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដែលសរសេរជាអក្សរកាត់ថា គ.អ.ឆ.ក. ជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងនិងការអភិវឌ្ឍនៅតាមតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ប្រកបដោយនិរន្តរភាពនិងការទទួលខុសត្រូវ។

## ជំពូកទី២
## រចនាសម្ព័ន្ធ

**មាត្រា ២.–**

គ.អ.ឆ.ក. មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| - នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | | ប្រធានកិត្តិយស |
| - រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | ប្រធាន |
| - រដ្ឋមន្ត្រីក្រសួងបរិស្ថាន | | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | | អនុប្រធានអចិន្ត្រៃយ៍ |
| - រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការពារជាតិ | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងផែនការ | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល | ០១ រូប | សមាជិក |
| - អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | សមាជិក |
| - អគ្គស្នងការនគរបាលជាតិ | | សមាជិក |
| - មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | | សមាជិក |
| - អភិបាលនៃគណៈអភិបាលខេត្តតំបន់ឆ្នេរសមុទ្រទាំង០៤ | | សមាជិក |
| - តំណាងគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ | ០១ រូប | សមាជិក |
| - តំណាងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | ០១ រូប | សមាជិក |
| - តំណាងអគ្គនាយកដ្ឋានបច្ចេកទេសនៃក្រសួងបរិស្ថាន | ០១ រូប | សមាជិក |

- តំណាងអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្មនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ០១ រូប សមាជិក
- អគ្គលេខាធិការ គ.អ.ឆ.ក. សមាជិក

សមាសភាពជាក់ស្តែងរបស់ គ.អ.ឆ.ក. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា ៣.-**

គ.អ.ឆ.ក. មានភារកិច្ចអនុវត្តការងាររបស់ខ្លួនលើឆ្នេរសមុទ្រ ដីចំណីឆ្នេរសមុទ្រ តំបន់រណប កោះ ដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលតភ្ជាប់ទៅនឹងសមុទ្រ និងផ្ទៃទឹកដែលជាប់នឹងឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា លើទិដ្ឋភាពនគរូបនីយកម្ម បរិស្ថាន និងទេសចរណ៍។

**មាត្រា ៤.-**

ត្រូវបានបង្កើតអគ្គលេខាធិការដ្ឋានមួយជាសេនាធិការជូន គ.អ.ឆ.ក. សម្រាប់ដំណើរការការងារប្រចាំថ្ងៃ ហើយដែលមានទីស្នាក់ការនៅក្រសួងទេសចរណ៍។

## ជំពូកទី៣
## តួនាទីនិងភារកិច្ចរបស់គ.អ.ឆ.ក.

**មាត្រា ៥.-**

គ.អ.ឆ.ក. មានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព កម្មវិធី និងគម្រោងផ្សេងៗ ដែលទាក់ទងនឹងការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ
- រៀបចំបទដ្ឋានគតិយុត្តនិងគោលការណ៍ចាំបាច់នានា ដើម្បីធានាបាននូវការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍនៅតាមតំបន់ឆ្នេរសមុទ្រ ប្រកបដោយតម្លាភាព សមធម៌ និងនិរន្តរភាពបរិស្ថាន
- ពិនិត្យ បង្ការ និងចាត់វិធានការចាំបាច់ ដើម្បីទប់ស្កាត់រាល់សកម្មភាពអសកម្មទាំងឡាយដែលអាចប៉ះពាល់ដល់បរិស្ថាននិងធនធានធម្មជាតិនៅតាមតំបន់ឆ្នេរសមុទ្រ
- ពិនិត្យនិងវាយតម្លៃរាល់គម្រោងអភិវឌ្ឍនិងការអនុវត្តគម្រោងទាំងនេះនៅតាមតំបន់ឆ្នេរសមុទ្រឲ្យស្របតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល សម្រាប់ការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ
- ចូលរួមពិនិត្យនិងផ្តល់មតិជូនស្ថាប័នសមត្ថកិច្ច ចំពោះសំណើសុំវិនិយោគដែលពាក់ព័ន្ធលើឆ្នេរសមុទ្រ ដីចំណីឆ្នេរសមុទ្រ តំបន់រណប កោះ ដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលតភ្ជាប់ទៅនឹងសមុទ្រ និងផ្ទៃទឹកដែលជាប់នឹងឆ្នេរសមុទ្រ
- ពិនិត្យ តាមដាន និងសម្របសម្រួលរាល់សកម្មភាពដែលកំពុងអនុវត្ត គ្រោងនឹងអនុវត្ត របស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការជាតិនិងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិលនានា និងផ្នែកឯកជនដែលមាននៅតាមតំបន់ឆ្នេរសមុទ្រ ដើម្បីឲ្យការងារមានភាពរលូន ប្រកបដោយប្រសិទ្ធភាព និងធានាបាននូវនិរន្តរភាព
- បញ្ជ្រាបការយល់ដឹងដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ផ្នែកឯកជន និងគ្រប់ភាគីពាក់ព័ន្ធឲ្យយល់ដឹងអំពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ
- ធ្វើសហការជាមួយនឹងក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោកនិងស្ថាប័នអន្តរជាតិពាក់ព័ន្ធនានា ដើម្បីជំរុញការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ
- អប់រំ បណ្តុះបណ្តាលធនធានមនុស្ស ដើម្បីឆ្លើយតបនឹងតម្រូវការក្នុងការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ

- ធ្វើសហការជាមួយនឹងក្រសួង ស្ថាប័ន ផ្នែកឯកជន និងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីសម្របសម្រួលការងារខាងលើឲ្យកាន់តែមានប្រសិទ្ធភាព
- រៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ **គ.អ.ឆ.ភ.**
- ធ្វើរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំ ជូនរាជរដ្ឋាភិបាល
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.អ.ឆ.ភ.

**មាត្រា ៦.-**

គ.អ.ឆ.ភ. ត្រូវប្រជុំយ៉ាងតិច២ដងក្នុង១ឆ្នាំតាមការអញ្ជើញរបស់ប្រធាន។

ក្នុងករណីចាំបាច់ ប្រធាន **គ.អ.ឆ.ភ.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន មន្ត្រីជំនាញ អ្នកឯកទេស ឬផ្នែកឯកជនចូលរួមប្រជុំពិគ្រោះ ពិភាក្សាយោបល់ និងសិក្សាស្រាវជ្រាវលើរាល់បញ្ហាទាំងឡាយដែលទាក់ទងនឹងក្របខ័ណ្ឌការងាររបស់ខ្លួន។

ក្នុងករណីដែលប្រធានអវត្តមាន អនុប្រធានមួយរូបអាចដឹកនាំការប្រជុំជំនួសបានតាមការប្រគល់សិទ្ធិពីប្រធាន។

**មាត្រា ៧.-**

គ.អ.ឆ.ភ. មានសិទ្ធិស្នើសុំកម្លាំងអន្តរាគមន៍ ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួនក្នុងករណីចាំបាច់។

**មាត្រា ៨.-**

គ.អ.ឆ.ភ. អាចទទួលយកទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិឬអន្តរជាតិនានាមួយចំនួនតាមការចាំបាច់។

**មាត្រា ៩.-**

អគ្គលេខាធិការដ្ឋាននៃ **គ.អ.ឆ.ភ.** ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ **គ.អ.ឆ.ភ.** ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា ១០.-**

គ.អ.ឆ.ភ. មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងកិច្ចដំណើរការការងាររបស់ខ្លួន។

**មាត្រា ១១.-**

បទបញ្ជាផ្ទៃក្នុង បែបបទ និងនីតិវិធីការងាររបស់ **គ.អ.ឆ.ភ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **គ.អ.ឆ.ភ.**

## ជំពូកទី៥
## ប្រភពធនធាន

**មាត្រា ១២.-**

គ.អ.ធ.ក. មានថវិកាដោយឡែករបស់ខ្លួនដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងទេសចរណ៍។

គ.អ.ធ.ក. មានសិទ្ធិទទួលនិងគ្រប់គ្រងមូលនិធិដែលបានមកពីហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍនិងសហប្រតិបត្តិការអន្តរជាតិ និងពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៤.-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១២

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

[illegible].១២០២.០៥៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

លេខៈ ៩៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ២០១២

អគ្គលេខាធិការ[illegible]រាជរដ្ឋាភិបាល

សយ សុខា

# ឧបសម្ព័ន្ធទី ៦

# អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ គ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា, លេខ១៧១អនក្រ/បក, 0៨ តុលា ២០១២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៧១ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៧៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដែលហៅកាត់ថា "អគ្គលេខាធិការដ្ឋាន **គ.អ.ឆ.ក.**"។

## ជំពូកទី២
## តួនាទីនិងភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន គ.អ.ឆ.ក.

**មាត្រា ២.-**

អគ្គលេខាធិការដ្ឋាន **គ.អ.ឆ.ក.** មានតួនាទីជាសេនាធិការរបស់ **គ.អ.ឆ.ក.** និងមានភារកិច្ចដូចតទៅ៖

- រៀបចំសេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ចាំបាច់នានា ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព កម្មវិធី និងគម្រោងផ្សេងៗដែលទាក់ទងនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដើម្បីដាក់ជូន **គ.អ.ឆ.ក.** ពិនិត្យនិងសម្រេច
- រៀបចំគម្រោងអប់រំ បណ្តុះបណ្តាល និងផ្សព្វផ្សាយដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ផ្នែកឯកជន និងគ្រប់ភាគីពាក់ព័ន្ធ អំពីការអភិរក្សនិងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- ចាត់វិធានការបង្ការនិងទប់ស្កាត់រាល់សកម្មភាពអសកម្មទាំងឡាយដែលអាចប៉ះពាល់ដល់បរិស្ថាននិងធនធានធម្មជាតិនៅតំបន់ឆ្នេរសមុទ្រកម្ពុជា តាមការណែនាំរបស់ **គ.អ.ឆ.ក.**
- លើកសំណើផ្តល់ការសរសើរដល់ការអភិវឌ្ឍនិងប្រើប្រាស់តំបន់ឆ្នេរសមុទ្រកម្ពុជាប្រកបដោយនិរន្តរភាព មានប្រសិទ្ធភាព ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តនិងគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ប្រមូលផ្តុំនិងចងក្រងឯកសារនិងព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- ពិនិត្យនិងផ្តល់យោបល់លើរាល់សំណើសុំវិនិយោគនិងអភិវឌ្ឍនៅតំបន់ឆ្នេរសមុទ្រកម្ពុជាជូន **គ.អ.ឆ.ក.**
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោងនិងសកម្មភាពអភិវឌ្ឍន៍នានានៅតាមតំបន់ឆ្នេរសមុទ្រកម្ពុជា តាមការណែនាំរបស់ **គ.អ.ឆ.ក.**
- តាមដាន ត្រួតពិនិត្យ និងសម្របសម្រួលរាល់សកម្មភាពដែលកំពុងអនុវត្ត គ្រោងនឹងអនុវត្តរបស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការជាតិនិងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិលនានា និងផ្នែកឯកជនដែលមាននៅតាមតំបន់ឆ្នេរសមុទ្រកម្ពុជា ដើម្បីឲ្យការងារមានភាពរលូន ប្រកបដោយប្រសិទ្ធភាព និងធានាបាននូវនិរន្តរភាព តាមការណែនាំរបស់ **គ.អ.ឆ.ក.**
- លើកសំណើធ្វើកិច្ចសហការជាមួយក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោកនិងស្ថាប័នអន្តរជាតិពាក់ព័ន្ធនានា ដើម្បីជំរុញការអភិវឌ្ឍនិងការអភិរក្សតំបន់ឆ្នេរសមុទ្រកម្ពុជា ជូន **គ.អ.ឆ.ក.**
- រៀបចំកិច្ចប្រជុំនានារបស់ **គ.អ.ឆ.ក.** និងរៀបចំរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ អំពីវឌ្ឍនភាពនៃកិច្ចដំណើរការការងាររបស់ **គ.អ.ឆ.ក.** និងធ្វើរបាយការណ៍ផ្សេងៗទៀតជូន **គ.អ.ឆ.ក.**/

- ផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត និងបទដ្ឋានបច្ចេកទេសដែលពាក់ព័ន្ធនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំផែនការសកម្មភាពនិងថវិកា ដើម្បីដាក់ជូន **គ.ស.ឆ.ក.** ពិនិត្យនិងសម្រេច ព្រមទាំងគ្រប់គ្រងថវិកានិងធ្វើរបាយការណ៍អំពីស្ថានភាពចំណូលចំណាយរបស់ **គ.ស.ឆ.ក.**
- សិក្សា ស្រាវជ្រាវ និងធ្វើបច្ចុប្បន្នកម្មឯកសារនានាសម្រាប់ដំណើរការអភិវឌ្ឍនិងសាងសង់នៅតំបន់ឆ្នេរសមុទ្រកម្ពុជា ដែលអាចឆ្លើយតបនឹងតម្រូវការសង្គម សេដ្ឋកិច្ច និងបរិស្ថាន ជូន **គ.ស.ឆ.ក.** ពិនិត្យនិងសម្រេច
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាន **គ.ស.ឆ.ក.** ប្រគល់ជូន។

## ជំពូកទី៣
## រចនាសម្ព័ន្ធនិងការគ្រប់គ្រង

**មាត្រា ៣._**

អគ្គលេខាធិការដ្ឋាន **គ.ស.ឆ.ក.** ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់។

អគ្គលេខាធិការរងបំពេញភារកិច្ចតាមសេចក្ដីសម្រេចស្ដីពីការបែងចែកភារកិច្ចរបស់អគ្គលេខាធិការ។

**មាត្រា ៤._**

អគ្គលេខាធិការដ្ឋាន **គ.ស.ឆ.ក.** មានរចនាសម្ព័ន្ធដូចតទៅ៖

- ផ្នែករៀបចំដែនដីនិងនគរូបនីយកម្ម
- ផ្នែកគ្រប់គ្រងបរិស្ថាននិងធនធានធម្មជាតិ
- ផ្នែកគ្រប់គ្រងនិងអភិវឌ្ឍទេសចរណ៍
- ផ្នែកអប់រំ បណ្ដុះបណ្ដាល ផ្សព្វផ្សាយ និងព័ត៌មានវិទ្យា
- ផ្នែកនីតិកម្មនិងដោះស្រាយវិវាទ
- ផ្នែកទំនាក់ទំនងសាធារណៈនិងសហប្រតិបត្តិការ
- ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន **គ.ស.ឆ.ក.** ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

អគ្គលេខាធិការដ្ឋាន **គ.ស.ឆ.ក.** អាចលើកសំណើកែសម្រួលរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន **គ.ស.ឆ.ក.** តាមការចាំបាច់។

**មាត្រា ៥._**

ផ្នែកនីមួយៗដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួនតាមការចាំបាច់។

ប្រធានផ្នែកមានឋានៈស្មើប្រធាននាយកដ្ឋាន និងអនុប្រធានផ្នែកមានឋានៈស្មើអនុប្រធាននាយកដ្ឋាន។

ផ្នែកនីមួយៗ មានការិយាល័យចំណុះមួយចំនួនតាមការចាំបាច់។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះផ្នែកនីមួយៗត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលជាប្រធាន **គ.ស.ឆ.ក.**។

**មាត្រា ៦._**

អគ្គលេខាធិការដ្ឋាន **គ.ស.ឆ.ក.** មានមន្ត្រីបម្រើការមកពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ត្រីរាជការនៅក្នុង[illegible]មុខងារសាធារណៈផ្សេងទៀត។ ក្នុងករណីចាំបាច់ អគ្គលេខាធិការដ្ឋាន **គ.ស.ឆ.ក.** អាចស្នើសុំ[illegible]កិច្ចសន្យាដើម្បីជួយបំពេញការងារ។

**មាត្រា ៧.-**

អគ្គលេខាធិការដ្ឋាន **គ.អ.ឆ.ក.** មានសិទ្ធិប្រើត្រាដោយឡែករបស់ខ្លួន។

## ជំពូកទី៤
## តួនាទីនិងភារកិច្ចរបស់ផ្នែកនីមួយៗ

**មាត្រា ៨.-**

ផ្នែករៀបចំដែនដីនិងនគរូបនីយកម្ម មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍ ប្លង់គោល និងផែនការប្រើប្រាស់ដី ដែលទាក់ទងនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដើម្បីដាក់ជូន **គ.អ.ឆ.ក.** ពិនិត្យនិងសម្រេច
- ពិនិត្យនិងផ្តល់មតិជូន**គ.អ.ឆ.ក.** លើរាល់គម្រោងអភិវឌ្ឍនិងការអនុវត្តគម្រោងដែលពាក់ព័ន្ធនឹងតំបន់ឆ្នេរសមុទ្រកម្ពុជា លើទិដ្ឋភាពរៀបចំដែនដីនិងនគរូបនីយកម្ម
- រៀបចំនិងចូលរួមសិក្សាស្រាវជ្រាវនិងលើកកម្ពស់វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងផ្តល់ប្រឹក្សាបច្ចេកទេស ដែលពាក់ព័ន្ធនឹងតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំ គ្រប់គ្រង និងធ្វើសមាហរណកម្មទិន្នន័យរូបវន្តដែលទទួលបានពីគ្រប់អង្គភាពពាក់ព័ន្ធ
- រៀបចំបទដ្ឋានបច្ចេកទេសពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីឲ្យមានការឯកភាពនៅតំបន់ឆ្នេរសមុទ្រកម្ពុជា
- សិក្សាស្រាវជ្រាវគោលនយោបាយ បទដ្ឋានគតិយុត្ត យុទ្ធសាស្ត្រ និងផែនការរបស់ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ ដែលទាក់ទងនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- សហការជាមួយផ្នែកនីមួយៗរបស់អគ្គលេខាធិការដ្ឋាន **គ.អ.ឆ.ក.** ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ ចំពោះការងាររៀបចំដែនដីនិងនគរូបនីយកម្មនៃតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំផែនការសកម្មភាព និងធ្វើរបាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការងាររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ តំបន់ឆ្នេរសមុទ្រកម្ពុជាតាមការកំណត់
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ **គ.អ.ឆ.ក.** ប្រគល់ជូន។

**មាត្រា ៩.-**

ផ្នែកគ្រប់គ្រងបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំបទដ្ឋានគតិយុត្តនិងគោលការណ៍ចាំបាច់នានា ដើម្បីធានាបាននូវការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍនៅតាមតំបន់ឆ្នេរសមុទ្រកម្ពុជា ប្រកបដោយតម្លាភាព សមធម៌ និងនិរន្តរភាពបរិស្ថាន
- រៀបចំលក្ខខណ្ឌនិងចាត់ថ្នាក់ធនធានធម្មជាតិដែលត្រូវអភិរក្សនៅតំបន់ឆ្នេរសមុទ្រកម្ពុជា
- សិក្សា ស្រាវជ្រាវ ប្រមូល និងចងក្រងទិន្នន័យពាក់ព័ន្ធនឹងបរិស្ថាន សេដ្ឋកិច្ច និងសង្គម
- រៀបចំវិធានការនានាសម្រាប់បង្ការ ទប់ស្កាត់សកម្មភាពទាំងឡាយណាដែលអាចប៉ះពាល់ដល់បរិស្ថាន និងធនធានធម្មជាតិនៅតាមតំបន់ឆ្នេរសមុទ្រកម្ពុជា
- តាមដានការអនុវត្តកម្មវិធី គម្រោងអភិវឌ្ឍ និងសកម្មភាពនានានៅតំបន់ឆ្នេរសមុទ្រកម្ពុជា ដោយផ្តោតសំខាន់លើទិដ្ឋភាពនៃកិច្ចការការពារបរិស្ថាននិងអភិរក្សធនធានធម្មជាតិតំបន់ឆ្នេរសមុទ្រកម្ពុជា
- ត្រួតពិនិត្យនិងវាយតម្លៃផលប៉ះពាល់បរិស្ថានពីគម្រោងវិនិយោគនិងអភិវឌ្ឍទាំងឡាយក្នុងតំបន់ឆ្នេរសមុទ្រកម្ពុជា
- សហការជាមួយផ្នែកនីមួយៗរបស់អគ្គលេខាធិការដ្ឋាន **គ.អ.ឆ.ក.** ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ ចំពោះកិច្ចការការពារបរិស្ថាននិងធនធានធម្មជាតិ និងរៀបចំផែនការអភិវឌ្ឍន៍បៃតងនៃតំបន់ឆ្នេរសមុទ្រកម្ពុជា។

- រៀបចំបទដ្ឋានបច្ចេកទេសនិងផ្តល់ប្រឹក្សាពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងធនធានធម្មជាតិនៅតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំផែនការយុទ្ធសាស្ត្រ កម្មវិធីសកម្មភាព និងធ្វើរបាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការងារគ្រប់គ្រងបរិស្ថាននិងធនធានធម្មជាតិតំបន់ឆ្នេរសមុទ្រកម្ពុជាតាមការកំណត់
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ **គ.ស.ឆ.ក**.ប្រគល់ជូន។

**មាត្រា ១០.-**

ផ្នែកគ្រប់គ្រងនិងអភិវឌ្ឍទេសចរណ៍ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ផ្សព្វផ្សាយអំពីអត្តសញ្ញាណនិងតំលៃនៃការអភិវឌ្ឍនិងការអភិរក្សតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំបទដ្ឋានបច្ចេកទេសទេសចរណ៍តំបន់ឆ្នេរ សម្រាប់ការអនុញ្ញាត និងការអនុវត្តសកម្មភាពទេស-ចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា មានជាអាទិ៍ឆ្នាំសមុទ្រ ទេសចរណ៍ក្នុងទឹកសមុទ្រ ខ្សែទស្សនកិច្ចតំបន់ឆ្នេរទេសចរណ៍តាមនាវា ដើម្បីធានាការគ្រប់គ្រងទេសចរណ៍តំបន់ឆ្នេរឲ្យបានល្អប្រសើរ
- ពិនិត្យនិងផ្តល់មតិទៅលើសកម្មភាពអភិវឌ្ឍទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា មានជាអាទិ៍ ការរៀបចំគម្រោងឆ្នេរគំរូ សកម្មភាពផ្ទះឆ្នេរ ប្រភេទទេសចរណ៍ផ្ទះទី២
- ពិនិត្យនិងវាយតម្លៃលើពាក្យស្នើសុំអនុវត្តសកម្មភាពទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា
- តាមដាននិងត្រួតពិនិត្យសកម្មភាពទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំលក្ខណៈវិនិច្ឆ័យសម្រាប់គ្រប់គ្រងអាជីវករនិងប្រតិបត្តិករនៅតំបន់ឆ្នេរសមុទ្រកម្ពុជា និងផ្តល់យោបល់លើពាក្យស្នើសុំធ្វើជាប្រតិបត្តិករទេសចរណ៍
- ពិនិត្យនិងផ្តល់យោបល់ ដើម្បីចាត់វិធានការបង្ការនិងទប់ស្កាត់រាល់សកម្មភាពទាំងឡាយដែលអាចប៉ះពាល់ដល់ការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា
- សម្រុះសម្រួលនិងដោះស្រាយវិវាទពាក់ព័ន្ធនឹងការអនុវត្តសកម្មភាពទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំបទដ្ឋានបច្ចេកទេសនិងផ្តល់ប្រឹក្សាពាក់ព័ន្ធនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍទេសចរណ៍នៅតំបន់ឆ្នេរសមុទ្រកម្ពុជា
- សហការជាមួយផ្នែកនីមួយៗរបស់អគ្គលេខាធិការដ្ឋាន **គ.ស.ឆ.ក**. ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ ចំពោះការងារគ្រប់គ្រងនិងអភិវឌ្ឍទេសចរណ៍នៃតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំផែនការយុទ្ធសាស្ត្រ កម្មវិធីសកម្មភាព និងធ្វើរបាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការងារទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជាតាមការកំណត់
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ **គ.ស.ឆ.ក**.ប្រគល់ជូន។

**មាត្រា ១១.-**

ផ្នែកអប់រំ បណ្តុះបណ្តាល ផ្សព្វផ្សាយ និងព័ត៌មានវិទ្យា មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ផ្សព្វផ្សាយដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ផ្នែកឯកជន និងគ្រប់ភាគីពាក់ព័ន្ធឲ្យយល់ដឹងអំពីការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- អប់រំ បណ្តុះបណ្តាលធនធានមនុស្ស ដើម្បីឆ្លើយតបនឹងតម្រូវការក្នុងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំការបណ្តុះបណ្តាលបំពេញបន្ថែម សិក្ខាសាលា វគ្គបំប៉នខ្លីៗ ដល់មន្ត្រី បុគ្គលិក ដែលត្រូវបំពេញការងារនៅក្នុងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- ស្រាវជ្រាវ ចងក្រង បោះពុម្ព និងផ្សព្វផ្សាយព័ត៌មាននិងទិន្នន័យដែលពាក់ព័ន្ធនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំ គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យានិងធ្វើបច្ចុប្បន្នកម្មគេហទំព័ររបស់ **គ.ស.ឆ.ក**

- សហការជាមួយផ្នែកនីមួយៗរបស់អគ្គលេខាធិការដ្ឋាន **គ.អ.ឆ.ក.** ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ ចំពោះការងារអប់រំ បណ្តុះបណ្តាល ផ្សព្វផ្សាយ និងព័ត៌មានវិទ្យា
- រៀបចំផែនការសកម្មភាពនិងចុះសរុបរបាយការណ៍សម្រាប់កិច្ចការអប់រំ បណ្តុះបណ្តាល ផ្សព្វផ្សាយ និងព័ត៌មានវិទ្យា
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ **គ.អ.ឆ.ក.** ប្រគល់ជូន។

**មាត្រា ១២.-**

ផ្នែកនីតិកម្មនិងដោះស្រាយវិវាទ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- សិក្សា ស្រាវជ្រាវ រៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត និងគោលការណ៍ចាំបាច់នានាពាក់ព័ន្ធនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដាក់ជូន **គ.អ.ឆ.ក.** ដើម្បីពិនិត្យនិងសម្រេច
- ផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត និងបទដ្ឋានបច្ចេកទេស ដែលពាក់ព័ន្ធនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំបទបញ្ជាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋាន **គ.អ.ឆ.ក.**
- ទទួលពាក្យបណ្តឹងតវ៉ា ធ្វើការស៊ើបអង្កេត និងសម្របសម្រួល ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងបណ្តឹងតវ៉ាទាំងនោះ ស្របតាមច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីជាធរមាន
- ពិនិត្យនិងផ្តល់មតិលើកិច្ចព្រមព្រៀងអន្តរជាតិនិងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- សហការជាមួយផ្នែកនីមួយៗរបស់អគ្គលេខាធិការដ្ឋាន **គ.អ.ឆ.ក.** ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ ចំពោះការងារនីតិកម្មនិងដោះស្រាយវិវាទ
- រៀបចំផែនការសកម្មភាពនិងរបាយការណ៍សម្រាប់កិច្ចការនីតិកម្មនិងដោះស្រាយវិវាទ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ **គ.អ.ឆ.ក.** ប្រគល់ជូន។

**មាត្រា ១៣.-**

ផ្នែកទំនាក់ទំនងសាធារណៈនិងសហប្រតិបត្តិការ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលនិងធ្វើទំនាក់ទំនងសហប្រតិបត្តិការជាមួយគ្រប់ភាគីពាក់ព័ន្ធ ក្នុងក្របខ័ណ្ឌជាតិ តំបន់ និងអន្តរជាតិ នូវរាល់សកម្មភាពដែលទាក់ទងនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- សម្របសម្រួលនិងធ្វើកិច្ចសហប្រតិបត្តិការជាមួយនិងក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក
- ធ្វើការផ្សព្វផ្សាយនិងរៀបចំដំណើរការប្រឡងប្រណាំងឆ្នេរសមុទ្រស្អាត
- តាមដាននិងវាយតម្លៃលើរាល់សកម្មភាពដែលមានចែងក្នុងកំណត់ហេតុ អនុស្សរណៈ ពិធីសារ និងកិច្ចព្រមព្រៀង ដែលបានចុះហត្ថលេខាជូនថ្នាក់ដឹកនាំពិនិត្យ សម្រេច ដើម្បីរកវិធានការបង្កើនប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- ធ្វើទំនាក់ទំនងសហប្រតិបត្តិការជាមួយបណ្តាប្រទេសក្នុងតំបន់និងអន្តរជាតិ ដើម្បីបញ្ជូនមន្ត្រី បុគ្គលិកទៅធ្វើការសិក្សា ដកបទពិសោធការងារពាក់ព័ន្ធនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- សហការជាមួយផ្នែកនីមួយៗរបស់អគ្គលេខាធិការដ្ឋាន **គ.អ.ឆ.ក.** ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ ចំពោះការងារទំនាក់ទំនងសាធារណៈនិងសហប្រតិបត្តិការ
- ធ្វើកិច្ចការឆ្លើយឆ្លងព័ត៌មានជាសាធារណៈ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ **គ.អ.ឆ.ក.** ប្រគល់ជូន។

**មាត្រា ១៤.-**

ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលសកម្មភាពគ្រប់ផ្នែករបស់អគ្គលេខាធិការដ្ឋាន **គ.អ.ឆ.ក.** ឲ្យមានភាពរលូននិងមានប្រសិទ្ធភាព
- គ្រប់គ្រងការងាររដ្ឋបាលទូទៅនិងការងារបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន **គ.អ.ឆ.ក.**
- រៀបចំសន្និបាត កិច្ចប្រជុំ សិក្ខាសាលា និងពិធីការនានា
- សម្របសម្រួលនិងរៀបចំផែនការសកម្មភាពនិងថវិការបស់ គ.**អ.ឆ.ក.**
- គ្រប់គ្រងថវិកានិងធ្វើរបាយការណ៍អំពីស្ថានភាពចំណូលចំណាយរបស់ **គ.អ.ឆ.ក.**
- ធ្វើលទ្ធកម្មក្នុងការផ្គត់ផ្គង់និងបែងចែកសម្ភារៈបរិក្ខារនិងធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់ **គ.អ.ឆ.ក.**
- សហការជាមួយផ្នែកនីមួយៗរបស់អគ្គលេខាធិការដ្ឋាន **គ.អ.ឆ.ក.** ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ ចំពោះការងាររដ្ឋបាលនិងហិរញ្ញវត្ថុ
- បូកសរុបរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ របស់ **គ.អ.ឆ.ក.**
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ **គ.អ.ឆ.ក.**ប្រគល់ជូន។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា ១៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងជាប្រធាន **គ.អ.ឆ.ក.** រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តតំបន់ឆ្នេរសមុទ្រទាំង៤ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។/ 

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៧៧ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ២០១២
ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន
នៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា

## អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន គ.អ.ឆ.ក.



គំរូត្រារបស់អគ្គលេខាធិការដ្ឋាន គ.អ.ឆ.ក.

ព្រះរាជាណាចក្រកម្ពុជា

អគ្គលេខាធិការដ្ឋាន

គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា

# ឧបសម្ព័ន្ធទី ៧

# ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានអភិរក្សសមុទ្រនិងតំបន់ឆ្នេរ នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ, លេខ៤៥១/ប្រក, 0៣ ធ្នូ ២០១៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ : ៤៥១ (ប្រក)... ប.ស្ក

# ប្រកាស

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានអភិរក្សសមុទ្រនិងតំបន់ឆ្នេរ នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ៥៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- លិខិតលេខ ២៩៧៧ មស.នក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងមុខងារសាធារណៈ

## សម្រេច

**ប្រការ ១.–**

ប្រកាសនេះកំណត់ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានអភិរក្សសមុទ្រនិងតំបន់ឆ្នេរ នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ។



អគារលេខ៤៨ មហាវិថីសម្តេចព្រះសីហនុ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: ០២៣ ២១៣ ៩០៨, ០២៣ ២២០ ៣៦៩ ទូរសារ: ០២៣ ២១២ ៥៤០

**ប្រការ ២.–**

នាយកដ្ឋានអភិរក្សសមុទ្រនិងតំបន់ឆ្នេរ មាន ៥(ប្រាំ)ការិយាល័យ ដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
- ការិយាល័យស្រាវជ្រាវធនធានសមុទ្រ និងតំបន់ឆ្នេរ
- ការិយាល័យអភិរក្សសមុទ្រ
- ការិយាល័យអភិរក្សតំបន់ឆ្នេរ
- ការិយាល័យអភិរក្សកោះ និងទីជម្រាលតំបន់ឆ្នេរ។

បណ្ដាការិយាល័យ នៃនាយកដ្ឋានអភិរក្សសមុទ្រនិងតំបន់ឆ្នេរ ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានពី២(ពីរ)រូបទៅ៤(បួន)រូប។

**ប្រការ ៣.–**

ការិយាល័យរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការការងាររបស់ការិយាល័យ
- សម្របសម្រួលការរៀបចំផែនការការងាររបស់នាយកដ្ឋាន និងត្រួតពិនិត្យការអនុវត្តក្នុងនាយកដ្ឋាន
- គ្រប់គ្រងលិខិតចេញ-ចូល
- គ្រប់គ្រងលិខិតរដ្ឋបាលទៅតាមមុខសញ្ញាការងារ
- តំកល់ឯកសារ និងគ្រប់គ្រងបណ្ណាល័យ
- គ្រប់គ្រងការងារបេសកកម្មក្នុងនាយកដ្ឋាន
- គេហបាលក្នុងនាយកដ្ឋាន (គ្រប់គ្រងត្រា សន្តិសុខសណ្ដាប់ធ្នាប់ កសាងបទបញ្ជាផ្ទៃក្នុង និងផ្សព្វផ្សាយសេចក្ដីប្រកាស ច្បាប់ អនុក្រឹត្យ សារាចរ លិខិតបទដ្ឋានគតិយុត្ត និងព័ត៌មានផ្សេងៗ ដល់គ្រប់ការិយាល័យក្នុងនាយកដ្ឋាន)
- គ្រប់គ្រងបែបបទសុំតម្លើងកាំប្រាក់ និងបៀវត្ស ឋានន្តរសក្តិ និងសំណុំលិខិតមន្ត្រីរាជការ
- ធ្វើកំណត់បង្ហាញសំណុំឯកសារផ្សេងៗរបស់នាយកដ្ឋាន
- រៀបចំកម្មវិធីប្រជុំ ការណាត់ជួបការងាររបស់ថ្នាក់ដឹកនាំនាយកដ្ឋាន
- ចូលរួមប្រជុំ ធ្វើកំណត់ហេតុ និងចុះបេសកកម្មជាមួយថ្នាក់ដឹកនាំតាមការចាំបាច់
- ទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយ
- ស្រាវជ្រាវ តាមដាន និងចងក្រងរាល់ព្រឹត្តិការណ៍ដែលទាក់ទងការងារនាយកដ្ឋាន
- គ្រប់គ្រងការងារផ្គត់ផ្គង់សម្ភារការិយាល័យ ឧបករណ៍ បរិក្ខារ និងគ្រប់គ្រងសារពើភ័ណ្ឌ
- រៀបចំការងារមន្ត្រីរាជការ ការងារស្ថិតិ និងការងារថវិកា
- ទំនាក់ទំនងជាមួយអង្គភាពចំណុះស្ថាប័នពាក់ពន្ធ័ អង្គការជាតិ-អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា
- លើកសំណើ ចាត់ចែង ចែកចាយ និងគ្រប់គ្រងសម្ភារៈការិយាល័យ និងគ្រឿងបរិក្ខារ
- រៀបចំការងាររដ្ឋបាលក្នុងកិច្ចប្រជុំ សិក្ខាសាលា វេទិកា វគ្គបណ្ដុះបណ្ដាល យុទ្ធនាការ និងទិវានានា



JCH

- រៀបចំគ្រប់គ្រង និងត្រួតពិនិត្យ ចំណូល-ចំណាយនានា
- រៀបចំរបាយការណ៍របស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

**ប្រការ ៤.–**

**ការិយាល័យស្រាវជ្រាវធនធានសមុទ្រ និងតំបន់ឆ្នេរ មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖**

- រៀបចំផែនការការងាររបស់ការិយាល័យជូននាយកដ្ឋាន
- សហការជាមួយស្ថាប័ននានាលើការសិក្សាស្រាវជ្រាវពីបញ្ហាបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ និងសេដ្ឋកិច្ចសង្គម ដែលមាននៅក្នុងសមុទ្រ និងតំបន់ឆ្នេរ
- កំណត់តំបន់ និងប្រភេទធនធានសមុទ្រ និងតំបន់ឆ្នេរសំខាន់ៗ ដែលងាយរងគ្រោះ សម្រាប់ស្តារ ការពារ និងគ្រប់គ្រង
- រៀបចំចងក្រងទិន្នន័យ និងព័ត៌មានបរិស្ថាន ស្តីពីធនធានសមុទ្រ តំបន់ឆ្នេរ កោះ និងទីជម្រាល
- ធ្វើបច្ចុប្បន្នភាពស្ថានភាពបរិស្ថាន សមុទ្រ តំបន់ឆ្នេរ កោះ និងទីជម្រាល
- សម្របសម្រួល និងផ្តល់សេវាដល់សាធារណជន ភ្ញៀវជាតិ អន្តរជាតិនានា
- សម្របសម្រួល និងចូលរួម ការងារសិក្សាស្រាវជ្រាវ អប់រំ បណ្តុះបណ្តាល ស្តីពីបញ្ហាបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ និងសេដ្ឋកិច្ចសង្គមដល់ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន គ្រឹះស្ថានសិក្សា និងដៃគូអភិវឌ្ឍន៍នានា
- សហការជាមួយនាយកដ្ឋានសេវាព័ត៌មានភូមិសាស្ត្រ ក្នុងការរៀបចំផែនការគ្រប់គ្រងទិន្នន័យធនធានសមុទ្រ និងតំបន់ឆ្នេរ
- ពង្រឹងការគ្រប់គ្រងមជ្ឈមណ្ឌលធនធានតំបន់ឆ្នេរសមុទ្រ ក្នុងការផ្សព្វផ្សាយឯកសារសមុទ្រ និងតំបន់ឆ្នេរ
- សហការជាមួយនាយកដ្ឋានផ្សេងៗ មជ្ឈមណ្ឌលព័ត៌មាននិងអប់រំបរិស្ថាន និងស្ថាប័ននានា ដើម្បីផ្សព្វផ្សាយ ផ្លាស់ប្តូរព័ត៌មាន និងបង្កើនចំណេះដឹងដល់សាធារណជន អំពីតម្លៃប្រព័ន្ធអេកូឡូស៊ីសមុទ្រ និងតំបន់ឆ្នេរ
- រៀបចំរបាយការណ៍របស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

**ប្រការ ៥.–**

**ការិយាល័យអភិរក្សសមុទ្រ មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖**

- រៀបចំផែនការការងាររបស់ការិយាល័យជូននាយកដ្ឋាន
- រៀបចំលិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិរក្សសមុទ្រ
- រៀបចំយន្តការសម្រាប់អនុវត្តផែនការ រួមមាន ការគ្រប់គ្រង ការអភិរក្ស ការស្តារប្រព័ន្ធអេកូឡូស៊ីប្រកបដោយចីរភាព និងការសិក្សា ស្តីពីបរិស្ថាន ធនធានធម្មជាតិ សេដ្ឋកិច្ចសង្គម ដែលមាននៅក្នុងតំបន់សមុទ្រ

- សម្របសម្រួល ចូលរួម និងរៀបចំកម្មវិធីបណ្តុះបណ្តាល អប់រំ ផ្សព្វផ្សាយ ស្តីពីការគ្រប់គ្រង ការអភិរក្ស និងការស្តារប្រព័ន្ធអេកូឡូស៊ីសមុទ្រ ដល់មន្ត្រីជំនាញថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធ
- អនុវត្តផែនការបរិស្ថានជាតិ ផែនការគ្រប់គ្រងសមុទ្រ និងផែនការនានាដែលពាក់ព័ន្ធសម្រាប់ការគ្រប់គ្រង ការអភិរក្ស និងការស្តារប្រព័ន្ធអេកូឡូស៊ីសមុទ្រ
- ស្រាវជ្រាវសក្តានុពលធនធានសមុទ្រ ក្នុងការរៀបចំឧទ្យានសមុទ្រ
- សម្របសម្រួល និងជម្រុញ ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី សហគមន៍មូលដ្ឋាន និងដៃគូពាក់ព័ន្ធ ក្នុងការរៀបចំផែនការគ្រប់គ្រង អភិរក្ស និងស្តារប្រព័ន្ធអេកូឡូស៊ីសមុទ្រ
- អនុវត្តគម្រោងសមាហរណកម្មគ្រប់គ្រងសមុទ្រ ដោយសហការ សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ និងស្វែងរកជំនួយពីដៃគូអភិវឌ្ឍន៍នានា
- ផ្សព្វផ្សាយ និងជម្រុញឱ្យមានការអនុវត្តតាមវិធាន និងគោលការណ៍អន្តរជាតិនានាដែលពាក់ពន្ធ័នឹងការអភិរក្សជីវចម្រុះសមុទ្រ
- សិក្សា និងចងក្រងឯកសារបច្ចេកទេស ស្តីពីជីវចម្រុះ ប្រព័ន្ធអេកូឡូស៊ីសមុទ្រ និងការគ្រប់គ្រងធនធានសមុទ្រ
- សហការ និងផ្លាស់ប្តូរព័ត៌មាន ជាមួយស្ថាប័នពាក់ព័ន្ធអំពីសារៈប្រយោជន៍ធនធានសមុទ្រ ដើម្បីគុណភាពការអភិរក្ស និងការអភិវឌ្ឍប្រកបដោយចីរភាព
- សហការជាមួយមន្ទីរបរិស្ថាន ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ក្នុងការទប់ស្កាត់ និងដោះស្រាយបទល្មើសបរិស្ថាន និងធនធានធម្មជាតិគ្រប់រូបភាព ដែលកើតមានក្នុងសមុទ្រ
- រៀបចំផែនការ ត្រួតពិនិត្យ តាមដានការអនុវត្តការងារយាមល្បាត សកម្មភាពផ្សេងៗក្នុងសមុទ្រ
- ទទួលអនុវត្តការកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

**ប្រការ ៦.-**

**ការិយាល័យអភិរក្សតំបន់ឆ្នេរ មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖**

- រៀបចំផែនការការងាររបស់ការិយាល័យជូននាយកដ្ឋាន
- រៀបចំលិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិរក្សតំបន់ឆ្នេរ
- រៀបចំយន្តការសម្រាប់អនុវត្តផែនការ រួមមាន ការគ្រប់គ្រង ការអភិរក្ស ការស្តារប្រព័ន្ធអេកូឡូស៊ីប្រកបដោយចីរភាព និងការសិក្សា ស្តីពីបរិស្ថាន ធនធានធម្មជាតិ សេដ្ឋកិច្ចសង្គម ដែលមាននៅក្នុងតំបន់ឆ្នេរ
- ទទួលសម្របសម្រួល និងរៀបចំកម្មវិធី បណ្តុះបណ្តាល អប់រំ ផ្សព្វផ្សាយ ស្តីពីការអភិរក្ស និងការស្តារប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរ ដល់មន្ត្រីជំនាញថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធ
- អនុវត្តផែនការបរិស្ថានជាតិផែនការគ្រប់គ្រងតំបន់ឆ្នេរ និងផែនការនានាដែលពាក់ព័ន្ធសម្រាប់ការគ្រប់គ្រង ការអភិរក្ស ការអភិវឌ្ឍ និងស្តារប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរ

- សម្របសម្រួល និងជម្រុញស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី សហគមន៍មូលដ្ឋាន និងដៃគូពាក់ព័ន្ធ ក្នុងការរៀបចំផែនការគ្រប់គ្រង អភិរក្ស និងស្ដារប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរ
- អនុវត្តគម្រោងសមាហរណកម្មគ្រប់គ្រងតំបន់ឆ្នេរ ដោយសហការ សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ និងស្វែងរកជំនួយពីដៃគូអភិវឌ្ឍន៍នានា
- ផ្សព្វផ្សាយ និងជម្រុញឱ្យមានការអនុវត្តតាមគោលការណ៍អន្តរជាតិនានាដែលពាក់ព័ន្ធទៅនឹងការអភិរក្សជីវចម្រុះតំបន់ឆ្នេរ
- សិក្សា និងចងក្រងឯកសារបច្ចេកទេស ស្ដីពីជីវចម្រុះ ប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរ និងការគ្រប់គ្រងធនធានតំបន់ឆ្នេរ
- កំណត់តំបន់ និងប្រភេទធនធានតំបន់ឆ្នេរសំខាន់ៗ ដែលងាយរងគ្រោះសម្រាប់ស្ដារការពារ និងគ្រប់គ្រង
- ផ្លាស់ប្ដូរព័ត៌មានជាមួយស្ថាប័នពាក់ព័ន្ធអំពីសារៈប្រយោជន៍ធនធានតំបន់ឆ្នេរ ដើម្បីតុល្យភាពការអភិរក្ស និងការអភិវឌ្ឍប្រកបដោយចីរភាព
- សហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ក្នុងការកំណត់ព្រំប្រទល់ កំណត់តំបន់អភិវឌ្ឍន៍ តំបន់អភិរក្ស និងការងារផ្សេងទៀតក្នុងតំបន់ឆ្នេរ
- សហការជាមួយនាយកដ្ឋានសេវាព័ត៌មានភូមិសាស្ត្រ ក្នុងការរៀបចំផែនទីសំខាន់ៗសម្រាប់រៀបចំនិងគ្រប់គ្រងតំបន់អភិរក្ស និងតំបន់ប្រើប្រាស់ដោយចីរភាព និងស្ដារអេកូឡូស៊ីតំបន់ឆ្នេរ
- សហការជាមួយមន្ទីរបរិស្ថាន ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ក្នុងការទប់ស្កាត់ និងដោះស្រាយបទល្មើសបរិស្ថាន និងធនធានធម្មជាតិគ្រប់រូបភាពដែលកើតមានក្នុងតំបន់ឆ្នេរ
- សិក្សាពីសក្ដានុពលក្នុងការរៀបចំអេកូទេសចរណ៍ក្នុងតំបន់ឆ្នេរ
- រៀបចំផែនការ ត្រួតពិនិត្យ តាមដានការអនុវត្តសកម្មភាពផ្សេងៗក្នុងតំបន់ឆ្នេរ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

**ប្រការ ៧.-**

**ការិយាល័យអភិរក្សកោះ និងទីជម្រាលតំបន់ឆ្នេរ មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖**

- រៀបចំផែនការការងាររបស់ការិយាល័យជូននាយកដ្ឋាន
- រៀបចំយន្តការសម្រាប់អនុវត្តផែនការ រួមមាន ការគ្រប់គ្រង ការអភិរក្ស ការស្ដារប្រព័ន្ធអេកូឡូស៊ីប្រកបដោយចីរភាព និងការសិក្សាស្ដីពីបរិស្ថាន ធនធានធម្មជាតិ សេដ្ឋកិច្ចសង្គម ដែលមាននៅក្នុងកោះ និងទីជម្រាលតំបន់ឆ្នេរ
- សម្របសម្រួល ចូលរួម និងរៀបចំកម្មវិធី បណ្ដុះបណ្ដាល អប់រំ ផ្សព្វផ្សាយ ស្ដីពីការអភិរក្ស និងការស្ដារប្រព័ន្ធអេកូឡូស៊ីកោះ និងទីជម្រាលតំបន់ឆ្នេរ ដល់មន្ត្រីជំនាញថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធ
- អនុវត្តផែនការបរិស្ថានជាតិ ផែនការគ្រប់គ្រងកោះ និងទីជម្រាលតំបន់ឆ្នេរ និងផែនការនានាដែលពាក់ព័ន្ធសម្រាប់ការគ្រប់គ្រង ការអភិរក្ស និងស្ដារប្រព័ន្ធអេកូឡូស៊ីកោះ និងទីជម្រាលតំបន់ឆ្នេរ

- សម្របសម្រួល និងជម្រុញស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី សហគមន៍មូលដ្ឋាន និងដៃគូពាក់ព័ន្ធក្នុងការរៀបចំផែនការគ្រប់គ្រង អភិរក្ស និងស្តារប្រព័ន្ធអេកូឡូស៊ីកោះ និងទីជម្រាលតំបន់ឆ្នេរ
- អនុវត្តគម្រោងសមាហរណកម្មគ្រប់គ្រងកោះ និងទីជម្រាលតំបន់ឆ្នេរ ដោយសហការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ និងស្វែងរកជំនួយពីដៃគូអភិវឌ្ឍន៍នានា
- ផ្សព្វផ្សាយ និងជម្រុញឱ្យមានការអនុវត្តតាមវិធាន និងគោលការណ៍អន្តរជាតិនានាដែលពាក់ពន្ធ័ទៅនឹងការអភិរក្សជីវចម្រុះកោះ និងទីជម្រាលតំបន់ឆ្នេរ
- សហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ក្នុងការកំណត់ព្រំប្រទល់ កំណត់តំបន់អភិវឌ្ឍន៍ តំបន់អភិរក្ស និងការងារផ្សេងទៀត នៅលើកោះ និងទីជម្រាលតំបន់ឆ្នេរ
- ផ្លាស់ប្តូរព័ត៌មានជាមួយស្ថាប័នពាក់ព័ន្ធអំពីសារៈប្រយោជន៍ធនធាននៅលើកោះ និងទីជម្រាលតំបន់ឆ្នេរ ដើម្បីតុល្យភាពការអភិរក្ស និងការអភិវឌ្ឍប្រកបដោយចីរភាព
- សហការជាមួយនាយកដ្ឋានសេវាព័ត៌មានភូមិសាស្ត្រ ក្នុងការរៀបចំផែនទីសំខាន់ៗសម្រាប់រៀបចំ និងគ្រប់គ្រងតំបន់អភិរក្ស និងតំបន់ប្រើប្រាស់ដោយចីរភាព និងស្តារអេកូឡូស៊ីកោះ និងទីជម្រាលតំបន់ឆ្នេរ
- សហការ និងផ្លាស់ប្តូរព័ត៌មានជាមួយស្ថាប័នពាក់ព័ន្ធអំពីសារៈប្រយោជន៍ធនធានកោះ និងទីជម្រាល ដើម្បីតុល្យភាពការអភិរក្ស និងការអភិវឌ្ឍប្រកបដោយចីរភាព
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

**ប្រការ ៨.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៩.–**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន អគ្គនាយកនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកខុទ្ទកាល័យ គ្រប់ប្រធានអង្គភាពចំណុះក្រសួងបរិស្ថាន ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ........................ចុះថ្ងៃទី............ខែ............ឆ្នាំ២០១៥

អង្គការលេខរបស់នាយកដ្ឋានអតិរេក្សសមុទ្រនិងតំបន់ឆ្នេរ

នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ



# ឧបសម្ព័ន្ធទី ៨

# ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរទេសចរណ៍រាជធានីខេត្ត, លេខ១២៣/ប្រក, ៣០ កក្កដា ២០១៩

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍
លេខ ១៤៣ ប្រក

# ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរទេសចរណ៍រាជធានីខេត្ត

### រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងលិខិតលេខ ២៥៥១ មស.នក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងមុខងារសាធារណៈ
- យោងលិខិតលេខ ៩២៧៤ សហវ.អថ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះមានគោលបំណងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរទេសចរណ៍រាជធានីខេត្ត។

**ប្រការ២ .-**

ប្រកាសនេះមានគោលដៅដូចខាងក្រោម៖

- រៀបចំតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរទេសចរណ៍រាជធានីខេត្ត
- រៀបចំឱ្យមានធនធានមនុស្សក្នុងរចនាសម្ព័ន្ធរបស់មន្ទីរទេសចរណ៍រាជធានីខេត្ត
- ធានាគុណភាពនិងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារក្នុងវិស័យទេសចរណ៍នៅថ្នាក់ក្រោមជាតិ។

# ជំពូកទី២
## តួនាទី និងភារកិច្ច

**ប្រការ៣ ..**

**មន្ទីរទេសចរណ៍រាជធានីខេត្ត** ជាសេនាធិការឱ្យក្រសួងទេសចរណ៍ទទួលបន្ទុកអនុវត្ត គ្រប់គ្រង តាមដាន ត្រួតពិនិត្យ វាយតម្លៃ រៀបចំផែនការអភិវឌ្ឍន៍ ពង្រឹងគុណភាពផលិតផល អាជីវកម្ម និងសេវាកម្មទេសចរណ៍ សំដៅធានាដល់ការគ្រប់គ្រងនិងការអភិវឌ្ឍទេសចរណ៍ប្រកបដោយប្រសិទ្ធភាព គុណភាព និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅថ្នាក់ក្រោមជាតិ។

**ប្រការ៤ ..**

**មន្ទីរទេសចរណ៍រាជធានីខេត្ត** មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ គ្រប់គ្រង សម្របសម្រួល និងអភិវឌ្ឍវិស័យទេសចរណ៍នៅថ្នាក់ក្រោមជាតិ
- រៀបចំគម្រោងអភិវឌ្ឍន៍ទេសចរណ៍ តាមតំបន់អាទិភាពទេសចរណ៍នៅក្នុងរាជធានីខេត្ត ដោយសហការជាមួយមន្ទីរអង្គភាពនិងផ្នែកពាក់ព័ន្ធដទៃទៀត ដើម្បីដាក់ជូនរដ្ឋបាលរាជធានីខេត្ត និងក្រសួងទេសចរណ៍ពិនិត្យនិងសម្រេច
- រៀបចំផែនការអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍ និងផែនការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ទាំងរដ្ឋនិងឯកជន ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យនិងសម្រេច
- គ្រប់គ្រង ត្រួតពិនិត្យព័ត៌មានទេសចរណ៍ និងជំរុញចលនាទេសចរណ៍ក្នុងស្រុកនៅក្នុងរាជធានីខេត្ត
- គ្រប់គ្រងរមណីយដ្ឋានទេសចរណ៍ អាជីវកម្មទេសចរណ៍ និងសេវាកម្មផ្សេងៗទៀត ដែលបម្រើឱ្យវិស័យទេសចរណ៍
- គ្រប់គ្រងនិងថែរក្សាតំបន់ទេសចរណ៍ មណ្ឌលទេសចរណ៍ រមណីយដ្ឋានទេសចរណ៍ សហគមន៍ទេសចរណ៍ កសិទេសចរណ៍ និងអេកូទេសចរណ៍ក្នុងរាជធានីខេត្ត
- គ្រប់គ្រងនិងរៀបចំក្របខណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ មុខតំណែង គ្រឿងឥស្សរិយយស និងប្រព័ន្ធលាភការផ្សេងៗទៀតរបស់មន្ត្រីរាជការក្រោមឱវាទ
- គ្រប់គ្រងស្ថានភាពចំណូលចំណាយហិរញ្ញវត្ថុនៅក្នុងមន្ទីរ ស្របតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អនុវត្តគោលនយោបាយ គោលការណ៍ ប្រកាស សារាចរ សេចក្តីណែនាំ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតរបស់ក្រសួងទេសចរណ៍ ដើម្បីរក្សានិរន្តរភាពវិស័យទេសចរណ៍និងរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ
- អនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ដើម្បីលើកកម្ពស់ និងជំរុញចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ" និងចលនាប្រឡងប្រណាំងធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ និងស្តង់ដារទេសចរណ៍
- ចូលរួមនិងជំរុញការអនុវត្តយន្តការនិងនីតិវិធីនៅថ្នាក់ក្រោមជាតិ ដើម្បីពិនិត្យ និងវាយតម្លៃលើសំណើសុំអាជ្ញាបណ្ណទេសចរណ៍ ដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ ទាំងការផ្តល់ ការបន្ត ការលុបចោល ការព្យួរ ឬការបញ្ឈប់ថ្នាក់អាជ្ញាបណ្ណទេសចរណ៍ និងការសុំបិទអាជីវកម្ម និងសេវាកម្មទេសចរណ៍ផ្សេងៗទៀត ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- រួមចំណែកការពារនិងថែរក្សាធនធានធម្មជាតិ សម្បត្តិវប្បធម៌ និងទំនៀមទម្លាប់ប្រពៃណី ដែលជាមូលដ្ឋានបម្រើឱ្យវិស័យទេសចរណ៍នៅក្នុងរាជធានីខេត្ត

- ទាក់ទងជាមួយវិនិយោគិននិងដៃគូអភិវឌ្ឍន៍នានា ក្នុងគោលបំណងទាក់ទាញការវិនិយោគ និងការអភិវឌ្ឍវិស័យទេសចរណ៍នៅក្នុងរាជធានីខេត្ត
- សិក្សាស្រាវជ្រាវទីផ្សារទេសចរណ៍និងផ្សព្វផ្សាយពីសក្តានុពលទេសចរណ៍ដែលមាននៅក្នុងមូលដ្ឋាន
- លើកសំណើនិងផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្រសួងក្នុងការកែលម្អនិងអភិវឌ្ឍវិស័យទេសចរណ៍ក្នុងរាជធានីខេត្ត ដោយមានការគាំទ្រពីរដ្ឋបាលថ្នាក់ក្រោមជាតិនិងអាជ្ញាធរមូលដ្ឋាន
- សម្រាប់មន្ទីរទេសចរណ៍ដែលមានឆ្នេរសមុទ្រនិងកោះ ត្រូវចូលរួមគ្រប់សកម្មភាពក្នុងការគ្រប់គ្រងនិងអភិវឌ្ឍរមណីយដ្ឋានឆ្នេរសមុទ្រ និងកោះស្របតាមផែនការអភិវឌ្ឍន៍របស់ក្រសួងទេសចរណ៍និងរដ្ឋបាលខេត្ត
- ធ្វើកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ក្នុងក្របខណ្ឌទ្វេភាគី ពហុភាគី អាស៊ាន តំបន់ និងអន្តរជាតិ
- សហការរៀបចំកិច្ចប្រជុំ ព្រឹត្តិការណ៍ និងសន្និសីទទេសចរណ៍ថ្នាក់អាស៊ាន តំបន់ និងអន្តរជាតិ
- សហការរួមចំណែកការពារបរិស្ថាននិងលើកកម្ពស់ "កម្ពុជាស្អាត កម្ពុជាបៃតង" នៅក្នុងរាជធានីខេត្ត
- សហការជាមួយក្រសួង ស្ថាប័នរដ្ឋបាលរាជធានីខេត្ត មន្ទីរនិងអង្គភាពពាក់ព័ន្ធនានា ក្នុងការអនុវត្តវិធានការចំពោះប្រតិបត្តិករទេសចរណ៍ដែលបានប្រព្រឹត្តផ្ទុយនឹងច្បាប់ស្តីពីទេសចរណ៍ និងបទប្បញ្ញត្តិជាធរមាន
- សហការគ្រប់គ្រងនិងត្រួតពិនិត្យអាជីវកម្ម ផលិតកម្ម សេវាកម្ម និងប្រតិបត្តិករទេសចរណ៍ ធានាបាននូវប្រសិទ្ធភាព គុណភាព និរន្តរភាព របៀបរៀបរយ អនាម័យ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិ
- សហការពង្រឹង និងចាត់វិធានការចាំបាច់ទាក់ទងនឹងការរក្សាសន្តិសុខ និងសុវត្ថិភាពទេសចរ កិច្ចការសង្គ្រោះបឋមនិងបន្ទាន់ នៅតាមតំបន់គោលដៅទេសចរណ៍ និងរមណីយដ្ឋានទេសចរនានា
- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធក្នុងការគ្រប់គ្រងនិងរៀបចំចងក្រងទិន្នន័យស្ថិតិទេសចរណ៍
- សហការជាមួយរដ្ឋបាលរាជធានីខេត្ត មន្ទីរ អង្គភាព និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីទប់ស្កាត់ការផលិត ការនាំចូល ការចែកចាយ ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀន និងការជួញដូរស្ត្រី និងកុមារក្នុងវិស័យទេសចរណ៍ ព្រមជាមួយនឹងការបញ្ជ្រៀបការយល់ដឹងពីជំងឺអេដស៍ និងបរិស្ថានគ្មានផ្សែងបារីក្នុងវិស័យទេសចរណ៍
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ឆ្នាំមាស និងឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីក្រសួងទេសចរណ៍។

មន្ទីរទេសចរណ៍រាជធានីខេត្ត ដឹកនាំដោយប្រធាន០១(មួយ)រូប និងអនុប្រធានមួយចំនួនតាមការចាំបាច់អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៣
## រចនាសម្ព័ន្ធ

**ប្រការ៥ ..**

មន្ទីរទេសចរណ៍រាជធានីខេត្ត មានការិយាល័យចំណុះដូចខាងក្រោម៖

ក. មន្ទីរទេសចរណ៍រាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តបាត់ដំបង មានការិយាល័យចំណុះចំនួន ០៧ (ប្រាំពីរ) ដូចតទៅ៖

១-ការិយាល័យរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងសន្តិសុខ សុវត្ថិភាពទេសចរ

២-ការិយាល័យផែនការ វិនិយោគ និងអភិវឌ្ឍន៍ផលិតផលទេសចរណ៍

៣-ការិយាល័យគ្រប់គ្រងឧស្សាហកម្មទេសចរណ៍

៤-ការិយាល័យអប់រំបណ្តុះបណ្តាល
៥-ការិយាល័យព័ត៌មានទេសចរណ៍និងផ្សព្វផ្សាយទេសចរណ៍
៦-ការិយាល័យគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍
៧-ការិយាល័យទីក្រុងស្អាត។

ខ.មន្ទីរទេសចរណ៍ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តស្វាយរៀងនិងខេត្តត្បូងឃ្មុំ មានការិយាល័យចំណុះចំនួន០៦(ប្រាំមួយ) ដូចតទៅ៖

១-ការិយាល័យរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងសន្តិសុខ សុវត្ថិភាពទេសចរ
២-ការិយាល័យផែនការ វិនិយោគ និងអភិវឌ្ឍន៍ផលិតផលទេសចរណ៍
៣-ការិយាល័យគ្រប់គ្រងឧស្សាហកម្មទេសចរណ៍
៤-ការិយាល័យអប់រំបណ្តុះបណ្តាល
៥-ការិយាល័យព័ត៌មានទេសចរណ៍និងផ្សព្វផ្សាយទេសចរណ៍
៦-ការិយាល័យទីក្រុងស្អាត។

គ.មន្ទីរទេសចរណ៍ខេត្តកំពត ខេត្តកែប និងខេត្តកោះកុង មានការិយាល័យចំណុះចំនួន០៧(ប្រាំពីរ)ដូចតទៅ៖

១-ការិយាល័យរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងសន្តិសុខ សុវត្ថិភាពទេសចរ
២-ការិយាល័យផែនការ វិនិយោគ និងអភិវឌ្ឍន៍ផលិតផលទេសចរណ៍
៣-ការិយាល័យគ្រប់គ្រងឧស្សាហកម្មទេសចរណ៍
៤-ការិយាល័យអប់រំបណ្តុះបណ្តាល
៥-ការិយាល័យព័ត៌មានទេសចរណ៍និងផ្សព្វផ្សាយទេសចរណ៍
៦-ការិយាល័យគ្រប់គ្រងឆ្នេរ
៧-ការិយាល័យទីក្រុងស្អាត។

ឃ.មន្ទីរទេសចរណ៍ខេត្តព្រះសីហនុមានការិយាល័យចំណុះចំនួន ០៩(ប្រាំបួន) ដូចតទៅ៖

១-ការិយាល័យរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងសន្តិសុខ សុវត្ថិភាពទេសចរ
២-ការិយាល័យផែនការ វិនិយោគ និងអភិវឌ្ឍន៍ផលិតផលទេសចរណ៍
៣-ការិយាល័យគ្រប់គ្រងឧស្សាហកម្មទេសចរណ៍
៤-ការិយាល័យអប់រំបណ្តុះបណ្តាល
៥-ការិយាល័យព័ត៌មានទេសចរណ៍និងផ្សព្វផ្សាយទេសចរណ៍
៦-ការិយាល័យគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍
៧-ការិយាល័យគ្រប់គ្រងឆ្នេរ
៨-ការិយាល័យទេសចរណ៍កោះរ៉ុង
៩-ការិយាល័យទីក្រុងស្អាត។

**ប្រការ៦ ..**

នៅតាមក្រុង ស្រុក ខណ្ឌនីមួយៗ ដែលមានសក្តានុពលទេសចរណ៍ ត្រូវមានការិយាល័យទេសចរណ៍ក្រុង ស្រុក ខណ្ឌ មួយដែលទទួលបន្ទុកអនុវត្តនិងសម្របសម្រួលសកម្មភាពនានារបស់ក្រសួង ក្រោមការគ្រប់គ្រងរបស់មន្ទីរទេសចរណ៍រាជធានីខេត្ត។

**ប្រការ៧ .-**

កាវិយាល័យនីមួយៗ ដឹកនាំដោយប្រធាន០១(មួយ)រូប និងអនុប្រធានមួយចំនួនតាមការចាំបាច់អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អង្គការលេខរបស់មន្ទីរទេសចរណ៍រាជធានីខេត្ត ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

## ជំពូកទី ៤
## តួនាទី និងភារកិច្ចរបស់ការិយាល័យ

**ប្រការ៨ .-**

ការិយាល័យនីមួយៗមានតួនាទី និងភារកិច្ចដូចតទៅ៖

**១-ការិយាល័យរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងសន្តិសុខ សុវត្ថិភាពទេសចរ** មានតួនាទី និងភារកិច្ច៖

- គ្រប់គ្រងលិខិតស្នាមដែលបញ្ជូនចេញនិងទទួលលិខិតពីបណ្តាមន្ទីរ អង្គភាពនិងក្រសួងស្ថាប័នដទៃទៀត
- ចរាចរលិខិតឯកសារចូល និងចេញទៅកាន់គោលដៅទាំងក្នុងនិងក្រៅមន្ទីរ
- លើកវិធានការ ការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ អនាម័យ និងសោភ័ណភាពរបស់មន្ទីរ
- រៀបចំតុបតែង និងលម្អមន្ទីរ នៅរៀងរាល់ពិធីបុណ្យជាតិ អន្តរជាតិ និងចូលរួមក្នុងការងារសង្គមនានា
- គ្រប់គ្រងស្ថិតិ ក្របខណ្ឌ និងតារាងព័ត៌មានការងារមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត និងរៀបចំផែនការធនធានមនុស្សរបស់មន្ទីរ
- រៀបចំសំណើសុំលើការជ្រើសរើស ការតាំងស៊ប់ក្នុងក្របខណ្ឌ ការរៀបចំបៀវត្សរ៍ ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ការតែងតាំង ការប្រគល់ភារកិច្ច ការផ្លាស់ប្តូរ ការផ្ទេរក្របខណ្ឌ ការផ្តល់រង្វាន់ ការផ្តល់គ្រឿងឥស្សរិយយស ការដាក់វិន័យ ការបញ្ចប់ភារកិច្ច ការលុបឈ្មោះឬបញ្ឈប់ពីការងារ ការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សរ៍ ការដាក់ឱ្យស្ថិតនៅក្រៅក្របខណ្ឌដើម និងការដាក់ឱ្យចូលនិវត្តឬបាត់បង់សម្បទាវិជ្ជាជីវៈនៃមន្ត្រីរាជការ
- រៀបចំសលាកបត្រវិញ្ញាបនបត្ររដ្ឋបាល លិខិតបញ្ជាបេសកកម្ម លិខិតឧទ្ទេសនាម សេចក្តីជូនដំណឹង លិខិតបទដ្ឋាន របាយការណ៍ និងកំណត់ហេតុនានា
- លើកគម្រោងផែនការថវិកាប្រចាំឆ្នាំ និងគ្រប់គ្រងចំណូលចំណាយរបស់មន្ទីរ ស្របតាមគោលការណ៍កំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់គ្រងចលនទ្រព្យនិងអចលនទ្រព្យ សន្និធិ សម្ភារ ប្រេងឥន្ធនៈ និងធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងគ្រប់គ្រងការប្រើប្រាស់ ការរៀបចំជួសជុលសម្ភារៈ បរិក្ខាររបស់មន្ទីរ
- រៀបចំនិងបើកប្រាក់បៀវត្ស របបសង្គមកិច្ច និងប្រាក់ឧបត្ថម្ភផ្សេងៗទៀត ជូនមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត
- សហការផ្សព្វផ្សាយ ណែនាំ និងជំរុញឱ្យគ្រប់អាជីវកម្មទេសចរណ៍ រមណីយដ្ឋានទេសចរណ៍ និងសេវាផ្សេងៗទៀតបម្រើឱ្យវិស័យទេសចរណ៍ ដើម្បីបង្កើនការការពារសន្តិសុខ និងសុវត្ថិភាពទេសចរ
- សហការជាមួយរដ្ឋបាលរាជធានីខេត្ត មន្ទីរ អង្គភាពពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីចាត់វិធានការចាំបាច់ទាក់ទងនឹងការរក្សាសន្តិសុខ និងសុវត្ថិភាពជូនទេសចរ កិច្ចការសង្គ្រោះបឋមនិងបន្ទាន់ ព្រមទាំងកិច្ចការសុវត្ថិភាពទេសចរផ្សេងៗទៀត ពិសេសនៅតាមតំបន់គោលដៅទេសចរណ៍ និងរមណីយដ្ឋានទេសចរណ៍នានា
- សហការជាមួយក្រសួង ស្ថាប័ន អគ្គាធិការដ្ឋាន នាយកដ្ឋានសវនកម្មផ្ទៃក្នុង មន្ទីរនិងអង្គភាពនានា ដើម្បីដោះស្រាយវិវាទនិងបំពេញភារកិច្ចអធិការកិច្ចនិងសវនកម្មផ្ទៃក្នុង

- ប្រមូលផ្ដុំ និងបូកសរុបរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ឧត្តមាស និងឆ្នាំ និងលើកទិសដៅការងារបន្តរបស់មន្ទីរទេសចរណ៍។

**២-ការិយាល័យផែនការ វិនិយោគ និងអភិវឌ្ឍន៍ផលិតផលទេសចរណ៍** មានតួនាទី និងភារកិច្ចៈ

- រៀបចំផែនការអភិវឌ្ឍវិស័យទេសចរណ៍នៅក្នុងរាជធានីខេត្ត រួមមានៈ ផែនការវិនិយោគ អភិវឌ្ឍន៍ទេសចរណ៍វប្បធម៌ អេកូទេសចរណ៍ ទេសចរណ៍សហគមន៍ កសិទេសចរណ៍ និងទេសចរណ៍ធម្មជាតិ ដោយសហការជាមួយក្រសួង ស្ថាប័ន រដ្ឋបាលរាជធានីខេត្ត មន្ទីរ និងអង្គភាពពាក់ព័ន្ធនានា
- រៀបចំបង្កើតសហគមន៍ទេសចរណ៍នៅតាមតំបន់ដែលមានសក្ដានុពលខ្ពស់ និងជំរុញឱ្យមានការថែរក្សាទីតាំងវប្បធម៌ប្រវត្តិសាស្ត្រ បេតិកភណ្ឌ ទីសក្ការៈបូជា ដើម្បីទាក់ទាញភ្ញៀវទេសចរ ដោយសហការជាមួយក្រសួង ស្ថាប័ន រដ្ឋបាលរាជធានីខេត្ត មន្ទីរ និងអង្គភាពពាក់ព័ន្ធនានា
- សិក្សានិងរៀបចំបញ្ជីសក្ដានុពលវិនិយោគទេសចរណ៍ និងធ្វើបច្ចុប្បន្នកម្មលើទិន្នន័យនិងស្ថិតិនៃគម្រោងវិនិយោគក្នុងវិស័យទេសចរណ៍នៅក្នុងរាជធានីខេត្ត
- ចូលរួមអនុវត្តបទដ្ឋានគតិយុត្ត ស្តង់ដារអប្បបរមា និងការអនុវត្តនានា ដើម្បីតាមដាន ត្រួតពិនិត្យ កែលម្អ និងរក្សាគុណភាពរមណីយដ្ឋានទេសចរណ៍វប្បធម៌ ប្រវត្តិសាស្ត្រ បេតិកភណ្ឌ និងធម្មជាតិ សហគមន៍ទេសចរណ៍ អេកូទេសចរណ៍ ទេសចរណ៍ជនបទ កសិទេសចរណ៍ ទេសចរណ៍ផ្សងព្រេង និងទេសចរណ៍ផ្សេងទៀតនៅថ្នាក់ក្រោមជាតិ
- ជំរុញសកម្មភាពភូមិមួយផលិតផលមួយរបស់សហគមន៍ទេសចរណ៍នៅក្នុងមូលដ្ឋាន
- ជំរុញលើកទឹកចិត្តឱ្យមានការផលិត និងប្រើប្រាស់ផលិតផលក្នុងស្រុកសម្រាប់បម្រើឱ្យទេសចរណ៍
- ធ្វើកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ក្នុងក្របខណ្ឌទ្វេភាគី ពហុភាគី អាស៊ាន និងអន្តរជាតិ
- សហការរៀបចំកិច្ចប្រជុំ ព្រឹត្តិការណ៍ និងសន្និសីទទេសចរណ៍ថ្នាក់អាស៊ាន តំបន់ និងអន្តរជាតិ
- សហការសិក្សាស្រាវជ្រាវប្រវត្តិរមណីយដ្ឋាន ប្រវត្តិវប្បធម៌ប្រពៃណី ទំនៀមទម្លាប់ ដើម្បីចងក្រងជាឯកសារ និងរៀបចំធ្វើជាព្រឹត្តិការណ៍ទេសចរណ៍នៅតាមរាជធានីខេត្ត និងគោលដៅទេសចរណ៍
- សហការចូលរួមជំរុញនិងអនុវត្តចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ"
- សហការជាមួយមន្ទីរវប្បធម៌និងវិចិត្រសិល្បៈ ក្នុងការពិនិត្យលើផ្នែកសំណង់ស្ថាបត្យកម្មទេសចរណ៍ឱ្យស្របទៅតាមរចនាបថខ្មែរ ទាំងការតុបតែងលម្អ ការប្រគំតន្ត្រីបុរាណ សម្លៀកបំពាក់តាមបែបបុរាណខ្មែរ និងការប្រើប្រាស់ផលិតផលក្នុងស្រុក នៅតាមមូលដ្ឋានអាជីវកម្មនិងសេវាកម្មទេសចរណ៍ ដោយរក្សាបាននូវអត្តសញ្ញាណជាតិ
- សហការត្រួតពិនិត្យការលក់ដូរវត្ថុអនុស្សាវរីយ៍ដល់ភ្ញៀវទេសចរ
- សហការសិក្សាផលប៉ះពាល់សង្គម សេដ្ឋកិច្ច វប្បធម៌ និងបរិស្ថាន ដែលបណ្ដាលមកពីគម្រោងវិនិយោគក្នុងវិស័យទេសចរណ៍និងការធ្វើអាជីវកម្មរមណីយដ្ឋានទេសចរណ៍នៅក្នុងមូលដ្ឋាន។

**៣-ការិយាល័យគ្រប់គ្រងឧស្សាហកម្មទេសចរណ៍** មានតួនាទី និងភារកិច្ចៈ

- គ្រប់គ្រង និងត្រួតពិនិត្យលើរាល់អាជីវកម្មនិងសេវាកម្មស្នាក់នៅទេសចរណ៍ ម្ហូបអាហារ ទេសចរណ៍ម៉ាយ MICE (ម៉ាយៈ ទេសចរណ៍បែបប្រជុំ សន្និសីទ និងពិព័រណ៍) សេវាកម្មម៉ាស្សានិងស្ប៉ា ទីភ្នាក់ងារដឹកជញ្ជូនទេសចរ សេវាកម្មរាំនិងកីឡាទេសចរណ៍ ព្រមទាំងអាជីវកម្ម និងសេវាកម្មទេសចរណ៍ផ្សេងៗទៀត ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ផ្សព្វផ្សាយនិងជំរុញអនុវត្តច្បាប់ស្ដីពីទេសចរណ៍ឱ្យបានទូលំទូលាយក្នុងផ្នែកសាធារណៈ និងឯកជន
- ចូលរួមនិងជំរុញការអនុវត្តយន្តការនិងនីតិវិធីនៅថ្នាក់ក្រោមជាតិដើម្បីពិនិត្យនិងវាយតម្លៃលើ

សំណើសុំអាជ្ញាបណ្ណទេសចរណ៍ ដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ ទាំងការផ្តល់ ការបន្ត ការលុបចោល ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍ និងការសុំបិទអាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍ ម្ហូបអាហារ ទេសចរណ៍-ម៉ាយ MICE (ម៉ាយៈ ទេសចរណ៍បែបប្រជុំ សន្និសីទ និងពិព័រណ៍) សេវាកម្មម៉ាស្សានិងស្ប៉ា ភ្នាក់ងារ ដឹកជញ្ជូនទេសចរ សេវាកម្សាន្ត និងកីឡាទេសចរណ៍ ព្រមទាំងអាជីវកម្មនិងសេវាកម្មទេសចរណ៍ផ្សេងៗទៀត ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន

- លើកសំណើ ដើម្បីពិនិត្យវាយតម្លៃចំណាត់ថ្នាក់ ការលើកសរសើរ ផ្តល់រង្វាន់ និងបណ្ណសរសើរ ដល់មូលដ្ឋានសេវាកម្ម អាជីវកម្ម និងប្រតិបត្តិករទេសចរណ៍គ្រប់ប្រភេទនៅក្នុងរាជធានីខេត្ត
- សហការចូលរួមជំរុញ និងអនុវត្តចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ"
- សហការពង្រឹងនិងជំរុញការប្រើប្រាស់ផលិតផលក្នុងស្រុក សំដៅបង្កើនតម្លៃបន្ថែមក្នុងវិស័យទេសចរណ៍ឱ្យបានជាអតិបរមា
- សហការជាមួយអាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធ និងផ្នែកឯកជន ក្នុងការអនុវត្តលិខិតបទដ្ឋានគតិយុត្ត ស្តង់ដារអប្បបរមា និងការអនុវត្តនានា ដើម្បីត្រួតពិនិត្យ តាមដាន កែលម្អ និងធានារក្សា គុណភាពអាជីវកម្ម និងការអនុវត្តរបស់សមាគមដែលពាក់ព័ន្ធនឹងអាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍ ម្ហូបអាហារ សេវាកម្មម៉ាស្សានិងស្ប៉ា ភ្នាក់ងារ ដឹកជញ្ជូនទេសចរ សេវាកម្សាន្តនិងកីឡាទេសចរណ៍ ព្រមទាំងអាជីវកម្មនិងសេវាកម្មទេសចរណ៍ផ្សេងៗទៀត
- សហការសិក្សាផលប៉ះពាល់សង្គម សេដ្ឋកិច្ច វប្បធម៌ និងបរិស្ថាន ដែលបណ្តាលមកពីការធ្វើអាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍ ម្ហូបអាហារ ទេសចរណ៍-ម៉ាយ MICE (ម៉ាយៈ ទេសចរណ៍បែបប្រជុំ សន្និសីទ និងពិព័រណ៍) សេវាកម្មម៉ាស្សា និងស្ប៉ា ភ្នាក់ងារ ដឹកជញ្ជូនទេសចរ សេវាកម្សាន្ត និងកីឡាទេសចរណ៍ ព្រមទាំងអាជីវកម្មនិងសេវាកម្មទេសចរណ៍ ផ្សេងៗទៀត
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចនិងផ្នែកពាក់ព័ន្ធនានា ដើម្បីទប់ស្កាត់បទល្មើសនិងការជួញដូរគ្រឿងញៀន ការជួញដូរស្ត្រីនិងកុមារក្នុងវិស័យទេសចរណ៍ លើកស្ទួយកិត្តិយស សេចក្តីថ្លៃថ្នូរ តម្លៃស្ត្រីនិងកុមារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមពាក្យស្លោក **ចូលរួមការពាររតនសម្បត្តិជាតិយើង**
- សហការផ្សព្វផ្សាយ ណែនាំ និងជំរុញឱ្យគ្រប់អាជីវកម្មទេសចរណ៍ និងសេវាផ្សេងៗទៀតបម្រើឱ្យវិស័យទេសចរណ៍ ដើម្បីបង្កើនការការពារសន្តិសុខនិងសុវត្ថិភាពទេសចរ។

**៤-ការិយាល័យអប់រំបណ្តុះបណ្តាល** មានតួនាទី និងភារកិច្ចៈ

- រៀបចំផែនការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ទាំងផ្នែករដ្ឋ ឯកជន និងសាធារណៈ ស្របតាមគោលការណ៍ និងការណែនាំរបស់ក្រសួង
- រៀបចំចងក្រងលិខិតបទដ្ឋានគតិយុត្តនិងឯកសារពាក់ព័ន្ធការងារវិស័យទេសចរណ៍ សម្រាប់បើកវគ្គបណ្តុះបណ្តាល
- បើកវគ្គបណ្តុះបណ្តាលលើគ្រប់ជំនាញនិងគ្រប់ទម្រង់ សេវាកម្មទេសចរណ៍ បដិសណ្ឋារកិច្ច និងការបញ្ជ្រាបយេនឌ័រក្នុងវិស័យទេសចរណ៍ សិទ្ធិកុមារ ច្បាប់ជាតិ អន្តរជាតិ អនុសញ្ញាជាតិ ដែលពាក់ព័ន្ធ ដើម្បីទប់ស្កាត់គ្រោះថ្នាក់នៃការកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្មកុមារក្នុងវិស័យទេសចរណ៍ ដល់ប្រតិបត្តិករទេសចរណ៍ដែលកំពុងធ្វើអាជីវកម្មសេវាកម្មទេសចរណ៍ក្នុងរាជធានីខេត្ត
- ទំនាក់ទំនងជាមួយផ្នែកឯកជន អង្គការក្រៅរដ្ឋាភិបាលឱ្យចូលរួមឧបត្ថម្ភគាំទ្រដល់ការបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យទេសចរណ៍
- សហការសិក្សាអំពីតម្រូវការ ការជ្រើសរើស និងការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍នៅតាមរាជធានីខេត្ត និងតំបន់ ដែលត្រូវបានកំណត់ដោយក្រសួងទេសចរណ៍

- សហការជាមួយមន្ទីរនិងអង្គភាពពាក់ព័ន្ធ ដើម្បីតម្រង់ទិសការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ តាមវិទ្យាល័យ សាលាចំណេះទូទៅនិងបច្ចេកទេស និងគ្រឹះស្ថានអប់រំនិងបណ្តុះបណ្តាលផ្សេងៗទៀត
- សហការត្រួតពិនិត្យ វាយតម្លៃ និងតាមដានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ សំដៅធានាឱ្យមានការបណ្តុះបណ្តាលប្រកបដោយគុណភាព និងស្របតាមស្តង់ដារនិងកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍កម្រិតជាតិ អន្តរជាតិ អាស៊ាន តំបន់ និងពិភពលោក។

**៥-ការិយាល័យព័ត៌មានទេសចរណ៍និងផ្សព្វផ្សាយទេសចរណ៍** មានតួនាទី និងភារកិច្ចៈ

- រៀបចំ គ្រប់គ្រង ប្រមូល និងចងក្រងស្ថិតិទេសចរណ៍នៅក្នុងរាជធានីខេត្ត
- ធ្វើទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាព អាជ្ញាធរពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ និងផ្នែកឯកជនលើការងារស្ថិតិទេសចរណ៍
- សិក្សាស្រាវជ្រាវ វិភាគនិន្នាការ និងព្យាករទេសចរណ៍នៅក្នុងរាជធានីខេត្ត
- សិក្សាស្រាវជ្រាវនិងវិភាគអំពីផលប៉ះពាល់នៃការអភិវឌ្ឍវិស័យទេសចរណ៍ ផលប៉ះពាល់វិជ្ជមានអវិជ្ជមាន ស្ថានភាពទេសចរណ៍ តម្រូវការហេដ្ឋារចនាសម្ព័ន្ធ សម្បទានិងសេវាកម្មទេសចរណ៍ សម្រាប់ធ្វើជាមូលដ្ឋានក្នុងការកំណត់តំបន់ទេសចរណ៍ដែលមានសក្តានុពល ដើម្បីអភិវឌ្ឍឱ្យក្លាយទៅជាគោលដៅទេសចរណ៍
- គ្រប់គ្រងមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ ប្រមូលទិន្នន័យ ភ្ញៀវទេសចរជាតិ និងអន្តរជាតិ និងផ្តល់ព័ត៌មានពិតជូនភ្ញៀវទេសចរ
- បង្កើតសៀវភៅផ្ទត់របស់មន្ទីរទេសចរណ៍ បង្ហាញពីផែនទីនិងផ្សព្វផ្សាយផលិតផលទេសចរណ៍ទាំងក្នុងទាំងក្រៅប្រទេស
- សហការបង្កើត គ្រប់គ្រង និងអភិវឌ្ឍគេហទំព័រ ប្រព័ន្ធទំនាក់ទំនងសង្គមនានា ដើម្បីផ្សព្វផ្សាយសក្តានុពលទេសចរណ៍ដែលមាននៅក្នុងរាជធានីខេត្ត
- សហការរៀបចំបង្កើតពិព័រណ៍ទេសចរណ៍និងព្រឹត្តិការណ៍ទេសចរណ៍នានានៅតាមតំបន់និងគោលដៅទេសចរណ៍ដើម្បីទាក់ទាញភ្ញៀវទេសចរជាតិនិងអន្តរជាតិ។

**៦-ការិយាល័យគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍** មានតួនាទី និងភារកិច្ចៈ

- ចូលរួមអនុវត្តយន្តការនិងនីតិវិធី ដើម្បីពិនិត្យនិងវាយតម្លៃលើសំណើសុំអាជ្ញាបណ្ណទេសចរណ៍ ដោយផ្អែកតាមលក្ខណវិនិច្ឆ័យដែលបានកំណត់ ទាំងការផ្តល់ ការបន្ត ការលុបចោល ការព្យួរ ឬការបញ្ចប់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍
- ជំរុញផ្សព្វផ្សាយនិងណែនាំមគ្គុទ្ទេសក៍ទេសចរណ៍ឱ្យអនុវត្តតាមលិខិតបទដ្ឋានគតិយុត្ត ក្រមប្រតិបត្តិ និងក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ និងបទប្បញ្ញត្តិជាធរមាន
- សិក្សាតម្រូវការមគ្គុទេសក៍ឱ្យស្របតាមកំណើននៃភ្ញៀវទេសចរ ក្នុងការបើកវគ្គបណ្តុះបណ្តាលភាសាជំនាញបន្ថែមផ្សេងៗ ឱ្យបានសមស្របនិងទាន់ពេលទៅតាមតម្រូវការទីផ្សារទេសចរណ៍
- លើកសំណើជូនក្រសួងទេសចរណ៍ ចំពោះបាតុភាពដែលធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម សម្បត្តិវប្បធម៌និងធនធានធម្មជាតិ ដែលបង្កឡើងដោយមគ្គុទ្ទេសក៍ទេសចរណ៍
- សហការគ្រប់គ្រងនិងត្រួតពិនិត្យរាល់អាជីវកម្ម និងសេវាកម្មទាក់ទងនឹងមគ្គុទ្ទេសក៍ទេសចរណ៍នៅក្នុងរាជធានីខេត្ត ឱ្យអនុវត្តទៅតាមគោលការណ៍របស់ថ្នាក់ជាតិ
- សហការជាមួយរដ្ឋបាលរាជធានីខេត្ត អាជ្ញាធរមូលដ្ឋាន និងផ្នែកពាក់ព័ន្ធ ដើម្បីពង្រឹងគុណភាពសេវាកម្មមគ្គុទ្ទេសក៍ទេសចរណ៍និងការអនុវត្តរបស់សមាគមដែលពាក់ព័ន្ធនឹងមគ្គុទ្ទេសក៍ទេសចរណ៍

- សហការរៀបចំកម្មវិធីផ្សេងៗក្នុងការប្រឡងជ្រើសរើសមគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកនិយាយភាសាបរទេសផ្សេងៗទៀត។

**៧-ការិយាល័យគ្រប់គ្រងឆ្នេរ** មានតួនាទី និងភារកិច្ចៈ

- រៀបចំផែនការនិងសកម្មភាពក្នុងការគ្រប់គ្រងនិងអភិវឌ្ឍរមណីយដ្ឋានឆ្នេរសមុទ្រនិងកោះ ស្របតាមផែនការអភិវឌ្ឍន៍របស់ក្រសួងទេសចរណ៍និងរដ្ឋបាលខេត្ត
- រៀបចំផែនការនិងចំណាត់ការចាំបាច់នានាក្នុងការការគ្រប់គ្រង បង្ការ ការជួយសង្គ្រោះ និងការធានាសុវត្ថិភាពដល់ទេសចរណ៍តាមឆ្នេរសមុទ្រនិងកោះ
- គ្រប់គ្រងទិន្នន័យនិងស្ថិតិភ្ញៀវទេសចរមកកម្សាន្តនៅរមណីយដ្ឋានឆ្នេរសមុទ្រនិងកោះ
- ត្រួតពិនិត្យនិងជួយសង្គ្រោះភ្ញៀវទេសចរមានបញ្ហាពេលហែលទឹកកម្សាន្ត
- ពង្រឹងគុណភាពផលិតផលទេសចរណ៍ សេវាកម្មទេសចរណ៍ និងបដិសណ្ឋារកិច្ចនៅតាមរមណីយដ្ឋានឆ្នេរសមុទ្រនិងកោះ
- ផ្សព្វផ្សាយ អប់រំ និងណែនាំដល់អាជីវករតាមឆ្នេរសមុទ្រនិងកោះ អំពីច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានា សំដៅដល់ការគ្រប់គ្រងនិងអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព និងការចូលរួមទទួលខុសត្រូវខ្ពស់
- ចូលរួមផ្សព្វផ្សាយ អប់រំនិងណែនាំដល់អាជីវករតាមឆ្នេរសមុទ្រនិងកោះ អំពីគុណភាពចំណីអាហារ ការថែរក្សាអនាម័យ និងបរិស្ថាននៅតាមឆ្នេរសមុទ្រនិងកោះ
- សម្របសម្រួលជម្លោះផ្សេងៗរវាងប្រតិបត្តិករទេសចរណ៍ និងភ្ញៀវទេសចរណ៍ និងរាយការណ៍មកមន្ទីរទេសចរណ៍ ដើម្បីមានវិធានការបន្ត
- លើកសំណើ និងផ្តល់យោបល់ជូនថ្នាក់ដឹកនាំមន្ទីរនិងក្រសួងទេសចរណ៍ក្នុងការកែលម្អ និងអភិវឌ្ឍស្តង់ដាររមណីយដ្ឋានឆ្នេរសមុទ្រ
- សហការជាមួយអង្គភាពពាក់ព័ន្ធនិងផ្នែកឯកជន ដើម្បីរៀបចំសកម្មភាពកម្សាន្តកីឡាទេសចរណ៍ និងព្រឹត្តិការណ៍ទេសចរណ៍នានានៅរមណីយដ្ឋានឆ្នេរសមុទ្រ។

**៨-ការិយាល័យទេសចរណ៍កោះរ៉ុង** មានតួនាទី និងភារកិច្ចៈ

- រៀបចំផែនការនិងសកម្មភាពក្នុងការគ្រប់គ្រងនិងអភិវឌ្ឍរមណីយដ្ឋានទេសចរណ៍តំបន់កោះរ៉ុង ឱ្យស្របតាមផែនការអភិវឌ្ឍន៍របស់ក្រសួងទេសចរណ៍និងរដ្ឋបាលខេត្តព្រះសីហនុ
- គ្រប់គ្រងទិន្នន័យនិងស្ថិតិភ្ញៀវទេសចរមកកម្សាន្តនៅតំបន់កោះរ៉ុង
- ត្រួតពិនិត្យនិងជួយសង្គ្រោះភ្ញៀវទេសចរមានបញ្ហាពេលហែលទឹកកម្សាន្ត
- រៀបចំផែនការនិងចំណាត់ការចាំបាច់នានាក្នុងការគ្រប់គ្រង បង្ការ ការជួយសង្គ្រោះ និងការធានាសុវត្ថិភាពដល់ទេសចរតាមឆ្នេរសមុទ្រនៅតំបន់កោះរ៉ុង
- ផ្សព្វផ្សាយ អប់រំ និងណែនាំដល់អាជីវករនៅតំបន់កោះរ៉ុង អំពីលិខិតបទដ្ឋានគតិយុត្តនិងគោលការណ៍ណែនាំនានា សំដៅដល់ការគ្រប់គ្រង និងអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាពនិងការចូលរួមទទួលខុសត្រូវខ្ពស់
- ចូលរួមផ្សព្វផ្សាយ អប់រំនិងណែនាំដល់អាជីវករ អំពីគុណភាពចំណីអាហារ ការថែរក្សាអនាម័យ និងបរិស្ថាននៅតាមឆ្នេរសមុទ្រនិងកោះនៃតំបន់កោះរ៉ុង
- ពង្រឹងគុណភាពផលិតផលទេសចរណ៍ សេវាកម្មទេសចរណ៍ និងបដិសណ្ឋារកិច្ចនៅតាមរមណីយដ្ឋានទេសចរណ៍តំបន់កោះរ៉ុង

- សម្របសម្រួលជម្លោះផ្សេងៗរវាងប្រតិបត្តិករទេសចរណ៍និងភ្ញៀវទេសចរ និងរាយការណ៍មកមន្ទីរទេសចរណ៍ ដើម្បីមានវិធានការបន្ត
- លើកសំណើ និងផ្តល់យោបល់ជូនថ្នាក់ដឹកនាំមន្ទីរនិងក្រសួងទេសចរណ៍ក្នុងការកែលម្អនិងអភិវឌ្ឍស្តង់ដាររមណីយដ្ឋានឆ្នេរសមុទ្រ
- សហការជាមួយអង្គភាពពាក់ព័ន្ធនិងផ្នែកឯកជន ដើម្បីរៀបចំសកម្មភាពកម្សាន្តកីឡាទេសចរណ៍ និងព្រឹត្តិការណ៍ទេសចរណ៍នានានៅរមណីយដ្ឋានទេសចរណ៍តំបន់កោះរ៉ុង
- សហការជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីការងារនិងថែរក្សាធនធានធម្មជាតិលើកោះនិងបាតសមុទ្រ។

**៩-ការិយាល័យទីក្រុងស្អាត** មានតួនាទី និងភារកិច្ចៈ
- ជំរុញលើកកម្ពស់សោភណភាពទីប្រជុំជននិងគោលដៅទេសចរណ៍ក្នុងក្រុងខណ្ឌបេក្ខភាពនៅរាជធានីខេត្ត
- រៀបចំ ជំរុញ ពិនិត្យ និងវាយតម្លៃទីប្រជុំជនស្អាត និងគោលដៅទេសចរណ៍ស្អាតនៅក្នុងមូលដ្ឋាន
- ចូលរួមអង្កេតនិងវាយតម្លៃការអនុវត្តផែនការនិងគម្រោងអភិវឌ្ឍន៍ការងារប្រឡងប្រណាំងទីក្រុងស្អាត ទីប្រជុំជនស្អាត និងគោលដៅទេសចរណ៍ស្អាតនៅក្នុងមូលដ្ឋាន
- ចូលរួមផ្សព្វផ្សាយ អប់រំការយល់ដឹងអំពីគុណប្រយោជន៍នៃវិស័យទេសចរណ៍ក្នុងបរិបទសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន និងទស្សនទាន "ស្អាត និងបៃតង" ដល់ប្រតិបត្តិករ អាជីវករ កម្មករ និងប្រជាពលរដ្ឋ ព្រមទាំងគោលដៅទេសចរណ៍ សាលារៀន រោងចក្រ ផ្សារ និងទីប្រជុំជននានា
- ចូលរួមរៀបចំ ចងក្រង និងផ្សព្វផ្សាយព័ត៌មានអំពីសក្តានុពលទេសចរណ៍ក្នុងតំបន់តាមរយៈគេហទំព័រសារអេឡិចត្រូនិចនិងបណ្តាញផ្សព្វផ្សាយសង្គម
- ចូលរួមរៀបចំនិងផ្សព្វផ្សាយព័ត៌មានអប់រំការយល់ដឹងជាសាធារណៈទាក់ទងនឹងកិច្ចអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាពនិងទទួលខុសត្រូវ
- សហការសិក្សាស្រាវជ្រាវ ប្រមូល ចងក្រង និងវិភាគទិន្នន័យនិងឯកសារ ដែលពាក់ព័ន្ធនឹងការងារវាយតម្លៃទីក្រុងស្អាត ទីប្រជុំជនស្អាត និងគោលដៅទេសចរណ៍ស្អាត
- សហការជំរុញការចូលរួមពីសាធារណជននិងគ្រប់ភាគីពាក់ព័ន្ធក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត ចលនាប្រឡងប្រណាំង "បដិសណ្ឋារកិច្ចល្អ" និងចលនាប្រឡងប្រណាំងរង្វាន់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍
- សហការផ្សព្វផ្សាយអំពីការប្រឡងប្រណាំងកម្ពុជាស្អាត សាលាស្អាត និងផ្សារស្អាត និងការប្រឡងប្រណាំងរង្វាន់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ដល់ប្រតិបត្តិករទេសចរណ៍និងស្ថាប័នពាក់ព័ន្ធ
- សហការផ្សព្វផ្សាយអំពីការប្រឡងប្រណាំងបដិសណ្ឋារកិច្ចល្អដល់ក្រុង ខណ្ឌបេក្ខភាពក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត បេក្ខភាពច្រកទ្វារអន្តរជាតិ និងប្រតិបត្តិករទេសចរណ៍។

**១០-ការិយាល័យទេសចរណ៍ក្រុង ស្រុក ខណ្ឌ** មានតួនាទី និងភារកិច្ចៈ
- ជាសេនាធិការឱ្យមន្ទីរទេសចរណ៍រាជធានីខេត្ត ក្នុងការអនុវត្តការងារទេសចរណ៍នៅក្នុងមូលដ្ឋាន
- ធានាអនុវត្តគោលនយោបាយ គោលការណ៍ សេចក្តីណែនាំ និងរាល់លិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួងទេសចរណ៍ និងផែនការទិសដៅភារកិច្ចរបស់មន្ទីរទេសចរណ៍រាជធានីខេត្ត
- គ្រប់គ្រងនិងត្រួតពិនិត្យរាល់មូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍ក្នុងមូលដ្ឋាន ដែលក្រសួងទេសចរណ៍ បានធ្វើប្រតិភូកម្មអំណាច
- ផ្តល់ព័ត៌មានអំពីការវិវឌ្ឍនិងដំណើរការប្រែប្រួលអាជីវកម្មនិងសេវាកម្មទេសចរណ៍នានា
- សម្របសម្រួលជាមួយរដ្ឋបាលខណ្ឌនិងអាជ្ញាធរមូលដ្ឋាន ដើម្បីជំរុញការអនុវត្តចលនាប្រឡងប្រណាំងទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ

- ជំរុញការផ្សព្វផ្សាយ និងការអនុវត្តច្បាប់ស្តីពីទេសចរណ៍ដល់ប្រតិបត្តិករទេសចរណ៍ឱ្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍នៅក្នុងខណ្ឌឱ្យបានត្រឹមត្រូវ និងរំឭក ដល់ម្ចាស់មូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ឱ្យសុំបន្តអាជ្ញាប័ណ្ណមុនពេលផុតសុពលភាព
- ស្រាវជ្រាវ ប្រមូលផ្តុំ និងផ្តល់ព័ត៌មានអំពីការអភិវឌ្ឍវិស័យទេសចរណ៍ និងដំណើការប្រែប្រួលអាជីវកម្មសេវាកម្មទេសចរណ៍នៅក្នុងមូលដ្ឋាន
- លើកគំនិតផ្តួចផ្តើមស្នើដល់មន្ទីរទេសចរណ៍រាជធានីខេត្ត ដើម្បីបើកវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍រយៈពេលខ្លីនិងមធ្យម ដល់និយោជក និយោជិត និងប្រតិបត្តិករទេសចរណ៍នានា ដែលធ្វើសកម្មភាពអាជីវកម្មនិងសេវាកម្មទេសចរណ៍
- លើកសំណើនិងផ្តល់យោបល់ដល់មន្ទីរទេសចរណ៍រាជធានីខេត្ត ក្នុងការកែលម្អនិងអភិវឌ្ឍវិស័យទេសចរណ៍នៅក្នុងមូលដ្ឋាន ដោយមានការគាំទ្រពីអាជ្ញាធរក្រុង ស្រុក ខណ្ឌ
- លើកសំណើនិងផ្តល់យោបល់ជូនមន្ទីរទេសចរណ៍រាជធានីខេត្ត ក្នុងការផ្តល់រង្វាន់និងបណ្ណសរសើរដល់ប្រត្តិបត្តិករទេសចរណ៍គំរូ
- សហការជាមួយរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនៅមូលដ្ឋាន ដើម្បីគ្រប់គ្រងស្ថិតិទេសចរណ៍ មូលដ្ឋានអាជីវកម្ម និងសេវាកម្មទេសចណ៍គ្រប់ប្រភេទនៅក្នុងក្រុង ស្រុក ខណ្ឌ និងចុះត្រួតពិនិត្យសកម្មភាពនានា ការរៀបចំរបៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ អនាម័យ និងរក្សាសុវត្ថិភាពនៅក្នុងសេវាកម្មទេសចរណ៍នៅក្នុងក្រុង ស្រុក ខណ្ឌ។

**ប្រការ៩ .-**

ការិយាល័យនីមួយៗ ចំណុះឱ្យមន្ទីរទេសចរណ៍រាជធានីខេត្ត មានតួនាទី និងភារកិច្ចៈ

- រៀបចំផែនការសកម្មភាពការងារនិងគម្រោងចំណាយប្រចាំឆ្នាំជូនប្រធានមន្ទីរទេសចរណ៍
- ធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ឧព្វមាស និងឆ្នាំជូនប្រធានមន្ទីរទេសចរណ៍
- ទទួលអនុវត្តតួនាទីភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីប្រធានមន្ទីរទេសចរណ៍។

## ជំពូកទី ៥
## អន្តរប្បញ្ញត្តិ

**ប្រការ១០ .-**

ការិយាល័យទេសចរណ៍ក្រុង ស្រុក ខណ្ឌ ដែលបានបង្កើតកន្លងមក ត្រូវអនុវត្តតាមតួនាទី និងភារកិច្ច ដូចមានកំណត់នៅក្នុងប្រកាសនេះ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**ប្រការ១១ .-**

ប្រកាសនេះ និរាករប្រកាសដូចខាងក្រោមៈ

- ប្រកាសលេខ០៦៧ ប្រក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីរទេសចរណ៍ខេត្ត-ក្រុង
- ប្រកាសលេខ១៨៧ ប្រក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យគ្រប់គ្រងឆ្នេរចំណុះឱ្យមន្ទីរទេសចរណ៍ខេត្តព្រះសីហនុ
- ប្រកាសលេខ០៦៨ ប្រក ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យទេសចរណ៍កោះរ៉ុងចំណុះឱ្យមន្ទីរទេសចរណ៍ខេត្តព្រះសីហនុ

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១២ ..**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ នាយកវិទ្យាស្ថានជាតិទេសចរណ៍ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានធនធានមនុស្ស ប្រធានគ្រប់អង្គភាពចំណុះក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានីខេត្ត ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៤រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**ថោង ខុន**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- រដ្ឋបាលរាជធានីខេត្ត
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ១២ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ